**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**សារណាបញ្ចប់ការសិក្សា**

# ផលិតភាពកសិកម្មនៅប្រទេសកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

| | |
|---|---|
| តាក់តែងឡើងដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ **ថាន ដាវីត** | បណ្ឌិត **ឌុយ ចាន់ឌីណា** |
| **ចាន់ រ៉ូហ្សា** | |

| | |
|---|---|
| ថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍ | ឆ្នាំចូលសិក្សា ២០១៦ |
| ជំនាន់ទី ៤ | ឆ្នាំសរសេរសារណា ២០២០ |

# សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ ថាន ដាវីត និង ចាន់ រ៉ូហ្សា ជានិស្សិតថ្នាក់បរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍ ជំនាន់ទី៤ ក្រុម D4A1 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

## សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ

មាតាបិតារបស់យើងខ្ញុំទាំងពីរនាក់ដែលបានផ្តល់កំណើត និងខិតខំប្រឹងប្រែងបីបាច់ថែរក្សាកូនតាំងពីតូចរហូតដល់ធំដឹងក្តីជាមួយការអប់រំល្អៗប្រកបដោយព្រហ្មវិហារធម៌ចំពោះកូន។ លោកទាំងទ្វេរបានជួយផ្គត់ផ្គង់គ្រប់បែបគ្រប់យ៉ាង មិនថាកម្លាំងកាយ កម្លាំងចិត្ត ផ្នែកស្មារតី ព្រមទាំងផ្នែកសម្ភារៈ ក្នុងគោលបំណងតែមួយគត់គឺចង់ឃើញកូនៗទទួលបានការអប់រំដែលល្អ។ លោកទាំងពីរជាព្រះព្រហ្ម ជាគ្រូបាអាចារ្យ ជាគ្រូពេទ្យ ជាអ្នកលើកទឹកចិត្តរបស់កូនគ្រប់ពេលវេលា។ លោកបានផ្តល់ឱកាសឲ្យយើងខ្ញុំទាំងពីរនាក់សិក្សារៀនសូត្រតាំងពីថ្នាក់កុមារដ្ឋាន រហូតដល់ថ្នាក់ឧត្តមសិក្សាដើម្បីឲ្យកូនបានក្លាយជាបុគ្គលមានតម្លៃទាំងចំពោះខ្លួនឯង គ្រួសារ និងសង្គមជាតិ។

ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ប្រធានការិយាល័យសិក្សា និងសាស្ត្រាចារ្យបណ្ឌិតគ្រប់មុខវិជ្ជាទាំងអស់នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយ កម្លាំងចិត្តក្នុងការបង្ហាត់បង្រៀន ផ្តល់ដំបូន្មានល្អៗ ព្រមទាំងផ្ទេរនូវចំណេះដឹងដល់ពួកយើងខ្ញុំ និងសិស្សដទៃទៀតតាំងពីថ្នាក់មូលដ្ឋាន រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រ។

លោកសាស្ត្រាចារ្យបណ្ឌិត **ឌុយ ចាន់ឌីណា** ដែលបានដឹកនាំក្នុងការសរសេរសារណាមួយនេះ ព្រមទាំងជួយណែនាំ ចង្អុលបង្ហាញ ផ្តល់មតិយោបល់ ដំបូន្មានល្អៗ ទាំងផ្នែកស្មារតី និងឯកសារព្រមទាំងជួយត្រួតពិនិត្យកែតម្រូវចំណុចខ្វះខាត ជាពិសេសគឺពេលវេលាដ៏មានតម្លៃរបស់លោកនៅក្នុងកិច្ចការស្រាវជ្រាវមួយនេះ ចាប់តាំងពីចំណុចចាប់ផ្តើមរហូតដល់សារណាមួយនេះបានបញ្ចប់ប្រកបដោយជោគជ័យ។

លោកស្រីសាស្ត្រាចារ្យ **សំណាង ផលដេត** ដែលបានជួយសម្រួលដល់ឯកសាររបស់ក្រុមខ្ញុំបាទ ក្នុងការសុំចុះស្រាវជ្រាវ និងចំណាយពេលវេលាដ៏មានតម្លៃជួយត្រួតពិនិត្យមើលរចនាបថនៃសារណារបស់យើងខ្ញុំ។

លោកស្រី **ផេង សុផាផា** ជាប្រធានការិយាល័យវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃអគ្គនាយកដ្ឋានផែនការនិងស្ថិតិ ក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានអនុញ្ញាតឲ្យយើងខ្ញុំចុះស្រាវជ្រាវឯកសារដែលពាក់ព័ន្ធ ព្រមទាំងជួយសម្រួលទៅដល់ដំណើរការចុះស្រាវជ្រាវតាមរយៈការគាំទ្រ ពិគ្រោះយោបល់ និងផ្តល់ឯកសារ។

ជាទីបញ្ចប់ យើងខ្ញុំសូមគោរពជូនពរទៅដល់មាតាបិតាដែលជាអ្នកមានគុណទាំងពីរ រួមទាំងឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យគ្រប់មុខវិជ្ជាទាំងអស់ មិត្តនិស្សិត

សិស្សានុសិស្ស និងមិត្តរួមជំនាន់គ្រប់រូបទាំងអស់ សូមឲ្យប្រកបនូវសេចក្ដីសុខទាំងផ្លូវកាយនិងផ្លូវចិត្ត ទទួលជោគជ័យគ្រប់ភារកិច្ចការងារ ព្រមទាំងជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានបញ្ចប់ការសិក្សាប្រកបដោយជោគជ័យរយៈពេល ៤ឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិ-សាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រុមយើងខ្ញុំត្រូវបានខាងសាកលវិទ្យាល័យតម្រូវឲ្យជ្រើសរើសក្នុងការសរសេរសារណាបញ្ចប់ការសិក្សា ទៅតាមជំនាញឯកទេសដែលបានសិក្សាកន្លងមក។ ការសរសេរសារណាបញ្ចប់ការសិក្សានេះ គឺជាការចូលរួមចំណែកមួយដ៏សំខាន់ដែលឆ្លុះបញ្ចាំងពីទ្រឹស្តីក្រោយពីបានសិក្សាកន្លងមក ជាមួយនឹងបទពិសោធន៍ផ្ទាល់ក៏ដូចជាការអនុវត្តជាក់ស្តែង ដើម្បីជាស្ពានឆ្ពោះទៅរកការអភិវឌ្ឍបន្ថែមទៀត។

ក្នុងរយៈពេលជាង ២ទសវត្សរ៍ចុងក្រោយនេះ ប្រទេសកម្ពុជាបានអភិវឌ្ឍន៍លើគ្រប់វិស័យ ទាំងវិស័យឧស្សាហកម្ម សេវាកម្ម ជាពិសេសគឺវិស័យកសិកម្ម ដែលត្រូវបានរាជរដ្ឋាភិបាលកម្ពុជាចាត់ទុកជាវិស័យស្នូលក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។ ដោយឈរលើមូលដ្ឋាននៃការស្តារហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធធារាសាស្ត្រ ព័ត៌មានទីផ្សារ ការបណ្តុះបណ្តាលបច្ចេកទេសស្តីពីការប្រើប្រាស់ធាតុផ្សំ(Inputs)កសិកម្មប្រកបដោយប្រសិទ្ធភាព ហើយអ្វីដែលសំខាន់គឺការអនុវត្តកសិកម្មតាមបែបទំនើបឬហៅម៉្យាងទៀតថាប្រពលវប្បកម្ម បានជំរុញឲ្យវិស័យមួយនេះកាន់តែមានសារៈសំខាន់ក្នុងសេដ្ឋកិច្ចកម្ពុជា ដែលបានខ្វាក់នូវការងារជាច្រើនក្រៃលែងទៅដល់ប្រជាជនក្នុងប្រទេស ជាពិសេសក្នុងតំបន់ជនបទ។ ការរីកចម្រើននូវកម្រិតជីវភាពរបស់ប្រជាកសិករដែលបានមកពីការកើនឡើងនូវផលិតភាព គឺជាការចូលរួមយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។ ដោយបានមើលឃើញពីតួនាទីសំខាន់របស់កសិកម្ម ក្នុងការលើកកម្ពស់កម្រិតជីវភាពប្រជាពលរដ្ឋ ក៏ដូចជាសេដ្ឋកិច្ចជាតិ ទើបក្រុមយើងខ្ញុំសម្រេចធ្វើការស្រាវជ្រាវនិងស្វែងរកឯកសារបន្ថែម ដែលពាក់ព័ន្ធទៅនឹងកសិកម្ម ដើម្បីចងក្រងជាសារណាមួយនេះឡើង ក្នុងគោលបំណងទុកជាឯកសារសម្រាប់សិស្សានុសិស្សនិងមិត្តអ្នកអានទាំងឡាយណាដែលមានបំណងស្វែងយល់ ស្រាវជ្រាវ ក៏ដូចជាពង្រីកចំណេះដឹងបន្ថែមស្តីអំពីកសិកម្ម។ ថ្វីត្បិតតែ សារណាមួយនេះបានចេញជារូបរាងទៅហើយក្តី ប៉ុន្តែក្រុមយើងខ្ញុំជឿជាក់ថា ជាមួយនឹងបទពិសោធន៍ស្រាវជ្រាវនៅមានកម្រិត ច្បាស់ជាធ្វើឲ្យសមិទ្ធិផលមួយនេះនៅមានចំណុចខ្វះខាតខ្លះជាក់ជាមិនខាន។ យ៉ាងណាមិញ សារណាមួយក្បាលនេះអាចក្លាយជាឯកសារសម្រាប់សិក្សាពិគ្រោះ និងស្រាវជ្រាវសម្រាប់មិត្តនិស្សិត ដែលចង់ពង្រីកចំណេះដឹងបន្ថែមពាក់ព័ន្ធនឹងកសិកម្ម ឬជាឯកសារយោងសម្រាប់ស្រាវជ្រាវផងដែរ។

ជាចុងក្រោយ យើងខ្ញុំទាំងពីរនាក់សូមអភ័យទោសពីសំណាក់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងមិត្តអ្នកអានទាំងអស់នូវរាល់ចំណុចខ្វះខាតទាំងខ្លឹមសារ និងអក្ខរាវិរុទ្ធដែលមិនត្រឹមត្រូវដោយអចេតនា ព្រមទាំងទទួលយករាល់មតិរិះគន់ក្នុងន័យស្ថាបនាផងដែរ។

# មាតិកា


បញ្ជីអក្សរកាត់ ........ vi

បញ្ជីតារាង ........ viii

បញ្ជីរូប ........ viii

បញ្ជីក្រាហ្វិក ........ ix

បញ្ជីឧបសម្ព័ន្ធ ........ x


# សេចក្តីផ្តើម


១. លំនាំបញ្ហា ........ ១

២. ចំណោទបញ្ហា ........ ២

៣. គោលបំណងនៃការស្រាវជ្រាវ ........ ២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ៣

៥. វិធីសាស្ត្រស្រាវជ្រាវ ........ ៣

ក. ការប្រមូលទិន្នន័យ ........ ៣

ខ. ការវិភាគទិន្នន័យ ........ ៤

៦. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៤

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤


# ជំពូកទី ១
# ការអភិវឌ្ឍ ផលិតភាព និងកសិកម្ម


១.១ និយមន័យ និងទ្រឹស្តីការអភិវឌ្ឍ ........ ៦

១.១.១ និយមន័យការអភិវឌ្ឍ ........ ៦

១.១.២ ទ្រឹស្តីការអភិវឌ្ឍ ........ ៦

១.១.២.១ ទ្រឹស្តីរបស់លោក Rostow ........ ៦

១.១.២.២ ទ្រឹស្តីរបស់លោក Adam Smith ........ ៧

១.១.២.៣ ទ្រឹស្តីរបស់លោក David Ricardo ........ ៨

១.១.២.៤ ទ្រឹស្តីរបស់លោក Michel P.Todaro ........ ៨

១.១.២.៥ ទ្រឹស្តីរបស់លោក W. Arthur Lewis ........ ៩

១.២ ផលិតភាពកសិកម្ម ........ ១០

១.២.១ ផលិតភាពដីដាំដុះ..............................................................................................................១០
១.២.២ ផលិតភាពកម្លាំងពលកម្ម.........................................................................................................១០
១.២.៣ ផលិតភាពគ្រាប់ពូជ..............................................................................................................១១
១.៣ កត្តាដែលនាំឲ្យមានការអភិវឌ្ឍ.....................................................................................................១១
១.៣.១ ធនធានមនុស្ស...................................................................................................................១១
១.៣.២ ធនធានធម្មជាតិ..................................................................................................................១១
១.៣.៣ សមោហធានមូលធន............................................................................................................ ១២
១.៣.៤ បច្ចេកវិទ្យា.......................................................................................................................... ១២
១.៤ ឧបសគ្គនៃការអភិវឌ្ឍ.................................................................................................................. ១៣
១.៤.១ ទស្សនៈផ្គត់ផ្គង់សរុប............................................................................................................. ១៣
១.៤.២ ទស្សនៈតម្រូវការសរុប............................................................................................................ ១៣
១.៤.៣ សំយោគទស្សនៈទាំងពីរ.........................................................................................................១៤
១.៤.៣.១ មូលធន និងផលិតភាពកសិកម្ម...........................................................................................១៤
១.៤.៣.២ ការអភិវឌ្ឍធនធានមនុស្ស.................................................................................................១៤
១.៥ ទ្រឹស្តីជាមូលដ្ឋានជំរុញការអភិវឌ្ឍកសិកម្ម.....................................................................................១៥
១.៥.១ និយមន័យ..........................................................................................................................១៥
១.៥.២ តួនាទីកសិកម្មក្នុងការអភិវឌ្ឍ.................................................................................................១៥
១.៥.២.១ អភិវឌ្ឍន៍វិស័យកសិកម្មដោយផ្ទាល់......................................................................................១៦

## ជំពូកទី ២

## ស្ថានភាពទូទៅនៃវិស័យកសិកម្ម

២.១ ស្ថានភាពសេដ្ឋកិច្ចប្រទេសកម្ពុជា................................................................................................១៨
២.២ ប្រព័ន្ធផលិតកម្មកសិកម្ម..............................................................................................................១៩
២.២.១ ប្រព័ន្ធផលិតកម្មកសិកម្មតាមប្រពៃណី.......................................................................................១៩
២.៣ ការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិ.............................................................២០
២.៣.១ អត្រាផលិតផលកសិកម្មដែលបានចូលរួមក្នុង ផ.ផ.ស ចាប់ពីឆ្នាំ២០១៥-២០១៩.................. ២០
២.៣.២ សមាសធាតុនៃអនុវិស័យក្នុងវិស័យកសិកម្ម............................................................................. ២១
២.៤ ការវិវឌ្ឍនៃផលិតភាពកសិកម្មតាមបណ្ដាអនុវិស័យ...................................................................២២

២.៤.១ ការវិវឌ្ឍនៃផលិតភាពដំណាំស្រូវ ២០១៥-២០១៩ ..................... ២២
២.៥ តួនាទីរបស់ស្ថាប័ននានានៅក្នុងវិស័យកសិកម្ម ..................... ២៤
២.៥.១ តួនាទីរបស់អង្គការក្រៅរដ្ឋាភិបាលក្នុងការអភិវឌ្ឍ ..................... ២៥
២.៥.២ តួនាទីដៃគូអភិវឌ្ឍន៍ក្នុងការអភិវឌ្ឍវិស័យកសិកម្ម ..................... ២៦
២.៥.៣ តួនាទីវិស័យឯកជនក្នុងការអភិវឌ្ឍវិស័យកសិកម្ម ..................... ២៦
២.៦ គោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម ..................... ២៧
២.៦.១ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣ ..................... ២៧
២.៦.២ យុទ្ធសាស្ត្រចម្បងៗសម្រាប់បង្កើនផលិតភាពកសិកម្ម ..................... ២៨

## ជំពូកទី ៣

## ផលិតភាពកសិកម្ម

៣.១ ការប្រែប្រួលនៃវិស័យកសិកម្មក្នុងប្រទេសកម្ពុជា ..................... ៣០
៣.១.១ កម្លាំងពលកម្មក្នុងវិស័យកសិកម្ម ..................... ៣០
៣.១.២ ការប្រើប្រាស់គ្រឿងយន្តក្នុងវិស័យកសិកម្ម ..................... ៣១
៣.១.៣ ការប្រើប្រាស់ជី និងថ្នាំកសិកម្ម ..................... ៣២
៣.១.៤ សហគមន៍របស់កសិករ ..................... ៣៣
៣.១.៥ ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តជនបទ ..................... ៣៤
៣.២ កត្តាដែលជះឥទ្ធិពលក្នុងការបង្កើនផលិតភាពកសិកម្ម ..................... ៣៦
៣.២.១ ការបង្កើនផលិតភាពតាមមធ្យោបាយផលិតកម្មកសិកម្ម ..................... ៣៦
៣.២.១.១ ផលិតភាពដី ..................... ៣៦
៣.២.១.២ កត្តាធនធានទឹក ..................... ៤២
៣.២.១.៣ ជីកសិកម្ម ..................... ៤៦
៣.២.១.៤ ផលិតភាពគ្រាប់ពូជ ..................... ៤៩
៣.២.២ ការបង្កើនផលិតភាពកម្លាំងពលកម្ម ..................... ៥៤
៣.២.២.១ កម្លាំងពលកម្មកសិកម្មដែលមានគុណភាព ..................... ៥៤
៣.២.២.២ ការអភិវឌ្ឍពលកម្មកសិកម្ម ..................... ៥៥
៣.២.២.៣ ការបង្កើតសាលារៀនស្រែកសិករ ..................... ៥៧
៣.២.៣ កត្តាបច្ចេកវិទ្យា ..................... ៥៨

៣.២.៣.១ ម៉ាស៊ីនភ្ជួររាស់ ......................................................................................................៥៩
៣.២.៣.២ ម៉ាស៊ីនដាំគ្រាប់ ឬស្ទូងស្រូវ .......................................................................................៦០
៣.២.៣.៣ ម៉ាស៊ីនស្រោចស្រព.....................................................................................................៦០
៣.២.៣.៤ ដ្រូនកសិកម្ម (Drone) ..................................................................................................៦០
៣.២.៣.៥ ម៉ាស៊ីនច្រូតកាត់.........................................................................................................៦១
៣.២.៤ កត្តាហេដ្ឋារចនាសម្ព័ន្ធ ............................................................................................... ៦២
៣.២.៤.១ ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ............................................................................................ ៦២
៣.២.៤.២ ហេដ្ឋារចនាសម្ព័ន្ធសង្គម ............................................................................................ ៦៣
៣.២.៤.៣ សេវាឥណទានជនបទ ..................................................................................................៦៤
៣.២.៤.៤ ហេដ្ឋារចនាសម្ព័ន្ធអេឡិចត្រូនិច.......................................................................................៦៥
៣.៣ ទីផ្សារកសិកម្ម ..............................................................................................................៦៦
៣.៣.១ សារៈសំខាន់របស់ទីផ្សារកសិកម្ម ................................................................................... ៦៧
៣.៣.២ ការតភ្ជាប់កសិករទៅកាន់ទីផ្សារក្នុងស្រុក ..........................................................................៦៨
៣.៣.៣ ផលិតផលកសិកម្មក្នុងទីផ្សារអន្តរជាតិ ...............................................................................៦៩
៣.៤ បទពិសោធន៍កសិកម្មរបស់ប្រទេសក្នុងតំបន់អាស៊ាន(ASEAN)............................................... ៧១
៣.៤.១ ប្រទេសថៃ................................................................................................................. ៧១
៣.៤.២ សមិទ្ធិផលកសិកម្មដែលសម្រេចបាន ............................................................................... ៧២
៣.៤.៣ ផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្មក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមជាតិ លើកទី១២ (២០១៧-២០២១) .......................................................................................................៧៣

## ជំពូកទី ៤

## ការវាយតម្លៃលើការសិក្សាស្រាវជ្រាវស្តីពីផលិតភាពកសិកម្មកម្ពុជា

៤.១. បញ្ហាប្រឈមជារួមដែលរាំងស្ទះដល់កំណើនផលិតភាពកសិកម្ម.................................................... ៧៦
៤.១.១ បញ្ហាបរិស្ថាន ............................................................................................................ ៧៦
៤.១.២ ផ្នែកផលិតភាពកសិកម្ម និងទីផ្សារ...................................................................................៧៧
៤.១.៣ ផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងស្តុកកសិកម្ម............................................................................ ៧៨
៤.១.៤ ផ្នែកស្រាវជ្រាវបច្ចេកវិទ្យា និងបច្ចេកទេសកសិកម្ម ............................................................... ៧៩
៤.១.៥ ធនធានមនុស្ស............................................................................................................ ៧៩

៤.២. ដំណោះស្រាយជារួមក្នុងការបង្កើនផលិតភាពកសិកម្ម ........ ៨០
៤.២.១ ការកែលម្អមធ្យោបាយផលិតកម្មកសិកម្ម ........ ៨០
៤.២.២ ទីផ្សារកសិកម្ម និងការរក្សាលំនឹងថ្លៃលក់ ........ ៨៤
៤.២.៣ ការលើកទឹកចិត្តឲ្យកសិករបន្ថែមការប្រើប្រាស់គ្រឿងយន្តកសិកម្ម ........ ៨៦
៤.២.៤ បន្ថែមការគាំទ្រដល់សេវាកម្មកសិកម្ម ........ ៨៧
៤.២.៥ ការបង្កើតកសិកម្មចម្រុះ ប្រពលវប្បកម្ម និងកសិ-ឧស្សាហកម្ម ........ ៨៨
៤.២.៦ ការស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធ ........ ៨៩

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១. សេចក្តីសន្និដ្ឋាន ........ ៩០
២. អនុសាសន៍ ........ ៩១

## ឯកសារយោង

## ឧបសម្ព័ន្ធ

# បញ្ជីអក្សរកាត់

| ពាក្យអក្សរកាត់ | | ការពន្យល់ |
|---|---|---|
| ម២ | ៖ | ម៉ែត្រការេ |
| ម៣ | ៖ | ម៉ែត្រគូប |
| គ.ក្រ | ៖ | គីឡូក្រាម |
| ហ.ត | ៖ | ហិកតា |
| គ.ក្រ/ហ.ត | ៖ | គីឡូក្រាមក្នុង១ហិកតា |
| ត/ហ.ត | ៖ | តោនក្នុង១ហិកតា |
| ដង/ឆ្នាំ | ៖ | ដងក្នុង១ឆ្នាំ |
| ផ.ផ.ស = GDP | ៖ | ផលិតផលក្នុងស្រុកសរុប |
| ស.ម | ៖ | សង់ទីម៉ែត្រ |
| % | ៖ | ភាគរយ |
| K | ៖ | ប៉ូតាស្យូម |
| N | ៖ | អាសូត |
| P | ៖ | ផូស្វ័រ |
| S | ៖ | ស្ពាន់ធ័រ |
| Mg | ៖ | ម៉ាញេស្យូម |
| DAP | ៖ | ជីដេអាប៉េ |
| KCL | ៖ | ជីប៉ូតាស្យូ |
| Urea | ៖ | ជីអ៊ុយរ៉េ |
| ADB | ៖ | Asian Development Bank<br>ធនាគារអភិវឌ្ឍន៍អាស៊ី |
| AFTA | ៖ | ASEAN Free Trade Area<br>កិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន |
| CARDI | ៖ | Cambodian Agricultural Research and Development Institute<br>វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា |

| | | |
|---|---|---|
| FAO | ៖ | Food and Agriculture Organization<br>អង្គការស្បៀងអាហារ និងកសិកម្មនៃសហប្រជាជាតិ |
| WTO | ៖ | World Trade Organization<br>អង្គការពាណិជ្ជកម្មពិភពលោក |
| EBA | ៖ | Everything But Arms<br>ប្រព័ន្ធអនុគ្រោះពន្ធអនុញ្ញាតឲ្យនាំចូលគ្រប់យ៉ាងលើកលែងសព្វាវុធ |

# បញ្ជីតារាង

តារាងទី ១៖ ផ្ទៃដីដាំដុះ ផ្ទៃដីប្រមូលផល និងទិន្នផលសរុបរបស់ដំណាំស្រូវ ២០១៥-២០១៩ ................. ២៣
តារាងទី ២៖ បង្ហាញពីទិន្នផលសរុប ផ្ទៃដីប្រមូលស្រូវ និងបរិមាណនាំចេញសរុប ................................. ៧២

# បញ្ជីរូប

រូបទី ១៖ ទស្សនៈផ្គត់ផ្គង់សរុប ......................................................................................... ១៣
រូបទី ២៖ ទស្សនៈតម្រូវការសរុប......................................................................................... ១៣
រូបទី ៣៖ សំយោគទស្សនៈផ្គត់ផ្គង់សរុប និងតម្រូវការសរុប.............................................................. ១៤

## បញ្ជីក្រាហ្វិក

ក្រាហ្វិកទី ១៖ អត្រាផលិតផលកសិកម្មដែលចូលរួមក្នុង ផ.ស.ស ឆ្នាំ ២០១៥-២០១៩........................២១
ក្រាហ្វិកទី ២៖ បង្ហាញពីការចូលរួមនៃអនុវិស័យកសិកម្មឆ្នាំ ២០១៥-២០១៩.......................................២២
ក្រាហ្វិកទី ៣៖ កំណើនបរិមាណផល និងទិន្នផលនៃផលិតកម្មដំណាំស្រូវឆ្នាំ ២០១៥-២០១៩ ...............២៤
ក្រាហ្វិកទី ៤៖ កម្លាំងពលកម្មក្នុងវិស័យកសិកម្មឆ្នាំ ២០១៥-២០១៧ .................................................៣១
ក្រាហ្វិកទី ៥៖ បម្រែបម្រួលគ្រឿងយន្តកសិកម្មឆ្នាំ ២០១៥-២០១៨ ....................................................៣២
ក្រាហ្វិកទី ៦៖ បម្រែបម្រួលការនាំចូលថ្នាំនិងជីកសិកម្មឆ្នាំ ២០១៦-២០១៩ ........................................៣៣
ក្រាហ្វិកទី ៧៖ បង្ហាញពីកំណើនសហគមន៍កសិកម្មឆ្នាំ ២០១៥-២០១៩ ............................................៣៤
ក្រាហ្វិកទី ៨៖ បម្រែបម្រួលហេដ្ឋារចនាសម្ព័ន្ធរូបវន្តជនបទឆ្នាំ ២០១៥-២០១៩....................................៣៥
ក្រាហ្វិកទី ៩៖ បង្ហាញពីស្ថានភាពនៃការនាំចេញកសិផលសរុប និងអង្ករផ្លូវការឆ្នាំ ២០១៥-២០១៩.........៧០

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី ១៖ (ក) បរិមាណផលិតកម្មដំណាំស្រូវប្រចាំឆ្នាំ ២០១៩-២០២០

(ខ) ផលិតកម្មដំណាំស្រូវរយៈពេល ១០ឆ្នាំ ២០១០-២០១៩

(គ) ផលិតផលស្រូវឆ្នាំ ២០១៩-២០២០ និងតុល្យភាពស្បៀងឆ្នាំ ២០២០

ឧបសម្ព័ន្ធទី ២៖ កម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ចឆ្នាំ ២០១៥-២០១៧

ឧបសម្ព័ន្ធទី ៣៖ លក្ខណៈសម្បត្តិរបស់ប្រភេទក្រុមដីទាំង ១១

ឧបសម្ព័ន្ធទី ៤៖ ប្រភេទក្រុមដីទាំង ១១ប្រភេទ

ឧបសម្ព័ន្ធទី ៥៖ ពូជស្រូវគុណភាពខ្ពស់ទាំង ១០ប្រភេទ

ឧបសម្ព័ន្ធទី ៦៖ ប្រភេទគ្រឿងយន្តកសិកម្ម

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ប្រទេសកម្ពុជា គឺជាប្រទេសកំពុងអភិវឌ្ឍន៍ ដែលមានខឿនសេដ្ឋកិច្ចជាតិពឹងផ្អែកខ្លាំងទៅលើវិស័យកសិកម្មក្នុងការជំរុញកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំនៅឡើយ ហើយក្នុងឆ្នាំ ២០១៩នេះ មានប្រជាពលរដ្ឋចំនួន ៧៥.១% រស់នៅតំបន់ជនបទ ក្នុងនោះភាគច្រើនប្រកបរបរកសិកម្មជាមុខរបរចម្បងសម្រាប់ចិញ្ចឹមជីវិត។[1] សារៈសំខាន់របស់វិស័យកសិកម្ម ត្រូវបានស្តែងឲ្យឃើញតាមរយៈក្របខណ្ឌគោលនយោបាយ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាច្រើន ដែលបានផ្តោតជាសំខាន់ទៅលើការជំរុញនិងលើកស្ទួយវិស័យកសិកម្ម ជាមួយនឹងរបត់ថ្មីដើម្បីឈានឆ្ពោះទៅរកការពន្លឿននូវកំណើនសេដ្ឋកិច្ចជាតិ និងការកាត់បន្ថយភាពក្រីក្រយ៉ាងឆាប់រហ័ស។ ទោះជាយ៉ាងនេះក្តី ផលិតភាពកសិកម្មនៅប្រទេសកម្ពុជានៅតែជាអនុគមន៍ទៅនឹងការប្រែប្រួលរបស់ធម្មជាតិដូចជាភាពរាំងស្ងួត ទឹកជំនន់ កត្តាសត្វល្អិតជាដើម ជាហេតុនាំឲ្យទិន្នផលមាននិន្នាការថយចុះ។ បន្ថែមពីនេះ មានបញ្ហាប្រឈមមួយចំនួនទៀតដូចជា ភាពមានកម្រិតនៃការស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកទេសក្នុងការធ្វើកសិកម្ម ចំនួនហេដ្ឋារចនាសម្ព័ន្ធនៅជនបទមិនគ្រប់គ្រាន់ កង្វះការផ្គត់ផ្គង់សម្ភារៈនិងឧបករណ៍កសិកម្ម ព័ត៌មានទីផ្សារ ទុនបង្វិល ឥណទាន សង្វាក់ផ្គត់ផ្គង់មិនទាន់មានភាពប្រទាក់ក្រឡាគ្នា ហើយជាពិសេសធាតុផ្សំក្នុងការបង្កើនផលិតភាពកសិកម្មមានកម្រិតទាប ដែលកត្តាទាំងអស់នេះបានធ្វើឲ្យផលិតផលកសិកម្មពិបាកប្រកួតប្រជែងជាមួយនឹងបណ្តាប្រទេសនាំចេញដទៃទៀត។

យ៉ាងណាមិញ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការអភិវឌ្ឍវិស័យកសិកម្មកំពុងត្រូវបានរៀបចំ កែទម្រង់ និងដោះស្រាយជាបណ្តើរៗ ដោយរាជរដ្ឋាភិបាលនិងអង្គការមួយចំនួនដែលពាក់ព័ន្ធ។ ដើម្បីសម្រេចបានគោលបំណងនេះ រាជរដ្ឋាភិបាលតាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរួមទាំងស្ថាប័នសង្គមស៊ីវិលបានតម្រង់ទិសនៃការអភិវឌ្ឍវិស័យកសិកម្មកម្ពុជាឲ្យក្លាយជាកសិកម្មទំនើប មានផលិតភាពខ្ពស់ គុណភាពខ្ពស់ មានភាពធន់នឹងបម្រែបម្រួលអាកាសធាតុ មានភាពប្រកួតប្រជែង និងជាឃ្លាំងសន្តិសុខស្បៀងជាតិជាមួយនឹងការអភិវឌ្ឍជនបទគ្រប់ជ្រុងជ្រោយ ដែលអាចទាញផលប្រយោជន៍ជាអតិបរមាសម្រាប់អ្នកទទួលផលពីវិស័យកសិកម្ម ជាពិសេសគឺប្រជាកសិករនៅតំបន់ជនបទ ក្នុងការបង្កើនចំណូល ព្រមទាំងជាមូលដ្ឋានជំរុញពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្ម ដើម្បីឈានទៅចូលរួមទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ចជាតិ។ ទន្ទឹមនឹងការងារអភិវឌ្ឍន៍កែលម្អវិស័យកសិកម្មប្រកបដោយប្រសិទ្ធភាពនិងចីរភាព ដរាបណាមានការចូលរួមពីប្រជាជននៅតាមមូលដ្ឋានជាកត្តាសំខាន់បំផុត។ ការចូលរួមរបស់ប្រជាជនមានន័យថា រាល់ការជាប់ទាក់ទងទាំងអស់

[1] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣

របស់ប្រជាជន ជាមួយនឹងផែនការអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលគឺជាយន្តការផ្សារភ្ជាប់ប្រជាជនទៅនឹងទីផ្សារកសិកម្ម តាមរយៈការផ្តល់ជាគំនិតនានាឆ្ពោះទៅការប្រកួតប្រជែង ការអនុវត្តសកម្មភាពជាដៃគូរ កំណត់បញ្ហាប្រឈម ស្វែងរកដំណោះស្រាយ និងសកម្មភាពអភិវឌ្ឍន៍ផ្សេងៗទៀត ដើម្បីឲ្យវិស័យកសិកម្មកម្ពុជាឈានទៅដល់ដំណាក់កាលប្រែប្រួលជាវិជ្ជមានថ្មីមួយទៀត។

## ២. ចំណោទបញ្ហា

ប្រទេសកម្ពុជា បានកំពុងតែស្ថិតនៅក្នុងសមាហរណកម្មសេដ្ឋកិច្ច ទាំងក្នុងកម្រិតតំបន់និងពិភពលោក ដូច្នេះហើយ ការប្រកួតប្រជែងនៅលើទីផ្សារក្នុងស្រុកនិងទីផ្សារអន្តរជាតិ ច្បាស់ជាមានការកើនឡើងជាក់ជាមិនខាន។ ក្នុងពេលបច្ចុប្បន្ន ការអនុវត្ត AFTA និង WTO បានធ្វើឲ្យរបាំងពាណិជ្ជកម្មនានាត្រូវបានលុបចោលសឹងទាំងស្រុង ជាមូលហេតុនាំឲ្យផលិតកម្មក្នុងស្រុក នឹងទទួលរងសម្ពាធពីការប្រកួតប្រជែងកាន់តែខ្លាំង។ ដូចនេះ ផលិតផលកសិកម្ម ក៏ដូចជាទំនិញនិងសេវាកម្មផ្សេងទៀតដែរគឺ នៅពេលដែលផលិតផលកសិកម្មបរទេសចូលក្នុងទីផ្សារកម្ពុជាដោយសេរីហើយនោះ កសិកម្មកម្ពុជានឹងអាចជួបប្រទះនូវព្យុះភ្លៀងបើសិនជាយើងមិនបង្កើននូវផលិតភាពឲ្យបានប្រសើរដើម្បីតតាំងនឹងផលិតករក្រៅប្រទេស។ ក្នុងគោលបំណងចូលរួមដោះស្រាយបញ្ហាដែលប្រឈម យើងត្រូវតែធ្វើឲ្យវិស័យកសិកម្មកាន់តែមានផលិតភាព ប៉ុន្តែជាដំបូង យើងត្រូវស្វែងយល់ឲ្យបានច្បាស់ពីកត្តាដែលជះឥទ្ធិពលដល់ផលិតភាពកសិកម្ម ទើបអាចចាត់វិធានការឲ្យមានប្រសិទ្ធភាព។ បញ្ហាដែលគួរយកមកពិភាក្សារួមមាន៖

- តើកសិកម្មនៅកម្ពុជាមានស្ថានភាពយ៉ាងដូចម្តេច?
- តើមានកត្តាអ្វីខ្លះដែលជះឥទ្ធិពលដល់ផលិតភាពកសិកម្ម?
- តើត្រូវធ្វើដូចម្តេចខ្លះដើម្បីបង្កើនផលិតភាពតាមរយៈកត្តាទាំងនោះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ជាការពិតណាស់ ដើម្បីឲ្យការសិក្សាស្រាវជ្រាវប្រកបដោយជោគជ័យ យើងត្រូវកំណត់គោលបំណងឲ្យបានច្បាស់ជាមុនសិន ដែលគោលបំណងទាំងនោះរួមមាន៖

- ការសិក្សាលើទ្រឹស្តីដែលពាក់ព័ន្ធ
- ចង់បង្ហាញពីស្ថានភាពកសិកម្មរបស់ប្រទេសកម្ពុជា
- ចង់បង្ហាញពីកត្តាដែលជះឥទ្ធិពលមកលើផលិតភាពកសិកម្ម
- និយាយពីវិធីសាស្ត្រជាមូលដ្ឋានដើម្បីបង្កើនផលិតភាពកសិកម្មតាមរយៈកត្តាទាំងនោះ
- ចង់ចែករំលែក និងផ្សព្វផ្សាយជាសាធារណៈនូវវិធីសាស្ត្រ ដែលបង្កើនផលិតភាពកសិកម្ម

❖ បង្ហាញពីយុទ្ធសាស្ត្រនានាដែលតាក់តែងឡើងដោយរាជរដ្ឋាភិបាល និងអង្គការពាក់ព័ន្ធដែលចូលរួមអភិវឌ្ឍន៍វិស័យកសិកម្ម។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវប្រធានបទស្តីពី "ផលិតភាពកសិកម្មនៅប្រទេសកម្ពុជា" ក្រុមយើងខ្ញុំបានផ្តោតសំខាន់តែទៅលើអនុវិស័យកសិកម្មដំណាំមួយប្រភេទគត់ ពោលគឺដំណាំស្រូវ។ មួយវិញទៀត ក្រុមយើងខ្ញុំបានធ្វើការសិក្សានៅចន្លោះឆ្នាំ ២០១៥ ដល់ ២០១៩ ដោយផ្អែកលើឯកសារដែលមានជាក់ស្តែង និយាយជាលក្ខណៈទូទៅនៃស្ថានភាពសេដ្ឋកិច្ចកម្ពុជានៅត្រឹមឆ្នាំ ២០១៩ និងពិភាក្សាលើកត្តាដែលជះឥទ្ធិពលចំពោះវិស័យកសិកម្មក្នុងការបង្កើនផលិតភាព។

## ៥. វិធីសាស្ត្រស្រាវជ្រាវ

វិធីសាស្ត្រនៃការស្រាវជ្រាវនេះ គឺធ្វើឡើងតាមរបៀបពិពណ៌នាពន្យល់ (វិធីសាស្ត្រគុណភាព)និងប្រើស្ថិតិពិពណ៌នាសម្រាប់ជាជំនួយក្នុងការបកស្រាយ និងបញ្ជាក់ឲ្យកាន់តែច្បាស់។

### ក. ការប្រមូលទិន្នន័យ

ក្នុងសារណានេះ ទិន្នន័យទាំងអស់ ត្រូវបានប្រមូលតាមរបៀបទិន្នន័យបន្ទាប់បន្សំ (Secondary data) សម្រាប់ដកស្រង់យកទិន្នន័យសំខាន់ៗដែលពាក់ព័ន្ធ។ ទិន្នន័យបន្ទាប់បន្សំ (Secondary data) គឺសម្តៅទៅលើប្រភេទទិន្នន័យស្រាវជ្រាវ ដែលប្រមូលបានតាមរយៈសៀវភៅ របាយការណ៍ ឯកសារផ្សេងៗជាច្រើនដូចជា៖

- សៀវភៅសារណា និងរបាយការណ៍បញ្ចប់ការសិក្សា នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យា-សាស្ត្រសេដ្ឋកិច្ច
- របាយការណ៍បូកសរុបការងារប្រចាំឆ្នាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ ២០១៩-២០២៣
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣
- ផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួងអភិវឌ្ឍន៍ជនបទឆ្នាំ ២០២០-២០២២
- ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុសម្រាប់វិស័យទឹក
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទឆ្នាំ ២០១៩-២០២៣
- ឯកសាររបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
- ឯកសារបានមកពីការស្រាវជ្រាវតាមប្រព័ន្ធអ៊ីនធឺណែត បណ្ណាល័យ និងស្ថាប័ននានា។

**ខ. ការវិភាគទិន្នន័យ**

បន្ទាប់ពីប្រមូលព័ត៌មាន និងទិន្នន័យរួចហើយ ក្រុមយើងខ្ញុំបានធ្វើការជ្រើសរើសព័ត៌មាននិងទិន្នន័យ ដែលពាក់ព័ន្ធ ដែលមានប្រយោជន៍សម្រាប់យកមកពិភាក្សាលើផលិតកម្មដំណាំស្រូវ ដោយប្រើកម្មវិធី Excel ជាជំនួយក្នុងការវិភាគឲ្យមានភាពសុក្រិត និងបង្ហាញជាតារាងដើម្បីងាយស្រួលក្នុងការបកស្រាយ។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

អត្ថប្រយោជន៍នៃការសិក្សាស្រាវជ្រាវអំពីប្រធានបទ "ផលិតភាពកសិកម្មនៅប្រទេសកម្ពុជា" មានដូចខាងក្រោម៖

- ទទួលបានចំណេះដឹងផ្នែកទ្រឹស្តី និងការវិភាគទិន្នន័យជាក់ស្តែង
- ទទួលបានចំណេះដឹងថ្មីៗ និងការពិគ្រោះយោបល់ពីសាស្ត្រាចារ្យណែនាំ តាំងពីដំណើរការនៃការប្រមូលទិន្នន័យ ចងក្រង ពិភាក្សា និងរហូតដល់សារណាមួយនេះលេចជារូបរាងឡើង
- ទទួលបានទំនាក់ទំនងល្អក្នុងសង្គមការងារស្រាវជ្រាវក្នុងជួររាជរដ្ឋាភិបាល
- ទទួលបានបទពិសោធន៍យ៉ាងច្រើនទាក់ទងទៅនឹងវិស័យកសិកម្ម ជាពិសេសគឺផលិតកម្មដំណាំស្រូវ ដោយបានដឹងពីទិន្នន័យពិតប្រាកដពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ បន្ថែមពីនេះ គឺបានដឹងពីកត្តាជារួមក្នុងការបង្កើនផលិតភាពកសិកម្ម។
- អាចចែករំលែកពីការសិក្សាស្រាវជ្រាវពីវិស័យកសិកម្ម ទៅដល់និស្សិតជំនាន់ក្រោយ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងប្រធានបទ "ផលិតភាពកសិកម្មនៅប្រទេសកម្ពុជា" ត្រូវបានបែងចែកចេញជា ៦ផ្នែកសំខាន់ៗ ដូចខាងក្រោម៖

- **សេចក្តីផ្តើម** គឺជាចំណុចផ្តើមនៃប្រធានបទមួយនេះ ដែលនឹងធ្វើការសិក្សាទៅលើផ្នែកមួយចំនួនដូចជា ស្ថានភាពទូទៅរបស់កសិកម្ម មូលហេតុនៃការសិក្សា គោលបំណងនៃការសិក្សា ទំហំនិងដែនកំណត់ក្នុងការស្រាវជ្រាវ វិធីសាស្ត្រស្រាវជ្រាវ ដែលនាំឲ្យកម្ពុជាផ្តោតសំខាន់លើវិស័យកសិកម្មក្នុងការជំរុញវិស័យមួយនេះឲ្យកាន់តែមានផលិតភាព។

- **ជំពូកទី១៖ ការអភិវឌ្ឍ ផលិតភាព និងកសិកម្ម** ក្នុងជំពូកនេះ ក្រុមយើងខ្ញុំបាននិយាយពីនិយមន័យខ្លះៗស្តីពីការអភិវឌ្ឍ និងបានលើកយកទ្រឹស្តីរបស់អ្នកប្រាជ្ញមួយចំនួន មកធ្វើការសិក្សាដែលធ្វើយ៉ាងណាជំរុញឲ្យមានការអភិវឌ្ឍ។ បន្ថែមពីលើនេះ យើងខ្ញុំក៏បានបកស្រាយពីនិយមន័យផលិតភាពកសិកម្មនិយាយជារួម និងផលិតភាពដោយផ្នែក ថែមទាំងពន្យល់ពីពាក្យកសិកម្មទៅតាមនិយមន័យផ្សេងៗគ្នាផងដែរ។

- **ជំពូកទី២៖ ស្ថានភាពទូទៅនៃវិស័យកសិកម្ម** នៅត្រង់នេះ យើងខ្ញុំនឹងធ្វើការសិក្សាទៅលើស្ថានភាពទូទៅនៃវិស័យកសិកម្មកម្ពុជា បង្ហាញពីការរួមចំណែករបស់វិស័យកសិកម្មនៅក្នុងសេដ្ឋកិច្ចជាតិ ព្រមទាំងនិយាយពីគោលនយោបាយរបស់រាជរដ្ឋាភិបាលនិងស្ថាប័នពាក់ព័ន្ធទាំងអស់ក្នុងការអភិវឌ្ឍវិស័យកសិកម្មដែលទាក់ទងនឹងដំណាំស្រូវ។
- **ជំពូកទី៣៖ ផលិតភាពកសិកម្ម** នេះគឺជាជំពូកសំខាន់ជាងគេនៅក្នុងប្រធានមួយនេះ ដោយនិយាយអំពីកត្តាសំខាន់ៗ ដែលបានជះឥទ្ធិពលទៅដល់ការបង្កើនផលិតភាពកសិកម្ម។ ការប្រែប្រួលជារួមនៃធាតុផ្សំនៅក្នុងវិស័យកសិកម្ម ទីផ្សារកសិកម្ម រួមទាំងបទពិសោធន៍កសិកម្មរបស់ប្រទេសជិតខាង ក៏ត្រូវបានលើកយកមកបង្ហាញក្នុងជំពូកនេះដែរ។
- **ជំពូកទី៤៖ ការវាយតម្លៃលើការសិក្សាស្រាវជ្រាវស្តីពីផលិតភាពកសិកម្មកម្ពុជា** ក្នុងជំពូកមួយនេះ ក្រុមយើងខ្ញុំនឹងធ្វើការបកស្រាយស្តីពីទិដ្ឋភាពជារួមសំខាន់ៗ ដែលជាបញ្ហាប្រឈមជារួមចំពោះកំណើនផលិតភាពនៃវិស័យកសិកម្មកម្ពុជា និងសិក្សារែកញែកថាតើត្រូវចាត់ចេញដំណោះស្រាយបែបណា ដែលសមស្របទៅនឹងបញ្ហាទាំងនោះ។
- **សន្និដ្ឋាន និងអនុសាសន៍** គឺជាចំណុចចុងក្រោយបង្អស់ ដែលធ្វើការសង្ខេបប្រធានបទឡើងវិញ និងមិនតែប៉ុណ្ណោះថែមទាំងមានភ្ជាប់ជាមតិយោបល់មួយចំនួន ធ្វើជាអនុសាសន៍ចំពោះប្រធានបទនេះទៀតផង។

# ជំពូកទី ១

# ការអភិវឌ្ឍ ផលិតភាព

# និងកសិកម្ម

# ជំពូកទី១

# ការអភិវឌ្ឍ ផលិតភាព និងកសិកម្ម

## ១.១ និយមន័យ និងទ្រឹស្តីការអភិវឌ្ឍ

### ១.១.១ និយមន័យការអភិវឌ្ឍ

ការអភិវឌ្ឍ គឺជាដំណើរការឬនីតិវិធីផ្សេងៗនៃការប្រែក្លាយរចនាសម្ព័ន្ធសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ស្ថាប័ន ដែលបង្កលក្ខណៈងាយស្រួល ឬអំណោយផលទៅដល់ការជំរុញសេដ្ឋកិច្ចឲ្យមានភាពរីកចម្រើន និងបន្តកំណើន រយៈពេលយូរ។ និយាយបែបម្យ៉ាងទៀត ការអភិវឌ្ឍគឺជាការបង្កលក្ខខណ្ឌដើម្បីឲ្យប្រសើរឡើងនៃសេដ្ឋកិច្ច សង្គម ប្រកបដោយចីរភាព។[2]

អភិវឌ្ឍន៍ គឺជាដំណើរការធ្វើឲ្យប្រសើរខាងគុណភាព នៃការរស់នៅរបស់មនុស្សទាំងអស់ដែលបង្ហាញ ក្រោមលក្ខខណ្ឌចំនួនបីដូចខាងក្រោម៖

- ការធ្វើឲ្យប្រសើរឡើងនូវ កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ ដូចជាកម្រិតប្រាក់ចំណូល បម្រើបម្រាស់របស់ប្រជាពលរដ្ឋកើនឡើង សេវាសុខាភិបាលល្អ និងការអប់រំប្រសើរជាងមុនដោយយោងតាមកំណើននៃសេដ្ឋកិច្ចប្រកបដោយសុខុមាលភាព។
- ការបង្កើតនូវលក្ខខណ្ឌដែលនាំឲ្យមានការគោរពខ្លួនឯង ដោយឆ្លងតាមរយៈការបង្កើននូវស្ថាប័នសង្គម ស្ថាប័ននយោបាយ និងស្ថាប័នសេដ្ឋកិច្ចជាដើម។
- ការបង្កើតសេរីភាពក្នុងការប្រើប្រាស់ឲ្យកាន់តែមានទំហំធំ ដូចជាប្រជាជនមានសិទ្ធិសេរីភាពក្នុងការសម្រេចចិត្ត ក្នុងការទិញទំនិញនិងសេវាដែលខ្លួនពេញចិត្ត។

### ១.១.២ ទ្រឹស្តីការអភិវឌ្ឍ

អភិវឌ្ឍន៍ គឺជាពាក្យមួយដែលមានអត្ថន័យទូលំទូលាយ ហើយមានការប្រែប្រួលខ្លឹមសារទៅតាមសម័យកាលនីមួយៗ និងទៅតាមការយល់ឃើញរបស់អ្នកប្រាជ្ញផ្សេងៗគ្នាពីមួយជំនាន់ទៅមួយជំនាន់ផងដែរ។ ដើម្បីឲ្យយល់ឃើញកាន់តែច្បាស់ពីពាក្យ "អភិវឌ្ឍន៍" ក្រុមយើងខ្ញុំសូមលើកយកការបកស្រាយខ្លឹមសារពីសំណាក់អ្នកប្រាជ្ញមួយចំនួនដូចខាងក្រោម៖

#### ១.១.២.១ ទ្រឹស្តីរបស់លោក Rostow

លោក Rostow ជាសេដ្ឋវិទូជនជាតិអាមេរិក បានឲ្យនិយមន័យថា គ្រប់ប្រជាជាតិទាំងអស់អាចឈានទៅ

[2] ឡៃ ប៉ូរ៉ាពីន, *ការអភិវឌ្ឍវិស័យកសិកម្មនៅប្រទេសកម្ពុជា(២០១៧)*, ទំព័រ ៦។

ដល់ការអភិវឌ្ឍបាន ដរាបណាពួកគេដើរតាមគន្លងរបស់ប្រទេសអភិវឌ្ឍន៍ ហើយរក្សានូវលក្ខខណ្ឌក្នុងការធានាឲ្យមានកំណើនសេដ្ឋកិច្ចយូរអង្វែង ដែលតម្រូវឲ្យប្រទេសទាំងនោះត្រូវឆ្លងកាត់តាមដំណាក់កាលទាំង ៥៖

**ក. ដំណាក់កាលសង្គមប្រពៃណី**

ដំណាក់កាលនេះ ជាដំណាក់កាលដែលប្រទេសមានសេដ្ឋកិច្ចពឹងផ្អែកទៅលើកសិកម្មខ្លាំង ដែលប្រភពចំណូលមានតែមួយគត់គឺកសិកម្ម (កសិកម្មបែបគ្រួសារ)។ លទ្ធភាពក្នុងការជំរុញឲ្យមានការកែប្រែសង្គម និងដំណើរការផលិតកម្មសឹងតែស្មើសូន្យ ជាពិសេសមានការប្រកាន់ឋានានុក្រមខ្លាំងក្នុងទំនាក់ទំនងសង្គម មានន័យថាជាប្រទេសមួយដែលមានការរីកចម្រើនតិចតួចបំផុត។

**ខ. ដំណាក់កាលសង្គមស្ថិតក្នុងចំណុចរបត់ទៅរកការអភិវឌ្ឍ**

ជាដំណាក់កាលដែលមានការចាប់ផ្តើមធ្វើបដិវត្តនៅក្នុងផ្នែកផលិតកម្ម មានការកើនឡើងនៃធាតុផ្សំ (Inputs) ការវិនិយោគ មានន័យថា ជាប្រទេសដែលស្ថិតនៅក្នុងចន្លោះអន្តរកាលនៃការអភិវឌ្ឍ។

**គ. ដំណាក់កាលនៃការចាប់ផ្តើមអភិវឌ្ឍន៍**

វិស័យឧស្សាហកម្ម ដែលជាវិស័យចលករនៃសេដ្ឋកិច្ចបានចាប់កំណើត និងរីកចម្រើនលូតលាស់ធំធាត់ជាលំដាប់។ សកម្មភាពសេដ្ឋកិច្ចមានភាពមមាញឹកជាងមុន រក្សាបាននូវកំណើនសេដ្ឋកិច្ចដែលចាប់ផ្តើមអភិវឌ្ឍន៍ក្នុងប្រទេស ជាពិសេសគឺទីក្រុងនិងទីប្រជុំជន។

**ឃ. ដំណាក់កាលសង្គមចាស់ទុំ**

ការអភិវឌ្ឍបានជ្រាបចូលទៅដល់គ្រប់ច្រកល្ហកនៅក្នុងប្រទេស ជាពិសេសតំបន់ជនបទ។ ផ្នែកផលិតកម្មមានការរីកចម្រើនគួរឲ្យកត់សម្គាល់ ដោយសារតែមានការកើនឡើងវត្តមាននៃបច្ចេកវិទ្យាដែលធ្វើឲ្យវិស័យឧស្សាហកម្មប្រទេសទាំងនោះមានវ័យចំណាស់ និងចូលរួមក្នុងសេដ្ឋកិច្ចជាតិយ៉ាងខ្លាំងក្លា។

**ង. ដំណាក់កាលនៃបម្រើបម្រាស់ទ្រង់ទ្រាយធំ**

នេះជាដំណាក់កាលចុងក្រោយ មានកំណើនខ្លាំងនៃបម្រើបម្រាស់ និងសេចក្តីត្រូវការជាមូលដ្ឋានរបស់ប្រជាជនត្រូវបានដោះស្រាយជាស្ថាពរ។ ការអភិវឌ្ឍវិស័យសុខាភិបាលសង្គម ពង្រីកអំណាចសេដ្ឋកិច្ច ប្រទេសដែលមានលក្ខណៈដូចខាងលើត្រូវបានគេហៅថាប្រទេសមហាអំណាចសេដ្ឋកិច្ច។[3]

**១.១.២.២ ទ្រឹស្តីរបស់លោក** Adam Smith

លោក Adam Smith គឺជាសេដ្ឋវិទូក្លាស៊ីក ដែលត្រូវបានគេប្រសិទ្ធនាមជាបិតាសេដ្ឋកិច្ច ពីព្រោះតែរូបលោកបានបង្កើតនូវទ្រឹស្តីសេដ្ឋកិច្ចជាច្រើន ដែលសុទ្ធតែមានឥទ្ធិពលមកដល់ពេលបច្ចុប្បន្ន។ ក្នុងនោះដែរ តាមលោក Adam Smith បាននិយាយថា ការអភិវឌ្ឍ គឺសង្កត់ធ្ងន់ទៅលើការពង្រឹងសមត្ថភាពរបស់ប្រជាជនម្នាក់ៗ មាន

[3] ឡៃ ប៉ូរ៉ាពីន, *ការអភិវឌ្ឍវិស័យកសិកម្មនៅប្រទេសកម្ពុជា(២០១៧)*, ទំព័រ ៧។

ន័យថា ជាការធ្វើឲ្យកើនឡើងនូវចំណេះ និងជំនាញផ្សេងៗដែលពាក់ព័ន្ធទៅនឹងការប្រកបការងារប្រចាំថ្ងៃ។ លោកបានបន្ថែមទៀតថា នៅពេលប្រជាជនមានជំនាញច្បាស់លាស់ មានន័យថាពួកគេមានផលិតភាពការងារខ្ពស់ ពេលនោះដែរ ការងាររបស់ពួកគេនឹងទទួលបានទិន្នផលខ្ពស់និងល្អជាង បើប្រៀបធៀបទៅអ្នកដែលមិនមានជំនាញ។ និយាយម្យ៉ាងទៀត ពេលប្រជាជនក្នុងប្រទេសសុទ្ធតែមានជំនាញនិងផលិតភាពការងារខ្ពស់ ពួកគេមិនត្រឹមអាចផលិតទំនិញសម្រាប់ផ្គត់ផ្គង់ក្នុងស្រុកប៉ុណ្ណោះទេ ថែមទាំងអាចធ្វើការនាំចេញទៅកាន់ទីផ្សារអន្តរជាតិទៀតផង។ ពេលនោះហើយ ដែលប្រទេសមួយមានការអភិវឌ្ឍជាលំដាប់។[4]

**១.១.២.៣ ទ្រឹស្តីរបស់លោក** David Ricardo

លោក David Ricardo គឺជាសេដ្ឋវិទូក្លាស៊ីកម្នាក់ដ៏មានឥទ្ធិពល ក្នុងការបង្កើតនូវទ្រឹស្តីសេដ្ឋកិច្ចជាច្រើនដែលផ្តល់ផលប្រយោជន៍ជូនមនុស្សជាតិ។ ក្នុងគំនិតរបស់លោក David Ricardo ការអភិវឌ្ឍ គឺអាស្រ័យទៅលើតួអង្គសេដ្ឋកិច្ចសំខាន់ៗ៣ក្រុមដែលមានវត្តមាននៅក្នុងសង្គមសេដ្ឋកិច្ចមួយគឺ អ្នកមានដីធ្លីជាកម្មសិទ្ធិ អ្នកមានមូលធន និងអ្នកធ្វើការ ដែលតួអង្គសេដ្ឋកិច្ចទាំង៣ក្រុមនេះគឺមានទំនាក់ទំនងគ្នាយ៉ាងស្អិតរមួតក្នុងការបង្កើតទ្រព្យសម្បត្តិប្រជាជាតិ។ មានន័យថា អ្នកមានដីគួរតែជួលដីទៅឲ្យអ្នកមានមូលធនក្នុងការបង្កបង្កើនផលកសិកម្មឬវិនិយោគ ជាថ្នូរនឹងទៅប្រាក់ជួលដីទទួលបាន ចៀសជាងទុកដីទំនេរចោល។ ក្នុងនោះដែរ អ្នកធ្វើការអាចផ្គត់ផ្គង់កម្លាំងពលកម្មទៅឲ្យក្រុមមូលធនជាថ្នូរនឹងប្រាក់ខែដែលទទួលបាន ដើម្បីពង្រីកជីវភាពរស់នៅ។ ដំណើរការនេះចេះតែបន្តទៅមុខ តួអង្គសេដ្ឋកិច្ចទាំង៣បំពេញមុខងារដើម្បីទទួលបានផលប្រយោជន៍រៀងៗខ្លួន ពេលនោះសង្គមនឹងមានការអភិវឌ្ឍជាក់ជាមិនខាន។[5]

**១.១.២.៤ ទ្រឹស្តីរបស់លោក** Michel P.Todaro

តាមគំនិតរបស់លោក Michel P.Todaro បាននិយាយថា ការអភិវឌ្ឍអាចនឹងកើតមានឡើងប្រកបដោយចីរភាពបានគឺគេត្រូវចាប់ផ្តើមចេញពីតំបន់ជនបទទៅ ជាពិសេសគឺផ្តោតសំខាន់ទៅលើវិស័យកសិកម្ម។ លោកបានលើកឡើងទៀតថា ប្រជាជាតិមួយអាចឈានទៅដល់ការអភិវឌ្ឍយ៉ាងហោចណាស់ត្រូវមានកត្តាចំនួនបីគឺ ការពន្លឿននូវធាតុចេញ(Outputs) តាមរយៈការធ្វើកំណែទម្រង់ផ្នែកស្ថាប័ន ក៏ដូចជាបច្ចេកវិទ្យា ដែលត្រូវបានរៀបចំឡើងដើម្បីបង្កើនផលិតភាពសម្រាប់កសិកម្មតូចតាច បង្កើតតម្រូវការក្នុងស្រុកសម្រាប់ផលិតកម្មកសិកម្មដែលមានប្រភពមកពីយុទ្ធសាស្ត្រអភិវឌ្ឍន៍ការងារជាយក្រុង ជាពិសេសគឺសកម្មភាពអភិវឌ្ឍន៍ជនបទ ដើម្បី

[4] Dr. Pranav K. Desai, *Agricultural Economics[សេដ្ឋកិច្ចកសិកម្ម], (បោះពុម្ពឆ្នាំ២០១០)*, ទំព័រ ១៨-១៩។

[5] Dr. Pranav K. Desai, *Agricultural Economics[សេដ្ឋកិច្ចកសិកម្ម], (បោះពុម្ពឆ្នាំ២០១០)*, ទំព័រ ២០។

ពង្រីកកម្លាំងពលកម្មមិនមែនកសិកម្ម ក៏ដូចជាវិស័យដទៃផ្សេងទៀតដែលជួយគាំទ្រដោយផ្ទាល់ ឬដោយប្រយោលពីសមាគមន៍កសិកម្ម។[6]

**១.១.២.៥ ទ្រឹស្តីរបស់លោក** W. Arthur Lewis

ទ្រឹស្តីសេដ្ឋកិច្ចអភិវឌ្ឍន៍របស់លោក Lewis គឺជាដំណើរការនៃការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច ពីវិស័យដែលពុំទាន់ទទួលបានការអភិវឌ្ឍល្អ ទៅទំនើបកម្មនិងឧស្សាហកម្មទីក្រុង។ និយាយបែបផ្សេង តាមលោក Lewis លំនាំនៃការអភិវឌ្ឍ គឺជាការផ្លាស់ប្តូរខឿនសេដ្ឋកិច្ចជាតិដែលពឹងផ្អែកទៅលើវិស័យតែមួយ ភាគច្រើនគឺលើវិស័យកសិកម្ម ទៅជាខឿនសេដ្ឋកិច្ចដែលពឹងផ្អែកលើវិស័យថ្មីផ្សេងៗទៀត គឺវិស័យឧស្សាហកម្មនិងសេវាកម្ម ហើយវិស័យទាំងពីរនេះបានដើរតួនាទីជាក្បាលម៉ាស៊ីនសេដ្ឋកិច្ចជំនួសឲ្យវិស័យកសិកម្ម។ ទ្រឹស្តីនេះបានក្លាយជាទ្រឹស្តីទូទៅនៃដំណើរការ អភិវឌ្ឍន៍ សម្រាប់ប្រទេសជាតិមួយ ដែលមានភាពលើសនៃកម្លាំងពលកម្មសកម្ម កំឡុងទសវត្សរ៍ទី៦០ និង៧០។ ក្នុងគំនិតរបស់លោក Lewis ខឿនសេដ្ឋកិច្ចអភិវឌ្ឍន៍មានពីរស៊ិចទ័រ គឺស៊ិចទ័រប្រពៃណីឬស៊ិចទ័រកសិកម្ម និងស៊ិចទ័រឧស្សាហកម្មទីក្រុង។[7]

- **ស៊ិចទ័រប្រពៃណីឬស៊ិចទ័រកសិកម្ម** គឺជាស៊ិចទ័រកសិកម្មតាមជនបទដែលមានប្រជាជនលើសលប់ធ្វើការក្នុងវិស័យនេះ។ នៅពេលនោះ ផលិតភាពពលកម្មម៉ាស៊ីណាល់ក្នុងវិស័យកសិកម្មស្មើសូន្យ ដោយសារតែមានអ្នកធ្វើការកសិកម្មច្រើនជ្រុល ជាហេតុនាំឲ្យដំណើរការកសិកម្មមានភាពយឺតយ៉ាវនិងទិន្នផលទាប។ ស្ថានភាពនេះ ត្រូវបានគេហៅថា ពលកម្មលើស ក្នុងអត្ថន័យដែលគេអាចដកកម្លាំងពលកម្មចេញពីស៊ិចទ័រកសិកម្ម ទៅស៊ិចទ័រឧស្សាហកម្មដោយសឹងតែគ្មានប៉ះពាល់ដល់ផលិតផលកសិកម្មឡើយ។
- **ស៊ិចទ័រឧស្សាហកម្ម** ស៊ិចទ័រនេះមានផលិតភាពខ្ពស់និងរួមចំណែកក្នុងសេដ្ឋកិច្ចជាតិច្រើន ព្រមទាំងមានលំហូរនៃកម្លាំងពលកម្មចេញពីស៊ិចទ័រកសិកម្មបន្តិចម្តងៗ។ តាមគំនិតលោក គឺគេផ្តោតសំខាន់ទៅលើដំណើរការនៃការផ្ទេរកម្លាំងពលកម្មនិងអត្រានិកម្មភាពក្នុងស៊ិចទ័រឧស្សាហកម្ម។ ល្បឿននៃការពង្រីកក្នុងវិស័យនេះ អាស្រ័យទៅលើការកើនឡើងផលិតផល (Outputs) ដែលជាគ្រឿងលើកទឹកចិត្តក្នុងការវិនិយោគបន្ថែមទៅលើសមោធានមូលធនក្នុងស៊ិចទ័រមួយនេះ។ នៅពេលប្រាក់ចំណេញមានការកើនឡើង ពួកគេបានយកទៅវិនិយោគក្នុងមូលធនទាំងអស់ ដើម្បីពង្រីកដំណើរការឧស្សាហកម្មរបស់ពួកគេ ជាហេតុនាំឲ្យតម្រូវការពលកម្មមានការកើនឡើងជាលំដាប់។ លោក Lewis បានបន្ថែម

[6] ឡៃ ប៉ូរ៉ាពីន, *ការអភិវឌ្ឍវិស័យកសិកម្មនៅប្រទេសកម្ពុជា(២០១៧)*, ទំព័រ ៦-៧។

[7] នាង អ៊ីសាយ និង ឡុងមុំ សុជីវី, *ការអភិវឌ្ឍជនបទកម្ពុជាផ្អែកលើវិស័យកសិកម្ម(២០១៣)*, ទំព័រ ១២។

ទៀតថា ពលកម្មដែលធ្វើការក្នុងស៊ិចទ័រឧស្សាហកម្មទទួលបានប្រាក់ខែខ្ពស់ជាង ប្រាក់ចំណូលពីស៊ិចទ័រកសិកម្ម ហើយនេះក៏ជាមូលហេតុក្នុងការទាក់ទាញកម្លាំងពលកម្ម ពីស៊ិចទ័រកសិកម្មមកស៊ិចទ័រឧស្សាហកម្មដែរ។

## ១.២ ផលិតភាពកសិកម្ម

ពាក្យថា **ផលិតភាព** មានន័យថាជាភាពដែលអាចផលិតបានក្នុងចំណាយ ១ឯកតា។[8] ចំណែកឯ **ផលិតភាពកសិកម្ម** គឺជាបរិមាណផលិតផលឬទិន្នផលកសិកម្មដែលគេអាចផលិតបានសមាមាត្រជាមួយធាតុផ្សំរបស់កសិកម្ម។ ក្នុងនោះដែរ ផលិតភាពកសិកម្មត្រូវបានគេបែងចែកជា ៣ផ្នែកសំខាន់ៗគឺ ផលិតភាពដីដាំដុះ ផលិតភាពកម្លាំងពលកម្ម និងផលិតភាពគ្រាប់ពូជ។

### ១.២.១ ផលិតភាពដីដាំដុះ

ផលិតភាពដីដាំដុះ មានន័យថាជាភាពដែលដីអាចផលិត ឬផ្តល់ទិន្នផលបានក្នុងផ្ទៃដី១ហិកតា។

| |
|---|
| ផលិតភាពដីដាំដុះ = ទិន្នផល/ទំហំផ្ទៃដី(ហិកតា) |

**ឧទាហរណ៍** គ្រួសារដារ៉ាជាប្រជាកសិករ ពួកគាត់ប្រកបរបរដាំស្រូវក្នុងទំហំផ្ទៃដី ៤ហិកតា។ នៅក្នុងឆ្នាំនេះទិន្នផលស្រូវរបស់គាត់បានទទួលចំនួន ៤តោន។ (១ហិកតា = ១០,០០០ម$^{២}$ និង ១តោន = ១,០០០គ.ក្រ)

យោងទៅតាមសម្មតិកម្មខាងលើ យើងអាចដឹងបានថា ផលិតភាពដីដាំដុះរបស់គ្រួសារដារ៉ា មានចំនួន ១ត/ហ.ត ឬ១,០០០ គ.ក្រ/ហ.ត។

### ១.២.២ ផលិតភាពកម្លាំងពលកម្ម

ផលិតភាពកម្លាំងពលកម្ម មានន័យថាជាភាពដែលអាចផលិតបានរបស់ប្រជាកសិករម្នាក់ៗ។

| |
|---|
| ផលិតភាពកម្លាំងពលកម្ម = ទិន្នផល/ចំនួនពលកម្ម(១នាក់) |

**ឧទាហរណ៍** ដូចនៅក្នុងឧទាហរណ៍ខាងលើដែរ។ ក្នុងទំហំដី ៤ហិកតានោះ ពួកគាត់បានប្រើកម្លាំងពលកម្មចំនួន ១០នាក់។

ដូចនេះយើងអាចដឹងបានថា ផលិតភាពកម្លាំងពលកម្មក្នុងម្នាក់ៗរបស់គ្រួសារដារ៉ាមានចំនួន ៤០០គ.ក្រ។

[8] វណ្ណា ដារិទ្ធ, *ការបង្កើនផលិតភាពកសិកម្មស្រុកសំឡូត(២០០៦)*, ទំព័រ ៥។

#### **១.២.៣ ផលិតភាពគ្រាប់ពូជ**

ផលិតភាពគ្រាប់ពូជ គឺជាភាពដែលគ្រាប់ពូជអាចផលិត ឬផ្តល់ទិន្នផលបានក្នុងចំនួន ១គីឡូក្រាម។

| ផលិតភាពគ្រាប់ពូជ = ទិន្នផល/ចំនួនគ្រាប់ពូជ(គីឡូក្រាម) |
|---|

**ឧទាហរណ៍** តពីឧទាហរណ៍ខាងលើដដែល។ ក្នុងផ្ទៃដី ៤ហិកតានោះ ពួកគាត់បានប្រើគ្រាប់ពូជស្រូវអស់ចំនួន ១,៦០០ក្រាម ឬ១.៦គ.ក្រ ដើម្បីសាបព្រោះ។ ដូចនេះយើងអាចដឹងបានថា ផលិតភាពគ្រាប់ពូជស្រូវរបស់គ្រួសារដារ៉ា បានប្រើអស់ចំនួន ៤០០ក្រាមដើម្បីផលិតស្រូវបាន ១តោន។ និយាយម៉្យាងទៀត ក្នុងផ្ទៃដី១ហិកតាត្រូវការគ្រាប់ពូជស្រូវ ៤០០ក្រាម ហើយផ្តល់ទិន្នផលបាន ១តោនឬ១,០០០គ.ក្រ។

### **១.៣ កត្តាដែលនាំឲ្យមានការអភិវឌ្ឍ**

សេដ្ឋវិទូបានកំណត់ថា សឹងគ្រប់ប្រទេសទាំងអស់មិនថាជាប្រទេសអភិវឌ្ឍន៍ ឬប្រទេសកំពុងអភិវឌ្ឍន៍ក៏ដោយ ត្រូវមានកត្តារួមផ្សំចំនួន ៤ យ៉ាងដើម្បីធ្វើឲ្យសេដ្ឋកិច្ចរបស់ខ្លួនអាចមានការអភិវឌ្ឍទៅមុខប្រកបបានដោយចីរភាព។[9]

#### **១.៣.១ ធនធានមនុស្ស**

សេដ្ឋវិទូជាច្រើនបានជឿជាក់ថា ការដែលកម្លាំងពលកម្មមានជំនាញ ចំណេះដឹង ព្រមទាំងបទពិសោធន៍មានន័យថា គឺជាធនធានមនុស្សដ៏សំខាន់ជាងគេបំផុតនៅក្នុងដំណើរការផលិតកម្ម ហើយក៏ជាកត្តាមួយដែលមិនអាចខ្វះបានក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។ គេអាចទិញធាតុផ្សំផ្សេងៗបន្ថែមចូលទៅក្នុងផលិតកម្មដូចជា ទំនិញ មូលធន វត្ថុធាតុដើម បច្ចេកវិទ្យាដែលស្ថិតក្រោមទម្រង់ឧបករណ៍សព្វបែបយ៉ាងដូចជាកុំព្យូទ័រ ឧបករណ៍អគ្គីសនី ឧបករណ៍ទូរគមនាគមន៍ជាដើម ប៉ុន្តែមានតែកម្មករដែលមានការបណ្តុះបណ្តាលច្បាស់លាស់និងមានជំនាញទេ ដែលអាចប្រើប្រាស់និងជួសជុលមូលធនទាំងនេះបានយ៉ាងមានប្រសិទ្ធភាពទៀតផង។ ការរីកចម្រើនក្នុងផ្នែកសុខភាព វិន័យ កាត់បន្ថយអនក្ខរភាព ហើយថ្មីៗនេះការរីកចម្រើនសមត្ថភាពក្នុងការប្រើប្រាស់កុំព្យូទ័រ បានបង្កើនផលិតភាពការងារយ៉ាងខ្ពស់។

#### **១.៣.២ ធនធានធម្មជាតិ**

ធនធានធម្មជាតិជាកត្តាទី២ នៃដំណើរការផលិតកម្ម ដែលកាលពីមុនសេដ្ឋវិទូពួកក្លាស៊ីកបានចាត់ទុកថាដីជាកត្តាទី២ក្នុងដំណើរការផលិតកម្ម។ ធនធានធម្មជាតិសំខាន់ៗរួមមាន ប្រេងឆៅនិងឧស្ម័នធម្មជាតិ ព្រៃឈើ

[9] កង តារ៉ាវុធ និង ពូក សុភាព, *វិស័យកសិកម្ម និងការអភិវឌ្ឍ(២០១២)*, ទំព័រ១២-១៤។

ទឹកនិងរ៉ែក្រោមដីផ្សេងៗ។ ជាទូទៅ ធនធានធម្មជាតិដែលមានតម្លៃជាងគេបំផុតរបស់បណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ គឺជាដីដែលមានជីជាតិហើយអាចដាំដុះបាន។ ភាគច្រើននៃកម្លាំងពលកម្មសកម្ម ជាពិសេសនៅតំបន់ជនបទរបស់ប្រទេសកំពុងអភិវឌ្ឍន៍ គឺធ្វើការនៅតាមស្រែចម្ការ។ ដូច្នេះផលិតកម្មរបស់ដីនឹងកើនឡើង អាស្រ័យទៅលើបច្ចេកទេសកាប់ដីភ្ជួររាស់ឲ្យបានត្រឹមត្រូវ និងមានការរក្សាគុណភាពដីបានល្អ គឺជាមូលហេតុធ្វើឲ្យផលិតផលកសិកម្មរបស់ប្រទេសកើនឡើង។ លើសពីនេះទៅទៀត ការផ្ដល់ឲ្យមានលទ្ធភាពកាន់កាប់ដីក្នុងរូបភាពឯកជន គឺជាគន្លឹះនៃការលើកទឹកចិត្តដ៏ខ្លាំងក្លាចំពោះកសិករ ឲ្យមានការវិនិយោគបន្ថែមទៅលើទំនិញមូលធននិងបច្ចេកវិទ្យា ក្នុងគោលបំណងបង្កើនទិន្នផលដីរបស់ពួកគេ ព្រមទាំងអនុវត្តន៍នូវការរក្សាគុណភាពដីឲ្យមានសមស្រប។

### ១.៣.៣ សមោហធានមូលធន

ដោយសារតែប្រទេសដែលមានចំណូលខ្ពស់គឺមានមូលធនច្រើន គឺជាកត្តាមួយនៅក្នុងចំណោមកត្តាចម្បងផ្សេងៗទៀត ដែលនាំឲ្យពួកគេមានផលិតភាពខ្ពស់។ សមោធានមូលធនទាមទារឲ្យមានការលះបង់នូវបម្រើបម្រាស់នាពេលបច្ចុប្បន្នក្នុងរយៈពេលច្រើនឆ្នាំ ក្នុងគោលបំណងទទួលបានផលចំណេញនាពេលអនាគត។ សេដ្ឋវិទូមួយចំនួនជឿថា ប្រទេសដែលមានកត្តាផលិតកម្មច្រើននិងជឿនលឿន គឺដោយសារតែពួកគេបានចាប់ផ្ដើមសន្សំដើម្បីយកទៅវិនិយោគតាំងពីពេលមុនមកម្ល៉េះ។ ជាឧទាហរណ៍ ប្រទេសដែលមានកំណើនសេដ្ឋកិច្ចខ្ពស់ តែងវិនិយោគទឹកប្រាក់ចំនួន ១០-២០% នៃចំណូលជាតិរបស់ពួកគេដើម្បីទិញទំនិញមូលធន។ ផ្ទុយមកវិញ ពេលអត្រាសន្សំរបស់ជាតិទាប និងបណ្ដាលឲ្យកើតមានបញ្ហាសេដ្ឋកិច្ច។ នៅពេលយើងនិយាយដល់មូលធន ភាគច្រើនគឺសម្ដៅទៅលើគ្រឿងបរិក្ខារ រោងចក្រ និងឧបករណ៍ផ្សេងៗទៀត ប៉ុន្តែជាក់ស្ដែង មានមូលធនខ្លះមានតែរដ្ឋាភិបាលទេទើបអាចវិនិយោគបាន។ វិនិយោគបែបនោះមានឈ្មោះហៅថា **មូលធនចំណាយលើសង្គម** **(Social overhead capital)** ឬហៅម្យ៉ាងទៀត **មូលធនរូបវន្តឬរចនាសម្ព័ន្ធ** ដែលមានដូចជា ផ្លូវថ្នល់ អគ្គីសនី ប្រព័ន្ធធារាសាស្ត្រ សេវាសាធារណៈផ្សេងៗទៀតជាដើម។ គម្រោងវិនិយោគបែបនេះ វិស័យឯកជនមិនអាចរ៉ាប់រងបានទេ ដែលមានតែរដ្ឋាភិបាលទេទើបអាចធានារ៉ាប់រងលើវិនិយោគនេះបាន។

### ១.៣.៤ បច្ចេកវិទ្យា

បច្ចេកវិទ្យា គឺជាកត្តាសំខាន់ដែលធ្វើឲ្យមានកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស។ បច្ចេកវិទ្យារួមបញ្ចូលទាំងបម្រែបម្រួលបច្ចេកវិទ្យា និងការបញ្ចូលរបៀបថ្មីៗ។ ការបង្កើតថ្មីនាំឲ្យផលិតភាពកើនឡើង ឯបម្រែបម្រួលបច្ចេកវិទ្យា ជាសញ្ញានៃបម្រែបម្រួលក្នុងដំណើរការផលិតកម្ម ឬជាសញ្ញានៃការដាក់ផលិតផលថ្មីឲ្យប្រើប្រាស់ជាលើកដំបូង ហើយដែលគេអាចផលិតផលិតផលបានច្រើនជាងមុន ប្រើពេលតិចជាងមុន និងល្អជាងមុន ជាមួយនឹង

ធាតុផ្សំ(Inputs)នៃកត្តាផលិតកម្មដូចពីមុន។ បម្រែបម្រួលបច្ចេកវិទ្យា តាមពិតគឺជាដំណើរការកែលម្អគុណភាពក្នុងទ្រង់ទ្រាយតូចទៅទ្រង់ទ្រាយធំ។

## ១.៤ ឧបសគ្គនៃការអភិវឌ្ឍ

ប្រទេសជាច្រើន ទាំងប្រទេសអភិវឌ្ឍន៍ឬកំពុងអភិវឌ្ឍន៍ បានមើលឃើញចំណុចមួយរួមដែលជាឧបសគ្គឬរនាំងចម្បងនៃការអភិវឌ្ឍគឺ វដ្តនៃភាពក្រីក្រ ដែលគេអាចបកស្រាយបានទៅតាមទស្សនៈ ២យ៉ាងគឺ ទស្សនៈផ្គត់ផ្គង់សរុប និងទស្សនៈតម្រូវការសរុប។[10]

### ១.៤.១ ទស្សនៈផ្គត់ផ្គង់សរុប

រូបទី ១ បង្ហាញពីទស្សនៈផ្គត់ផ្គង់សរុប




បើមើលទៅតាមរូបទី ១ បង្ហាញឲ្យឃើញថា នៅពេលដែលខាងផ្គត់ផ្គង់មានផលិតភាពក្នុងផ្នែកផលិតកម្មទាប ធ្វើឲ្យគេផលិតបានធាតុចេញ(Outputs)ទាប ជាហេតុនាំឲ្យទទួលបានប្រាក់ចំណូលទាប។ ពេលប្រាក់ចំណូលទាប បានធ្វើឲ្យអត្រាសន្សំទាប នោះវិនិយោគបន្ថែមចូលទៅក្នុងផ្នែកផលិតកម្មក៏ទាបដែរ ជាហេតុនាំឲ្យខ្វះខាតមូលធនក្នុងការពង្រីកកត្តាផលិតកម្មបន្ថែម ដែលចុងក្រោយក៏បានធ្វើឲ្យផលិតភាពក្នុងផលិតកម្មកាន់តែទាប។

### ១.៤.២ ទស្សនៈតម្រូវការសរុប

រូបទី ២ បង្ហាញពីទស្សនៈតម្រូវការសរុប




តាមរូបទី ២ បង្ហាញឲ្យឃើញថា នៅពេលដែលខាងតម្រូវការមានផលិតភាពពលកម្មមនុស្សទាប ធ្វើឲ្យពួកគេទទួលបាននូវប្រាក់ចំណូលទាប។ ពេលដែលប្រាក់ចំណូលរបស់ប្រជាជនទាប បានជះឥទ្ធិពលទៅដល់ផ្នែកតម្រូវការទាំងទំនិញ និងសេវាកម្មក៏មានការធ្លាក់ចុះដែរ ជាហេតុនាំឲ្យផ្នែកផ្គត់ផ្គង់ខ្វះកត្តាជំរុញដែលឲ្យមានការវិនិយោគបន្ថែមទៅក្នុងផ្នែកផលិតកម្មពីព្រោះតែតម្រូវការធ្លាក់ចុះ។

[10] ឡៃ បូរ៉ាពីន, *ការអភិវឌ្ឍវិស័យកសិកម្មនៅប្រទេសកម្ពុជា(២០១៧)*, ទំព័រ ១០-១១។

### ១.៤.៣ សំយោគទស្សនៈទាំងពីរ

រូបទី ៣ បង្ហាញអំពីការសំយោគទស្សនៈផ្គត់ផ្គង់សរុប និងតម្រូវការសរុប




ផលិតភាពទាបជាមូលហេតុចម្បងមួយក្នុងចំណោមមូលហេតុចម្បងផ្សេងៗទៀត ដែលរារាំងដល់ការអភិវឌ្ឍសេដ្ឋកិច្ច ជាពិសេសគឺវដ្តនៃភាពក្រីក្ររបស់មនុស្ស ដែលបណ្តាលមកពីការអប់រំ និងការបណ្តុះបណ្តាលទាប ជាហេតុនាំឲ្យអត្រាប្រជាពលរដ្ឋក្នុងសង្គមមានកំណើនយ៉ាងលឿន។ ជាទូទៅ គេមានមធ្យោបាយចំនួនពីរយ៉ាង ក្នុងការបង្កើនផលិតភាព ដើម្បីជំរុញទៅដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងប្រទេសជាតិ ដែលមធ្យោបាយពីរយ៉ាងនោះគឺៈ

#### ១.៤.៣.១ មូលធន និងផលិតភាពកសិកម្ម

ដើម្បីឲ្យផលិតភាពពលកម្មកើនឡើង ទាមទារឲ្យមានការបង្កើនមូលធនទាំងបរិមាណ និងគុណភាព ហើយប្រភពធនធាន ដើម្បីឲ្យសម្រេចគោលដៅនេះបានមកពីការអនុវត្តនយោបាយកៀងគរនូវការសន្សំតូចតាច ដែលរាយប៉ាយពាសពេញផ្ទៃប្រទេស តាមរយៈការជំរុញឲ្យមហាជនចូលរួមក្នុងការសន្សំកាន់តែច្រើនឡើង។ ការបញ្ចូលខ្លួនទៅនឹងខ្សែសង្វាក់ផលិតកម្មនៃសមាហរណកម្មសេដ្ឋកិច្ចពិភពលោក ក្នុងគោលបំណងចម្បងមួយគឺដើម្បីទទួលបានជំនួយអភិវឌ្ឍន៍ និងឥណទានអភិវឌ្ឍន៍សម្រាប់យកមកពង្រីកកត្តាផលិតកម្ម ក៏ដូចជាផលិតភាពរបស់ពលករ។

#### ១.៤.៣.២ ការអភិវឌ្ឍធនធានមនុស្ស

ការបង្កើនផលិតភាពរបស់ពលករឬកសិករ តាមរយៈការសិក្សាបណ្តុះបណ្តាលបច្ចេកទេសផ្សេងៗ រួមទាំងការវិនិយោគធនធានមនុស្ស ដោយផ្អែកលើការថែរក្សាសុខភាព បង្កើននូវជំនាញ ចំណេះដឹង និងការចូលរួមយ៉ាងមមារញឹកពីសំណាក់ប្រជាជនទៅក្នុងសកម្មភាពសេដ្ឋកិច្ចឲ្យបានច្រើនជាងកំណើនប្រជាជនដែលកំពុងតែកើនឡើង គឺសុទ្ធតែជាមូលដ្ឋានគ្រឹះនៅក្នុងការអភិវឌ្ឍធនធានមនុស្ស សេដ្ឋកិច្ចជាតិ ក៏ដូចជាប្រទេសជាតិ។

## ១.៥ ទ្រឹស្តីជាមូលដ្ឋានជំរុញការអភិវឌ្ឍកសិកម្ម

### ១.៥.១ និយមន័យ

កសិកម្ម ត្រូវបានគេឲ្យនិយមន័យខុសៗគ្នា ទៅតាមទស្សនៈនិងការយល់ឃើញរបស់អ្នកប្រាជ្ញនីមួយៗ និង ទៅតាមសម័យកាល ក៏ប៉ុន្តែអត្ថន័យរបស់វាមិនមានភាពខុសគ្នាខ្លាំងប៉ុន្មានទេ។ ទាំងនេះ គឺជានិយមន័យដែល គេពេញនិយមបកស្រាយពីពាក្យកសិកម្ម។[11]

**កសិកម្ម** គឺជាផ្នែកមួយនៃផលិតកម្មរបស់មនុស្សជំនាន់ដើម ដែលមានការចូលរួមពីកត្តាផលិតកម្មរបស់វា ពាក់ព័ន្ធទៅនឹងការកែប្រែដី ការដាំដុះ និងការចិញ្ចឹមសត្វ។

**កសិកម្ម** គឺជាសកម្មភាពឬក៏អំពើរបស់មនុស្សក្នុងការកែប្រែដី ការដាំដុះ និងការចិញ្ចឹមសត្វ។

**កសិកម្ម** គឺជាវិធីសាស្ត្រឬសិល្បៈ នៃការកែច្នៃដី ការចិញ្ចឹម ការធ្វើគ្រាប់ពូជ ការបង្កាត់ពូជ និងការផលិត ស្បៀងអាហារគ្រប់មុខ ដើម្បីផ្គត់ផ្គង់តម្រូវការរបស់មនុស្ស។

ជាពិសេសទៅទៀត ការអភិវឌ្ឍវិស័យកសិកម្ម សម្តៅទៅលើការធ្វើឲ្យប្រែប្រួលទិន្នផលកសិកម្មជាវិជ្ជមាន និងការកែប្រែគុណភាពរបស់ដីពីទាបទៅខ្ពស់ ឬធ្វើការយកនូវបច្ចេកវិទ្យាថ្មីៗចូលទៅក្នុងផលិតកម្មកសិកម្ម ដែលគេហៅថា យន្តូបនីយកម្ម។

### ១.៥.២ តួនាទីកសិកម្មក្នុងការអភិវឌ្ឍ

ពេលបច្ចុប្បន្ននេះ រាល់ប្រទេសកាន់តែមានការអភិវឌ្ឍជឿនលឿន យើងសង្កេតឃើញថាវិស័យកសិកម្មបាន ចូលរួមកាន់តែតិចទៅៗ ចូលក្នុងផលិតផលក្នុងស្រុកសរុប។ ការធ្លាក់ចុះនៃចំណែករបស់វិស័យកសិកម្មក្នុង ផលិតផលក្នុងស្រុកសរុប មិនមែនដោយសារវិស័យកសិកម្មបានថយចុះកំណើននោះទេ ផ្ទុយទៅវិញគឺនៅតែ មានកំណើន ប៉ុន្តែដោយសារតែកម្លាំងពលកម្មមួយភាគបានចាកចេញទៅក្នុងវិស័យឧស្សាហកម្ម ជាហេតុ បណ្តាលឲ្យវិស័យឧស្សាហកម្មបានចូលរួមក្នុង ផ.ផ.ស មួយខ្ពស់ជាង។ ក្នុងន័យនេះ ការរួមចំណែកផល ចំណូលសរុបរបស់វិស័យកសិកម្មកាន់តែតិច រីឯការប្រើប្រាស់កម្លាំងពលកម្មសកម្មក៏កាន់តែតិចដែរ។ ងាកទៅ មើលប្រទេសកំពុងអភិវឌ្ឍន៍ឬប្រទេសក្រីក្រវិញ វិស័យកសិកម្មបានដើរតួនាទីមួយសំខាន់ណាស់ក្នុងការអភិវឌ្ឍ សេដ្ឋកិច្ចជាតិឲ្យមានការរីកចម្រើន ក៏ព្រោះតែវិស័យមួយនេះបានចូលរួមក្នុង ផ.ផ.ស ក្នុងកម្រិតមួយខ្ពស់ ព្រម ទាំងបានផ្គត់ផ្គង់នូវការងារជាច្រើនទៅដល់ប្រជាជននៅតំបន់ជនបទទៀតផង។ ដូចនេះហើយ ប្រទេសកំពុង អភិវឌ្ឍន៍ឬប្រទេសក្រីក្រទាំងអស់ គប្បីគួរតែសិក្សាឲ្យបានស៊ីជម្រៅ ទៅលើទំនាក់ទំនងរវាងវិស័យកសិកម្មនិង សេដ្ឋកិច្ច ដើម្បីជាសូចនាករក្នុងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាព។

[11] ឡៃ បូរ៉ាពីន, *ការអភិវឌ្ឍវិស័យកសិកម្មនៅប្រទេសកម្ពុជា(២០១៧)*, ទំព័រ ១២។

### ១.៥.២.១ អភិវឌ្ឍន៍វិស័យកសិកម្មដោយផ្ទាល់

ក្នុងតួនាទីជាអ្នកផ្គត់ផ្គង់ស្បៀងអាហារ និងរួមចំណែកទៅដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ វិស័យកសិកម្មអាចរីកចម្រើនទៅបានដោយពឹងផ្អែកទៅលើ៖

**ក. ការធ្វើបដិវត្តន៍បៃតង**

ការធ្វើបដិវត្តន៍បៃតង គឺជាការផ្លាស់ប្តូរនូវបច្ចេកទេសដាំដុះដែលមានលក្ខណៈច្បាស់លាស់ពិតប្រាកដ ព្រមទាំងសមស្របទៅតាមសណ្ឋានដី អាកាសធាតុ សង្គមកិច្ច សេដ្ឋកិច្ច និងប្រពៃណីរបស់ប្រទេសតតីយលោកទៀតផង។ ការផ្ទេរបច្ចេកទេសពីប្រទេសអភិវឌ្ឍន៍ត្រូវបានបង្ហាញដោយលោក Schutz(ជាអ្នកមានឥទ្ធិពលក្នុងការប្រើប្រាស់ចំណេះដឹង និងបទពិសោធន៍របស់ប្រទេសឧស្សាហកម្ម មកប្រើឡើងវិញក្រោមរូបភាពជាបដិវត្តន៍បៃតង) ដែលរូបលោកបានធ្វើការស្នើសុំឲ្យប្រទេសអភិវឌ្ឍន៍ធ្វើការផ្ទេរនូវបទពិសោធន៍ វិធីសាស្ត្រ និងចំណេះដឹងទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍ដែលគ្មានបច្ចេកទេសទាំងនេះ។ ប៉ុន្តែបច្ចេកទេសដែលផ្ទេរទាំងអស់នេះ គឺមិនមែនជាបច្ចេកទេសដែលហួសសម័យ ហើយប្រទេសជឿនលឿនលែងប្រើប្រាស់នោះទេ ហើយបច្ចេកទេសដែលផ្ទេរទាំងអស់នោះ គឺត្រូវតែសមស្របទៅនឹងសណ្ឋានដី ជីវសាស្ត្រ និងទីកន្លែងផងដែរ។

**ខ. បច្ចេកទេសបដិវត្តន៍បៃតង**

ការធ្វើបដិវត្តន៍បៃតង ត្រូវបានបង្កើតឡើងជា ៤ វិធីសាស្ត្រថ្មីគឺ៖

- សម្ភារៈជីវសាស្ត្រ ដែលទទួលបានលទ្ធផលល្អបំផុតព្រមទាំងត្រូវបានគេផ្សព្វផ្សាយយ៉ាងខ្លាំងគឺ គ្រាប់ពូជដែលមានទិន្នផលខ្ពស់
- ការផ្សព្វផ្សាយនិងបង្រៀនពីវិធីសាស្ត្រប្រើប្រាស់ជី(ជីគីមី ជីកំប៉ុស) គឺជាកម្លាំងចលករមួយសំខាន់បំផុតក្នុងការបង្កើនទិន្នផលកសិកម្ម
- ប្រព័ន្ធធារាសាស្ត្រ ត្រូវតែមានការពង្រឹង និងពង្រីកឲ្យមានភាពល្អប្រសើរថែមទៀត
- ការធ្វើប្រពលវប្បកម្មក្នុងការប្រើប្រាស់ដី ដែលមានដូចជាបច្ចេកទេសក្នុងការដាំដុះ និងការប្រមូលផលត្រូវធ្វើតាមបច្ចេកទេសដើម្បីទទួលបានផលិតភាពខ្ពស់។

**គ. វិធានការប្រពលវប្បកម្ម**

វិធានការប្រពលវប្បកម្ម គឺជាការធ្វើកសិកម្មបែបអតិផល ឬការដាំដុះឲ្យបានទិន្នផលខ្ពស់។ គោលបំណងនេះអាចសម្រេចទៅបាន ពិតជាត្រូវការចាំបាច់ឲ្យមានការអភិវឌ្ឍទៅលើកត្តា៖

- ការប្រើប្រាស់ដីឲ្យអស់លទ្ធភាព ពោលគឺកំណើនផលិតផលតាមរយៈការពង្រីកផ្ទៃដី
- ពង្រីកបច្ចេកវិទ្យាតាមរយៈការស្រាវជ្រាវ
- ពង្រីកប្រព័ន្ធធារាសាស្ត្រ

- កសាងផ្លូវថ្នល់ ដើម្បីងាយស្រួលដឹកជញ្ជូនកសិផលទៅកាន់ទីផ្សារ
- ការបណ្តុះបណ្តាល (សម្រាប់ទទួលផលរយៈពេលវែង និងពេលខ្លី)
- កម្មសិទ្ធិដីធ្លីច្បាស់លាស់
- លំហូរព័ត៌មានអំពី ការបញ្ជាទិញ បច្ចេកវិទ្យាថ្មីៗ ...រវាងរដ្ឋាភិបាលជាមួយនឹងកសិករ។

**ឃ. ផលិតភាព និងផលប្រយោជន៍**

កសិកម្មប្រពៃណី ត្រូវបានកត់សម្គាល់ដោយការប្រើប្រាស់វត្ថុធាតុដើមដែលមានស្រាប់ ជាមួយនឹងតម្លៃទាបជាងការប្រើប្រាស់កម្លាំងពលកម្ម ពោលគឺការប្រើប្រាស់កម្លាំងពលកម្មមានច្រើន។ ទិន្នផលទាប ផលិតភាពរបស់មនុស្សម្នាក់ៗទាប និងកត្តាដទៃទៀតរបស់កសិកម្មប្រពៃណីកាន់តែទាប។ បើធ្វើការពិចារណាឲ្យស៊ីជម្រៅចំពោះកសិកម្មប្រពៃណី យើងឃើញថា ការប្រើប្រាស់ធនធានតិច នោះផលិតភាពតិចដែរ ក៏ប៉ុន្តែផលប្រយោជន៍សេដ្ឋកិច្ចដែលបានមកខ្ពស់។ ហើយផលិតភាពចាំបាច់ត្រូវតែបង្កើនឡើងតាមៈ

- បច្ចេកវិទ្យាថ្មីអាចជួយលទ្ធភាពផលិតកម្មដល់កសិករ
- ការសិក្សាថ្មីៗអាចជួយកសិករឲ្យចេះថ្លឹងថ្លែងការប្រើប្រាស់ធនធាន ទៅនឹងការផ្លាស់ប្តូរលក្ខខណ្ឌ ក៏ដូចជាការទាញយកផលប្រយោជន៍ក្នុងកម្រិតខ្ពស់របស់ពួកគេដែរ។[12]

**ង. សន្តិសុខស្បៀងអាហារ**

ស្ថេរភាពវិស័យកសិកម្ម មានន័យថាជាការធានាសន្តិសុខស្បៀងអាហាររបស់ជាតិ។ តម្រូវការចម្បងរបស់ប្រទេសជាតិ គឺសន្តិសុខស្បៀងអាហារ។ សន្តិសុខស្បៀង បានការពារការកើតមានឡើងនូវកង្វះអាហារូបត្ថម្ភ។ កង្វះអាហារូបត្ថម្ភ គឺជាបញ្ហាមួយយ៉ាងសំខាន់ដែលប្រទេសកំពុងអភិវឌ្ឍន៍ រួមទាំងកម្ពុជាបានកំពុងព្យាយាមដោះស្រាយ។ គោលនយោបាយជំរុញនូវផលិតកម្មកសិកម្ម ដើម្បីធានាបានសន្តិសុខស្បៀង គឺជារបៀបវារៈសន្តិសុខជាតិមួយ ដែលមានន័យថា ការវិនិយោគលើសន្តិសុខស្បៀងអាហារ និងអាហារូបត្ថម្ភ តាមរយៈការអភិវឌ្ឍកសិកម្ម បានដើរតួជាម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ ដោយវាធ្វើឲ្យប្រសើរឡើងនូវសុខភាព ការអប់រំ ឱកាសសេដ្ឋកិច្ច និងផ្តល់អំណាចទៅដល់ប្រជាពលរដ្ឋក្នុងប្រទេស។[13]

---

[12] វណ្ណា ដារិទ្ធ, *ការបង្កើនផលិតភាពកសិកម្មស្រុកសំឡូត(២០០៦)*, ទំព័រ៧, ១២។

[13] ជា លេងស្រ៊ុន, ទិត ប៊ុនឈឿន, ឈុន គូរី, យិនវឌ្ឍនា និង រ៉ូ សោភ័ណរិទ្ធ, *ការយល់ដឹងពីកសិកម្ម(២០១៩)*, ទំព័រ ១០។

# ជំពូកទី ២
# ស្ថានភាពទូទៅនៃវិស័យកសិកម្ម

# ជំពូកទី២
# ស្ថានភាពទូទៅនៃវិស័យកសិកម្ម

## ២.១ ស្ថានភាពសេដ្ឋកិច្ចប្រទេសកម្ពុជា

ស្ថិតនៅតំបន់អាស៊ីអាគ្នេយ៍ ប្រទេសកម្ពុជាគឺជាប្រទេសកំពុងអភិវឌ្ឍន៍ដែលមានការរីកចម្រើនលឿនបំផុតមួយ ជាមួយនឹងកំណើន ផ.ស.ស ជាមធ្យមប្រមាណ ៧% នាមួយទសវត្សរ៍កន្លងមកនេះ ។ តាមរបាយការណ៍ធនាគារពិភពលោកបានលើកបង្ហាញថា ប្រទេសកម្ពុជាបានឆ្លងកាត់ដោយជោគជ័យពីប្រទេសដែលមានប្រាក់ចំណូលទាប ក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប ព្រមទាំងកំពុងប្រឹងប្រែងដើម្បីក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៦០។ ជាក់ស្តែង ក្នុងឆ្នាំ២០១៨កន្លងទៅនេះ កម្ពុជាអាចសម្រេចបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រា ៧.៥% ដែលជាកំណើនមួយខ្ពស់បំផុតក្នុងរយៈពេល ១០ឆ្នាំចុងក្រោយនេះ ទោះបីជាមានភាពតានតឹងនៃសង្គ្រាមពាណិជ្ជកម្ម បញ្ហាចលាចលនៅទីក្រុងហុងកុង និងអស្ថិរភាពទីផ្សារហិរញ្ញវត្ថុនៅសាកលលោកក៏ដោយ។ ក្នុងនោះដែរ វិស័យឧស្សាហកម្មបានដើរតួយ៉ាងសំខាន់ជាមួយនឹងកំណើន១១.០% វិស័យសេវាកម្មបានបន្តកំណើនរឹងមាំក្នុងអត្រាប្រមាណ៦.៧% និងជាចុងក្រោយគឺវិស័យកសិកម្មមានកំណើនក្នុងអត្រា១.០%។ ជាមួយនឹងកំណើនដ៏រឹងមាំនៅក្នុងឆ្នាំ ២០១៨នេះ បានធ្វើឲ្យសេដ្ឋកិច្ចក្នុងឆ្នាំ២០១៩ នៅតែមានសន្ទុះ។ ជាអាទិ៍ ក្នុងឆ្នាំ២០១៩ សកម្មភាពសេដ្ឋកិច្ចកម្ពុជានៅតែបន្តមានវឌ្ឍនភាពល្អប្រសើរ ជាមួយនឹងកំណើន ៧.១% ដែលគាំទ្រដោយការកើនឡើងខ្ពស់នៃអនុវិស័យសំណង់ អនុវិស័យអចលនទ្រព្យ និងអនុវិស័យដឹកជញ្ជូននិងគមនាគមន៍ស្របនឹងកំណើនល្អប្រសើរនៃអនុវិស័យកាត់ដេរ អនុវិស័យឧស្សាហកម្មមិនមែនកាត់ដេរ អនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន និងអនុវិស័យលក់ដុំ-រាយ ដែលខណៈវិស័យកសិកម្មមានកំណើនតិចតួច ប៉ុន្តែក៏បានរួមចំណែកយ៉ាងសំខាន់ក្នុងការទ្រទ្រង់សេដ្ឋកិច្ចជាតិជារួមផងដែរ។ ជាមួយនឹងកំណើនរឹងមាំក្នុងឆ្នាំ២០១៩នេះបានជំរុញ ផ.ស.ស ថ្លៃបច្ចុប្បន្នត្រូវបានប៉ាន់ស្មានថានឹងកើនឡើងដល់ ១០៦,២៩៨ប៊ីលានរៀល និងធ្វើឲ្យ ផ.ស.ស សម្រាប់មនុស្សម្នាក់អាចនឹងកើនឡើងដល់ ១,៦៧៤ដុល្លារអាមេរិក។[14] ចំពោះអត្រាអតិផរណាវិញមានកម្រិតត្រឹម ១.៩% ទាបជាងឆ្នាំមុន(២.៥%) និងឆ្នាំ២០១៧(២.៩%) ជាមួយនឹងអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកបន្តមានស្ថិរភាព ជាមធ្យមប្រមាណ ៤.០៥៥ ក្នុងមួយដុល្លារអាមេរិកធៀបនឹងឆ្នាំមុន (៤.០៥១) ដែលបានរួមចំណែករក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចយ៉ាងរឹងមាំ។[15]

---

[14] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, *សូចនាករម៉ាក្រូសេដ្ឋកិច្ច*, ភ្នំពេញ៖ https://mef.gov.kh/(ចូលទស្សនាថ្ងៃទី២៦ ឧសភា ២០២០)

[15] ធនាគារជាតិនៃកម្ពុជា, *របាយការណ៍ប្រចាំឆ្នាំ២០១៩*, ភ្នំពេញ, ទំព័រ ៣

បើតាមរបាយការណ៍ធនាគារជាតិនៃកម្ពុជាបានឲ្យដឹងថា លំហូរវិនិយោគផ្ទាល់ពីបរទេសនៅកម្ពុជា បានកើនឡើងដល់ទៅប្រមាណជា ៣,៦០០លានដុល្លារអាមេរិកនៅក្នុងឆ្នាំ២០១៩ ស្មើនឹងកំណើន ១២%ធៀបទៅនឹងឆ្នាំ២០១៨។ នៅក្នុងនោះ ការវិនិយោគផ្ទាល់ពីបរទេសនៅក្នុងវិស័យហិរញ្ញវត្ថុ មានប្រមាណ ១,២០០លានដុល្លារអាមេរិក ខណៈដែលវិស័យមិនមែនហិរញ្ញវត្ថុ មានការវិនិយោគប្រមាណ ២,៤០០លានដុល្លារអាមេរិក។ បើតាមរបាយការណ៍ដដែលបានឲ្យដឹងទៀតថា ប្រទេសចិននៅតែជាប្រភពទុនវិនិយោគផ្ទាល់ពីបរទេសធំជាងគេបង្អស់របស់កម្ពុជា ដែលមានចំណែករហូតដល់ទៅ៤៣% បន្ទាប់មកគឺកូរ៉េខាងត្បូង១១% វៀតណាមប្រមាណ ៧% ជប៉ុនមាន៦% សឹង្ហបុរីមាន៦% និងប្រទេសផ្សេងៗទៀតមាន២៧%។

បន្ថែមពីលើនេះ ធនាគារអភិវឌ្ឍន៍អាស៊ី(ADB) ក៏បានធ្វើការព្យាករណ៍នៅពាក់កណ្ដាលឆ្នាំ ២០១៩ ពីកំណើនសេដ្ឋកិច្ចរបស់កម្ពុជានៅក្នុងឆ្នាំ២០២០ ថាអាចនឹងមានការធ្លាក់ចុះបន្តិចមកត្រឹម ៦.៨% ដោយសារតែមូលហេតុចម្បងពីរគឺ ការទទួលរងពីឥទ្ធិពលនៃសង្គ្រាមពាណិជ្ជកម្មចិន-អាមេរិក និងការបាត់បង់មួយផ្នែកនៃប្រព័ន្ធអនុគ្រោះពន្ធ (EBA ឬទំនិញគ្រប់មុខលើកលែងតែសព្វាវុធ)។[16]

## ២.២ ប្រព័ន្ធផលិតកម្មកសិកម្ម[17]

ក្នុងទិដ្ឋភាពភូមិសាស្ត្ររបស់ប្រទេសកម្ពុជា តំបន់កសិកម្មដែលមានសក្តានុពលសំខាន់ៗ រួមមានតំបន់អាងទំនាបកណ្តាល តំបន់ខ្ពង់រាប និងតំបន់ជួរភ្នំ ដែលលក្ខខណ្ឌនេះបានកំណត់ពីលក្ខណៈនៃប្រព័ន្ធដំណាំកសិកម្មខុសៗគ្នា ប៉ុន្តែប្រព័ន្ធផលិតកម្មកសិកម្មបែបប្រពៃណីមានចំនួនច្រើនជាងគេ។

ប្រព័ន្ធដាំដុះដំណាំកសិកម្មអាចត្រូវបានបែងចែកទៅតាមភាពខុសគ្នានៃរបបទឹកជំនន់ ការគ្រប់គ្រងប្រភពទឹក និងរបៀបនៃការដាំដុះ ទីតាំងភូមិសាស្ត្រ និងប្រភេទដី។ ការជ្រើសរើសប្រព័ន្ធដាំដុះ និងពូជសម្រាប់ដាំគឺត្រូវសម្របទៅតាមភាពខុសគ្នានៃស្ថានភាពអេកូឡូស៊ី ហើយកសិករតែងព្យាយាមគ្រប់គ្រងនូវហានិភ័យ ដើម្បីទប់ទល់ទៅនឹងបរិស្ថានធម្មជាតិដែលមិនទៀងទាត់។

### ២.២.១ ប្រព័ន្ធផលិតកម្មកសិកម្មតាមប្រពៃណី

កសិករប្រពៃណីនៅតែប្រើប្រាស់ឧបករណ៍ដែលប្រើប្រាស់ដោយដៃដូចជា ចប ប៉ែល និងកណ្តៀវ ឬប្រើប្រាស់កម្លាំងសត្វពាហនៈក្នុងការអូសទាញនង្គ័លភ្ជួររាស់ដីជាដើម។ ឧបករណ៍ទាំងនេះអាចត្រូវបានគេប្រើសម្រាប់ការប្រមូល ឬការបាចព្រោះវត្ថុធាតុនានាក្នុងស្រែ។ វត្ថុធាតុទាំងនេះ រួមមានជាអាទិ៍ គ្រាប់ពូជដំណាំ និងជីកំប៉ុស។ កសិករបានពឹងផ្អែកលើការផ្គត់ផ្គង់ទឹកពីធម្មជាតិ គឺកសិកម្មពឹងទឹកភ្លៀងនៅក្នុងអតីតកាល ប៉ុន្តែនៅ

[16] Asian Development Bank (ធនាគារអភិវឌ្ឍន៍អាស៊ី), *របាយការណ៍ការអភិវឌ្ឍនៅអាស៊ីក្នុងឆ្នាំ ២០១៩*, ទំព័រ ២៦៩។

[17] បណ្ឌិត ហង់ ជួន ណារ៉ុន, *សេដ្ឋកិច្ចកម្ពុជា(២០១៥)*, ទំព័រ ១៨២-១៨៤។

តំបន់ដីស្រែចម្ការជាច្រើននៃប្រទេសកម្ពុជា កសិករបានចាប់ផ្តើមបង្កើតប្រព័ន្ធធារាសាស្ត្រ។ កសិករជាច្រើនបាន នឹងកំពុងចាប់ផ្តើមប្រើប្រាស់គ្រឿងយន្តកសិកម្មនានាផងដែរ។ ប្រព័ន្ធដំណាំកសិកម្មបែបប្រពៃណី អាចចាត់ថ្នាក់តាមវិធីខុសៗគ្នាជាច្រើន។ ប្រសិនយករដូវកាលជាលក្ខណៈវិនិច្ឆ័យ នោះប្រព័ន្ធដំណាំស្រូវដាំដុះនៅកម្ពុជាមានបួនបែបខុសៗគ្នា ក្នុងនោះបីប្រភេទនៅក្នុងរដូវវស្សា និងមួយប្រភេទក្នុងរដូវប្រាំង។ ប្រភេទទាំងបួននេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងលក្ខខណ្ឌអាកាសធាតុះ

- **ស្រូវវស្សាទំនាបះ** គ្រប់ដណ្តប់លើសពាក់កណ្តាល នៃតំបន់ដាំដុះស្រូវនៅតំបន់ទំនាប។
- **ស្រូវវស្សាខ្ពង់រាប ឬស្រូវចម្ការះ** ជាប្រភេទស្រូវដែលមានវដ្តលូតលាស់ខ្លីបំផុត សម្របខ្លួនយ៉ាងល្អទៅនឹងការប្រែប្រួលនៃលក្ខខណ្ឌជុំវិញ ជាពិសេសកសិកម្មពនេចរ និងមានទំហំផ្ទៃដីជិត២% នៃផ្ទៃដីដាំដុះស្រូវ។ ជាទូទៅ ស្រូវប្រភេទនេះត្រូវបានដាំដុះជាមួយនឹងដំណាំសម្រាប់លក់យកប្រាក់ផ្សេងទៀត។
- **ស្រូវលិចទឹកះ** ត្រូវបានដាំនៅក្នុងតំបន់ដែលមានរយៈកម្ពស់ទាប ជាទីដែលទឹកអាចឡើងដល់ជម្រៅពី ២-៣ម៉ែត្រ និងគ្រប់ដណ្តប់ ៣២%នៃផ្ទៃដីដាំស្រូវ។
- **ស្រូវប្រាំងះ** ស្រូវប្រាំងរួមមានស្រូវប្រាំងដែលស្រោចស្រពដោយធារាសាស្ត្រ និងស្រូវប្រាំងប្រដេញទឹក។ ការស្រោចស្រពស្រូវប្រាំង ធ្វើឡើងតាមរយៈទឹកដែលរក្សាទុកក្នុងអាងស្តុកទឹក ឬទឹកទន្លេដែលនៅសេសសល់។ ស្រូវប្រាំងក៏អាចជាស្រូវប្រដេញទឹកដែលត្រូវបានដាំដុះក្នុងតំបន់លិចទឹក ឬក៏ធ្វើនៅតាមបណ្តោយមាត់បឹងទន្លេសាប ជាទីដែលកម្រិតទឹកបានស្រកចុះបន្តិចម្តងៗ។

ស្រូវវស្សានៅតំបន់ទំនាប គឺជាដំណាំដែលសំខាន់ជាងគេ ដែលត្រូវដាំដុះនៅក្នុងរដូវវស្សាពីខែឧសភាដល់ខែធ្នូ។ ស្រូវវស្សាមានបីប្រភេទ ទៅតាមរយៈពេលនៃការលូតលាស់ និងប្រមូលផលគឺស្រូវស្រាល ស្រូវកណ្តាល និងស្រូវធ្ងន់។ ស្រូវប្រាំងត្រូវបានដាំដុះពីខែធ្នូដល់ខែឧសភា មានផ្ទៃដីប្រហែល១០%នៃផ្ទៃដីសរុប និងប្រមូលផលបានប្រមាណ ១៨%នៃកសិកម្ម។

## ២.៣ ការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិ

### ២.៣.១ អត្រាផលិតផលកសិកម្មដែលបានចូលរួមក្នុង ផ.ផ.ស ចាប់ពីឆ្នាំ២០១៥-២០១៩

វិស័យកសិកម្មគឺជាឆ្អឹងខ្នងសេដ្ឋកិច្ចកម្ពុជា។ វាមានសារៈសំខាន់សម្រាប់ការកាត់បន្ថយភាពក្រីក្រ និងការធ្វើឲ្យប្រសើរឡើងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ កំណើនប្រជាជននាំឲ្យមានកំណើនការប្រើប្រាស់ ដូច្នេះត្រូវតែកែលម្អផលិតភាពក្នុងវិស័យកសិកម្ម ដើម្បីឆ្លើយតបទៅនឹងតម្រូវការនេះ។ ប្រជាជនកម្ពុជាប្រមាណ ៧៥% រស់នៅតំបន់ជនបទ ពួកគេមួយភាគធំមានសកម្មភាពពាក់ព័ន្ធនឹងកសិកម្ម។ យោងតាមជំរឿនកសិកម្មកម្ពុជាឆ្នាំ ២០១៣ បង្ហាញថា ៨៥%នៃចំនួនគ្រួសារសរុប បានពាក់ព័ន្ធក្នុងសកម្មភាពដាំដុះ(CAV, 2013)។ ក្នុងចំណោម

គ្រួសារទាំងនោះមាន ១៩% ពឹងផ្អែកទាំងស្រុងលើប្រាក់ចំណូលពីផលដំណាំ។[18] ប៉ុន្តែក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ គឺក្នុងចន្លោះឆ្នាំ២០១៥-២០១៩ យើងសង្កេតឃើញថា ការចូលរួមចំណែករបស់វិស័យកសិកម្មនៅក្នុងផ.ស.ស នៅក្នុងប្រទេសកម្ពុជាមានការប្រែប្រួលពី២៦.៦% ដល់២០.៨% ដោយមានអត្រាធ្លាក់ចុះជាមធ្យមប្រមាណ ១.១៦%ក្នុងមួយឆ្នាំ ដោយសារតែវិស័យឧស្សាហកម្ម សំណង់ និងសេវាកម្មផ្សេងទៀតកំពុងតែមាននិន្នាការកើនឡើងគួរឲ្យកត់សម្គាល់។[19] ពិសេសជាងនេះទៀត គឺដោយសារការជួបប្រទះធ្ងន់ធ្ងរពីកត្តាធម្មជាតិដែលមានដូចជា គ្រោះរាំងស្ងួត គ្រោះទឹកជំនន់ ការបំផ្លាញផលដំណាំដោយសារសត្វចង្រៃ និងការថយចុះនៃប្រជាជនអាស្រ័យផលកសិកម្មផងដែរ។

ក្រាហ្វិកទី ១៖ បង្ហាញពីអត្រាផលិតផលកសិកម្មដែលចូលរួមក្នុង ផ.ស.ស ឆ្នាំ ២០១៥-២០១៩




ប្រភព៖ ក្រសួងផែនការឆ្នាំ២០១៩ (ការវាយតម្លៃជំហានដំបូង)

### ២.៣.២ សមាសធាតុនៃអនុវិស័យក្នុងវិស័យកសិកម្ម

ជាក់ស្តែងឆ្នាំ២០១៩នេះ ការចូលរួមចំណែកនៃអនុវិស័យក្នុងផលិតផលក្នុងស្រុកសរុបរបស់វិស័យកសិកម្មរួមមាន ផ្នែកដំណាំ ៥៧.៦៧% ផ្នែកផលិតកម្មសត្វ ១១.១១% ផ្នែកជលផល ២៣.៣០% និងផ្នែកព្រៃឈើ ៦.៩១%។ ជាការកត់សម្គាល់ ផ្នែកដំណាំ និងជលផល គឺជាកម្លាំងចលករនាំមុខក្នុងវិស័យកសិកម្ម (ការចូលរួម

[18] ជា លេងស្រ៊ុន, ឈុន តូរី, រ៉ូ សោភ័ណរិទ្ធ, ទិត ប៊ុនឈឿន, យិន វឌ្ឍនា, *ការយល់ដឹងពីកសិកម្ម (២០១៩)*, ទំព័រ ១១។

[19] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១៩-២០២០ និងទិសដៅអនុវត្តឆ្នាំ២០២០-២០២១*, ទំព័រ ១៧។

ចំណែកច្រើនជាងគេក្នុងវិស័យទាំងមូល)។ ផលិតកម្មសត្វ គឺជាមុខព្រួញសំខាន់មួយទៀត ក្នុងការផ្គត់ផ្គង់តម្រូវការក្នុងស្រុក និងការនាំចេញ ដែលផ្នែកនេះត្រូវជំរុញអភិវឌ្ឍន៍ឲ្យបានខ្លាំងក្លាផងដែរ។

ក្រាហ្វិកទី ២៖ បង្ហាញពីការចូលរួមនៃអនុវិស័យកសិកម្មឆ្នាំ២០១៥-២០១៩ (%)

**ការចូលរួមនៃអនុវិស័យកសិកម្មឆ្នាំ២០១៥-២០១៩**




| | 2015 | 2016 | 2017 | 2018 | 2019 |
|---|---|---|---|---|---|
| ដំណាំ | 59.50% | 58.97% | 58.55% | 58.12% | 57.67% |
| បសុសត្វ | 11.30% | 11.30% | 11.21% | 11.12% | 11.11% |
| ជលផល | 22.29% | 22.93% | 23.48% | 24.04% | 24.30% |
| ព្រៃឈើ | 6.90% | 6.80% | 6.76% | 6.72% | 6.91% |

ប្រភព៖ ក្រសួងផែនការឆ្នាំ២០១៩ (ការវាយតម្លៃជំហានដំបូង)

## ២.៤ ការវិវឌ្ឍនៃផលិតភាពកសិកម្មតាមបណ្ដាអនុវិស័យ

### ២.៤.១ ការវិវឌ្ឍនៃផលិតភាពដំណាំស្រូវ ២០១៥-២០១៩[20]

ដំណាំស្រូវមានតួនាទីយ៉ាងសំខាន់ក្នុងការទ្រទ្រង់ដល់ការរស់រានមានជីវិត សម្រាប់ប្រជាពលរដ្ឋប្រមាណជិតពាក់កណ្ដាលនៅក្នុងពិភពលោក ស្ទើរទាំងស្រុងនៅទ្វីបអាស៊ី ព្រមទាំងជាអាហារចម្បង និងចាំបាច់បំផុតសម្រាប់ប្រទេសកម្ពុជា។ សម្រាប់ប្រជាពលរដ្ឋកម្ពុជា ស្រូវអង្ករ ឬបាយ គឺជាប្រភពផ្ដល់ថាមពលរហូតដល់ប្រមាណពី ៦០-៧០%នៃបរិមាណកាឡូរីចាំបាច់។[21]

ដោយឡែកបើយើងនិយាយពីដំណាំស្រូវរបស់កម្ពុជាក្នុងឆ្នាំ២០១៩នេះ ផ្ទៃដីដាំដុះស្រូវសរុបទូទាំងប្រទេសសម្រេចបានចំនួន ៣.៣២៨លានហិកតា ក្នុងនោះស្រូវរដូវវស្សាមានចំនួន ២.៧៣១លានហិកតា និងស្រូវរដូវប្រាំងមានចំនួន ០.៥៩៧លានហិកតា ដែលផ្ទៃដីដាំដុះស្រូវសរុបនេះ ថយចុះប្រមាណ០.២១% ធៀបនឹងឆ្នាំ

[20] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១៩-២០២០ និងទិសដៅអនុវត្តឆ្នាំ២០២០-២០២១*, ទំព័រ ១៨-១៩។

[21] ម៉ែន សារុម, ឆយ លីណា, និង ជេដ្ឋ គីមង៉ុយ, *ដំណាំស្រូវនៅកម្ពុជា (២០១៩)*, ទំព័រ ១។

២០១៨ និងកើនឡើងប្រមាណ ២៧៧,០០០ហិកតា ស្មើនឹង៩.០៩% ធៀបនឹងឆ្នាំ២០១៥ ដែលមានប្រមាណ ៣.០៥១លានហិកតា។ ផ្ទៃដីប្រមូលផលសរុបនៅក្នុងឆ្នាំ២០១៩ មានចំនួន ៣.២៦៣លានហិកតា ក្នុងនោះដែរ ស្រូវវស្សាមានចំនួន ២.៦៧១លានហិកតា ស្រូវប្រាំងមានចំនួន ០.៥៩២លានហិកតា ដែលផ្ទៃដីប្រមូលផលសរុបនេះ កើនឡើងប្រមាណ០.៤៦% ធៀបនឹងឆ្នាំ២០១៨ និងកើនឡើងប្រមាណ២៣៧,០០០ហិកតា ស្មើនឹង ៧.៨៣% ធៀបនឹងឆ្នាំ២០១៥។ ចំពោះបរិមាណផលស្រូវសរុបឆ្នាំ២០១៩ ទទួលបានចំនួន ១០.៨៨៥លានតោន ថយចុះប្រមាណ ០.០៦% ធៀបនឹងឆ្នាំ២០១៨ និងកើនឡើងប្រមាណ ១.៥៥០លានតោនស្មើនឹង ១៦.៦% បើធៀបនឹងឆ្នាំ២០១៥ ក្នុងនោះបរិមាណផលស្រូវរដូវវស្សា ទទួលបានប្រមាណ ៨.២៦៩ លានតោន និងបរិមាណផលស្រូវរដូវប្រាំង ទទួលបានប្រមាណ ២.៦១៦លានតោន ដោយមានអតិរេកស្រូវជាង ៥.៨៦ លានតោន គិតជាអង្ករស្មើនឹង ៣.៦៩លានតោនក្នុងឆ្នាំ ២០១៩។ សម្រាប់ទិន្នផលស្រូវជាមធ្យមប្រចាំឆ្នាំ២០១៩ ទទួលបាន ៣.៣៣៥ត/ហ.ត ក្នុងនោះទិន្នផលស្រូវរដូវវស្សាទទួលបាន ៣.០៩៥ ត/ហ.ត និងទិន្នផលស្រូវរដូវប្រាំងទទួលបាន ៤.៤១៨ ត/ហ.ត ក្នុងឆ្នាំ២០១៩។

តារាងទី ១៖ ផ្ទៃដីដាំដុះ ផ្ទៃដីប្រមូលផល និងទិន្នផលសរុបរបស់ដំណាំស្រូវ ២០១៥-២០១៩

| ឆ្នាំ | ផ្ទៃដីដាំដុះ(លានហិកតា) | ផ្ទៃដីប្រមូលផល(លានហិកតា) | ទិន្នផលសរុប(លានតោន) |
|---|---|---|---|
| ២០១៥ | ៣.០៥១ | ៣.០២៦ | ៩.៣៣៥ |
| ២០១៦ | ៣.១១៨ | ៣.១ | ៩.៩៥២ |
| ២០១៧ | ៣.២០៧ | ៣.១៨៩ | ១០.៥១៨ |
| ២០១៨ | ៣.៣៣៦ | ៣.២៤៨ | ១០.៨៩២ |
| ២០១៩ | ៣.៣២៨ | ៣.២៦៣ | ១០.៨៨៥ |

តាមរយៈលទ្ធផលសម្រេចបានខាងលើនេះបង្ហាញថា ស្ថានភាពផលិតកម្មដំណាំស្រូវនៅឆ្នាំ២០១៩ នេះនៅតែល្អប្រសើរ ធានាបានសន្តិសុខស្បៀង និងអតិរេកស្រូវសម្រាប់ការកែច្នៃនាំចេញ បើទោះបីជាបានទទួលរងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុដូចជា គ្រោះរាំងស្ងួតពីដើមរដូវ និងចុងរដូវវស្សា កង្វះខាតទឹកនៅរដូវប្រាំង និងគ្រោះទឹកជំនន់ ដែលធ្វើឲ្យផ្ទៃដីដាំដុះ ទិន្នផលជាមធ្យមប្រចាំឆ្នាំ និងបរិមាណផលស្រូវសរុប មានការថយចុះធៀបនឹងឆ្នាំ២០១៨ ប៉ុន្តែវាក៏មានការកើនឡើងយ៉ាងល្អប្រសើរផងដែរ បើធៀបនឹងឆ្នាំ២០១៥។

ក្រាហ្វិកទី ៣៖ បង្ហាញពីកំណើនបរិមាណផល និងទិន្នផលនៃផលិតកម្មដំណាំស្រូវឆ្នាំ២០១៥-២០១៩




ប្រភព៖ របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ ២០១៩-២០២០

## ២.៥ តួនាទីរបស់ស្ថាប័ននានានៅក្នុងវិស័យកសិកម្ម[22]

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានតួនាទីទទួលខុសត្រូវសម្រាប់ការអភិវឌ្ឍលើវិស័យកសិកម្ម មានន័យថា ជាការទទួលខុសត្រូវអនុវត្តតាមអង្គភាពជំនាញនៃអនុវិស័យនីមួយៗក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងត្រូវភ្ជាប់ទំនាក់ទំនងជាមួយនឹងអន្តរវិស័យផ្សេងៗទៀត ដូចជាធនធានទឹក ផ្លូវថ្នល់ ជនបទ សុខភាព អប់រំ ពាណិជ្ជកម្ម កសិ-ឧស្សាហកម្ម និងផ្នែកហិរញ្ញវត្ថុ ដើម្បីគាំទ្រមុខងារ និងការអនុវត្តផែនការយុទ្ធសាស្ត្រប្រកបដោយជោគជ័យ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ជាស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្តកម្មវិធីធំៗ នៃផែនការយុទ្ធសាស្ត្រទាំងមូល តាមរយៈអង្គភាពជំនាញក្រោមឱវាទក្រសួង។ អង្គភាពក្រោមឱវាទរបស់ក្រសួងត្រូវរៀបចំសកម្មភាពលម្អិត និងផែនការថវិកាតាមឆ្នាំនីមួយៗ ព្រមទាំងចូលរួមកៀងគរថវិកាពីដៃគូរអភិវឌ្ឍន៍ និងវិស័យឯកជន ដើម្បីធ្វើយ៉ាងណាឲ្យការអនុវត្តការងារបានរលូន និងសម្រេចតាមផែនការដែលគ្រោងទុក។

តួនាទីរបស់គណៈកម្មាធិការកែទម្រង់ហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង ដែលមាននាយកដ្ឋានផែនការ និងស្ថិតិ និងនាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ជាសេនាធិការត្រូវសម្របសម្រួលការងារអនុវត្ត ជាពិសេសដោះស្រាយបញ្ហា ភាពមិនស៊ីសង្វាក់គ្នាក្នុងការអនុវត្តផែនការសកម្មភាពរបស់អង្គភាពពាក់ព័ន្ធ សម្របសម្រួល

[22] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣*, ទំព័រ ៦៦-៦៨។

ជាមួយដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ព្រមទាំងសម្របសម្រួលក្នុងការពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធី។ ការសម្របសម្រួលការអនុវត្តសកម្មភាពផែនការយុទ្ធសាស្ត្ររួមមាន៖

- ពិនិត្យ និងធ្វើការកែទម្រង់បែបបទការងារក្នុងការអនុវត្តវិស័យកសិកម្ម ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រនេះបានលឿនតាមផែនការកំណត់។
- សម្របសម្រួលក្នុងការបែងចែកធនធានទៅតាមអនុវិស័យ ដែលអនុវត្តការងារល្អប្រសើរ និងមានអាទិភាពខ្ពស់។
- រៀបចំម្ការសិក្សាវាយតម្លៃ និងកែសម្រួលការងារអនុវត្តផែនការយុទ្ធសាស្ត្រឲ្យបានល្អប្រសើរជាងមុន។
- តាមដាន និងវាយតម្លៃការងារអនុវត្តផែនការសកម្មភាព។

ស្ថាប័នសំខាន់ៗ និងការទទួលខុសត្រូវដែលទាក់ទងនឹងវិស័យកសិកម្មរួមមាន៖

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានតួនាទីគាំទ្រថវិកា សម្របសម្រួលកិច្ចការវិនិយោគ និងហិរញ្ញប្បទានផ្សេងៗ ដើម្បីឲ្យការងារអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មទទួលបានជោគជ័យតាមផែនការកំណត់។
- ក្រសួងផែនការមានតួនាទីតាមដាន និងវាយតម្លៃស្ថានភាពអំពីវឌ្ឍនភាព ព្រមទាំងពិនិត្យលើរបាយការណ៍ប្រចាំឆ្នាំអំពីលទ្ធផលនៃការអនុវត្ត។
- ក្រសួងអភិវឌ្ឍន៍ជនបទ គឺទទួលខុសត្រូវលើការអភិវឌ្ឍដំណាំ ការស្តារផ្លូវឡើងវិញ ការគ្រប់គ្រងធនធានទឹក ការស្រាវជ្រាវ និងការផ្សព្វផ្សាយ។
- ក្រសួងធនធានទឹក និងឧតុនិយមគឺគ្រប់គ្រងធនធានទឹក ដោយរួមបញ្ចូលទាំងប្រព័ន្ធស្រោចស្រព។
- ក្រសួងបរិស្ថានគឺត្រូវការពារ និងគ្រប់គ្រងតំបន់បរិស្ថានវាយតម្លៃ និងការបន្ធូរបន្ថយសក្តានុពលភាពនៃផលប៉ះពាល់ដល់បរិស្ថាន។
- ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ទទួលបន្ទុកគ្រប់គ្រងដីធ្លី ការវាស់វែងចេញប័ណ្ណកម្មសិទ្ធិ។
- ក្រសួងពាណិជ្ជកម្មមានតួនាទីជំរុញ និងគាំទ្រទីផ្សារ ជំនួយ និងការនាំចេញ។
- ក្រសួងកិច្ចការនារី និងអតីតយុទ្ធជនបានជួយជំរុញទៅដល់ផលិតកម្មស្បៀងជាលក្ខណៈគ្រួសារ។

### ២.៥.១ តួនាទីរបស់អង្គការក្រៅរដ្ឋាភិបាលក្នុងការអភិវឌ្ឍ

អង្គការក្រៅរដ្ឋាភិបាល គឺជាអង្គការមិនស្វែងរកប្រាក់ចំណេញហើយបង្កើតឡើងដើម្បីបម្រើផលប្រយោជន៍សាធារណៈ។ អង្គការក្រៅរដ្ឋាភិបាលបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍវិស័យកសិកម្ម និងមានបទ

ពិសោធន៍លើការងារផ្សព្វផ្សាយកសិកម្ម និងសន្តិសុខស្បៀង ព្រមទាំងបានចូលរួមចំណែកក្នុងវឌ្ឍនភាពនៃការរីកលូតលាស់សេដ្ឋកិច្ចនៅជនបទ។ ទោះបីជាការងាររបស់អង្គការក្រៅរដ្ឋាភិបាលមានសារៈសំខាន់ក៏ដោយក៏អង្គការទាំងនេះនឹងអាចបន្តសកម្មភាពរបស់ខ្លួនលុះត្រាតែអង្គការទាំងនេះចាត់ចែងបានល្អ ហើយផ្តល់សេវាកម្មចាំបាច់ដែលបម្រើផលប្រយោជន៍សាធារណៈ។ អង្គការក្រៅរដ្ឋាភិបាលក៏ជាស្ថាប័នអភិវឌ្ឍន៍មួយអាចចូលរួមវិភាគទានយ៉ាងច្រើន ចំពោះផែនការកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។ កិច្ចការប្រចាំថ្ងៃរបស់អង្គការក្រៅរដ្ឋាភិបាលគឺធ្វើការយ៉ាងជិតស្និទ្ធជាមួយអ្នកក្រីក្រ និងក្រុមជនងាយរងគ្រោះ។ អង្គការក្រៅរដ្ឋាភិបាលក៏មានទំនាក់ទំនងជិតស្និទ្ធជាមួយក្រសួងក្នុងផ្នែកជាច្រើន ដើម្បីដោះស្រាយនូវរាល់បញ្ហាដែលជួបប្រទះរហូតឈានដល់ការអភិវឌ្ឍ។

### ២.៥.២ តួនាទីដៃគូអភិវឌ្ឍន៍ក្នុងការអភិវឌ្ឍវិស័យកសិកម្ម

ដៃគូអភិវឌ្ឍន៍ទាំងទ្វេភាគី និងពហុភាគី បានជួយគាំទ្រផ្នែកបច្ចេកទេស និងធនធានហិរញ្ញវត្ថុដល់វិស័យកសិកម្មកម្ពុជា។ បច្ចុប្បន្នដោយសារកម្ពុជាមានកំណើនសេដ្ឋកិច្ចល្អប្រសើរ និងមានសមត្ថភាពហិរញ្ញវត្ថុដោយខ្លួនឯង តួនាទីហិរញ្ញវត្ថុរបស់ដៃគូអភិវឌ្ឍន៍មានការថយចុះ ហើយផ្នែកមួយចំនួនធំរបស់ផែនការសកម្មភាពត្រូវបានរាជរដ្ឋាភិបាលប្រើប្រាស់ថវិកាជាតិដើម្បីគាំទ្រដល់ការអនុវត្តផែនការសកម្មភាព។ ទោះបីជាយ៉ាងណាក៏ដោយ ដៃគូអភិវឌ្ឍន៍ ទាំងទ្វេភាគី និងពហុភាគីនៅតែមានតួនាទីយ៉ាងសំខាន់ ជាពិសេសលើគម្រោងសកម្មភាព និងគំនិតផ្តួចផ្តើមថ្មីៗដែលគាំទ្រដល់វឌ្ឍនភាពនៃវិស័យកសិកម្ម ព្រមទាំងក្នុងការដឹកនាំធ្វើគម្រោងសាកល្បងផ្សេងៗពាក់ព័ន្ធក្នុងការធ្វើទំនើបកម្មកសិកម្ម។ ជាមួយគ្នានេះ ដៃគូអភិវឌ្ឍន៍ត្រូវជួយគាំទ្រសកម្មភាពរបស់កម្មវិធីដោយផ្តល់សេវាកម្ម និងការគាំទ្រដល់ការអភិវឌ្ឍកសិកម្មនៅជនបទឲ្យបានកាន់តែទូលាយថែមទៀត។ បច្ចុប្បន្នដៃគូអភិវឌ្ឍន៍បានយល់ពីស្ថានភាព និងអត្ថប្រយោជន៍នៃការប្រឹក្សាជាមួយរាជរដ្ឋាភិបាល ពិសេសជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការគាំទ្រដល់កម្មវិធីនានាក្នុងផែនការយុទ្ធសាស្ត្រ ជាជាងធ្វើការអនុវត្តគម្រោងកម្មវិធីដោយជម្រើសជាឯកតោភាគី។ ក្នុងន័យនេះ ដៃគូអភិវឌ្ឍន៍ដែលផ្តល់ជំនួយហិរញ្ញវត្ថុ គួរដាក់បញ្ចូលនូវធនធានថវិកា និងប្រើប្រាស់ជាបណ្តើរៗនូវប្រព័ន្ធថវិការាជរដ្ឋាភិបាល។

### ២.៥.៣ តួនាទីវិស័យឯកជនក្នុងការអភិវឌ្ឍវិស័យកសិកម្ម

វិស័យឯកជនជាកម្លាំងចលករចម្បងក្នុងការអភិវឌ្ឍវិស័យកសិកម្ម និងកសិ-ធុរកិច្ច។ ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ នឹងសម្របសម្រួលការអនុវត្តគម្រោងវិនិយោគឯកជនក្នុងវិស័យកសិកម្មឲ្យមានប្រសិទ្ធ-ភាពខ្ពស់។ វិស័យទាំងនេះរួមមាន ផ្នែកផលិតកម្មដំណាំ ចិញ្ចឹមសត្វ វារីវប្បកម្ម ផ្នែកកែច្នៃ និងវេចខ្ចប់ផលិតផល ភ្នាក់ងារប្រមូលទិញ គ្រប់គ្រងទីផ្សារ និងលក់ធាតុផ្សំ(Inputs)កសិកម្មជាដើម។ល។ តួនាទីចាំបាច់របស់វិស័យ

ឯកជនគឺផ្តោតជាសំខាន់លើការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តគាំទ្រដល់ផលិតលកម្ម ការកែច្នៃ ការរៀបចំបង្កើតទីផ្សារបោះដុំ និងចែកចាយបន្លែផ្លែឈើដែលមានស្តង់ដារ និងអនាម័យខ្ពស់ ព្រមទាំងការគាំទ្រលើសេវាកម្មហិរញ្ញវត្ថុ និងសេវាកម្មពាក់ព័ន្ធដទៃទៀត។

## ២.៦ គោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម[23]

### ២.៦.១ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣

ចក្ខុវិស័យសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្មគឺ ទំនើបកម្មកសិកម្មកម្ពុជា ដែលមានលក្ខណៈប្រកួតប្រជែងធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តភាព ដែលនាំដល់ការកើនឡើងប្រាក់ចំណូលគ្រួសារកសិករ វិបុលភាព និងសុខុមាលភាពរបស់ប្រជាជនកម្ពុជា។ ដើម្បីចូលរួមចំណែកក្នុងការសម្រេចបាននូវចក្ខុវិស័យនេះ ក្រសួងបានកំណត់នូវគោលបំណងយុទ្ធសាស្ត្ររួមសម្រាប់អនុវត្តគឺ "ជំរុញកំណើនកសិកម្មប្រកបដោយការប្រកួតប្រជែង ផលិតផលមានគុណភាព សុវត្ថិភាព និងអាហារូបត្ថម្ភ ព្រមទាំងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានព្រៃឈើ និងជលផលប្រកបដោយនិរន្តភាព"។

វិស័យកសិកម្មនៅតែដើរតួនាទីយ៉ាងសំខាន់ ក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ការអភិវឌ្ឍជនបទ ជាពិសេសបានចូលរួមកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ កំណើនកសិកម្មត្រូវរីកលូតលាស់ និងត្រូវបានវាស់វែងដោយអត្រាកំណើននៃតម្លៃបន្ថែមសរុបរបស់វិស័យកសិកម្ម។

ក្នុងរយៈពេល៥ឆ្នាំកន្លងទៅ តម្លៃបន្ថែមសរុបរបស់វិស័យកសិកម្ម (Gross Value Added-GVA) សម្រេចបានក្នុងរង្វង់ពី ៣-៥%ក្នុងមួយឆ្នាំ។ ក្នុងរយៈ៥ឆ្នាំខាងមុខ ការព្យាករណ៍នៃកំណើននេះ នឹងត្រូវសម្រេចឲ្យបានក្នុងរង្វង់ ៤%ក្នុងមួយឆ្នាំ។ ដើម្បីសម្រេចបាន ក្រសួងបានកំណត់យកនូវគោលដៅយុទ្ធសាស្ត្រជាអាទិភាពមួយគឺការបង្កើនផលិតភាពដំណាំស្រូវ ពិពិធកម្មកសិកម្ម ការប្រកួតប្រជែង និងពាណិជ្ជូបនីយកម្មកសិកម្ម។ ហើយដើម្បីសម្រេចបាននូវគោលបំណង និងគោលដៅយុទ្ធសាស្ត្រខាងលើ យុទ្ធសាស្ត្រដែលត្រូវបានដាក់ចេញឲ្យអនុវត្តក្នុងរយៈពេល ៥ឆ្នាំខាងមុខគឺ៖

(១) បង្កើនផលិតភាពដំណាំស្រូវ ពិពិធកម្មដំណាំកសិកម្ម និងពង្រីកកសិកម្ម-ធុរកិច្ច

(២) បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងស្ថាប័ន សេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស

យុទ្ធសាស្ត្រខាងលើនេះនឹងត្រូវអនុវត្តឲ្យមានប្រសិទ្ធភាព ដោយមានកម្មវិធីទាំង២ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលជាតួអង្គសំខាន់សម្រាប់ប្រតិបត្តិ និងគ្រប់គ្រងដោយអង្គភាពថវិការបស់ក្រសួង។

កម្មវិធីទាំង ២នោះរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមមាន៖

---

[23] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣*, ទំព័រ ៣៨-៤៣។

**កម្មវិធីទី ១៖ បង្កើនផលិតភាព និងពិពិធកម្មដំណាំកសិកម្ម**

គោលបំណងកម្មវិធី គឺជំរុញកំណើនផលិតកម្មគ្រប់មុខដំណាំ ជាពិសេសគឺផលិតកម្មដំណាំស្រូវឲ្យបានក្នុងរង្វង់៥% និងបង្កើនការនាំចេញផលិតផលដំណាំកសិកម្ម ៧%ក្នុងមួយឆ្នាំ ដោយពង្រីកទំនើបកម្មកសិកម្ម បង្កើនផលិតភាព ពិពិធកម្មដំណាំដែលមានសក្តានុពល និងការប្រកួតប្រជែងទីផ្សារខ្ពស់។

**កម្មវិធីទី ២៖ បង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស**

ការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងស្ថាប័ន ការផ្តល់សេវាគាំទ្រ និងការពង្រឹងសមត្ថភាពផ្នែកអប់រំ និងបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយនិរន្តភាព។

## ២.៦.២ យុទ្ធសាស្ត្រចម្បងៗសម្រាប់បង្កើនផលិតភាពកសិកម្ម

**ទី១៖** បន្តលើកកម្ពស់ការស្រាវជ្រាវអភិវឌ្ឍន៍បច្ចេកវិទ្យា និងបច្ចេកទេសកសិកម្មទំនើប ក្នុងទិសដៅបង្កើនបរិមាណ គុណភាព អាហារូបត្ថម្ភ និងពិពិធកម្មផលិតផលកសិកម្មប្រកបដោយនិរន្តភាព និងការប្រែប្រួលអាកាសធាតុ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវទីផ្សារក្នុងស្រុក និងក្រៅប្រទេស។ យកចិត្តទុកដាក់អភិវឌ្ឍន៍ធនធានមនុស្ស និងជាពិសេសបង្កើនចំនួនអ្នកស្រាវជ្រាវ និងអ្នកវិទ្យាសាស្ត្រកសិកម្មឲ្យបានច្រើន ដោយផ្តល់ការលើកទឹកចិត្តដល់អ្នកស្រាវជ្រាវ និងអ្នកវិទ្យាសាស្ត្រជាចាំបាច់។ ត្រូវធ្វើកសិកម្មចម្រុះប្រកបដោយភាពវៃឆ្លាត មិនត្រូវធ្វើតែដំណាំស្រូវមួយមុខ ឬការធ្វើតាមគ្នា ដោយមិនបានវិភាគឲ្យបានស៊ីជម្រៅនោះឡើយ។ ទន្ទឹមនឹងនេះ ត្រូវយកចិត្តទុកដាក់ជំរុញការប្រើប្រាស់បច្ចេកទេសកសិកម្មថ្មីៗ ប្រកបដោយនវានុវត្តន៍ រួមមានជាអាទិ៍ ការអនុវត្តកសិកម្មល្អ ការកែលម្អការគ្រប់គ្រង និងប្រើប្រាស់ធនធានដីប្រកបដោយចីរភាព ការកែលម្អប្រព័ន្ធស្រោចស្រព និងការគ្រប់គ្រងទឹក ការប្រើប្រាស់យន្តូបនីយកម្មកសិកម្ម និងបច្ចេកវិទ្យាក្រោយប្រមូលផល ការបង្កើនភាពធន់នឹងអាកាសធាតុ និងគ្រោះធម្មជាតិ ការលើកកម្ពស់គុណភាពនៃការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម ឲ្យបានទៅដល់សហគមន៍កសិកម្ម ព្រមទាំងការពង្រីកការគ្រប់គ្រង និងត្រួតពិនិត្យពូជដំណាំកសិកម្ម ធាតុផ្សំរបស់កសិកម្ម មជ្ឈមណ្ឌលស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្មឲ្យបានល្អប្រសើរ។

**ទី២៖** ពង្រឹងសមត្ថភាពសហគមន៍កសិកម្មដែលបានចុះបញ្ជីរួចហើយ ឲ្យមានលក្ខណៈជាពាណិជ្ជកម្ម ដោយជំរុញឲ្យអនុវត្តបច្ចេកវិទ្យាសមស្រប ការផ្គត់ផ្គង់ប្រព័ន្ធស្រោចស្រពដោយសន្សំសំចៃទឹកនៅតាមសហគមន៍កសិកម្ម និងអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា ព្រមទាំងលើកកម្ពស់ការចូលរួមវិនិយោគពីវិស័យឯកជនក្នុងគ្រប់ខ្សែចង្វាក់តម្លៃកសិកម្ម តាមអភិក្រមភាពជាដៃគូរវាងរដ្ឋ ឯកជន និងផលិតករ/សហគមន៍ ឲ្យមានលក្ខណៈប្រទាក់ក្រឡាគ្នាក្នុងការរកទីផ្សារបន្ថែមសម្រាប់ផលិតផលកសិកម្មជាអាទិភាព។ លើសពីនេះទៅទៀត ត្រូវ

ពិនិត្យមើលលទ្ធភាពធ្វើយ៉ាងណាឲ្យសហគមន៍អាចទទួលបានផលប្រយោជន៍ និងមានចំណូលសម្រាប់ដំណើរការអភិវឌ្ឍន៍របស់ខ្លួនប្រកបដោយភាពម្ចាស់ការ។

**ទី៣៖** ជំរុញការធ្វើពិពិធកម្មកសិកម្មទៅរកផលិតផលដែលមានតម្លៃបន្ថែមខ្ពស់ និងមានសក្តានុពលលើដំណាំ ដែលផ្តោតសំខាន់លើដំណាំស្រូវ ព្រមទាំងមានការវិនិយោគលើការកែច្នៃកសិផលសំខាន់ៗ ដោយត្រូវបន្តលើកកម្ពស់គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម ការកែច្នៃវេចខ្ចប់ និងពង្រឹងសមត្ថភាពពិសោធន៍ឲ្យត្រូវស្តង់ដារគុណភាពក៏ដូចជាពង្រឹងវិធានការការពារដំណាំ អនាម័យ តាមរយៈការចរចារជាមួយបណ្តាប្រទេសដែលទិញផលិតផលកសិកម្មពីកម្ពុជា ការរៀបចំពិធីស្តីពីការនាំចេញផលិតផលកសិកម្មកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ។

**ទី៤៖** ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជិតខាង និងបណ្តាប្រទេសដៃគូអភិវឌ្ឍន៍នានាទាំងក្នុងក្របខណ្ឌទ្វេភាគី ពហុភាគី និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ និងអន្តរជាតិ ដើម្បីស្វែងរកជំនួយហិរញ្ញវត្ថុ និងជំនួយបច្ចេកទេសថ្មីៗ សម្រាប់ការធ្វើទំនើបភាវូបនីយកម្មកសិកម្មព្រមទាំងខិតខំបង្កើនកិច្ចសហប្រតិបត្តិការ និងធ្វើការចរចារដើម្បីបើកច្រកទីផ្សារសម្រាប់ការនាំចេញផលិតផលកសិកម្ម ឲ្យបានទូលំទូលាយជាមួយប្រទេសនានាក្នុងបរិបទនៃសាកលភាវូបនីយកម្ម។ លើកទឹកចិត្តដល់អ្នកវិនិយោគទុនទាំងក្នុង និងក្រៅប្រទេសបង្កើនទុនវិនិយោគក្នុងវិស័យកសិកម្មលើគ្រប់ខ្សែសង្វាក់តម្លៃកសិកម្ម ជាពិសេសការកែច្នៃផលិតផលកសិកម្មដើម្បីផ្សារភ្ជាប់កសិករ ឬសហគមន៍កសិកម្ម ទៅនឹងទីផ្សារតាមអភិក្រមភាពជាដៃគូរវាងរដ្ឋហើយឯកជន ជាមួយនឹងអ្នកផលិត។ ទន្ទឹមនឹងនេះ ត្រូវជំរុញដល់ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការជាតិ អន្តរជាតិទាំងអស់ឲ្យបន្តគាំទ្រការលើកកម្ពស់ និងជំរុញការអភិវឌ្ឍវិស័យកសិកម្មតាមគ្រប់រូបភាព ដើម្បីធានាឲ្យបានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទាំងនៅក្នុងកម្រិតគ្រួសារ សហគមន៍ និងថ្នាក់ជាតិ។ ជាមួយគ្នានេះដែរ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនឹងអនុវិស័យនៃវិស័យកសិកម្មនឹងត្រូវជំរុញ និងដាក់ឲ្យអនុវត្តចេញប្រកបដោយប្រសិទ្ធភាពខ្ពស់។

# ជំពូកទី ៣
# ផលិតភាពកសិកម្ម

# ជំពូកទី៣

# ផលិតភាពកសិកម្ម

នៅក្នុងជំពូកទី៣នេះ ក្រុមយើងខ្ញុំមានគោលបំណងសំខាន់បំផុតគឺធ្វើការសិក្សាស្រាវជ្រាវពីកត្តាដែលបានជះឥទ្ធិពលទៅដល់ការបង្កើនផលិតភាពកសិកម្មនៅប្រទេសកម្ពុជា ដើម្បីសិក្សាវែកញែកឲ្យកាន់តែស៊ីជម្រៅក្នុងគោលបំណងដោះស្រាយនូវបញ្ហាទាំងឡាយណាដែលរារាំងដល់ការបង្កើនទិន្នផលកសិកម្ម។ មួយវិញទៀតក្រុមយើងខ្ញុំក៏បានសិក្សាទៅលើទិដ្ឋភាពជារួមមួយចំនួន នៃការប្រែប្រួលរបស់វិស័យកសិកម្មក្នុងប្រទេសកម្ពុជាដែលពាក់ព័ន្ធនឹងដំណាំស្រូវ។ ទាំងនេះគឺជាគោលបំណងសំខាន់នៃជំពូកទី៣ និងជាការឆ្លើយតបផងដែរនៃការស្រាវជ្រាវទៅលើប្រធានបទ។

## ៣.១ ការប្រែប្រួលនៃវិស័យកសិកម្មក្នុងប្រទេសកម្ពុជា

### ៣.១.១ កម្លាំងពលកម្មក្នុងវិស័យកសិកម្ម

ប្រទេសកម្ពុជានៅតែបន្តមានមនុស្សច្រើនចូលរួមក្នុងសកម្មភាពកសិកម្ម ប៉ុន្តែក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះឃើញថា វិស័យកសិកម្មបានបន្ថយឥទ្ធិពលរបស់ខ្លួនក្នុងការស្រូបយកកម្លាំងពលកម្មមកធ្វើការជាមួយវិស័យមួយនេះ។ ស្ថិតក្នុងក្របខ័ណ្ឌនៃសេដ្ឋកិច្ចប្រទេសកម្ពុជា កម្លាំងពលកម្មសកម្មត្រូវបានបែងចែកជាបីប្រភេទសំខាន់ៗគឺ ពលកម្មក្នុងវិស័យកសិកម្ម ពលកម្មក្នុងវិស័យឧស្សាហកម្ម ហើយនិងពលកម្មនៅក្នុងវិស័យសេវាកម្ម។ តាមការអង្កេតកន្លងមកឃើញថា ពលកម្មនៅក្នុងផ្នែកកសិកម្មបាននឹងកំពុងតែបន្តការធ្លាក់ចុះគួរឲ្យកត់សម្គាល់។ មូលហេតុចម្បងមួយនៃនិន្នាការធ្លាក់ចុះនេះគឺបណ្តាលពីការកើនឡើងនៃវិស័យឧស្សាហកម្ម និងសេវាកម្មបានស្រូបទាញនូវកម្លាំងពលកម្មពីវិស័យកសិកម្មជារៀងរាល់ឆ្នាំ។ បើយោងទៅតាមរបាយការណ៍អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជារបស់ក្រសួងផែនការ បានបង្ហាញឲ្យឃើញច្បាស់ថា កម្លាំងពលកម្មក្នុងវិស័យកសិកម្មឆ្នាំ ២០១៥ មានចំនួន ៤១.៥%នៃចំនួនពលកម្មសកម្មសរុប ហើយធ្លាក់ចុះមកត្រឹមតែ ៣៦.៤%ក្នុងឆ្នាំ២០១៦ និងមានការកើនឡើងវិញបន្តិចមក ៣៧%នៅឆ្នាំ២០១៧។

ខាងក្រោមនេះ បង្ហាញពីក្រាហ្វិកនៃចំនួនពលកម្មសរុប ដែលចូលរួមទៅក្នុងវិស័យកសិកម្មរបស់ប្រទេសកម្ពុជាពីឆ្នាំ ២០១៥ទៅដល់ឆ្នាំ ២០១៧។

ក្រាហ្វិកទី ៤៖ កម្លាំងពលកម្មក្នុងវិស័យកសិកម្មឆ្នាំ ២០១៥-២០១៧




ចំពោះកម្លាំងពលកម្មក្នុងវិស័យកសិកម្ម សូមទៅមើលបន្ថែមនៅឧបសម្ព័ន្ធទី ២

ចរន្តនៃការធ្វើចំណាកស្រុកពីជនបទមកកាន់ទីក្រុង និងទៅក្រៅប្រទេសកំពុងមាននិន្នាការកើនឡើង។ យន្តការនេះបានជះឥទ្ធិពលទៅដល់រចនាសម្ព័ន្ធឬការផ្គត់ផ្គង់ពលកម្មជនបទដែលធ្វើការនៅក្នុងវិស័យកសិកម្ម ជាហេតុធ្វើឲ្យពលកម្មកសិកម្មមានការថយចុះ។ ប៉ុន្តែចំណុចដែលប្រសើរនោះគឺ យន្តូបនីយកម្មកសិកម្ម បានចូលជំនួសនូវការបាត់បង់កម្លាំងពលកម្មនោះ។ ជាការកត់សម្គាល់បន្ថែមទៀត យន្តូបនីយកម្មកសិកម្មពិតជាបាននឹងកំពុងដើរតួនាទីសំខាន់ ព្រមទាំងបំពេញនូវកម្លាំងពលកម្មដែលកំពុងខ្វះខាតក្នុងវិស័យកសិកម្មនាពេលកន្លងមកនេះទៀតផង។

### ៣.១.២ ការប្រើប្រាស់គ្រឿងយន្តក្នុងវិស័យកសិកម្ម

ស្របពេលដែលកម្លាំងពលកម្មក្នុងវិស័យកសិកម្មកំពុងតែមានការថមថយចុះ ការប្រើប្រាស់គ្រឿងយន្តកសិកម្មក៏កំពុងតែកើនឡើងជារឿយៗដែរ។ ប្រជាកសិករនៅតាមជនបទ បានផ្លាស់ប្តូរនូវទម្លាប់តាមផលិតកម្មកសិកម្មតាមបែបបុរាណរបស់គាត់ ងាកមកប្រើនូវគ្រឿងចក្របន្ថែមទៀត ដោយបានមើលឃើញពីទិន្នផលកសិកម្មមានការកើនឡើងក៏ដូចជាចំណាយដើមទុនតិច និងពេលវេលាលឿនជាងមុន។ ជាក់ស្តែង ការប្រើប្រាស់គ្រឿងយន្តកសិកម្ម កំពុងមាននិន្នាការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ បើតាមរបាយការណ៍បូកសរុបការងារកសិកម្មឆ្នាំ២០១៩ បង្ហាញថាក្នុងឆ្នាំ២០១៨កន្លងទៅ ការភ្ជួររាស់បានផ្លាស់ប្តូរទៅប្រើគោយន្ត ៣៧៥,៧៥៥ គ្រឿង ម៉ាស៊ីនបូមទឹកមានចំនួន ៤០០,៧៨៣គ្រឿង ត្រាក់ទ័រមានចំនួន ២២,២២១គ្រឿង និងម៉ាស៊ីនច្រូតកាត់

មានចំនួន ៧,៤២១គ្រឿង។ ទិន្នន័យមួយនេះបង្ហាញថា គ្រឿងចក្រទាំងនេះមានការកើនឡើងនូវការប្រើប្រាស់ពីសំណាក់ប្រជាកសិករគិតពីឆ្នាំ២០១៥មក។

ក្រាហ្វិកទី ៥៖ បម្រែបម្រួលគ្រឿងយន្តកសិកម្មឆ្នាំ ២០១៥-២០១៨




ប្រភព៖ របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១៨-២០១៩

### ៣.១.៣ ការប្រើប្រាស់ជី និងថ្នាំកសិកម្ម

បច្ចុប្បន្ននេះ តម្រូវការប្រើប្រាស់ជីកសិកម្ម និងថ្នាំកសិកម្មមានការកើនឡើងជារៀងរាល់ឆ្នាំ ស្របតាមស្ថានភាពអភិវឌ្ឍន៍ជាប្រចាំរបស់ផលិតកម្មកសិកម្មនៅក្នុងប្រទេស ដែលធ្វើឲ្យបរិមាណនាំចូលថ្នាំនិងជីកសិកម្ម ក៏ដូចជាបរិមាណថ្នាំនិងជីកសិកម្មដែលផលិតលាយផ្សំក្នុងស្រុកមានការកើនឡើងផងដែរ។ រាជរដ្ឋាភិបាលកម្ពុជាមានចក្ខុវិស័យដោយបានកំណត់យុទ្ធសាស្ត្រមិនយកពន្ធ ឬកំណត់អត្រាពន្ធទាបសឹងស្មើសូន្យលើការនាំចូលថ្នាំនិងជីកសិកម្ម ក្នុងគោលបំណងបង្កភាពប្រកួតប្រជែងទីផ្សារកសិកម្មក្នុងស្រុក ដែលអាចឲ្យកសិករទិញសម្ភារៈកសិកម្មទាំងនោះប្រកបដោយគុណភាព និងតម្លៃថោក។ ធ្វើបែបនេះ ប្រជាកសិករអាចចំណាយដើមតិចនៅក្នុងការទិញថ្នាំនិងជីកសិកម្ម ដែលជាធាតុផ្សំមួយមិនអាចខ្វះបានក្នុងដំណើរការកសិកម្មរបស់ពួកគាត់ ក៏ជាកត្តាមួយដែលជំរុញឲ្យថ្លៃផលិតផលកសិកម្មមានតម្លៃទាប ងាយស្រួលប្រកួតប្រជែងក្នុងទីផ្សារទាំងក្នុងស្រុកនិងក្រៅស្រុក។ក្នុងនោះផងដែរ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកំពុងតែខិតខំពង្រឹងការគ្រប់គ្រងការធ្វើអាជីវកម្មថ្នាំនិងជីកសិកម្មដែលបានចុះបញ្ជីការត្រឹមត្រូវ ព្រមទាំងពង្រឹងនូវការត្រួតពិនិត្យអាជីវកម្មលក់ដុំលក់រាយសម្ភារៈកសិកម្មទាំងនោះ នៅតាមបណ្ដារាជធានី-ខេត្តឲ្យបានសមស្របទៅតាមនីតិវិធី។

ក្រាហ្វិកទី ៦៖ បម្រែបម្រួលការនាំចូលថ្នាំនិងជីកសិកម្មឆ្នាំ ២០១៦-២០១៩




ប្រភព៖ របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១៩-២០២០

តាមក្រាហ្វិកនិងតារាងខាងលើបង្ហាញថា ការនាំចូលថ្នាំកសិកម្មនៅក្នុងឆ្នាំ២០១៦ មានចំនួន ៤១,៦៤៩.២០តោន និងបានកើនឡើងទៅដល់ ៨១,០៩៧.៨៨តោនក្នុងឆ្នាំ២០១៩ ពោលគឺមានការកើនឡើងចំនួន ៣៩,៤៤២.៦៨តោន ក្នុងរយៈពេល៤ឆ្នាំចុងក្រោយនេះ។ ដូចគ្នានេះដែរ ការនាំចូលជីកសិកម្មក្នុងឆ្នាំ២០១៦មានចំនួន ៩៩០,៩១៩.៤០តោន នឹងបានកើនឡើងទៅដល់ ១,១៤៩,៦១៥.២៦តោនក្នុងឆ្នាំ២០១៩ ពោលគឺមានការកើនឡើងចំនួន ១៥៨,៦៩៥.៨៦តោនក្នុងរយៈពេល៤ឆ្នាំចុងក្រោយនេះដែរ។ ជាមួយនឹងកំណើននៃតម្រូវការប្រើប្រាស់ថ្នាំនិងជីកសិកម្ម រាជរដ្ឋាភិបាលក៏ដូចជាក្រសួងនិងស្ថាប័នពាក់ព័ន្ធ បានធ្វើការផ្សព្វផ្សាយអប់រំនិងលើកកម្ពស់ការយល់ដឹងអំពីសម្ភារៈកសិកម្មទាំងនោះនូវរបៀបក្នុងការប្រើប្រាស់ ដើម្បីទទួលបានទិន្នផលខ្ពស់ព្រមទាំងកាត់បន្ថយផលជាអវិជ្ជមានមកលើដំណាំ ដី និងមនុស្សទៀតផង។

### ៣.១.៤ សហគមន៍របស់កសិករ

ដើម្បីដឹកនាំ និងគាំទ្រដល់ការផ្ដល់សេវាផ្សព្វផ្សាយកសិកម្មពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ឲ្យមានប្រសិទ្ធភាព រាជរដ្ឋាភិបាលកម្ពុជាបានចាត់ចេញនូវគោលនយោបាយរួមមួយគឺការបង្កើតឲ្យមានសហគមន៍កសិករ ក្នុងគោលបំណងងាយស្រួលចែកចាយនូវព័ត៌មានផ្សេងៗពាក់ព័ន្ធទៅនឹងកសិកម្ម ក៏ដូចជាមានអំណាចនៅក្នុងទីផ្សារកសិកម្មផងដែរ។ ជាក់ស្ដែងក្នុងឆ្នាំ២០១៩នេះ មានចំនួនសហគមន៍កសិកម្មសរុប ១,១៩០សហគមន៍ ដែលមានម្ចាស់ភាគហ៊ុនសរុបចំនួន ១៤០,០៥១នាក់ ក្នុងនោះមានសមាជិកនារីចំនួន ៨៧,៨៩២នាក់។ ក្នុងចំណោមសហគមន៍កសិកម្មទាំង១,១៩០ មានសហគមន៍កសិកម្មចំនួន ១៦៥សហគមន៍ បានធ្វើអាជីវកម្មចុះកិច្ចសន្យា

ជាមួយក្រុមហ៊ុនឯកជន ក្នុងចំនួនសហគមន៍ទាំងអស់នោះរួមមាន ការផលិតស្រូវក្រអូប(៩៣សហគមន៍) និងស្រូវសរីរាង្គ(៤៣សហគមន៍)។ ក្រៅពីនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានចងក្រងសហគមន៍កសិកម្មទៅជាសហភាពសហគមន៍កសិកម្ម ដែលបច្ចុប្បន្ននៅទូទាំងប្រទេសមានសហភាពសហគមន៍កសិកម្មចំនួន ១០ដែលមានសមាជិកជាសហគមន៍កសិកម្មចំនួន ១៦៨។ ជាពិសេសទៀត ក្រសួងបានបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាដែលជារចនាសម្ព័ន្ធចាត់តាំងកំពូលនៃសហគមន៍កសិកម្ម និងសហភាពសហគមន៍កសិកម្មនៅកម្ពុជា។[24]

ក្រាហ្វិកទី ៧៖ បង្ហាញពីកំណើនសហគមន៍កសិកម្មឆ្នាំ ២០១៥-២០១៩




ប្រភព៖ របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ ២០១៩-២០២០

ដោយមើលឃើញនូវផលប្រយោជន៍ជាច្រើនសម្រាប់កសិករក្នុងការចូលជាសហគមន៍កសិកម្ម បានធ្វើឲ្យចំនួនសហគមន៍កសិកម្មមានការកើនឡើងជាលំដាប់ ដូចដែលបានបង្ហាញក្នុងក្រាហ្វិកខាងលើ។ ជាក់ស្តែងក្នុងឆ្នាំ២០១៥ សហគមន៍កសិកម្មមានចំនួន៧៥០ បានកើនឡើងដល់ ៨៨០សហគមន៍នៅឆ្នាំ២០១៧ និងបានបន្តកើនឡើងទៀតរហូតដល់ ១,១៩០សហគមន៍ក្នុងឆ្នាំ ២០១៩។ និយាយម៉្យាងទៀត គិតនៅត្រឹមឆ្នាំ២០១៩ សហគមន៍កសិកម្មបានកើនឡើងចំនួន ៤៤០សហគមន៍បើប្រៀបធៀបទៅឆ្នាំ២០១៥។

### ៣.១.៥ ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តជនបទ

ហេដ្ឋារចនាសម្ព័ន្ធជនបទបានចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការធ្វើសមាហរណកម្មរវាងតំបន់ជនបទ និងទីប្រជុំជន។ ការស្តាបនា និងការជួសជុលហេដ្ឋារចនាសម្ព័ន្ធនៅជនបទបន្ថែមបាននឹងកំពុងនាំមកនូវ

[24] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *របាយការណ៍បូកសរុបការងារប្រចាំឆ្នាំ២០១៩-២០២០* (ភ្នំពេញ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ២០២០), ទំព័រ ២២។

កំណើនសេដ្ឋកិច្ច ការងារ សមធម៌ និងប្រសិទ្ធភាពជូនដល់ប្រជាជនគ្រប់ទិសទីនៅទូទាំងប្រទេស ជាពិសេសគឺតំបន់ជនបទ។ ជាក់ស្តែង បណ្តាញផ្លូវថ្នល់ជនបទនៅកម្ពុជា ៦៣% ជាផ្លូវគ្រួសក្រហម និងផ្លូវដី។[25] តាមក្រសួងអភិវឌ្ឍន៍ជនបទបានលើកឡើងថា ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តជនបទមានដូចជា ផ្លូវគមនាគមន៍ ប្រព័ន្ធធារាសាស្ត្រ ស្ពាន សាលារៀន អណ្តូងទឹក ស្រះទឹក អគ្គីសនីជាដើម ប៉ុន្តែក្នុងបណ្តាហេដ្ឋារចនាសម្ព័ន្ធទាំងនោះ ក្រសួងអភិវឌ្ឍន៍ជនបទទទួលខុសត្រូវតែទៅលើផ្លូវគមនាគមន៍ជនបទនិងប្រព័ន្ធធារាសាស្ត្រតែប៉ុណ្ណោះ។ [26] ក្នុងនោះដែរ ក្រសួងអភិវឌ្ឍន៍ជនបទបាននឹងកំពុងស្ថាបនាផ្លូវជនបទបន្ថែម ក៏ដូចជាធ្វើការកែលម្អឲ្យមានភាពល្អប្រសើរជាងមុន ដើម្បីបង្កភាពងាយស្រួលក្នុងការធ្វើដំណើរ កាត់បន្ថយចំណាយទៅលើការដឹកជញ្ជូនកសិផល។

ក្រាហ្វិកទី ៨៖ បម្រែបម្រួលហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តជនបទឆ្នាំ ២០១៥-២០១៩




ប្រភព៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ

តាមក្រាហ្វិកខាងលើ រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងអភិវឌ្ឍន៍ជនបទ បានខិតខំស្ថាបនាបន្ថែមទៀត និងបានកែលម្អនូវផ្លូវដែលមានផលប៉ះពាល់ពីគ្រោះធម្មជាតិ ដែលធ្វើឲ្យតួលេខនៃការស្ថាបនានិងជួសជុលមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ ជាក់ស្តែងក្នុងឆ្នាំ២០១៥ ផ្លូវជនបទដែលបានស្តារ និងសាងសង់មានប្រវែងសរុប ២៨,២៨៤.៥គ.ម ហើយបានកើនទៅដល់ ២៩,១៧២.៤គ.ម នៅឆ្នាំ២០១៨។[27] ចំណែកឯនៅឆ្នាំ ២០១៩ កន្លងទៅនេះ ផ្លូវជនបទបានស្តារនិងសាងសង់បន្ថែមបានប្រវែងសរុប ៣០,៧៤០គ.ម។[28]

[25] បណ្ឌិត ហង់ ជួន ណារ៉ុន, *សេដ្ឋកិច្ចកម្ពុជា* (២០១៥), ទំព័រ ២០៨។

[26] ក្រសួងអភិវឌ្ឍន៍ជនបទ, *ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២*, ទំព័រ ១៣។

[27] រាជរដ្ឋាភិបាលកម្ពុជា, *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣*, ទំព័រ ៦៩។

[28] ក្រសួងអភិវឌ្ឍន៍ជនបទ, *ផែនការអភិវឌ្ឍន៍ជនបទឆ្នាំ ២០១៩-២០២៣*, ទំព័រ ១៤។

## ៣.២ កត្តាដែលជះឥទ្ធិពលក្នុងការបង្កើនផលិតភាពកសិកម្ម

ការបង្កើនផលិតភាពកសិកម្ម ត្រូវមានការចូលរួមពីវត្តមានរបស់កត្តាសំខាន់ៗដែលមិនអាចខ្វះបាននូវមធ្យោបាយផលិតកម្មកសិកម្ម(ដី ទឹក ជីកសិកម្ម និងគ្រាប់ពូជ) ការបង្កើនផលិតភាពកម្លាំងពលកម្ម ការចូលរួមពីកត្តាបច្ចេកវិទ្យា និងកត្តាហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលត្រូវបានចាត់ទុកថាជាសរសៃឈាមនៃវិស័យកសិកម្ម។

### ៣.២.១ ការបង្កើនផលិតភាពតាមមធ្យោបាយផលិតកម្មកសិកម្ម

កត្តាផលិតកម្មកសិកម្មដែលមិនអាចខ្វះបានរួមមានដី ទឹក ជី និងគ្រាប់ពូជ បានកំពុងនឹងជំរុញនូវដំណើរការបង្កើនផលិតភាពកសិកម្ម។ ប្រព័ន្ធផលិតកម្មកសិកម្មពឹងផ្អែកលើធនធានដី ហើយដីដែលអាចបង្កបង្កើនផលបានជាប្រភេទដីប្រើប្រាស់ក្នុងការធ្វើកសិកម្មនិងសម្រាប់ដំណាំគ្រប់ប្រភេទ។ ទឹកគឺជាធាតុផ្សំដ៏សំខាន់សម្រាប់ការធ្វើកសិកម្ម បើគ្មានទឹកទេនោះរាល់វត្ថុមានជីវិតទាំងអស់គឺមិនអាចរស់រានបានឡើយ។ ចំណែកឯជីជាកម្លាំងចលករដែលជំរុញទិន្នផលកសិកម្មកើនឡើងជាលំដាប់ពីព្រោះជីបានបង្កើននូវផលិតភាពទាំងចំពោះដំណាំនិងដី។ និយាយពីគ្រាប់ពូជវិញ ជាធាតុផ្សំដោយផ្ទាល់ទៅនឹងផលិតភាពរបស់ដំណាំគ្រប់ប្រភេទ ជាពិសេសគឺស្រូវ។ មធ្យោបាយផលិតកម្មទាំងបួននេះ មានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមកយ៉ាងស្អិតរមួតក្នុងការបង្កើននូវផលិតភាពកសិកម្មនិយាយជារួម។

#### ៣.២.១.១ ផលិតភាពដី

ប្រទេសកម្ពុជា មានលក្ខណៈសណ្ឋានដីអំណោយផលដល់ការធ្វើកសិកម្មទៅលើដំណាំស្ទើរគ្រប់មុខ។ នេះដោយសារតែដីភាគច្រើនជាដីទំនាប និងស្ថិតជាប់នៅបឹងទន្លេសាបនិងទន្លេមេគង្គ ដែលជាប្រភេទដីមានជីជាតិល្អ សម្បូរសារធាតុសរីរាង្គ ដែលសុទ្ធតែប្រភពអាហារយ៉ាងសំខាន់សម្រាប់ការលូតលាស់ដំណាំគ្រប់ប្រភេទ ជាពិសេសគឺស្រូវ។ ដូចនេះគេអាចនិយាយបានថា កម្ពុជាមានផលិតភាពដីខ្លាំង ហើយផលិតភាពដីគឺជាលទ្ធផលនៃកត្តាមួយចំនួនដូចជា ជីជាតិដី ការគ្រប់គ្រងដីបានល្អ ការផ្គត់ផ្គង់ទឹកគ្រប់គ្រាន់ដែលអំណោយផលទៅដល់ការបង្កើនទិន្នផលដំណាំកសិកម្ម។ យ៉ាងណាមិញ ការប្រើប្រាស់ដីប្រទេសកម្ពុជា នៅមិនទាន់មានប្រសិទ្ធភាពនៅឡើយទេ ដោយសារការប្រើប្រាស់ដីមិនត្រឹមត្រូវទៅតាមបច្ចេកទេសដូចជា ការប្រើប្រាស់ជីគីមីមិនសមស្របការដាំដំណាំដដែលៗដែលធ្វើឲ្យជីជាតិដីមានការថយចុះពីមួយឆ្នាំទៅមួយឆ្នាំ ជាមូលហេតុចម្បងនៃការធ្លាក់ចុះគុណភាពដី។ មូលហេតុមួយផ្សេងទៀតគឺការមិនមានតុល្យភាពគ្នានៃការយកផលចំណេញពីដី ទៅនឹងការដាក់សារធាតុសរីរាង្គនិងសារធាតុចិញ្ចឹមទៅឲ្យដីវិញ។ ការធ្វើស្រែច្រើនដងក្នុងមួយឆ្នាំ ហើយពុំបានផ្តល់សារធាតុចិញ្ចឹមទៅឲ្យដីវិញគ្រប់គ្រាន់បានធ្វើឲ្យដីប្រែជាខ្សោះជីជាតិ និងរឹងដែលអាចនឹងទទួលទិន្នផលទាប។ ការមិនយល់ដឹងច្បាស់ពីសណ្ឋានដីនិងប្រភេទដី បានធ្វើឲ្យកសិករធ្វើស្រែទទួលបានទិន្នផលមិនសូវល្អក៏ព្រោះតែមិន

មានចំណេះដឹងគ្រប់គ្រាន់ទៅនឹងការរៀបចំប្រភេទដីទាំងនោះ ព្រមទាំងផ្តល់នូវសារធាតុចិញ្ចឹមទៅឲ្យដីវិញមិនត្រឹមត្រូវទៅតាមប្រភេទដី។ ហេតុដូចនេះ ដើម្បីបង្កើនផលិតភាពដីប្រកបដោយប្រសិទ្ធភាព ប្រជាកសិករគប្បីក្រឡេកមើលឡើងវិញនូវចំណុចស្នូលទាំងនេះ។

**ក. ប្រភេទសណ្ឋានដី និងគ្រប់គ្រងជីជាតិដី**

ការយល់ដឹងច្បាស់ពីសណ្ឋានដីកសិកម្មសម្រាប់ផលិតកម្មដំណាំស្រូវ ពិតជាមានសារៈសំខាន់ណាស់សម្រាប់ការដាំដុះ ពីព្រោះវាបានជួយក្នុងការគ្រប់គ្រងជីជាតិដីបានយ៉ាងត្រឹមត្រូវដែលជាសារធាតុចិញ្ចឹមទៅដល់ដំណាំស្រូវឲ្យទិន្នផលខ្ពស់ និងធានាបាននូវនិរន្តរភាពផលិតកម្ម ប្រសិទ្ធភាពសេដ្ឋកិច្ច ក៏ដូចជាគុណភាពប្រព័ន្ធបរិស្ថាន។ ការបែងចែកឲ្យបានច្បាស់ពីសណ្ឋានដីនេះ បានជួយឲ្យប្រជាកសិករយល់ជ្រាបពីសារធាតុចិញ្ចឹមរបស់ដីទៅឲ្យដំណាំ ក៏ដូចជាផ្តល់នូវតម្រូវការទៅកាន់ដីវិញដើម្បីឲ្យដីកាន់តែមានផលិតភាព និងផ្តល់ទិន្នផលបានខ្ពស់។ ជាលទ្ធផលនៃការដាំដំណាំ សារធាតុសរីរាង្គ និងសារធាតុរ៉ែរបស់ដីមួយចំនួនធំបានថយចុះឬបាត់បង់ ពេលនោះបើយើងមិនបានបំពេញបន្ថែមសារធាតុទាំងនោះដល់ដីវិញទេ នាំឲ្យដីបាត់បង់ជីជាតិជាប្រចាំ ហើយជាលទ្ធផលធ្វើឲ្យដំណាំស្រូវដុះលូតលាស់មិនបានល្អ និងផ្តល់ទិន្នផលទាប។ ជារៀងរាល់រដូវ ស្រូវបានស្រូបយកសារធាតុចិញ្ចឹមសំខាន់ចំនួន ៣ ពីដីសម្រាប់បំប៉នខ្លួនដូចជា អាសូត(N) ផូស្វ័រ(P) ប៉ូតាស្យូម(K) និងសារធាតុចិញ្ចឹមមួយចំនួនទៀតដូចជា ម៉ាញេស្យូម(Mg) និងស្ពាន់ធ័រ(S)ជាដើម។ ដូច្នេះដើម្បីរក្សាជីជាតិនៅក្នុងដីឲ្យបានល្អ គេត្រូវបំពេញបន្ថែមឡើងវិញនូវសារធាតុចិញ្ចឹម N, P, K និងសារធាតុចិញ្ចឹមផ្សេងទៀត ដែលត្រូវបានស្រូបយកដើម្បីផ្គត់ផ្គង់ដំណាំស្រូវត្រូវការចាំបាច់ក្នុងការលូតលាស់ល្អ។ ប៉ុន្តែ សារធាតុចិញ្ចឹមទាំងនេះ មានច្រើន ឬតិចគឺអាស្រ័យទៅតាមសណ្ឋានដីខុសៗគ្នាដែលមាននៅតាមតំបន់ផ្សេងៗគ្នាក្នុងប្រទេស។ ប្រភេទក្រុមដីនីមួយៗត្រូវបានណែនាំពីការបំពេញនូវសារធាតុចិញ្ចឹម N, P, K និង សារធាតុផ្សេងទៀតទៅដល់ដីវិញ ដែលសារធាតុទាំងនោះឃើញមាននៅក្នុងប្រភេទជីដូចជា ជីអ៊ុយរ៉េ(Urea) ជីដេអាប៉េ(DAP) និងជីប៉ូតាស្យូ(KCL) ដែលត្រូវតាមបទដ្ឋានរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មនៅកម្ពុជា(CARDI) ដើម្បីបង្កើនផលិតភាពរបស់ដី។ ជាក់ស្តែង នៅក្នុងប្រទេសកម្ពុជា សម្រាប់ដីដែលត្រូវបានប្រើប្រាស់ក្នុងវិស័យកសិកម្ម ជាពិសេសសម្រាប់ដំណាំស្រូវត្រូវបានគេចែកចេញជា ១១ក្រុមរួមមាន ក្រុមដីព្រៃខ្មែរ ក្រុមដីប្រទះឡាង ក្រុមដីឡាបានសៀក ក្រុមដីអូរ្លង ក្រុមដីក្រគរ ក្រុមដីបាកាន ក្រុមដីក្បាលពោធិ ក្រុមដីកៀនស្វាយ ក្រុមដីទួលសំរោង ក្រុមដីគោកត្រប់ និងក្រុមដីកំពង់សៀម។[29]

[29] វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មនៅកម្ពុជា(CARDI), *ការគ្រប់គ្រងជីជាតិដីលើដំណាំស្រូវនៅកម្ពុជា*, ទំព័រ ៤។

**I. ក្រុមដីព្រៃខ្មែរ៖** ជាប្រភេទដីម៉្យាងដែលកើតឡើងលើទំនាបល្បាប់ជំនន់ចាស់ ឬទំនាបល្បាប់ជំនន់សំណឹក ដែលមានស្រទាប់ខាងលើលក្ខណៈជាខ្សាច់ជម្រៅជាង ៥០ស.ម។ ដីប្រភេទនេះមានប្រមាណ ១១%នៃផ្ទៃដីដាំដុះស្រូវសរុប។ ដីប្រភេទនេះលំបាកក្នុងការគ្រប់គ្រង សម្រាប់ផលិតកម្មស្រូវ ពីព្រោះដីនេះពុំសមស្របចំពោះការស្រោចស្រពទេ ហើយជីជាតិនៃដីក៏មានតិចដែរ។ តាមការពិសោធន៍របស់ផ្ទះកញ្ចក់បង្ហាញថា ដីនេះកើតមាននូវកង្វះសារធាតុ N, P, K, S និង Mg។ មិនតែប៉ុណ្ណោះ កម្រិតនៃសារធាតុសរីរាង្គទាប ហើយការគ្រប់គ្រងជីជាតិមានការលំបាក ដោយសារដីប្រភេទនេះងាយជ្រាបទឹក និងមានការលំបាកក្នុងការតម្រូវអាហារធាតុទៅនឹងសេចក្តីត្រូវការរបស់ដំណាំ។ ដីប្រភេទនេះពុំសូវឆ្លើយតបខ្លាំងទៅនឹងការប្រើប្រាស់ជីដើម្បីផ្តល់សារធាតុចិញ្ចឹមទៅឲ្យដីវិញទេ ជាហេតុធ្វើឲ្យដីប្រភេទនេះមានផលិភាពទាប ទោះផ្តល់សារធាតុសរីរាង្គខ្លាំងក្តី ។ ដូចនេះគេត្រូវផ្គត់ផ្គង់ទឹកឲ្យបានគ្រប់គ្រាន់ បូកជាមួយការប្រើប្រាស់បរិមាណជីដែលមានជាតិ N និង K ត្រូវតាមបទដ្ឋាន។ ការប្រើប្រាស់ជី គេត្រូវប្រើជីអ៊ុយរ៉េក្នុងបរិមាណ ៥០-៨៧.៥ គ.ក្រ/ហ.ត ជីដេអាប៉េ ១៧-២៥ គ.ក្រ/ហ.ត និងជីប៉ូតាស្យូម ៦៧គ.ក្រ/ហ.ត។ បើផ្គត់ផ្គង់ជីទៅតាមបរិមាណនេះ នោះដីនឹងផ្តល់ទិន្នផលបានចន្លោះពី ១.៧-២ ត/ហ.ត។

**II. ក្រុមដីប្រទះឡាង៖** ជាប្រភេទដីកើតឡើងលើទំនាបល្បាប់ជំនន់ចាស់ ឬល្បាប់សំណឹក ដែលមានខ្សាច់កម្រាស់ជាង ៤០ស.ម ហើយមានដីស្រទាប់ក្រោមជាល្បាប់ឬឥដ្ឋ។ ដីប្រភេទនេះជាដីដំណាំស្រូវទូទៅ និងមានប្រមាណជា ២៥%នៃតំបន់ដាំដុះសរុប។ ក្រុមដីប្រទះឡាងនេះមានការលំបាកបន្តិចក្នុងការគ្រប់គ្រងចំពោះផលិតកម្មដំណាំស្រូវ។ ប្រសិនបើការស្រោចស្រពទឹក អាចត្រូវបានប្រើក្នុងតម្លៃថោកនោះ កសិករសង្ឃឹមទទួលបានផលចំណេញពីក្រុមដីប្រភេទនេះ ដោយសារដីនេះជ្រាបទឹកលឿន។ ដោយសារដីនេះមានស្រទាប់លើជាខ្សាច់ជម្រៅជាង ៤០ស.ម និងស្រទាប់ក្រោមជាដីល្បាយឬឥដ្ឋ ដូចនេះគេត្រូវប្រើជីក្នុងបរិមាណមួយច្រើន និងផ្គត់ផ្គង់ទឹកឲ្យបានគ្រប់គ្រាន់ ទើបអាចធ្វើឲ្យដីមានផលិតភាពអាចទទួលយកបាន។ ជាក់ស្តែង គេត្រូវប្រើប្រាស់ជីអ៊ុយរ៉េចាប់ពី ៥០-៨៧.៥ គ.ក្រ/ហ.ត ជីដេអាប៉េ ៥០-៨៨ គ.ក្រ/ហ.ត និងជីប៉ូតាស្យូម ៥០ គ.ក្រ/ហ.ត ពេលនោះដីនឹងផ្តល់ទិន្នផលស្រូវពី ២-២.៥ ត/ហ.ត។

**III. ក្រុមដីឡាបានសៀក៖** ដីឡាបានសៀកកើតមាននៅតាមជើងភ្នំ ឬលើភ្នំ ដែលមានដីពណ៌ក្រហម ផ្ទៃខាងលើមានសភាពជាឥដ្ឋ មានទម្រង់ខ្ទេច ហើយស្រទាប់ក្រោមមានសភាពជាឥដ្ឋដែរ។ ដីនេះមានប្រមាណ ១%នៃផ្ទៃដីដាំដុះសរុប។ ក្រុមដីនេះមានជីជាតិមធ្យម កម្រិតនៃសារធាតុសរីរាង្គប្រែប្រួលពីមធ្យមទៅខ្ពស់ ហើយមិនសមស្របនឹងផលិតកម្មស្រូវ។ ការពិសោធន៍នៅផ្ទះកញ្ចក់បង្ហាញថា ដីនេះខ្វះ N, P, K និង S នៅលើស្រែ។ ជាទូទៅដីនេះមានលក្ខណៈអាស៊ីតខ្សោយ។ ដោយសារតែមានសណ្ឋានបែបនេះ ទើបធ្វើឲ្យដីប្រភេទនេះមិនមែនជាដីសមប្រកបសម្រាប់ការធ្វើកសិកម្មដំណាំស្រូវទេ ពីព្រោះវាផ្តល់ទិន្នផលក្នុងកម្រិតមួយទាប។ ដូចនេះ គេត្រូវ

បំប៉នជីជាតិឲ្យដីក្នុងកម្រិតមួយខ្ពស់។ បើសិនជា គេប្រើជីអ៊ុយរ៉េចំនួន ៦៥ គ.ក្រ/ហ.ត និងជីដេអាប៉េចំនួន ១០០ គ.ក្រ/ហ.ត នោះដីនឹងឲ្យទិន្នផលមកវិញក្នុងកម្រិតទាបខ្លាំង ពោលគឺ ១ ត/ហ.ត។

**IV. ក្រុមដីអូរ្សង៖** ជាដីប្រភេទវាលល្បាប់ចាស់ មានលក្ខណៈជាដីល្បាយ ឬឥដ្ឋ មានពណ៌ប្រផេះទៅប្រផេះភ្លឺ និងមានស្នាមប្រេះរាក់ៗនៅលើផ្ទៃខាងលើ។ ស្រទាប់ក្រោម ជាដីខ្សាច់មានកម្រាស់ពី ១០-២០ស.ម និងគ្របដណ្ដប់លើផ្ទៃដីដាំដុះស្រូវទាំងមូលប្រមាណ ២%នៃផ្ទៃដីសរុប។ ចំពោះដីប្រភេទនេះ ការប្រើប្រាស់ជី N និង P ទៅដីតែងបានផលិតភាពខ្ពស់ ប៉ុន្តែការប្រើប្រាស់នូវជីប៉ូតាស្យូដែលមានជាតិ K មិនសូវបានទិន្នផលប៉ុន្មានទេ ដោយសារវាមានស្រទាប់លើជាខ្សាច់និងស្រទាប់ក្រោមជាឥដ្ឋ។ ប្រសិនបើ ស្រែមានប្រព័ន្ធទឹកគ្រប់គ្រាន់សម្រាប់ដាំដុះ នោះគេគួរប្រើជី N និង P ឲ្យបានខ្ពស់ទើបទទួលបានទិន្នផលល្អ។ គេគប្បីគួរប្រើប្រាស់ជីអ៊ុយរ៉េចន្លោះពី ១១៧-១៣៤ គ.ក្រ/ហ.ត ជីដេអាប៉េ ៦៧គ.ក្រ/ហ.ត និងជីប៉ូតាស្យូ ៣៥ គ.ក្រ/ហ.ត ទៅឲ្យដីវិញ ទើបដីអាចមានផលិតភាពដែលផ្ដល់ផលពី ២.៨-៣.២ ត/ហ.ត បាន។

**V. ក្រុមដីក្រគរ៖** ជាដីមានពណ៌ប្រផេះត្នោត មានទម្រង់ជាដីល្បាប់ ឬដីឥដ្ឋនៅស្រទាប់ខាងលើ និងមានទម្រង់ជាដីខ្សាច់ ឬដីឥដ្ឋនៅស្រទាប់ក្រោម។ ដីនេះកើតមាននៅវាលទំនាប ហើយមាននៅគ្រប់ខេត្តដែលមានចំនួន ១៥%នៃផ្ទៃដីដាំស្រូវនៅកម្ពុជា។ ដីក្រគរមានសក្ដានុពលខ្ពស់ និងមានការឆ្លើយតបល្អទៅនឹងការគ្រប់គ្រងព្រមទាំងអំណោយផលចំពោះការស្រោចស្រព ប្រសិនបើគេអាចគ្រប់គ្រងទឹកបានល្អ។ ការពិសោធន៍នៅផ្ទះកញ្ចក់បង្ហាញថា ដីនេះជាក្រុមដីមានជីជាតិល្អ ហើយឆ្លើយតបទៅនឹងការប្រើប្រាស់ N និង P ប៉ុណ្ណោះ។ ដីក្រុមនេះមានជីជាតិល្អ ហើយជាប្រភេទដីដែលអំណោយផលយ៉ាងខ្លាំងក្នុងការធ្វើកសិកម្មដំណាំស្រូវ។ ជាក់ស្ដែងការប្រើប្រាស់ជីអ៊ុយរ៉េក្នុងបរិមាណ ២៣៨-៣៥០ គ.ក្រ/ហ.ត និងជីដេអាប៉េ ៥០-១០០ គ.ក្រ/ហ.ត នោះគេអាចបានទិន្នផលខ្ពស់គឺ ៦ ត/ហ.ត។

**VI. ក្រុមដីបាកាន៖** កើតនៅលើទំនាបល្បាប់ចាស់ ដែលមានដីស្រទាប់លើជាល្បាយឬឥដ្ឋ ពុំមានក្រហែងទេ ឬបើមាន គឺមានតែនៅផ្ទៃដីលើរាក់ៗប៉ុណ្ណោះ។ គេប្រទះឃើញក្រុមដីនេះមានគ្រប់ទីកន្លែង នៃតំបន់ធ្វើស្រែក្នុងប្រទេស។ ដីស្រទាប់ក្រោមជាដីល្បាយ ឬឥដ្ឋ និងមានប្រមាណ ១២%នៃដីដាំដុះស្រូវសរុប ហើយដីនេះសមស្របទៅនឹងផលិតកម្មស្រូវ។ ការគ្រប់គ្រងទឹកបានល្អគឺជាលក្ខខណ្ឌមួយដ៏ប្រសើរ សម្រាប់ការបង្កើនទិន្នផលស្រូវ។ ដីនេះមានជីជាតិកម្រិតមធ្យម និងបើតាមការពិសោធន៍នៅផ្ទះកញ្ចក់ថា ដីប្រភេទនេះកង្វះធាតុ N, P, K និង S ទៀតផង។ ដីក្រុមនេះមានលក្ខណៈប្រហាក់ប្រហែលទៅនឹងដីអូរ្សងដែរ។ ខុសគ្នាត្រង់ដីប្រភេទនេះមានច្រើនជាងក្រុមដីអូរ្សងនៃផ្ទៃដីដាំដុះសរុប។ ការប្រើប្រាស់ជី N និង P ដល់កម្រិតដែលដីត្រូវការ នឹងធ្វើឲ្យដីអាចបង្កើនផលិតភាពបាន។ បើតាមបទដ្ឋានបច្ចេកទេសនៃផ្ទៃដី គេត្រូវប្រើជីអ៊ុយរ៉េចន្លោះពី ១១៣-១៣៨ គ.ក្រ/ហ.ត

ជីដេអាប៉េពី ៤៣-៦៥ គ.ក្រ/ហ.ត និងជីប៉ូតាស្យូចំនួនប្រមាណ ៥០ គ.ក្រ/ហ.ត គេនឹងបានផលចន្លោះចាប់ពី ២.៨-៣.២ ត/ហ.ត។

VII. **ក្រុមដីក្បាលពោធិ៖** ក្រុមដីនេះមានពណ៌ប្រផេះក្រម៉ៅ ឬត្នោតក្រម៉ៅខ្លាំង ដែលមានដីស្រទាប់លើជាឥដ្ឋ បែកក្រហែងធំៗពេលដីស្ងួត។ ប្រភេទដីនេះកើតនៅទំនាបលិចទឹក និងមានទំហំប្រមាណ ១៣% នៃផ្ទៃដីដាំស្រូវសរុប។ ដីនេះមានការងាយស្រួលក្នុងការគ្រប់គ្រង និងស្រោចស្រព ដោយសារអំណោយផលដល់ផលិតកម្មស្រូវ។ ការប្រើជីដែលមានជាតិ N ច្រើន គួបផ្សំនឹងមានប្រព័ន្ធទឹកស្រោចស្រពគ្រប់គ្រាន់ល្អ និងការអនុវត្តប្រព័ន្ធប្រពលវប្បកម្ម នឹងធ្វើឲ្យដីនេះមានផលិតភាពខ្ពស់។ ការប្រើប្រាស់ជីអ៊ុយរ៉េនៅចន្លោះពី ១២៥-៣០០ គ.ក្រ/ហ.ត ជីដេអាប៉េចំនួនប្រហែល ១០០ គ.ក្រ/ហ.ត ព្រមជាមួយជីប៉ូតាស្យូចំនួន ៥០ គ.ក្រ/ហ.ត នោះគេនឹងបានទិន្នផលប្រមាណ ៦.២ ត/ហ.ត។

VIII. **ក្រុមដីកៀនស្វាយ៖** មានសភាពជាដីឥដ្ឋឬល្បាយទាំងពីរស្រទាប់ ហើយមានពណ៌ត្នោតភ្លឺទៅពណ៌ត្នោត។ ដីក្រុមនេះកើតនៅលើច្រាំងទន្លេ លើទំនាបជម្រាលពីច្រាំងទន្លេ និងមានផ្ទៃដីប្រមាណ ២%នៃផ្ទៃដីដាំដុះសរុប។ ដីនេះងាយស្រួលក្នុងការគ្រប់គ្រង និងអំណោយផលយ៉ាងខ្លាំងទៅដល់ដំណាំស្រូវ។ ក្រុមដីកៀនស្វាយនេះ ខ្វះនូវជីជាតិ N និង P តែទោះបីខ្វះខាតសារធាតុនេះក៏ដោយ ក៏មិនចាំបាច់ប្រើជីPក្នុងកម្រិតខ្ពស់ដែរ។ ស្ថិតក្នុងក្រុមដីដែលមានស្រទាប់លើជាដីឥដ្ឋ ធ្វើឲ្យដីនេះមានជីវជាតិល្អ សមស្របនឹងដំណាំស្រូវ បន្លែ និងឈើហូបផ្លែ។ ដីក្រុមនេះត្រូវការជី N ខ្លាំងសម្រាប់បង្កើនផលិតភាពរបស់ដី។ ដូចនេះ កសិករគប្បីប្រើប្រាស់តែជីអ៊ុយរ៉េដែលមានជាតិ N នៅក្នុងបរិមាណ ១២៥ គ.ក្រ/ហ.ត ចំណែកឯទិន្នផលដែលដីផ្តល់មកវិញក្នុងកម្រិតមួយខ្ពស់គឺចាប់ពី ៥-៥.២ត/ហ.ត។

IX. **ក្រុមដីទួលសំរោង៖** កើតនៅលើទំនប់ល្បាប់ចាស់ ឬល្បាប់សំណឹក និងមានលក្ខណៈជាដីឥដ្ឋឬល្បាយមានពណ៌ប្រផេះឬត្នោត និងបែកក្រហែងធំពេលដីស្ងួត។ ដីនេះមានប្រហែល ១០%នៃផ្ទៃដីដាំដុះសរុប ហើយមានសក្តានុពលបង្គួរទៅខ្ពស់សម្រាប់ដំណាំស្រូវ និងមានការឆ្លើយតបល្អ ចំពោះការគ្រប់គ្រងនិងស្រោចស្រព។ តាមការសង្កេត ដីនេះមានផលល្អចំពោះការប្រើប្រាស់ N និង P តែប៉ុណ្ណោះ។ ដីប្រភេទនេះមានស្រទាប់លើជាល្បាយឬឥដ្ឋ មានកម្រាស់១០-២០ស.ម។ ជាទូទៅ ការប្រើប្រាស់ជីដែលមានជាតិ K គឺមានបរិមាណពុំសូវច្រើនប៉ុន្មានទេ លើកលែងតែតំបន់ខ្លះដែលមានលក្ខណៈហូរច្រោះខ្លាំងជាងធម្មតា។ ក្នុងបទដ្ឋាននៃការបង្កើនផលិតភាពដីតាមរយៈការដាក់ជី គេត្រូវជីអ៊ុយរ៉េពី ១១៣-១៩៤ គ.ក្រ/ហ.ត និងជីដេអាប៉េ ៥០-៧៥ គ.ក្រ/ហ.ត គឺអាចទទួលបានទិន្នផលស្រូវប្រមាណ ៤ ត/ហ.ត។

X. **ក្រុមដីគោកគ្រប់៖** កើតលើល្បាប់ទំនន់ចាស់ មានលក្ខណៈជាដីល្បាយឬឥដ្ឋមានពណ៌ប្រផេះក្រម៉ៅឬត្នោតក្រម៉ៅ និងបែកក្រហែងតូចទៅមធ្យមពេលដីស្ងួត។ ដីគោកគ្រប់ មានប្រហែល ៥%នៃដីដាំដុះសរុប ដែលភាគច្រើនមាននៅភាគខាងត្បូងនៃប្រទេសកម្ពុជាដូចជាខេត្តព្រៃវែង ស្វាយរៀង និងមួយភាគតូចទៀតមាននៅខេត្តកណ្តាល និងតាកែវជាដើម។ ប្រភេទដីនេះ ជាដីខ្សត់ជីជាតិដោយសារមានជាតិអាស៊ីតខ្លាំង ដូចនេះវាពុំសាកសមជាដីសម្រាប់ការងារកសិកម្មប៉ុន្មានទេ។ សម្រាប់ដីនេះ បើពុំដាក់ជី N និង P ទេនោះ ដំណាំស្រូវពុំលូតលាស់ល្អទេ។ កាលណាគេដាក់ជី N និង P ជាមួយគ្នានោះនឹងធ្វើឲ្យដីមានផលិតភាពគួរសម។ បើគេប្រើជីអ៊ុយរ៉េពី ៦៧-១២៥គ.ក្រ/ហ.ត ជីដេអាប៉េពី ៥០-៦១ គ.ក្រ/ហ.ត និងប៉ូតាស្យូ ៥០ គ.ក្រ/ហ.ត នោះគេនឹងទទួលបានផលត្រឡប់មកវិញប្រហែល ១.៩-២ ត/ហ.ត។

XI. **ក្រុមដីកំពង់សៀម៖** ក្រុមដីនេះកើតនៅលើច្រាំងទន្លេ លើទំនាបជម្រាលពីច្រាំងទន្លេដែលមានសណ្ឋានដីប្រែប្រួលខ្ពស់ទាបមិនរាបស្មើ និងមានលក្ខណៈជាដីល្បាយឬឥដ្ឋ មានពណ៌ត្នោតភ្លឺទៅត្នោត។ ក្រុមនេះមានប្រហែល ២%នៃផ្ទៃដីដាំដុះស្រូវសរុបនៅកម្ពុជា។ ដីនេះសមស្របសម្រាប់ផលិតកម្មស្រូវ ឯទិន្នផលឆ្លើយតបល្អទៅនឹងការគ្រប់គ្រងបែបទំនើប ហើយតាមការពិសោធន៍របស់ផ្ទះកញ្ចក់បង្ហាញថា ក្រុមដីកំពង់សៀមកង្វះសារធាតុ N និង P។ សមត្ថភាពស្តុកទឹករបស់ដីស្រទាប់លើល្អ ប៉ុន្តែក្នុងកំឡុងពេលមានភ្លៀងតិច ដីនេះអាចហួតហែងដោយសារតែស្តុកទឹកបានតិច។ ការប្រើជីដែលមានជាតិ N ច្រើននឹងធ្វើឲ្យមានប្រសិទ្ធភាពល្អនៅក្នុងការបង្កើនផលិតភាពដី បន្ទាប់មកគឺជីដែលមានជាតិ P។ តាមបទដ្ឋាននៃដីប្រភេទមួយនេះ គេត្រូវប្រើប្រាស់អ៊ុយរ៉េចំនួន ១២៥-២០០ គ.ក្រ/ហ.ត និងជីដេអាប៉េក្នុងចំនួន ៣៧.៥ គ.ក្រ/ហ.ត ពេលនោះដីនឹងផ្តល់ទិន្នផលបាន ៣.២-៣.៤ ត/ហ.ត។

លក្ខណៈនៃសណ្ឋានដីទាំង ១១ក្រុមខាងលើនេះ មានចំណុចពិសេស និងមានផ្ទុកនូវបរិមាណសារធាតុចិញ្ចឹមដល់ដំណាំស្រូវខុសៗគ្នា ដែលតម្រូវឲ្យកសិករត្រូវយល់ដឹងពីប្រភេទនៃក្រុមដីទាំងនោះដើម្បីជាប្រយោជន៍សម្រាប់ផលិតកម្មដំណាំស្រូវទទួលបានទិន្នផលខ្ពស់។ បន្ថែមពីនេះ ដើម្បីការពារការធ្លាក់ចុះផលិតភាពឬគុណភាពដី ដែលបណ្តាលមកពីការផ្តល់នូវសារធាតុចិញ្ចឹមទៅឲ្យដីខុសតម្រូវការ ជាហេតុនាំឲ្យដីប្រែក្លាយជារឹង គ្មានជីជាតិ។ ការដាក់បន្ថែមនូវសារធាតុចិញ្ចឹមទៅឲ្យដីតាមប្រភេទនៃក្រុមដីទាំង ១១នេះ ធ្វើឲ្យមានការកកើតជីជាតិដីឡើងវិញដែលជួយបង្កើនផលិតភាពដីរបស់ក្រុមប្រភេទដីទាំងនោះ តាមរយៈការលាយចូលគ្នានូវសារធាតុជីដែលមានស្រាប់របស់ដី បូករួមជាមួយសមាសធាតុរបស់ជីបំប៉ន។ ដូចនេះ គឺចាំបាច់ក្នុងការកំណត់បរិមាណសារធាតុចិញ្ចឹមដែលអាស្រ័យទៅតាមក្រុមនៃដី ដើម្បីជំរុញឲ្យដីកាន់តែមានផលិតភាពខ្ពស់ក្នុងការបង្កើនទិន្នផលដំណាំស្រូវ។

**ខ. ការរៀបចំដី**

ការរៀបចំដី គឺបច្ចេកវិទ្យាមួយដើម្បីបង្កើនទិន្នផលស្រូវនៅក្នុងប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ ហើយក៏ជាកត្តាដ៏សំខាន់បំផុតមួយដែលមានឥទ្ធិពលយ៉ាងខ្លាំងលើការលូតលាស់របស់ដំណាំកសិកម្ម ជាពិសេសស្រូវ។ ការរៀបចំដីបានល្អ គឺធ្វើឲ្យដីស្រែផុសល្អព្រមទាំងមានរន្ធខ្យល់ច្រើនដែលអាចជួយសម្រួលដល់ការលូតលាស់របស់ប្រព័ន្ធឫស ក្នុងការទាញយកសារធាតុចិញ្ចឹមពីក្នុងដីបានកាន់តែច្រើន។ ជាងនេះទៅទៀត ការរៀបចំដីបានត្រឹមត្រូវបានទាំងបង្កើនជីជាតិរបស់ដីតាមរយៈការភ្ជួរលប់ស្មៅនិងគល់ជញ្ជ្រាំង ងាយស្រួលក្នុងការគ្រប់គ្រងទឹក ជាពិសេសកាត់បន្ថយវត្តមានស្មៅ ពពួកផ្សិត សត្វល្អិតជាដើម។ ជាការប្រសើរ កសិករត្រូវភ្ជួររាស់ដីស្រែដើម្បីបង្កលក្ខខណ្ឌល្អសម្រាប់ការលូតលាស់របស់ដំណាំស្រូវតាមការអនុវត្តវិធី៖

- ត្រូវកៀរពង្រាបដីស្រែ ហើយភ្ជួររាស់ដីឲ្យបានសព្វល្អសម្រាប់ងាយស្រួលដល់ដំណាំស្រូវមុនពេលដាំ
- យកជីលាមកសត្វនិងជីគីមីដែលមានសារធាតុ N, P និង K ដាក់ចូលទៅក្នុងដីសម្រាប់ទ្រាប់បាត ហើយត្រូវលាយច្របល់បង្កប់ទៅក្នុងដី ដើម្បីឲ្យដីនិងជីច្របល់ចូលគ្នា ព្រមផ្លាស់ប្តូរស្រទាប់ដីបានល្អ។
- ត្រូវរៀបចំដីស្រែឲ្យមានភ្លឺត្រឹមត្រូវ គៀរពង្រាបឲ្យបានស្មើ ទើបងាយស្រួលក្នុងការរក្សានិងគ្រប់គ្រងទឹក ដើម្បីប្រើប្រាស់ទឹកអស់បរិមាណតិច។ ការធ្វើឲ្យមានកម្ពស់ទឹកក្នុងស្រែស្មើគ្នាល្អ ធ្វើឲ្យមិនមានស្មៅដុះច្រើន និងស្រូវមានការលូតលាស់បានល្អ។
- មិនត្រូវភ្ជួរដីជ្រៅពេក ឬរាក់ពេកទេ។ ជម្រៅនៃការភ្ជួរគឺអាស្រ័យទៅតាមប្រភេទនៃក្រុមដី។ ឧទាហរណ៍ សម្រាប់ដីលើជាល្បាយខ្សាច់ គួរភ្ជួរជម្រៅ ១០-១៥ ស.ម និងដីល្បាយឥដ្ឋ គួរភ្ជួរជម្រៅ ១៥-២៥ ស.ម។ ធ្វើបែបនេះ គឺឲ្យខ្យល់ចូលស្រួល បង្កលទ្ធភាពឲ្យប្រព័ន្ធឫសលូតលាស់បានល្អ ព្រមទាំងកម្ចាត់នូវកត្តាចង្រៃផងដែរ។

ការរៀបចំដីបានល្អ នឹងធ្វើឲ្យដីស្រែបង្កើនផលិតភាពដាំដុះផ្តល់នូវទិន្នផលស្រូវកើនខ្ពស់ជាងធម្មតាប្រមាណ ៣០%។ មូលហេតុមួយទៀតបានបន្ថយនូវបរិមាណស្មៅប្រហែល ៤០%ដែលជាកត្តាបង្អាក់ដល់ការបង្កើនផលស្រូវ។ ការប្រើប្រាស់ទឹកតិច ងាយស្រួលក្នុងការគ្រប់គ្រងកម្រិតទឹកក្នុងស្រែ ហើយធ្វើឲ្យស្រូវលូតលាស់ល្អនិងទុំដំណាលគ្នាព្រមទាំងមានទំហំគ្រាប់ស្មើៗគ្នាគឺជាអត្ថប្រយោជន៍ដែលចេញពីការរៀបចំដីបានល្អ។

**៣.២.១.២ កត្តាធនធានទឹក**

ទឹកមានសារៈសំខាន់ណាស់សម្រាប់ភាវៈរស់ទាំងអស់នៅលើពិភពលោកនេះ ដែលវាសមស្របទៅតាមសុភាសិតមួយឃ្លាពោលថា គ្មានទឹកគឺគ្មានជីវិត។ សម្រាប់កម្ពុជា គឺជាប្រទេសមួយដែលមានទឹកច្រើនសន្ធឹកសន្ធាប់នៅក្នុងតំបន់។ បណ្តាស្ទឹង បឹង ទន្លេ ទឹកក្រោមដី សុទ្ធសឹងតែជាប្រភពដ៏សំខាន់ជាអាយុជីវិតសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិនៅក្នុងវិស័យជាច្រើន ជាពិសេសគឺវិស័យកសិកម្ម។ ទឹកនៅកម្ពុជាមានពីរប្រភេទគឺ ទឹក

ភ្លៀងប្រចាំឆ្នាំប្រមាណ ៧៥,០០០លានម៣ និងទឹកនៅក្រោមដីប្រមាណ ១៧,៦០០លានម៣ ហើយបរិមាណទឹកដែលយកទៅបម្រើវិស័យកសិកម្មក្នុងផលិតកម្មដំណាំស្រូវ គឺមានប្រមាណជិត ១០%នៃបរិមាណទឹកសរុប (៧១០លានម៣)តាមរយៈកិច្ចការធារាសាស្ត្រ។[30] បន្ថែមពីនេះ ទឹកគឺជាធាតុផ្សំយ៉ាងសំខាន់នៅក្នុងដំណើរការនៃផលិតកម្មកសិកម្មទាំងអស់ ពីព្រោះបើសិនជាកង្វះនូវធនធានទឹក វានឹងប៉ះពាល់ទៅដល់ការលូតលាស់និងការអភិវឌ្ឍរបស់ដំណាំ ហើយជាលទ្ធផលគឺវាប៉ះពាល់ដល់ទិន្នផល និងគុណភាពរបស់ដំណាំ ដោយសារតែទំនាក់ទំនងគ្នាទៅវិញទៅមកយ៉ាងស្អិតរមួតទៅនឹងផលិតភាពដីជាមួយស្លេភាពទិន្នផល តាមរយៈសារធាតុចិញ្ចឹមផ្សេងៗដែលទឹកមានសម្រាប់ចិញ្ចឹមដំណាំស្រូវ។ ការបន្សំគ្នាដ៏សមស្របរវាងទឹក និងសារធាតុផ្សេងៗទៀត បានបង្កើននូវផលិតភាពកសិកម្មកាន់តែខ្ពស់ផងដែរ។ យ៉ាងណាមិញ ការប្រើប្រាស់ទឹកនៅក្នុងវិស័យកសិកម្មកម្ពុជានៅមានកម្រិតនិងមិនទាន់មានប្រសិទ្ធភាពនៅឡើយ ដូចនេះតម្រូវឲ្យមានបច្ចេកទេសក្នុងការគ្រប់គ្រងទឹកឲ្យបានល្អ រួមទាំងពង្រីកប្រព័ន្ធធារាសាស្ត្របន្ថែមទៀត ដើម្បីស្រោចស្រពផ្ទៃដីកសិកម្មឲ្យបានគ្រប់គ្រាន់។ មួយវិញទៀត ប្រព័ន្ធទឹកសម្រាប់កសិកម្ម គឺអាស្រ័យលើគុណភាពទឹកដែលអាចប្រើប្រាស់បាន។ ការប្រើប្រាស់យ៉ាងច្រើននូវបរិមាណទឹកដែលមានគុណភាពគ្រប់គ្រាន់មានន័យថា គម្រោងទំនប់ថ្មី និងគម្រោងចាស់ៗដែលស្វែងរកការផ្គត់ផ្គង់ទឹកថ្មីបន្ថែម ដើម្បីចៀសវាងពីបញ្ហានៅពេលប្រើប្រាស់ទឹកដែលមានគុណភាពអន់ គឺត្រូវមានផែនការច្បាស់លាស់ដើម្បីធានាថាគុណភាពទឹកនោះត្រូវបានប្រើប្រាស់ឲ្យអស់លទ្ធភាព និងឲ្យល្អបំផុតតាមវិធីសាស្ត្រផ្សេងៗគ្នា។

**ក. ការគ្រប់គ្រងទឹក**

ស្រូវជាដំណាំត្រូវការទឹកខ្លាំង បើដំណាំស្រូវមិនទទួលបានទឹកគ្រប់គ្រាន់ វានឹងចេញគ្រាប់មិនពេញល្អ។ ការធ្វើឲ្យមានទឹកដក់ជាប់ជាប្រចាំនៅក្នុងស្រែជាមធ្យោបាយមួយ គឺជាការគ្រប់គ្រងទឹកបានល្អដែលអាចជួយបង្កើនផលិតភាពរបស់ដំណាំ រួមទាំងបានកាត់បន្ថយវត្តមានស្មៅចង្រៃ ដែលមានឥទ្ធិពលលើទិន្នផលនិងគុណភាពគ្រាប់ស្រូវ។ ផ្ទុយទៅវិញ ការបង្ហូរទឹកចេញយឺតពេលពេក អាចធ្វើឲ្យពិបាកច្រូតកាត់ដោយស្រូវងាយដួលដើម។ ទន្ទឹមនឹងនេះ ដើម្បីឲ្យមានលទ្ធភាពគ្រប់គ្រងទឹកត្រឹមត្រូវ ដីស្រែត្រូវមានសភាពរាបស្មើនិងមានភ្លឺមាំទាំ ដើម្បីរក្សាទឹកក្នុងស្រែឲ្យមានជម្រៅប្រហាក់ប្រហែលគ្នាធ្វើឲ្យស្រូវដុះលូតលាស់ស្មើៗគ្នា ហើយគ្រាប់ស្រូវដែលទទួលបានមានអត្រាសំណើមស្រដៀងគ្នា។ យ៉ាងណាមិញ តម្រូវការទឹករបស់ដំណាំស្រូវប្រែប្រួលខុសគ្នាទៅតាមវគ្គលូតលាស់របស់ដំណាំ។ ជាក់ស្តែង ដើម្បីបញ្ចូលទឹកនៅពេលស្ទូងស្រូវតាមបច្ចេកទេសទឹកក្នុងស្រែ គួររក្សាទឹកក្នុងកម្រិត ១-៥ ស.ម។ ដំណាក់កាលក្រោយពេលស្ទូង១០ថ្ងៃ ត្រូវរក្សាទឹកក្នុងកម្រិត ៥-១០ ស.ម។ ក្នុងករណីមាន

[30] ក្រសួងធនធានទឹក និងឧតុនិយម, *ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុសម្រាប់ធនធានទឹក(២០១៣-២០១៧)*, ទំព័រ ៧-៨។

ប្រព័ន្ធបញ្ចេញបញ្ចូលទឹកគ្រប់គ្រាន់ នៅក្នុងដំណាក់កាលបែកគុម្ព គួររក្សាទឹកនៅក្នុងស្រែកម្ពស់ប្រមាណ ២-៥ ស.ម។ ក្នុងកំឡុងពេលនៃវគ្គលូតលាស់ កសិករគួរទុកស្រែឲ្យស្ងួតក្នុងរយៈពេលពី ២-៣ថ្ងៃ ទើបបញ្ចូលទឹកជាថ្មី ដើម្បីធ្វើឲ្យប្រព័ន្ធឫសរបស់ស្រូវលូតលាស់ល្អ និងបែកគុម្ពបានច្រើន។[31] ជាទូទៅ ការគ្រប់គ្រងទឹកបានល្អមានសារៈប្រយោជន៍ដូចជា ១)កសិករចំណេញថវិកាដែលត្រូវចំណាយក្នុងការស្រោចស្រព។ ២)កាត់បន្ថយចំណាយលើការធ្វើស្មៅ។ ៣)ដំណាំលូតលាស់បានល្អ បែកគុម្ពច្រើន និងផ្តល់ទិន្នផលខ្ពស់។ ៤)កាត់បន្ថយហានិភ័យក្នុងការខ្វះទឹកដែលអាចធ្វើឲ្យស្រូវស្លក។

**ខ. ការពង្រីកប្រព័ន្ធស្រោចស្រព**

ការគ្រប់គ្រងទឹកសម្រាប់ធ្វើកសិកម្ម ជាពិសេសសម្តៅទៅលើប្រព័ន្ធស្រោចស្រពគឺ កំពុងត្រូវបានជំរុញជាប្រចាំដោយរាជរដ្ឋាភិបាលកម្ពុជា ឲ្យក្លាយទៅជាផែនការសំខាន់មួយក្នុងការបង្កើននូវផលិតភាពកសិកម្មឲ្យកាន់តែរីកចម្រើននិងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច។ បច្ចុប្បន្ន ប្រព័ន្ធស្រោចស្រពដំណាំកសិកម្មនៅប្រទេសកម្ពុជាគឺនៅមិនទាន់គ្រប់គ្រាន់នៅឡើយទេសម្រាប់ធ្វើការដាំដុះជាពិសេសគឺនៅរដូវប្រាំង។ ម៉្យាង ការដាំដុះភាគច្រើនរបស់កសិករនៅមានការពឹងពាក់លើទឹកភ្លៀង ឬគេហៅថាធ្វើស្រែរំពឹងមេឃ បូករួមជាមួយករណីធម្មជាតិដែលជះឥទ្ធិពលអវិជ្ជមានមកលើទិន្នផលស្រូវមានការធ្លាក់ចុះ។ មួយវិញទៀត តំបន់ភាគច្រើនដែលមានប្រព័ន្ធស្រោចស្រពស្រាប់ក្នុងប្រទេសកម្ពុជា គឺសមស្របតែក្នុងរដូវវស្សាប៉ុណ្ណោះ ចំណែកឯរដូវប្រាំងមានការរួមតូចនៃផ្ទៃទឹកសម្រាប់ផ្គត់ផ្គង់កសិកម្ម។ ទោះបីរាជរដ្ឋាភិបាលបានកែលម្អប្រព័ន្ធធារាសាស្ត្រពីមួយឆ្នាំទៅមួយឆ្នាំក៏ដោយ ក៏កសិករនៅតែត្រូវការចំណាយថវិកាសម្រាប់ថ្លៃបូមទឹកដាក់ស្រែដែលនៅឆ្ងាយពីប្រឡាយមេ។ ដូចនេះហើយបានជាតម្រូវឲ្យរាជរដ្ឋាភិបាល អង្គការដែលពាក់ព័ន្ធ ក៏ដូចជាស្ថាប័នក្រៅរដ្ឋាភិបាលទាំងអស់ ព្យាយាមបន្ថែមទៀតក្នុងការវិនិយោគកសាងពង្រីក ស្ថាបនាបន្ថែមនូវប្រព័ន្ធធារាសាស្ត្រឲ្យបានកាន់តែច្រើនរហូតអាចនិយាយបានថាទីណាមានដីស្រែ ទីនោះគឺមានប្រព័ន្ធធារាសាស្ត្រ ដើម្បីបំពេញតម្រូវការដំណាំកសិកម្មក្នុងគោលបំណងចម្បងគឺកាត់បន្ថយចំណាយនៃការបូមទឹកពីប្រឡាយ ដើម្បីធ្វើឲ្យថ្លៃដើមផលិតផលកសិកម្មមានតម្លៃទាប និងទទួលបានទិន្នផលខ្ពស់។ ហេតុដូចនេះហើយ ការកែលម្អនិងវិនិយោគនូវប្រព័ន្ធស្រោចស្រពថ្មីៗនឹងជំរុញផលិតកម្មដំណាំ





[31] នាយកដ្ឋានដំណាំស្រូវនៃអគ្គនាយកដ្ឋានកសិកម្ម, *សៀវភៅបង្គុំបច្ចេកទេសប្រពលវប្បកម្មស្រូវ*, ទំព័រ ៣៣។

កសិកម្មតាមរយៈការដាំដុះពី ២-៣ដង/ឆ្នាំ។ ស្របពេលជាមួយនេះដែរ ការពង្រីកបន្ថែមប្រព័ន្ធធារាសាស្ត្រក៏នឹងជួយទប់ទល់ការប្រែប្រួលអាកាសធាតុ ដែលជាញឹកញាប់បណ្តាលឲ្យមានភាពរាំងស្ងួត ថែមទាំងមានសីតុណ្ហភាពឡើងខ្ពស់។

**គ. ការប្រើប្រាស់ទឹកឲ្យមានប្រសិទ្ធភាពសម្រាប់ការដាំដុះដំណាំ**

ការដាក់ឲ្យប្រើបច្ចេកទេសដែលប្រើប្រាស់ទឹកតិច គឺមានតួនាទីសំខាន់ក្នុងការជួយដំណាំឲ្យរស់រានទៅក្នុងលក្ខខណ្ឌស្ត្រេសបរិស្ថានដូចជា លក្ខខណ្ឌខ្វះខាតទឹកដែលអាចកើតមាននៅរដូវប្រាំងជាដើម។ ការប្រើប្រាស់ប្រព័ន្ធស្រោចស្រពដំណក់ទឹក គឺជាប្រភេទនៃការស្រោចស្រពប្រើប្រាស់ដំណក់ទឹកតូចៗដែលមានសមត្ថភាពសន្សំទឹក និងសារធាតុចិញ្ចឹមដោយអនុញ្ញាតឲ្យទឹកធ្លាក់ជាដំណក់ទឹកយឺតៗទៅប៉ះនឹងឫសរបស់ដំណាំ។ ហើយវិធីសាស្ត្រស្រោចស្រពបែបនេះ មានលក្ខណៈស្រដៀងទៅនឹងភ្លៀងធ្លាក់បែបធម្មជាតិផងដែរ។ គោលដៅសំខាន់នៃប្រព័ន្ធស្រោចស្រពប្រភេទនេះ គឺធ្វើឲ្យដំណក់ទឹកធ្លាក់ចំទៅតំបន់ឫសនិងធ្វើឲ្យកម្រិតរំហួតមានតិចបំផុត សន្សំនៃបរិមាណទឹក ប្រើប្រាស់ឲ្យមានប្រសិទ្ធភាពបំផុត ហើយកាត់បន្ថយការចំណាយថ្លៃបូមទឹក ដែលអាចបណ្តាលមកពីប្រឡាយមេមានទីតាំងនៅឆ្ងាយពីតំបន់ស្រោចស្រព។ ប្រព័ន្ធស្រោចស្រពដំណក់ទឹក គេអាចធ្វើការចែកចាយទឹកបានដោយប្រើប្រាស់បំពង់បង្ហូរទឹក ដែលមានប្រព័ន្ធបើកបិទទឹក ទុយោទឹកតូចៗ និងសម្ភារៈចែកចាយទឹកផ្សេងៗទៀត រួចភ្ជាប់ទៅនឹងឧបករណ៍សម្រាប់ស្រោចស្រពផ្សេងៗដូចជា ឧបករណ៍ដែលមានក្បាលរបស់វាអាចវិលបានជាដើម។ ។ ប្រព័ន្ធនេះមានប្រសិទ្ធភាព គឺវាអាស្រ័យទៅលើការរៀបចំ ការបំពាក់ ការថែរក្សា និងការដំណើរការដែលភាគច្រើនប្រើប្រាស់នៅក្នុងប្រទេសដែលមានបច្ចេកទេសខ្ពស់ និងមានប្រភពទឹកតិច។ ប្រព័ន្ធធារាសាស្ត្រប្រភេទនេះ អាចប្រើប្រាស់បានចំពោះប្រភេទដំណាំ សណ្ឋានដី និងប្រភេទដីជាច្រើនប្រភេទ ជាពិសេសវាមានប្រសិទ្ធភាពខ្ពស់ទៅលើប្រភេទដំណាំបែបបន្លែ ផ្លែឈើ និងជាពិសេសគឺផលិតកម្មដំណាំស្រូវ ដោយសារតែវាបានស្រោចស្រពទៅលើដំណាំមួយដើមៗ និងគុណសម្បត្តិរបស់វាគឺការប្រើប្រាស់ទឹកដោយមានការបាត់បង់ក្នុងកម្រិតតិចតួចបំផុត ព្រមទាំងទទួលបាននូវទិន្នផលខ្ពស់ទៀតផង។





### ៣.២.១.៣ ជីកសិកម្ម

ជីជាសារធាតុចិញ្ចឹមសំខាន់របស់ដំណាំស្រូវ ដូច្នេះដើម្បីលូតលាស់បាននិងផ្តល់ផ្លែផ្កាបានល្អ ស្រូវត្រូវការសារធាតុចិញ្ចឹមគ្រប់គ្រាន់ទៅតាមតម្រូវការរបស់វា។ ការទទួលបានជីជាតិមិនស្មើគ្នា អាចធ្វើឲ្យដើមស្រូវលូតលាស់និងបែកគុម្ពមិនស្មើគ្នា ហើយបណ្តាលឲ្យគ្រាប់ស្រូវទុំក៏មានទំហំនិងសំណើមមិនស្មើគ្នាដែរ។ ការផ្តល់ជីកសិកម្មដែលមានជីជាតិយឺតពេលនិងមិនគ្រប់គ្រាន់អាចធ្វើឲ្យស្រូវលូតលាស់យឺត ហើយមិនងាយទុំដែលនាំឲ្យទទួលរងផលប៉ះពាល់ពីលក្ខខណ្ឌធម្មជាតិមិនគាប់ប្រសើរដូចជា មានភ្លៀងធ្លាក់ខ្លាំងពេក ឬមានទឹកដក់ច្រើនក្នុងស្រែនៅពេលច្រូតកាត់ជាដើម។ ជាក់ស្តែង នៅក្នុងផលិតកម្មដំណាំស្រូវ ជីកសិកម្មដែលត្រូវបានប្រើគឺមាន ជីធម្មជាតិនិងជីគីមី។ ការប្រើប្រាស់ជីធម្មជាតិតែមួយប្រភេទ មិនអាចផ្តល់សារធាតុចិញ្ចឹមគ្រប់គ្រាន់ឲ្យស្រូវបានទេ ផ្ទុយទៅវិញការប្រើប្រាស់ជីគីមីតែមួយប្រភេទ វាមានលទ្ធភាពផ្តល់សារធាតុចិញ្ចឹមជាច្រើនទៅឲ្យស្រូវ ប៉ុន្តែក្នុងពេលតែមួយ វាក៏បានបំផ្លាញដីនិងធ្វើឲ្យដីបាត់បង់ជីជាតិទៀតផង។

#### ក. ជីធម្មជាតិ

ជីធម្មជាតិរួមមាន ជីកំប៉ុសនិងជីបៃតង។ ជីទាំងនេះមានគុណប្រយោជន៍ប្រើប្រាស់សំខាន់ក្នុងគោលបំណងសម្រាប់កែលម្អទាំងជីជាតិដី និងបង្កើនទិន្នផលស្រូវ ប៉ុន្តែចំពោះជីជាតិវិញ វាមានកម្រិតតិច ដូច្នេះគេត្រូវប្រើវាក្នុងបរិមាណច្រើន។ ជាការចាំបាច់ កសិករត្រូវមានរោងសន្សំជីធម្មជាតិនៅតាមផ្ទះនីមួយៗដែលអាចផ្សំពីលាមកសត្វ ទឹកនោមសត្វ កាកសំណល់ផ្ទះបាយ កាកសំណល់រុក្ខជាតិ ព្រមទាំងកាកសំណល់ចំណីសត្វនិងផេះ ដែលនេះជារោងចក្រផលិតជីកំប៉ុសនៅតាមគ្រួសារដោយចំណាយទុនតិច ប៉ុន្តែទទួលបានផលច្រើន។ ជីធម្មជាតិដែលទទួលបានពីឡជីវឧស្ម័ន គឺមានគុណភាពល្អនិងបានសម្លាប់មេរោគបង្កជម្ងឺ ព្រមទាំងស្មៅដែលអាចប៉ះពាល់ដល់ស្រូវទៀតផង។ ដូច្នេះ ប្រជាកសិករដែលមានលទ្ធភាព គួរយកចិត្តទុកដាក់នៅក្នុងការកសាងឡជីវឧស្ម័នតាមគ្រួសារ ពីព្រោះវាបានផ្តល់ប្រយោជន៍ច្រើន គឺអាចសន្សំជីធម្មជាតិបានច្រើន និងមានគុណភាពខ្ពស់ ដែលធ្វើឲ្យបរិស្ថានជុំវិញផ្ទះស្អាតនិងមានអនាម័យ។



សម្រាប់ជីកំប៉ុស ត្រូវការវត្ថុធាតុដើមដូចជា ផេះ កាកសំណល់ចំណីសត្វ កាកសំណល់ផ្ទះសម្ល្បែង និងស្រែចម្ការ ហើយវត្ថុធាតុដើមដែលសំខាន់ជាងគេនោះគឺ លាមកសត្វគោ ក្របី មាន់ទា ជ្រូក ពីព្រោះលាមកសត្វផ្តល់សារធាតុ N យ៉ាងច្រើនសម្រាប់បង្កើនគុណភាពទៅដល់ជីកំប៉ុស។ ជាមធ្យម គោធំ



មួយក្បាលអាចផ្តល់លាមកចន្លោះពី ១០-១២ គ.ក្រ ក្នុងមួយថ្ងៃ និងប្រហែល ៤ តោនក្នុងមួយឆ្នាំ។ ដូច្នេះ គោធំមួយនឹមអាចផ្តល់ជីកំប៉ុសបាន ១២ តោនក្នុងមួយឆ្នាំ។[32] ផេះឬកំបោរផូស្វាត ជួយបន្ថែមសារធាតុរ៉ែដល់ជីកំប៉ុសឲ្យឆាប់រលួយបានល្អ ព្រមទាំងជួយបន្ថយជាតិអាស៊ីត បង្កលក្ខណៈងាយស្រួលក្នុងការប្រើប្រាស់ទៀតផង។ ចំពោះការប្រើប្រាស់ជីកំប៉ុសវិញ គេគប្បីគួរប្រើជាស្រទាប់បាតនៅក្នុងបរិមាណជីពី ៥-១០ ត/ហ.ត ដោយភ្ជួរលប់ភ្លាមក្រោយពេលដាក់ជីរួច ដើម្បីចៀសវាងការបាត់បង់សារធាតុចិញ្ចឹម។ កសិករក៏អាចប្រើប្រាស់ជីកំប៉ុសសម្រាប់ដាក់បំប៉នដំណាំស្រូវនៅក្នុងដំណាក់កាលលូតលាស់ផងដែរ។

ចំណែកឯជីបៃតង គឺជាការអនុវត្តនៃការដាំ និងភ្ជួរលប់ដំណាំបៃតងជាមួយដី ដើម្បីកែលម្អនូវជីជាតិរបស់ដី និងផលិតភាពដី។ ជីបៃតងមានប្រសិទ្ធភាពទៅលើដីនិងដំណាំ ប្រហាក់ប្រហែលនឹងជីកំប៉ុសដែរ។ វាមានតម្លៃថោក ហើយជាមធ្យោបាយដ៏ល្អបំផុតក្នុងការបង្កើនជីជាតិដី ដោយសារតែវាអាចជំនួសជីកាកសំណល់កសិដ្ឋាន និងជីសរីរាង្គ ដោយមិនចំណាយថ្លៃខ្ពស់។ ជីបៃតង បានផ្តល់ជាតិ N និងសារធាតុសរីរាង្គដល់ដីចាំបាច់ក្នុងការបង្កើនទិន្នផលដំណាំ។ តាមរយៈការធ្វើជីបៃតង គេអាចទទួលបាននូវសារធាតុរ៉ែសម្រាប់ដំណាំ កាត់បន្ថយការបាត់បង់សារធាតុសរីរាង្គរបស់ដីដោយសារតែការហូរច្រោះ និងការលិចជ្រាប។ ការប្រើប្រាស់ជីបៃតង ក៏អាចជួយលក្ខខណ្ឌខ្យល់ និងការបង្ហូរទឹកទៅក្នុងដីបានល្អ។ វត្ថុធាតុដើមសម្រាប់ធ្វើជីបៃតងរួមមាន សំរាម ស្លឹកឈើកម្ទេចកម្ទីរុក្ខជាតិដែលនៅជុំវិញផ្ទះនិងស្រែចម្ការ ទន្ទ្រានខែត្រ សណ្តែកបាយ ដែលគេចិញ្ច្រាំជាតូចៗមុននឹងដាក់ក្នុងស្រែ។ ចំពោះគល់ជញ្ជ្រាំង គឺជាប្រភពជីធម្មជាតិដ៏សំខាន់សម្រាប់ទ្រទ្រង់ជីជាតិដី ហេតុនេះ កសិករមិនត្រូវដុតគល់ជញ្ជ្រាំងចោលទេដោយត្រូវភ្ជួរលប់គល់ជញ្ជ្រាំងនៅក្រោយពេលប្រមូលផលស្រូវរួច។ កសិករភាគច្រើនមិនបានភ្ជួរលប់គល់ជញ្ជ្រាំងក្រោយពេលប្រមូលផលឡើយ គឺទុករហូតដល់មានភ្លៀងធ្លាក់នៅខែ ឧសភា ទើបភ្ជួរលប់ ហើយខ្លះទៀតដុតគោលជញ្ជ្រាំងចោលតែម្តង។ ការធ្វើបែបនេះ ជញ្ជ្រាំងមួយចំណែកធំត្រូវបាត់បង់ ជាហេតុនាំឲ្យប៉ះពាល់ដល់ជីជាតិរបស់ដី។ ហើយការប្រើជីធម្មជាតិជាមូលដ្ឋាន ផ្តល់អត្ថប្រយោជន៍ដូចខាងក្រោម ១)ធ្វើឲ្យដីធូរ និងបង្កើនសមត្ថភាពចាប់ទឹក ព្រមទាំងអាចរក្សាសារធាតុចិញ្ចឹមក្នុងដីបានយូរ។ ២)កសិករអាចកាត់បន្ថយចំណាយលើការទិញជីគីមី។ ៣)កាត់បន្ថយការប្រើប្រាស់ជីគីមីដែលគេជឿថា អាចធ្វើឲ្យប៉ះពាល់ទៅដល់បរិស្ថាន ជាពិសេសគឺការប្រែប្រួលអាកាសធាតុ។ ៤)ដំណាំស្រូវលូតលាស់បានល្អ ផ្តល់ទិន្នផលខ្ពស់។

---

[32] បណ្ណាល័យកសិកម្ម, *បង្កើនជីជាតិដីឲ្យកាន់តែល្អប្រសើរ*, ទំព័រ ១១។

**ខ. ជីគីមី**



កសិករក៏អាចប្រើប្រាស់ជីគីមីបន្ថែម នៅក្នុងករណីការផ្តល់ជីធម្មជាតិមិនគ្រប់គ្រាន់ ទៅតាមតម្រូវការរបស់ដំណាំស្រូវ។ ដើម្បីឲ្យការប្រើប្រាស់ជីគីមីប្រកបដោយប្រសិទ្ធភាព ស្ថាប័នដែលពាក់ព័ន្ធ គប្បីត្រូវតែផ្សព្វផ្សាយឲ្យបានច្បាស់ពីវិធីសាស្ត្រនៃការប្រើប្រាស់។ មួយវិញទៀតរាល់ជីគីមីដែលត្រូវបានលក់ទាំងអស់នៅក្នុងទីផ្សារ ត្រូវតែមានសរសេរជាភាសាខ្មែរទាំងស្លាកសញ្ញាណែនាំ វិធីប្រើប្រាស់ និងស្លាកសញ្ញាឈ្មោះផលិតផល ដើម្បីចៀសវាងការប្រើប្រាស់ខុសបច្ចេកទេសដែលវានឹងជំរុញឲ្យទិន្នផលស្រូវធ្លាក់ចុះ ដីបាត់បង់ជីជាតិ ប៉ះពាល់ដល់សុខភាព និងបរិស្ថានជាដើម។ ការប្រើប្រាស់ជីគីមី គឺត្រូវអនុវត្តតាមបច្ចេកទេសត្រឹមត្រូវ ដោយបាចជីដែលមានសារធាតុចិញ្ចឹមប្រភេទ P ជាជីទ្រាប់បាតឬបំប៉នលើកទី១ ក្រោយស្ទូងចំនួន ១០-១៥ថ្ងៃ ហើយសារធាតុចិញ្ចឹមប្រភេទ N និង K ជាជីបំប៉ន នៅដំណាក់កាលបែកគុម្ព និងនៅដំណាក់កាលកកើតកួរស្រូវ។ ចំពោះបរិមាណដែលត្រូវប្រើ គឺប្រែប្រួលអាស្រ័យតាមលក្ខខណ្ឌជីជាតិដី និងស្ថានភាពលូតលាស់របស់ដំណាំស្រូវដោយបានណែនាំពីសំណាក់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI)។ ចំពោះការបាចជីគីមីគឺមានប្រសិទ្ធភាពល្អ និងត្រូវគោរពតាមលក្ខខណ្ឌដូចជា៖

១) ត្រូវប្រើប្រាស់ជីឲ្យបានត្រឹមត្រូវតាមដំណាក់កាលនីមួយៗដែលស្រូវត្រូវការ។

២) ត្រូវបាចជីមុនពេលស្ទូងដោយបង្កប់ជីឲ្យចូលទៅក្នុងដី មិនត្រូវបង្ហើរជីដោយមិនបង្កប់វាទេឬមិនត្រូវបាចជីក្នុងទឹកក្រោយពីស្ទូងរួចភ្លាមទេ។

៣) ការបាចជីដែលល្អ គឺត្រូវឲ្យស្រែមានជម្រៅទឹក ៥ ស.ម។

៤) ការប្រើប្រាស់ជីត្រូវគិតគូរពីតុល្យភាព N P និង K ហើយប្រើបរិមាណជីឲ្យបានគ្រប់គ្រាន់ នោះគេនឹងទទួលបានស្រូវមានដើមបែកគ្រាប់ល្អ និងទិន្នផលខ្ពស់។

៥) ចៀសវាងបាចជីនៅពេលដើមស្រូវនៅសើម ហើយក៏មិនត្រូវបាចជីពេលភ្លៀងខ្លាំងដែរ។

ត្រូវចងចាំថា ការប្រើប្រាស់ជីធម្មជាតិធ្វើឲ្យគុណភាពដីកាន់តែល្អប្រសើរពីមួយឆ្នាំទៅមួយឆ្នាំ ហើយធ្វើឲ្យដីមានជីវិតនិងសម្បូរជីជាតិ។ ប៉ុន្តែផ្ទុយទៅវិញ បើយើងប្រើជីគីមី ដោយគ្មានការប្រើជីធម្មជាតិលាយផ្សំក្នុងកម្រិតច្រើន រយៈពេលយូរនឹងធ្វើឲ្យដីខូចគុណភាព ព្រមទាំងទិន្នផលស្រូវមានការថយចុះទៀតផង។ ម្យ៉ាងទៀត ការដាក់ជីមិនគ្រប់គ្រាន់តាមតម្រូវការរបស់ស្រូវ នឹងធ្វើឲ្យដំណាំស្រូវលូតលាស់ខ្សោយ ឆាប់ទទួលរងការបំផ្លិច

បំផ្លាញពីសមាសភាពចង្រៃដូចជា ស្មៅ និងសត្វល្អិតជាដើម។ យ៉ាងណាមិញ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានលើកទឹកចិត្តឲ្យប្រជាកសិករប្រើប្រាស់នូវជីធម្មជាតិឲ្យបានច្រើន ដោយសារតែជីធម្មជាតិមានប្រសិទ្ធភាពខ្ពស់ទាំងសម្រាប់បង្កើនផលិតភាពដី ងាយស្រួលក្នុងការផលិត មិនប៉ះពាល់ដល់បរិស្ថាននិងសុខភាព ដែលសុទ្ធសឹងជាកត្តាជំរុញឲ្យថ្លៃដើមផលិតកម្មកសិកម្មធ្លាក់ចុះ អាចប្រកួតប្រជែងក្នុងទីផ្សារទាំងក្នុងនិងក្រៅស្រុកជាមួយនឹងតម្លៃល្អប្រសើរ។

### ៣.២.១.៤ ផលិតភាពគ្រាប់ពូជ

ដើម្បីឆ្លើយតបឲ្យបាននូវទិសដៅគោលនយោបាយ ស្តីពីការជំរុញផលិតកម្មដំណាំស្រូវនិងការនាំចេញអង្ករដែលត្រូវបានប្រកាសដាក់ឲ្យអនុវត្តពីថ្ងៃទី ៧ ខែសីហា ឆ្នាំ២០១០ កន្លងទៅនេះ ពីសំណាក់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសង្កត់ធ្ងន់ទៅលើ "ការបង្កើនផលិតភាពដំណាំស្រូវ ជាពិសេសប្រពលវប្បកម្មដំណាំស្រូវ និងពិពិធភាវូបនីយកម្ម" ដែលនេះគឺជាចំណុចគន្លឹះក្នុងការយកចិត្តទុកដាក់លើការបង្កើតសេវាកម្មនិងអន្តរាគមន៍នានា ដើម្បីជួយដល់ការបង្កើនផលិតផលស្រូវ ការផ្ទេរបច្ចេកទេសសមស្របដល់កសិករ ជាពិសេសគឺការដាក់ចេញនូវគ្រាប់ពូជស្រូវដែលមានផលិតភាព រួមទាំងគុណភាពខ្ពស់ផងដែរ។ ជាក់ស្តែង ដើម្បីសម្រេចបាននូវគោលនយោបាយមួយនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានដាក់ចេញនូវពូជស្រូវ ដែលមានផលិតភាពនិងគុណភាពអង្ករខ្ពស់ចំនួន ១០ ពូជដែលក្នុងនោះរួមមានៈ

- ពូជស្រូវស្រាលដែលមិនប្រកាន់រដូវមានចំនួន ៣ ពូជគឺពូជសែនពិដោរ ពូជអ៊ីអ៊ែរ៦៦ និងពូជជលសារ
- ពូជស្រូវកណ្តាលប្រកាន់រដូវមានចំនួន ៤ ពូជគឺពូជផ្ការំដួល ពូជផ្ការំដេង ពូជផ្ការមៀត និងពូជផ្កាច័ន្ទសែនសរ
- ពូជស្រូវធ្ងន់ប្រកាន់រដូវមានចំនួន ៣ ពូជគឺពូជរាំងជ័យ ពូជខា៤ និងពូជខា៦។[33]

### ក. ពូជស្រូវស្រាលមិនប្រកាន់រដូវ

ពូជស្រូវស្រាលមិនប្រកាន់រដូវ គឺជាពូជស្រូវដែលមានអាយុកាលលូតលាស់ប្រមាណតែ ១២០ ថ្ងៃហើយត្រូវបានគេដាំដុះនៅលើផ្ទៃដីប្រហែលជា ២០% នៃផ្ទៃដីទំនាបដែលមានវិសាលភាពធំជេងជាងគេបំផុតគឺនៅវាលទំនាបជុំវិញបឹងទន្លេសាប ទន្លេមេគង្គ និងទន្លេបាសាក់ ដែលជាទំនាបសម្រាប់ដំណាំស្រូវមានទឹកដក់ និងមានប្រភពទឹកគ្រប់គ្រាន់។ ក្នុងពេលថ្មីៗនេះ កសិករភាគច្រើនបានដាំពូជទាំងនេះនៅដើមរដូវវស្សា។ បន្ទាប់ពីប្រមូលផលហើយ ពួកគាត់អាចដាំពូជស្រូវកណ្តាលនិងពូជស្រូវធ្ងន់បានទៀត។ នៅតំបន់ផ្សេងទៀត កសិករបានដាំវានៅពេលទឹកស្រក ដូច្នេះពូជទាំងនេះត្រូវបានគេហៅថា ពូជស្រូវប្រដេញទឹក។

---

[33] អគ្គនាយកដ្ឋានកសិកម្ម, *ពូជស្រូវសំខាន់ៗសម្រាប់ផលិតកម្មស្រូវនិងអង្ករនាំចេញ*, ទំព័រ ១។

**ក.១ ពូជស្រូវសែនពិដោរ**

ពូជស្រូវសែនពិដោរ ជាប្រភេទពូជស្រូវស្រាលនិងជាពូជស្រូវក្រអូប ដែលបានបញ្ចេញនិងផ្សព្វផ្សាយឲ្យកសិករប្រើប្រាស់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅដើមឆ្នាំ២០០២ ហើយមកដល់ពេលនេះ ពូជស្រូវសែនពិដោរកំពុងត្រូវបានប្រើប្រាស់ក្នុងផលិតកម្មដំណាំស្រូវដោយប្រជាកសិករនៅទូទាំងប្រទេស។ ពូជនេះមានផលិតភាពខ្ពស់ មានក្លិនក្រអូប មានគុណភាពអង្ករល្អ ហើយជាពូជមានប្រភេទអង្ករមានតម្លៃខ្ពស់ក្នុងទីផ្សារជាតិនិងអន្តរជាតិ។ ពូជសែនពិដោរ ជាប្រភេទពូជស្រូវមិនប្រកាន់រដូវ ដែលអាចដាំនៅគ្រប់រដូវកាលទាំងអស់ ជាពិសេសដើមរដូវវស្សា ស្រូវប្រដេញទឹក និងស្រូវរដូវប្រាំង។ ពូជនេះមានអាយុកាលចាប់ពីថ្ងៃសាបរហូតដល់ពេលច្រូតកាត់ប្រហែល ១១០-១២០ថ្ងៃ មានកម្ពស់ដើមពី ៩៥-១១០ស.ម ចំនួនដើមបែកផ្តល់ផលពី ៥-២០ដើមក្នុង១គុម្ព ប្រវែងកួរពី ២០-៣០ស.ម និងចំនួនគ្រាប់ក្នុង១កួរមានពី ១១០-១៧០គ្រាប់។ ពូជសែនពិដោរជាប្រភេទពូជមិនធន់នឹងមមាចត្នោត ហើយមានទិន្នផលពី ៣.៥-៥.៥ ត/ហ.ត ហើយបើស្ថិតក្នុងលក្ខខណ្ឌអំណោយផលល្អ (មានប្រព័ន្ធស្រោចស្រពគ្រប់គ្រាន់ ផ្តល់ជីជាតិដល់ដីដែលធ្វើឲ្យដីមានផលិតភាពល្អ ផ្គត់ផ្គង់ជីទៅតាមតម្រូវការរបស់ស្រូវគ្រប់គ្រាន់) នោះវាអាចផ្តល់ទិន្នផលរហូតដល់ទៅ ៨-១០ ត/ហ.ត។

**ក.២ ពូជស្រូវអ៊ីអ៊ែរ៦៦**

ពូជស្រូវអ៊ីអ៊ែរ៦៦ ជាប្រភេទពូជស្រូវស្រាលដែលបានបញ្ចេញនិងផ្សព្វផ្សាយឲ្យកសិករ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅដើមឆ្នាំ១៩៩០ ហើយមកដល់ពេលបច្ចុប្បន្ននេះ ពូជស្រូវប្រភេទនេះ កំពុងប្រើប្រាស់ក្នុងផលិតកម្មស្រូវរដូវប្រាំង និងស្រូវស្រាលដើមរដូវវស្សា នៅទូទាំងប្រទេស។ ពូជនេះមានផលិតភាពខ្ពស់ មានគុណភាពអង្ករល្អ និងជាពូជមានប្រភេទអង្ករអាចលក់បានខ្ពស់នៅក្នុងទីផ្សារជាតិនិងអន្តរជាតិ។ ពូជអ៊ីអ៊ែរ៦៦ ជាប្រភេទពូជស្រូវមិនប្រកាន់រដូវដែលគេអាចដាំដុះបាននៅគ្រប់រដូវ។ ពូជនេះមានអាយុកាលចាប់ពីពេលសាបរហូតដល់ពេលច្រូតកាត់ពី ១០៥-១១៥ថ្ងៃ មានកម្ពស់ដើមពី ៨០-១១៨ស.ម ចំនួនដើមបែកផ្តល់ផលពី ១២-១៨ដើមក្នុង១គុម្ព មានប្រវែងកួរពី ២៥-២៦ស.ម និងចំនួនគ្រាប់ក្នុងកួរមានពី ១០០-១២០គ្រាប់។ ពូជស្រូវនេះ ជាប្រភេទពូជមិនធន់នឹងមមាចត្នោតទេ ហើយមានទិន្នផលពី ៤.៥-៦.៥ ត/ហ.ត បើស្ថិតក្នុងលក្ខខណ្ឌអំណោយផលល្អ និងអនុវត្តតាមប្រព័ន្ធប្រពលវប្បកម្មស្រូវ វាអាចផ្តល់ទិន្នផលស្រូវបានរហូតទៅដល់ ៨-១០ ត/ហ.ត។

**ក.៣ ពូជស្រូវជលសារ**

ពូជស្រូវជលសារ ជាប្រភេទពូជស្រូវដែលបានបញ្ចេញនិងផ្សព្វផ្សាយឲ្យកសិករប្រើប្រាស់ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅដើមឆ្នាំ១៩៩៩ ហើយត្រូវបានកំពុងប្រើប្រាស់នៅក្នុងផលិតកម្មដំណាំស្រូវនៅរដូវប្រាំង និងស្រូវស្រាលដើមរដូវវស្សាដោយកសិករនៅទូទាំងប្រទេសពេលបច្ចុប្បន្ន។ ពូជស្រូវប្រភេទនេះ

មានផលិតភាពខ្ពស់ មានគុណភាពអង្ករល្អ និងជាពូជដែលមានបាយទន់ឆ្ងាញ់។ ពូជស្រូវនេះ មានអាយុកាលចាប់ពីថ្ងៃសាប រហូតដល់ថ្ងៃច្រូតកាត់ពី ៩៥-១១៥ថ្ងៃ មានកម្ពស់ដើមពី ៧៥-៩៥ស.ម ចំនួនដើមបែកផ្តល់ផលពី ១០-១៥ដើមក្នុង១គុម្ព ប្រវែងកួរស្រូវមានពី ២០-២៧ស.ម និងចំនួនគ្រាប់ក្នុង ១កួរមានពី ១០០-១៥០គ្រាប់។ ពូជស្រូវជលសារ ជាប្រភេទពូជមិនធន់នឹងសត្វមមាចត្នោត ហើយមានទិន្នផលពី ៤.០-៦.០ ត/ហ.ត ហើយប្រសិនបើស្ថិតក្នុងលក្ខខណ្ឌអំណោយផលល្អ រួមជាមួយការដាំដុះបែបប្រពលវប្បកម្មដំណាំស្រូវ នោះទិន្នផលស្រូវអាចទទួលបរិមាណពី ៧.០-៨.០ ត/ហ.ត។

**ខ. ពូជស្រូវកណ្តាលប្រកាន់រដូវ**

ពូជស្រូវកណ្តាលប្រកាន់រដូវ ត្រូវបានគេដាំដុះនៅតំបន់ទំនាបមធ្យម ដែលជាដីទំនាបសម្រាប់ដំណាំស្រូវនៅចន្លោះរវាងទំនាបខ្ពស់ និងទំនាបទាបដែលសមស្របនឹងការលូតលាស់ដំណាំស្រូវ ព្រមទាំងគ្របដណ្តប់ប្រមាណជា ៤០% នៃផ្ទៃដីដាំដុះ។ ពូជស្រូវកណ្តាលប្រកាន់រដូវនេះ ចេញផ្កាចន្លោះពាក់កណ្តាលខែតុលាដល់ពាក់កណ្តាលខែវិច្ឆិកានៃឆ្នាំ។[34]

**ខ.១ ពូជស្រូវក្រអូបផ្ការំដួល**

ពូជផ្ការំដួល ជាពូជក្រអូបដែលបានបញ្ចេញ និងផ្សព្វផ្សាយឲ្យកសិករប្រើប្រាស់នៅឆ្នាំ ១៩៩៩ ហើយបច្ចុប្បន្ននេះ ពូជស្រូវនេះកំពុងពេញនិយមក្នុងផលិតកម្មស្រូវវស្សាដោយកសិករនៅទូទាំងប្រទេស។ ពូជនេះមានផលិតភាពខ្ពស់ មានក្លិនក្រអូប គុណភាពអង្ករល្អ ជាពិសេសជាពូជមានប្រភេទអង្ករមានតម្លៃខ្ពស់នៅក្នុងទីផ្សារជាតិ និងអន្តរជាតិ។ ពូជស្រូវផ្ការំដួល ជាប្រភេទពូជស្រូវកណ្តាលដែលប្រកាន់រដូវ និងជាមធ្យមចាប់ចេញផ្កានៅពាក់កណ្តាលខែតុលា និងច្រូតកាត់នៅពាក់កណ្តាលខែវិច្ឆិកា អាស្រ័យតាមអាកាសធាតុ និងពេលវេលាដាំដុះ។ ពូជនេះមានកម្ពស់ដើមពី ១១០-១៧០ ស.ម ចំនួនដើមបែកគុម្ពផ្តល់ផលពី ៥-១០ ដើមក្នុង១គុម្ព ប្រវែងកួរស្រូវមានពី ២០-៣០ ស.ម និងមានចំនួនគ្រាប់ក្នុង១កួរមានពី ១១០-១៥០ គ្រាប់។ ពូជផ្ការំដួលជាប្រភេទពូជធន់នឹងការលិចទឹកជំនន់តែវាមិនសូវធន់នឹងសត្វមមាចទេ ហើយបើស្ថិតក្នុងលក្ខខណ្ឌដីមានជីជាតិល្អ និងអនុវត្តតាមប្រពលវប្បកម្មដំណាំស្រូវ ទិន្នផលអាចមានពី ៣.៥-៥.៥ ត/ហ.ត។

**ខ.២ ពូជស្រូវក្រអូបផ្ការំដេង**

ពូជផ្ការំដេងជាពូជស្រូវក្រអូបដែលបានបញ្ចេញ និងផ្សព្វផ្សាយឲ្យប្រជាកសិករប្រើប្រាស់នៅឆ្នាំ ២០០៦ ហើយពេលបច្ចុប្បន្ននេះ កំពុងពេញនិយមប្រើប្រាស់ដោយកសិករនៅទូទាំងប្រទេស។ ពូជនេះមានផលិតភាពខ្ពស់ មានក្លិនក្រអូប មានគុណភាពអង្ករល្អ និងជាពិសេសជាពូជស្រូវមានតម្លៃខ្ពស់នៅក្នុងទីផ្សារជាតិ និងអន្តរ

[34] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *ការជ្រើសរើសពូជស្រូវសម្រាប់ការដាំដុះតំបន់ទំនាបទឹកភ្លៀង*, ទំព័រ ៤។

ជាតិ។ ពូជផ្ការំដេង ជាប្រភេទពូជស្រូវកណ្តាលប្រកាន់រដូវមធ្យមចាប់ចេញផ្កានៅពាក់កណ្តាលខែតុលា និងច្រូតកាត់នៅពាក់កណ្តាលខែវិច្ឆិកា អាស្រ័យតាមអាកាសធាតុ និងពេលវេលាដាំដុះ។ ពូជនេះមានកម្ពស់ដើមពី ១០០-១៧៥ ស.ម ចំនួនដើមបែកផ្តល់ផលពី ៨-២០ ដើមក្នុង១គុម្ព ប្រវែងកួរមានពី ២០-៣០ ស.ម និងចំនួនគ្រាប់ក្នុង១កួរមានចំនួនពី ១១០-១៥០ គ្រាប់។ ពូជផ្ការំដួល ជាប្រភេទពូជធន់នឹងទឹកជំនន់តែវាមិនសូវធន់នឹងសត្វមមាចត្នោតទេ ហើយបើមានលក្ខខណ្ឌដីមានជីជាតិល្អ វានឹងអាចផ្តល់ទិន្នផលពី ៣.៥-៥.៨ ត/ហ.ត។

**ខ.៣ ពូជស្រូវក្រអូបផ្ការមៀត**

ពូជផ្ការមៀតជាពូជស្រូវក្រអូបដែលបានបញ្ចេញ និងផ្សព្វផ្សាយឲ្យប្រជាកសិករប្រើប្រាស់នៅឆ្នាំ ២០០៦ ហើយពេលបច្ចុប្បន្ននេះ កំពុងពេញនិយមប្រើប្រាស់ដោយប្រជាកសិករនៅទូទាំងប្រទេសកម្ពុជា។ ពូជស្រូវប្រភេទនេះមានផលិតភាពខ្ពស់ មានក្លិនក្រអូប មានគុណភាពអង្ករល្អ និងជាពិសេសជាពូជស្រូវដែលមានតម្លៃខ្ពស់ទាំងក្នុងទីផ្សារជាតិ និងអន្តរជាតិ។ ពូជនេះ ជាប្រភេទពូជស្រូវកណ្តាលប្រកាន់រដូវមធ្យមចាប់ចេញផ្កាពីថ្ងៃ ១៥-២៥ ខែតុលា និងច្រូតកាត់នៅពាក់កណ្តាលទៅចុងខែវិច្ឆិកា។ ពូជនេះមានកម្ពស់ដើមពី ១០០-១៥០ ស.ម ចំនួនបែកគុម្ពផ្តល់ផល ៨-១៨ដើមក្នុង១គុម្ព មានប្រវែងកួរពី ២០-៣០ ស.ម និងចំនួនគ្រាប់នៅក្នុង ១កួរមាន ១១០-១៥០គ្រាប់។ ពូជផ្ការមៀតជាប្រភេទពូជធន់នឹងទឹកលិច និងទឹកជំនន់ក្នុងរយៈពេលមធ្យមតែមិនសូវធន់នឹងមមាចត្នោតប៉ុន្មានទេ ហើយបើសិនដីមានលក្ខខណ្ឌមានជីជាតិល្អ និងអនុវត្តតាមប្រព័ន្ធប្រពលវប្បកម្ម នោះគេអាចបានផលពី ៣.៥-៥.៨ ត/ហ.ត។

**ខ.៤ ពូជស្រូវកណ្តាលផ្កាច័ន្ទសែនសរ**

ពូជផ្កាច័ន្ទសែនសរ ជាពូជស្រូវដែលបានបញ្ចេញ និងផ្សព្វផ្សាយឲ្យប្រជាកសិករប្រើប្រាស់នៅឆ្នាំ ២០០៩ ហើយពេលបច្ចុប្បន្ននេះ កំពុងពេញនិយមប្រើប្រាស់នៅទូទាំងប្រទេស។ ពូជនេះមានផលិតភាពខ្ពស់ មានក្លិនក្រអូប មានគុណភាពអង្ករល្អ និងជាពិសេសជាពូជស្រូវមានតម្លៃខ្ពស់ក្នុងទីផ្សារជាតិ និងអន្តរជាតិ។ ពូជផ្កាច័ន្ទសែនសរ ជាប្រភេទពូជស្រូវកណ្តាលប្រកាន់រដូវមធ្យមចាប់ចេញផ្កានៅចុងខែតុលាដល់ដើមខែវិច្ឆិកានិងច្រូតកាត់នៅដើមខែធ្នូ។ ពូជនេះមានកម្ពស់ពី ១៥០-១៦០ ស.ម ចំនួនដើមបែកផ្តល់ផល ៧-១០ដើមក្នុង១គុម្ព មានប្រវែងកួរពី ២០-៣០ ស.ម និងមានចំនួនគ្រាប់ក្នុង១កួរពី ១៦៩-២៣៣គ្រាប់។ បើមានលក្ខខណ្ឌដីល្អ រួមជាមួយការអនុវត្តតាមប្រព័ន្ធប្រពលវប្បកម្ម នោះគេនឹងអាចទទួលបានទិន្នផលស្រូវពី ៣.៥-៥.០ ត/ហ.ត។

**គ. ពូជស្រូវធ្ងន់ប្រកាន់រដូវ**

ស្រូវធ្ងន់គឺជាស្រូវដែលមានអាយុកាលលូតលាស់វែង និងចេញផ្កានៅពាក់កណ្តាលខែវិច្ឆិកានៃឆ្នាំ។ គេដាំវានៅវាលទំនាបទាបសម្រាប់ដំណាំស្រូវ និងគ្របដណ្តប់លើផ្ទៃដីប្រហែល ៣៣%។ របបទឹកភ្លៀងមិនទៀងទាត់បង្កជាគ្រោះរាំងស្ងួត និងទឹកជំនន់ដែលធ្វើឲ្យកសិករមានទំនោរទៅរកការដាំដុះស្រូវកណ្តាលជំនួសស្រូវធ្ងន់វិញ។

**គ.១ ពូជស្រូវរាំងជ័យ**

ពូជរាំងជ័យ ជាពូជស្រូវធ្ងន់ដែលដែលបានបញ្ចេញនៅឆ្នាំ ១៩៩៩ ហើយត្រូវបានកសិករប្រើប្រាស់ក្នុងផលិតកម្មស្រូវវស្សានៅកម្ពុជា។ ពូជនេះមានផលិតភាពខ្ពស់ និងមានគុណភាពអង្ករល្អប្រសើរ។ ពូជរាំងជ័យមានប្រភេទពូជស្រូវប្រកាន់រដូវមធ្យមចាប់ចេញផ្កានៅពាក់កណ្តាលខែវិច្ឆិកា និងច្រូតកាត់នៅពាក់កណ្តាលខែធ្នូ និងដើមខែមករា។ ពូជនេះមានកម្ពស់ដើមពី ១០៥-១៦៨ ស.ម ចំនួនដើមបែកគុម្ពផ្តល់ផលពី ៥-១០គុម្ពក្នុង១ដើម មានប្រវែងក្លួរពី ១៦-៣០ ស.ម និងចំនួនគ្រាប់ក្នុង១ក្លួរមានពី ១៨៦-៣៣៤គ្រាប់។ ពូជរាំងជ័យ ជាប្រភេទពូជធន់ទ្រាំមធ្យមទៅនឹងទឹកជំនន់ ហើយបើមានលក្ខខណ្ឌដីមានជីជាតិ និងអនុវត្តតាមប្រព័ន្ធប្រពលវប្បកម្ម វាអាចផ្តល់ទិន្នផលបានពី ៣.៥-៥.៥ ត/ហ.ត។

**គ.២ ពូជស្រូវខា៤**

ពូជខា៤ ជាពូជស្រូវធ្ងន់ដែលដែលបានបញ្ចេញនៅឆ្នាំ ១៩៩៥ ហើយត្រូវបានកសិករប្រើប្រាស់ក្នុងផលិតកម្មស្រូវវស្សានៅកម្ពុជា ជាពិសេសនៅតំបន់ស្រែទឹកជ្រៅ។ ពូជនេះមានផលិតភាពខ្ពស់ និងមានគុណភាពអង្ករល្អប្រសើរ។ ពូជខា៤ មានប្រភេទពូជស្រូវប្រកាន់រដូវចាប់ចេញផ្កានៅពាក់កណ្តាលខែវិច្ឆិកា និងច្រូតកាត់នៅពាក់កណ្តាលខែធ្នូ។ ពូជនេះមានកម្ពស់ដើមពី ១៣២-១៧២ ស.ម ចំនួនដើមបែកផ្តល់ផលពី ៦-១០ ដើមក្នុង១គុម្ព មានប្រវែងក្លួរពី ២០-៣០ ស.ម និងមានចំនួនគ្រាប់ក្នុង១ក្លួរពី ១៦០-១៩០គ្រាប់។ ពូជខា៤ ជាប្រភេទពូជធន់ទៅនឹងភាពរាំងស្ងួត ប៉ុន្តែមិនសូវធន់នឹងសត្វមមាចត្នោតទេ ហើយបើដីមានជីជាតិល្អព្រមទាំងអនុវត្តតាមប្រព័ន្ធប្រពលវប្បកម្ម វានឹងអាចផ្តល់ទិន្នផលស្រូវពី ២.៥-៥.០ ត/ហ.ត។

**គ.៣ ពូជស្រូវខា៦**

ពូជខា៦ ជាពូជស្រូវធ្ងន់ដែលដែលបានបញ្ចេញនៅឆ្នាំ ២០០៥ ហើយត្រូវបានកសិករប្រើប្រាស់ក្នុងផលិតកម្មស្រូវវស្សានៅកម្ពុជា។ ពូជនេះមានផលិតភាពខ្ពស់ និងមានគុណភាពអង្ករល្អប្រសើរ។ ពូជខា៤ មានប្រភេទពូជស្រូវប្រកាន់រដូវចាប់ចេញផ្កានៅពាក់កណ្តាលខែវិច្ឆិកា និងច្រូតកាត់នៅពាក់កណ្តាលទៅចុងខែធ្នូ។ ពូជនេះមានកម្ពស់ដើមចាប់ពី ១២៩-១៧៧ ស.ម ចំនួនដើមបែកផ្តល់ផលពី ៧-៩ដើមក្នុង១គុម្ព មានប្រវែងក្លួរពី ២១-២៥ ស.ម និងចំនួនគ្រាប់ក្នុង១ក្លួរពី ១៥៥-១៨៨គ្រាប់។ បើស្ថិតក្នុងលក្ខខណ្ឌដីមានជីជាតិ និងអនុវត្តប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ នោះវាអាចនឹងផ្តល់ទិន្នផលស្រូវសរុបចន្លោះពី ៣.៥-៥.៨ ត/ហ.ត។

**ឃ. បច្ចេកទេសដាំដុះ**

ចំពោះបច្ចេកទេសដាំដុះគ្រាប់ពូជទាំង ១០ប្រភេទនេះវិញគឺ មិនមានលក្ខណៈខុសគ្នាប៉ុន្មានទេ។ សម្រាប់ស្រូវសន្ទូង ក៏ដូចជាស្រូវពង្រោះដែរ អាចនិយាយបានថាគ្រាប់ពូជទាំង ១០នេះមានបច្ចេកទេសដាំដុះដូចគ្នា។

**ឃ.១ សម្រាប់ស្រូវសន្ទូង**

ដើម្បីឲ្យសំណាប និងដើមស្រូវមានសុខភាពល្អ ត្រូវប្រើពូជស្រូវសុទ្ធហើយមានគុណភាពល្អ ដោយប្រើពូជពី ២០-៤០ គ.ក្រ/ហ.ត។ ថ្នាលសំណាបត្រូវនៅជិតប្រភពទឹកដោយរៀបចំថ្នាលសំណាបឲ្យបានស្មើល្អ ដោយភ្ជួររាស់ឲ្យបានច្រើនដងរួចប្រើជីកំប៉ុស្តពី ២-៣ រទេះគោលើផ្ទៃដីសំណាប។ សំណាបមានអាយុកាលពី ១៥-២០ ថ្ងៃត្រូវដកយកទៅសន្ទូងដោយដកភ្លាមស្ទូងនៅថ្ងៃតែមួយ។ បន្ទាប់មកត្រូវភ្ជួរឲ្យបាន ២-៣ដងឲ្យបានស្មើល្អ និងលើកភ្លឺស្រែឲ្យបានខ្ពស់ ហើយប្រើជីកំប៉ុស ឬជីលាមកសត្វចំនួន ៥ តោន និងអាចប្រើជីអាដេប៉េចំនួន ៥០-១០០ គ.ក្រ ទ្រាប់បាតតាមប្រភេទដី។ បើដីមិនសូវមានជីជាតិ ឬដីល្បាយខ្សាច់វិញ ត្រូវប្រើជីប៉ូតាស្យូបន្ថែមជាមធ្យម ៥០គ.ក្រ/ហ.ត នៅពេលស្រូវមូរដើម ឬពេលស្រូវកកើតកួរ។ ក្រោយពេលស្ទូងរួច ៥-៧ថ្ងៃ ត្រូវស្ទូងជួសគុម្ពណាដែលបាត់ ហើយចុះមើលស្រែជាប្រចាំ និងបោចស្មៅ គ្រប់គ្រង ថែទាំទឹកក្នុងស្រែ ត្រួតពិនិត្យ សត្វល្អិត និងសត្វដែលមានប្រយោជន៍ជាប្រចាំ។

**ឃ.២ សម្រាប់ស្រូវពព្រោះ**

ការរៀបចំដីស្រែពព្រោះ គឺត្រូវភ្ជួរដីឲ្យបានច្រើនដងពី ២-៣ដងឲ្យបានស្មើល្អ ហើយប្រើជីកំប៉ុស ឬ ជីលាមកចំនួន ៣-៥ តោន បន្ទាប់មកព្រោះគ្រាប់ស្រូវពី ៧០-១០០ គ.ក្រ/ហ.ត ដោយប្រើឧបករណ៍ព្រោះគ្រាប់ស្រូវ ឬដោយដៃ។ បើសម្រាប់ដីមិនសូវមានជីជាតិ ជាមធ្យមសម្រាប់ពូជទាំង ១០គេអាចប្រើជីបន្ថែមដោយប្រើជីដេអាប៉េចំនួន ៥០-១០០ គ.ក្រ/ហ.ត និងជីប៉ូតាស្យូចំនួន ២៥ គ.ក្រ/ហ.ត។ នៅពេលក្រោយព្រោះប្រហែល ២០ថ្ងៃ គេត្រូវប្រើជីអ៊ុយរ៉េចំនួន ២៥ គ.ក្រ/ហ.ត និងជីប៉ូតាស្យូបន្ថែមទៀតចំនួន ២៥គ.ក្រ/ហ.ត នៅពេលស្រូវមូរដើម ឬពេលកកើតកួរ ហើយក៏ត្រូវចុះមើលស្រែជាប្រចាំ ជួសដើមណាដែលបាត់ បោចស្មៅ គ្រប់គ្រងទឹក និងត្រួតពិនិត្យសត្វល្អិតជាប្រចាំ។

### ៣.២.២ ការបង្កើនផលិតភាពកម្លាំងពលកម្ម

#### ៣.២.២.១ កម្លាំងពលកម្មកសិកម្មដែលមានគុណភាព

កម្លាំងពលកម្មរបស់មនុស្សនៅក្នុងវិស័យកសិកម្ម គឺជាកត្តាចម្បងដែលសំខាន់បំផុតក្នុងការបង្កើនផលិតភាពកសិកម្ម។ ជាមួយនឹងសាកលភាវូបនីយកម្មកាន់តែបើកចំហរ បានធ្វើឲ្យទីផ្សារផលិតផលកសិកម្មរបស់ប្រទេសកម្ពុជាកាន់តែធំឡើងៗ ដូច្នេះដើម្បីអាចចាប់យកចំណែកទីផ្សារកសិកម្មឲ្យបានច្រើនតាមដែលអាចធ្វើបាន កត្តាមុនដំបូងដែលគួរគិតគូរគឺការពង្រីកផ្ទៃដីកសិកម្មឲ្យមានទំហំកាន់តែរីកធំឡើងៗ ទើបធ្វើឲ្យផលិតផលកសិកម្មកម្ពុជាមានការកើនឡើងជាលំដាប់។ កម្លាំងពលកម្មកសិកម្ម ឬហៅថាកសិករគឺជាធាតុផ្សំដ៏សំខាន់ដែលចូលរួមដោយផ្ទាល់ទៅក្នុងដំណើរការផលិតកម្មកសិកម្ម ហើយដើម្បីឲ្យស្របគ្នានឹងផ្ទៃដីកសិកម្មដែលកំពុង

តែមានទំហំរីកធំជាលំដាប់ តម្រូវឲ្យប្រជាកសិករបង្កើននូវផលិតភាពរបស់ខ្លួនក្នុងគោលបំណងបង្កើននូវទិន្នផលកសិកម្ម ពីព្រោះតែបរិមាណផលិតផលកសិកម្ម គឺជាអនុគមន៍ដោយផ្ទាល់ទៅនឹងចំនួនកសិករ និងផលិតភាពរបស់កសិករ។ ដូចនេះ កសិករគប្បីគួរតែមានចំណុចគោល ២យ៉ាងក្នុងការធ្វើជាកម្លាំងពលកម្មកសិកម្មប្រកបដោយគុណភាព និងផលិតភាព ដែលកត្តាទាំង ២នោះគឺ កត្តារូបរាងកាយ និងកត្តាប្រាជ្ញា។[35]

**(១)កត្តារូបរាងកាយៈ** គុណភាពផ្នែករូបរាងកាយរបស់ពលកម្មកសិកម្មសម្តៅទៅលើការមានសុខភាពល្អកាយសម្បទាគ្រប់គ្រាន់ កម្លាំងមាំមួន ដែលធន់ទៅនឹងអាកាសធាតុក្តៅហើយសើម ទើបអាចធ្វើកសិកម្មប្រកបដោយផលិតភាព។ ជាធម្មតាមនុស្សដែលរស់នៅតំបន់ក្តៅ តែងមានសុខភាពរឹងមាំជាងមនុស្សរស់នៅតំបន់ត្រជាក់ ជាហេតុដែលប្រជាជននៅក្នុងតំបន់ក្តៅមានផលិតភាពផ្នែកកសិកម្មជាងមនុស្សរបស់នៅតំបន់ត្រជាក់។ បើសិនជាកសិករមិនមានកម្លាំងខ្លាំង រាងកាយមាំមួន និងមានសុខភាពល្អទេ ការដែលធ្វើកសិកម្មនៅក្រោមកម្តៅថ្ងៃយូរនឹងធ្វើឲ្យពួកគាត់មានអាការៈទន់ដៃទន់ជើង ឬអស់កម្លាំងជាដើម និងអាចធ្វើឲ្យសុខភាពចុះខ្សោយ ដោយសារតែរាងកាយមិនធន់នឹងអាកាសធាតុ។

**(២)កត្តាប្រាជ្ញាៈ** គុណភាពផ្នែកប្រាជ្ញារបស់ពលកម្មកសិកម្មគឺសម្តៅទៅលើកសិករដែលមានឱកាសទទួលបានការអប់រំថ្នាក់មធ្យមសិក្សា កម្រិតសិក្សាបច្ចេកទេស ការចូលរួមបណ្តុះបណ្តាលវិធីសាស្ត្រកសិកម្មជាដើម។ កាលណាប្រជាកសិករទទួលបានការអប់រំកម្រិតមធ្យមសិក្សា ធ្វើឲ្យពួកគាត់បាននូវចំណេះដឹងមូលដ្ឋានដើម្បីជាជំនួយសម្រាប់ប្រើប្រាស់ធាតុដែលពាក់ព័ន្ធទៅនឹងកសិកម្មដូចជា អាចអានរបៀបណែនាំរបស់ជីកសិកម្មក្នុងគោលបំណងប្រើប្រាស់វាឲ្យត្រូវបច្ចេកទេស មានឱកាសដឹងពីព័ត៌មានទីផ្សារកសិកម្មដែលបានផ្សព្វផ្សាយតាមប្រព័ន្ធផ្សេងៗ អាចស្វែងយល់ពីព័ត៌មានបណ្តុះបណ្តាលបច្ចេកទេសបានច្បាស់ជាងកសិករដែលមិនបានទទួលបានការអប់រំដោយសារពួកគាត់មិនចេះអក្សរបានច្បាស់ ជាហេតុធ្វើឲ្យពួកគាត់បាត់បង់នូវឱកាសទាំងនោះដើម្បីបង្កើននូវផលិតភាពផ្ទាល់ខ្លួន។ ម្យ៉ាងវិញទៀត អ្នកដែលទទួលបានការអប់រំ គឺអាចមានប្រាជ្ញា រៀនឆាប់ចាប់យកបច្ចេកទេសចំណេះដឹងកសិកម្មបានត្រឹមត្រូវល្អជាងកសិករដែលមិនទទួលបានការអប់រំ។ ការដែលឆាប់យល់ឆាប់ចាប់បានបច្ចេកទេសកសិកម្មបានលឿនជាង បានជំរុញឲ្យពួកគាត់បង្កើននូវផលិតភាពបានល្អ។

### ៣.២.២.២ ការអភិវឌ្ឍពលកម្មកសិកម្ម

កត្តាចម្បងក្នុងការអភិវឌ្ឍពលកម្មកសិកម្ម គឺការជំរុញការអប់រំដល់កសិករ។ ការអភិវឌ្ឍធនធានពលកម្មក្នុងវិស័យកសិកម្ម គឺសម្តៅទៅលើការបង្កើនចំណេះដឹងទាំងផ្នែកសុខភាព ផ្នែកបច្ចេកទេស និងជំនាញកសិកម្មពាក់ព័ន្ធនានា ដើម្បីឆ្លើយតបទៅតាមតម្រូវការផ្នែដីកសិកម្មដែលកំពុងតែកើនឡើងជាលំដាប់ ក៏ដូចជាស្រាវជ្រាវ

---

[35] Dr. Pranav K. Desai, *Agricultural Economics[សេដ្ឋកិច្ចកសិកម្ម], (បោះពុម្ពឆ្នាំ២០១០)*, ទំព័រ ២២១។

បន្ថែមនូវបច្ចេកវិទ្យានិងរបកគំហើញថ្មីៗ ក្នុងគោលបំណងអភិវឌ្ឍន៍សមត្ថភាពប្រជាកសិករឲ្យកើនឡើងមួយកម្រិតធំទៀត។ ប្រសិនបើកសិករចេះអាន វាជាការរួមចំណែកយ៉ាងសំខាន់ទៅដល់ការបើកច្រកទ្វានៃការប្រាស្រ័យទាក់ទងគ្នាបានលឿន តាមរយៈឯកសារជាលាយលក្ខណ៍អក្សរ និងដោយផ្ទាល់មាត់ ពីសំណាក់មន្ត្រីផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ក៏ដូចជាពីអង្គការបច្ចេកទេសនានាផងដែរ ដែលធ្វើឲ្យការបណ្តុះបណ្តាលកាន់តែមានភាពងាយស្រួលនិងមានប្រសិទ្ធភាព។ ភាគច្រើនកសិកររៀនសូត្រពីអ្នកជិតខាងរបស់ខ្លួន ដូចនេះប្រការចាំបាច់ គឺការលើកកម្ពស់ចំណេះដឹង ការទទួលបានព័ត៌មាន ការផ្ទេរបច្ចេកវិទ្យាទាក់ទងនឹងការអនុវត្តកសិកម្មពីកសិករទៅកសិករ វិធីសាស្ត្រគ្រប់គ្រងទឹកបានល្អ និងការលក់ផលិតផលកសិកម្មទៅទីផ្សារ តាមរយៈសិក្ខាសិលា និងមធ្យោបាយផ្សេងៗទៀតដោយមានអន្តរសកម្មភាពជាមួយកសិករដោយផ្ទាល់ ដើម្បីឲ្យកសិករអាចចែករំលែកចំណេះដឹងប្រកបដោយប្រសិទ្ធភាព ជាពិសេសគឺបង្កើតឲ្យមានការគាំទ្រផ្នែកបច្ចេកទេសទៅដល់សហគមន៍កសិករ តាមរយៈការលើកទឹកចិត្តឲ្យកសិករធ្វើការផ្លាស់ប្តូរ និងចែករំលែកការអនុវត្តល្អទៅក្នុងចំណោមសហគមន៍របស់ខ្លួន។ មួយវិញទៀត សេវាផ្សព្វផ្សាយកសិកម្ម គឺជាការផ្សារទំនាក់ទំនងយ៉ាងសំខាន់រវាងវិទ្យាស្ថានស្រាវជ្រាវ ទីផ្សារ និងកសិដ្ឋានពិសោធន៍ ទៅកាន់ប្រជាកសិករដែលជាអ្នកទទួលបានផលប្រយោជន៍ពីលទ្ធផលនៃការស្រាវជ្រាវនេះ។ ប៉ុន្តែ ការផ្តល់សេវាផ្សព្វផ្សាយកសិកម្មនៅមិនទាន់មានប្រសិទ្ធភាពនៅឡើយ ដោយសារមានតែកសិករ ១% ទេ ដែលអាចទទួលបានសេវានេះយ៉ាងត្រឹមត្រូវ ក៏ព្រោះតែកសិករភាគច្រើនមិនបានទទួលការអប់រំគ្រប់គ្រាន់ ដើម្បីអាចដឹងពីព័ត៌មានដែលបានផ្សព្វផ្សាយតាមទូរទស្សន៍ ឬប្រព័ន្ធអ៊ីនធឺណែតផ្សេងៗ។[36] ដូចនេះ ការបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេស និងការពង្រឹងសមត្ថភាពផ្នែកអប់រំដល់កសិករសម្រាប់ការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយនិរន្តរភាព គឺជាគ្រឹះដ៏រឹងមាំនៃដំណើរការអប់រំមួយ ដើម្បីឈានទៅសម្រេចបាននូវគោលដៅផែនការដែលបានដាក់ចេញ ក្នុងគោលបំណងដើម្បីអាចទទួលបានជោគជ័យក្នុងការធ្វើប្រពលវប្បកម្ម ដែលវាអាចកាត់បន្ថយគម្លាតបច្ចេកទេសទៅនឹងប្រតិបត្តិការរបស់កសិករនាពេលបច្ចុប្បន្នទាំងក្នុងផ្នែកផលិតកម្ម និងការប្រមូលផល ដោយប្រើប្រាស់គ្រប់មធ្យោបាយ ដែលមានដូចជាការផ្ទេរបច្ចេកវិទ្យា និងបច្ចេកទេសជាដើម។ និយាយបែបផ្សេង មុខងារផ្សព្វផ្សាយកសិកម្ម គឺដើម្បីសម្របសម្រួលការរៀនសូត្រ ពង្រីកចំណេះដឹង និងបច្ចេកវិទ្យាថ្មីៗ ក្នុងគោលបំណងជំរុញនូវផលិតភាពកសិកម្ម តាមរយៈការបង្កើនផលិតភាពកសិករ។ មួយវិញទៀត ការទទួលបានចំណេះដឹងបន្ថែមស្តីពីរបបអាហារដើម្បីជួយបំប៉នសុខភាពកសិករឲ្យរឹងមាំ គឺជាចំណុចមួយមិនអាចខ្វះបាន ដើម្បីឲ្យប្រជាកសិករអាចធ្វើកសិកម្មពោរពេញទៅដោយថាមពល និងមានផលិតភាព។ ហេតុដូចនេះ តម្រូវឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមទាំង

[36] បណ្ឌិត ហង់ ជួន ណារ៉ុន, *សេដ្ឋកិច្ចកម្ពុជា (២០១៥)*, ទំព័រ ២១៦។

ស្ថាប័នពាក់ព័ន្ធ បន្តពង្រឹង និងបង្កើនសេវាគាំទ្រការអភិវឌ្ឍធនធានពលកម្មក្នុងវិស័យកសិកម្មឲ្យកាន់តែមានប្រសិទ្ធភាព ដោយត្រូវបង្កើនសមត្ថភាពមន្ត្រី ឬអ្នកបង្រៀនពីបច្ចេកទេសកសិកម្មឲ្យបានច្បាស់ ដើម្បីឲ្យកសិកររៀនសូត្រ និងបង្កើនផលិតភាពរបស់ខ្លួន។ បន្ថែមពីនេះ ត្រូវលើកកម្ពស់សេវាផ្សព្វផ្សាយកសិកម្ម ដោយផ្តោតសំខាន់ទៅលើការបង្កើនប្រសិទ្ធភាពក្របខ័ណ្ឌការងារផ្សព្វផ្សាយ កៀរគរធនធានសម្រាប់គាំទ្រសេវាផ្សព្វផ្សាយតាមបច្ចេកវិទ្យា អភិវឌ្ឍន៍សមត្ថភាព ផ្សព្វផ្សាយសម្ភារៈកសិកម្មឲ្យកាន់តែទូលំទូលាយ ដើម្បីជំរុញឲ្យកសិករមានឱកាសខ្ពស់ជាងនេះក្នុងការអភិវឌ្ឍសមត្ថភាពរបស់ខ្លួន។

**៣.២.២.៣ ការបង្កើតសាលារៀនស្រែកសិករ**

ការបង្កើតសាលារៀនស្រែកសិករ គឺដើម្បីបណ្តុះបណ្តាលដល់ក្រុមកសិករពីបច្ចេកទេសដាំដុះ វិធីសាស្ត្រក្នុងការត្រួតពិនិត្យកសិដ្ឋានប្រកបដោយប្រសិទ្ធភាព និងការពង្រឹងសមត្ថភាពកសិករ។ គោលបំណងធំមួយទៀតរបស់សាលារៀនស្រែកសិករ គឺបង្កើតឡើងដើម្បីការរៀនសូត្រពីកសិករទៅកសិករ គឺជាវិធីសាស្ត្រមួយនៃការបណ្តុះបណ្តាលរយៈពេលវែងយ៉ាងមានប្រសិទ្ធភាព សម្រាប់បង្កើនផលិតភាពកសិករនៅតាមមូលដ្ឋាន។ ផ្អែកតាមបទពិសោធន៍នៅក្នុងប្រទេសជាច្រើនបង្ហាញថា កម្មវិធី ឬគម្រោងការផ្សព្វផ្សាយកសិកម្មទទួលបានជោគជ័យទាំងលក្ខណៈផ្លូវការ និងក្រៅផ្លូវការ ដោយមានការបញ្ជ្រាបចំណេះដឹងពីកសិករទៅកសិករ ដើម្បីលើកទឹកចិត្តកសិករនៅក្នុងមូលដ្ឋានចែករំលែកចំណេះដឹង ជំនាញ អ្នកផ្គត់ផ្គង់សម្ភារៈកសិកម្ម អ្នកទិញផលិតផល វិធីសាស្ត្រដាំដុះ ក៏ដូចជាចែករំលែកនូវបទពិសោធន៍រវាងកសិករទទួលបានជោគជ័យក្នុងផលិតកម្មដំណាំរបស់ខ្លួនទៅកាន់កសិករដទៃទៀតផងដែរ។ ការរៀបចំឲ្យមានការរៀនសូត្រពីកសិករទៅកសិករត្រូវបានទទួលស្គាល់ថា ជាយុទ្ធសាស្ត្រមួយនៃការផ្សព្វផ្សាយកសិកម្មប្រកបដោយប្រសិទ្ធភាព ក្នុងការជួយផ្តល់សិទ្ធិអំណាចដល់កសិករ ផ្តល់ឱកាសឲ្យកសិករ សហគមន៍កសិករ បានរៀនសូត្រនូវបច្ចេកទេសកសិកម្ម និងធ្វើការជាមួយគ្នា ដែលជាចំណុចគន្លឹះដើម្បីអភិវឌ្ឍន៍ផលិតភាពកសិករប្រកបដោយនិរន្តរភាព ក្នុងគោលបំណងសម្រួលដល់កសិករនៅតាមមូលដ្ឋានឲ្យសម្របខ្លួនតាមស្ថានភាពវិវត្តនៃសាកលភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្ម។ ជាទូទៅ កសិករទទួលយកការណែនាំ ការផ្តល់ដំបូន្មាន ពីកសិករផ្សេងៗដែលទទួលបានជោគជ័យក្នុងផលិតកម្មដំណាំរបស់ពួកគាត់។ ការអនុវត្តដោយផ្ទាល់នៅក្នុងកសិដ្ឋានជួយឲ្យកសិករអាចរៀនសូត្រ បង្កើនសមត្ថភាពផ្ទាល់ខ្លួន និងទទួលបានបទពិសោធន៍ជាក់ស្តែងពីបច្ចេកទេសកសិកម្ម ជំរុញការកសាងជំនាញ និងសមត្ថភាពរបស់កសិករក្នុងសហគមន៍មូលដ្ឋាន ដោយមានការសម្របសម្រួលពីភ្នាក់ងារផ្សព្វផ្សាយកសិកម្មរបស់ស្ថាប័នរដ្ឋ ដើម្បីធានាថាសកម្មភាពការសិក្សាពីកសិករទៅកសិករគឺត្រូវតាមបច្ចេកទេសស្តង់ដារ និងតាមតម្រូវការអ្នកប្រើប្រាស់។ ជាក់ស្តែង ដើម្បីសម្រេចបានការរៀនសូត្រពីកសិករទៅកសិករស្របតាមគោលការណ៍ណែនាំប្រកបដោយប្រសិទ្ធ-

ភាព តម្រូវឲ្យភ្នាក់ងារផ្សព្វផ្សាយកសិកម្មអនុវត្តតាមជំហានដូចខាងក្រោម ១) **ជ្រើសរើសកសិករគម្រូ** ជាការជ្រើសរើសកសិករគម្រូចេញពីក្រុមកសិករគោលដៅ ឬកសិករដែលមានសក្តានុពល មានបទពិសោធន៍ក្រាស់ក្រែល មានបច្ចេកទេសត្រឹមត្រូវ ចេះអាននិងសរសេរអក្សរខ្មែរបានគួរសម និងជាពិសេសអនុវត្តកសិកម្មរបស់ខ្លួនបានជោគជ័យជាលក្ខណៈអាជីព។ **២)បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពកសិករគម្រូ** គឺជាការពង្រឹងនូវសមត្ថភាពបន្ថែមដល់កសិករគម្រូ ដែលបានជ្រើសរើសស្របតាមតម្រូវការរបស់គាត់ ដើម្បីឲ្យគាត់កាន់តែមានជំនាញក្នុងការអនុវត្តជាក់ស្តែងនៅកសិដ្ឋាន ដោយឆ្លើយតបតាមតម្រូវការទីផ្សារ និងចែករំលែកបទពិសោធន៍ដល់កសិករដទៃទៀត។ ៣) **ការជ្រើសរើសកសិករឆ្នើម** ជាការជ្រើសរើសកសិករដែលមានស្នាដៃឆ្នើមបំផុតក្នុងចំណោមកសិករគម្រូ ដើម្បីចែករំលែកបទពិសោធន៍ និងភាពជោគជ័យនៃការអនុវត្តនៅលើផលិតកម្មរបស់ខ្លួនទៅដល់កសិករដទៃទៀត ដើម្បីឲ្យពួកគេបានរៀនចេះបច្ចេកទេសទាំងនោះយកទៅអនុវត្តទទួលបាននូវទិន្នផលខ្ពស់។ ហើយការជ្រើសរើសកសិករឆ្នើមនេះ គឺគេជ្រើសរើសម្នាក់ក្នុង ១សហគមន៍។ **៤)បណ្តុះបណ្តាលកសិករឆ្នើមឲ្យក្លាយជាគ្រូ** នេះជាវគ្គកាន់តែដុះខាត់នូវផលិតភាពពលកម្ម ដោយមានការបង្រៀនពីវិធីសាស្ត្រផ្សព្វផ្សាយកសិកម្ម ការផ្សារភ្ជាប់ផលិតផលទៅកាន់ទីផ្សារ ការអនុវត្តប្រព័ន្ធប្រពលវប្បកម្មថ្មីៗ បណ្តុះបណ្តាលបន្ថែមឆ្លើយតបតាមតម្រូវការសមត្ថភាពជាដើម។ **៥) ការបង្កើតបណ្តាញកសិករ** ជាយុទ្ធសាស្ត្រចែករំលែក បទពិសោធន៍ និងភាពជោគជ័យលើការអនុវត្តផលិតកម្មកសិកម្មរបស់កសិករឆ្នើម/កសិករគ្រូ ទៅដល់ក្រុមកសិករផ្សេងទៀតដែលអនុវត្តផលិតកម្មនោះ។

ដើម្បីបង្កើតបណ្តាញទទួលជោគជ័យត្រូវអនុវត្តតាមជំហាន (1)ចុះទៅកសិដ្ឋានកសិករជោគជ័យដោយផ្ទាល់ដើម្បីរៀនសូត្រ (2)កសិករឆ្នើម/កសិករគ្រូធ្វើការបណ្តុះបណ្តាលក្រុមកសិករ ដែលកំពុងអនុវត្តផលិតកម្មដំណាំដូចគ្នានឹងកសិករគម្រូ (3)រៀបចំវេទិការៀនសូត្ររវាងកសិករ និងអ្នកបច្ចេកទេស។ បន្ទាប់ពីបានឆ្លងកាត់នូវដំណាក់កាលទាំងអស់នេះហើយ ប្រជាកសិករនៅតាមមូលដ្ឋានសហគមន៍ ជាពិសេសគឺកសិករគម្រូ ប្រាកដជាមានការកើនឡើងនូវផលិតភាពរៀងៗខ្លួនជាក់ជាមិនខាន ដែលពួកគាត់អាចប្រើប្រាស់សមត្ថភាពនោះទៅបង្កើនផលិតភាពកសិកម្មនៅតាមកសិដ្ឋានរបស់ពួកគាត់។

### ៣.២.៣ កត្តាបច្ចេកវិទ្យា

បច្ចេកវិទ្យាគ្រឿងយន្តកសិកម្ម សម្តៅទៅលើបច្ចេកវិទ្យាដែលត្រូវបានប្រើប្រាស់លើកសិដ្ឋានជួយដល់ការដាំដុះ។ បច្ចេកវិទ្យាកសិកម្ម គឺស្ថិតក្នុងចំណោមបច្ចេកវិទ្យាទំនើបផ្សេងៗដែលត្រូវបានបង្កើតឡើងសម្រាប់ដំណើរការផលិតកម្មក្នុងការផលិតស្បៀងអាហារដើម្បីផ្គត់ផ្គង់ទៅលើទីផ្សារដែលកំពុងតែកើនឡើងជាលំដាប់ ស្របតាមកំណើនសាកលភាវូបនីយកម្ម និងកំណើនប្រជាជនឥតឈប់ឈរ។ សម្រាប់កម្ពុជា វាបានបើកនូវយុគ

សម័យថ្មីសម្រាប់ដំណើរការវិវត្តន៍ទៅរកទំនើបកម្មកសិកម្ម ដែលគ្រឿងយន្តកសិកម្មទាំងនោះគឺជាកម្លាំងចលករនៃការវិវត្តនេះ ក្នុងគោលបំណងជំនួសកម្លាំងមនុស្សដែលចាកចេញពីវិស័យកសិកម្មទៅរកវិស័យឧស្សាហកម្ម និងសេវាកម្ម ក៏ដូចជាជំនួសកម្លាំងសត្វពាហនៈដូចជា សត្វគោ ក្របី សេះជាដើម។ ឧបករណ៍គ្រឿងយន្តទាំងនេះ បានបង្កើននូវផលិតភាពការងារក្នុងកសិដ្ឋាន ជាពិសេសគឺកម្លាំងជំរុញយ៉ាងមានប្រសិទ្ធភាពក្នុងការបង្កើនលទ្ធផលការងាររបស់កសិករឲ្យភាពងាយស្រួលជាមុន ចំណេញពេលវេលា និងមាននិរន្តរភាព ដែលកត្តាទាំងនេះបានធ្វើឲ្យមានការផ្លាស់ប្តូរយ៉ាងខ្លាំងទៅក្នុងដំណើរការកសិកម្មតាមបែបទំនើប។ ដើម្បីសម្រេចចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ ២០៣០ ដែលធ្វើឲ្យវិស័យកសិកម្មឆ្ពោះទៅរកទំនើបកម្មកសិកម្មមានលក្ខណៈប្រកួតប្រជែងទីផ្សារក្នុងនិងក្រៅស្រុក ដើម្បីរួមចំណែកក្នុងការធានាសន្តិសុខស្បៀងអាហារ គឺតម្រូវឲ្យមានការអភិវឌ្ឍគ្រឿងយន្តកសិកម្ម និងប្រើបច្ចេកវិទ្យាបន្ថែមទៀតទៅក្នុងកសិកម្ម ពីព្រោះវាជាដំណោះស្រាយមួយដ៏សមស្របក្នុងការបង្កើនផលិតភាពរបស់កសិករ និងផលិតភាពកសិកម្ម ដោយប្រើប្រាស់ដីឲ្យអស់លទ្ធភាពព្រមទាំងទទួលបានប្រសិទ្ធភាព។ ជាក់ស្តែង នៅកម្ពុជាបច្ចុប្បន្នកំពុងតែធ្វើនូវយន្តូបនីយកម្មកសិកម្មជាបណ្តើរៗ ដែលត្រូវបានគេប្រើសម្រាប់ការងារកសិកម្មទៅតាមដំណាក់កាលនីមួយៗដូចជាម៉ាស៊ីនភ្ជួររាស់ ម៉ាស៊ីនដាំឬស្ទូងស្រូវ ម៉ាស៊ីនស្រោចស្រព ដ្រូនកសិកម្ម(Drone) និងម៉ាស៊ីនច្រូតកាត់ជាដើម។

#### ៣.២.៣.១ ម៉ាស៊ីនភ្ជួររាស់

ម៉ាស៊ីនភ្ជួររាស់ គឺប្រើសម្រាប់ភ្ជួររាស់ និងរៀបចំដីឲ្យបានស្មើល្អ ក្នុងគោលបំណងធ្វើឲ្យដីធូរ សម្លាប់ស្មៅ ឬរុក្ខជាតិណាដុះប្រជែងជាមួយដំណាំស្រូវ ដែលបង្អាក់ទៅដល់ការលូតលាស់បានល្អ។ ជាទូទៅ ម៉ាស៊ីនភ្ជួររាស់ គឺសម្តៅទៅលើគោយន្ត និងត្រាក់ទ័រ ហើយមុខងារចម្បងរបស់ឧបករណ៍ទាំង ២នេះគឺប្រើសម្រាប់ភ្ជួរដីដែលអាចរក្សាសំណើមឲ្យដីបានល្អ ដើម្បីឲ្យដីផ្តល់សារធាតុចិញ្ចឹមទៅដល់ដំណាំបានគ្រប់គ្រាន់។ គិតជាមធ្យមត្រឹមឆ្នាំ ២០១៧ ផ្ទៃដីស្រូវភាគច្រើនក្នុងខេត្តទាំង ៦ដែលមានភាពលេចធ្លោក្នុងការប្រើគ្រឿងចក្រ បានធ្វើការភ្ជួររាស់ដោយប្រើគ្រឿងយន្តរួមមាន គោយន្តនិងត្រាក់ទ័របានកើនឡើងរហូតដល់ ៩៧.៥% នៃផ្ទៃដីដាំដុះស្រូវសរុប។[37] មួយវិញទៀត តាមការស្រាវជ្រាវរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មបង្ហាញថា ក្នុងផ្ទៃដី ១ហិកតា បើសិនប្រើគោយន្តភ្ជួរ១គ្រឿងជាមួយកម្លាំងមនុស្ស២នាក់ ត្រូវចំណាយពេលជាមធ្យម ៣-៥ម៉ោង ប៉ុន្តែបើគេប្រើត្រាក់ទ័រ១គ្រឿង ត្រូវចំណាយពេលវេលាតែ ១-២ម៉ោងប៉ុណ្ណោះ។[38] នេះបញ្ជាក់ថា ការប្រើឧបករណ៍ភ្ជួរទាំងនេះ

[37] វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា, *របាយការណ៍សង្ខេបសមិទ្ធិផលនៃការស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យាឆ្នាំ ២០១៨ និងទិសដៅសម្រាប់ឆ្នាំ ២០១៩*, ទំព័រ ៩។

[38] ច័ន្ទ សារុន, *"យុទ្ធសាស្ត្របង្កើនផលិតកម្មដំណាំស្រូវប្រកបដោយចីរភាព"*, (និក្ខេបបទបណ្ឌិត, សាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា , ២០០៦), ទំព័រ ១៣៨។

បានបំពេញបន្ថែមនូវកម្លាំងពលកម្មដែលបានចាកចេញ ចំណេញពេលវេលាក្នុងការភ្ជួររាស់ ហើយធ្វើឲ្យដីមានសភាពល្អជាងវិធីភ្ជួររាស់តាមបែបបុរាណទៀតផង។ ជាពិសេស គោយន្ត និងត្រាក់ទ័រថៃមទាំងអាចដឹកជញ្ជូននូវកសិផលពីស្រែយកមកផ្ទុកនូវស្តុកកសិកម្មតាមផ្ទះរៀងខ្លួនក្នុងបរិមាណដ៏ច្រើន ព្រមទាំងកាត់បន្ថយនូវពេលវេលាដឹកជញ្ជូនទៀតផង។

**៣.២.៣.២ ម៉ាស៊ីនដាំគ្រាប់ ឬស្ទូងស្រូវ**

ឧបករណ៍ដាំ ឬហៅថាឧបករណ៍ស្ទូង គឺប្រើសម្រាប់ស្ទូងនិងដាំសំណាបដោយប្រើពេលវេលាលឿន មានប្រសិទ្ធភាព និងប្រើកម្លាំងពលកម្មតិច ដែលវាគឺជាគ្រឿងយន្តចាំបាច់មួយក្នុងដំណើរការកសិកម្មបែបទំនើប។ ឧបករណ៍នេះមានលក្ខណៈស្វ័យប្រវត្តិ និងពាក់កណ្តាលស្វ័យប្រវត្តិ ដែលអាចដាំសំណាបនៅក្នុងស្រែបានស្មើគ្នាល្អ ពោលគឺចម្ងាយពីសំណាប ១ទៅ១ មានប្រវែងប្រហែលពី ៦០-៩០ សង់ទីម៉ែត្រ។ តាមការស្រាវជ្រាវបង្ហាញថា ការដាំគ្រាប់ឬស្ទូងដោយប្រើម៉ាស៊ីន បានកាត់បន្ថយកម្លាំងពលកម្មការងារនេះពី ៣៥នាក់ មកត្រឹមតែ ១ឬ២នាក់ក្នុង ១ហិកតាប៉ុណ្ណោះ។[39] ផលប្រយោជន៍នៃការប្រើម៉ាស៊ីនប្រភេទនេះគឺ ចំណេញពេលវេលាក្នុងការស្ទូង ឬដាំសំណាបស្រូវ ឬក៏ពូជដំណាំសាកវប្បកម្មផ្សេងដោយប្រើកម្លាំងពលកម្មតិច មានសភាពនៃការដាំឬស្ទូងស្មើគ្នាល្អជាងការដាំដោយដៃ ជាពិសេសគឺចំណាយលើថ្លៃដើមផលិតកម្មតិចជាងការដែលជួលកម្លាំងពលកម្មច្រើន ជាហេតុជំរុញឲ្យទទួលបានផលចំណេញច្រើនដែរ។

**៣.២.៣.៣ ម៉ាស៊ីនស្រោចស្រព**

ការស្រោចស្រពទឹកដែលមានលក្ខណៈទំនើប និងមានប្រសិទ្ធភាព គឺពឹងផ្អែកលើគ្រឿងយន្តយ៉ាងខ្លាំង។ មានម៉ាស៊ីនមួយចំនួនដូចជាម៉ាស៊ីនបូមទឹក និងឧបករណ៍គ្រឿងចក្រមួយចំនួនទៀតត្រូវបានគេប្រើប្រាស់ដើម្បីចែកចាយទឹកបានយ៉ាងលឿន ក្នុងបរិមាណយ៉ាងច្រើនទៅក្នុងតំបន់ដាំដុះដ៏ធំ និងទទួលបានទិន្នផលខ្ពស់។ ការប្រើឧបករណ៍ស្រោចស្រពទឹកទាំងអស់នេះ គឺមានផលចំណេញខ្លាំងណាស់ដោយសារចំណាយដើមតិចក្នុងការទិញម៉ាស៊ីនទាំងនោះមកប្រើ ចំណេញពេលវេលាក្នុងការស្រោចស្រព ប្រើធនធានទឹកឲ្យអស់លទ្ធភាព ព្រមទាំងអាចធ្វើឲ្យដំណាំមានសំណើមស្មើៗគ្នា និងទទួលបានទិន្នផលខ្ពស់។

**៣.២.៣.៤ ដ្រូនកសិកម្ម** ( Drone )

ក្រៅពីត្រាក់ទ័រ ម៉ាស៊ីនស្រោចស្រព ឧបករណ៍ស្ទូង នៅមានគ្រឿងយន្តមួយប្រភេទទៀតត្រូវបានគេយកមកប្រើជាជំនួយក្នុងដំណើរការកសិកម្មឲ្យកាន់តែមានភាពងាយស្រួលជាងមុនទៀតគឺ ដ្រូនកសិកម្ម(Drone)។ គេ

[39] ច័ន្ទ សារុន, *"យុទ្ធសាស្ត្របង្កើនផលិតកម្មដំណាំស្រូវប្រកបដោយចីរភាព"*, (និក្ខេបបទបណ្ឌិត, សាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា , ២០០៦), ទំព័រ ១៣៨។

ប្រើវាសម្រាប់បាញ់ថ្នាំសម្លាប់សត្វល្អិត ឬជីកសិកម្មលើដំណាំគ្រប់ប្រភេទ ក៏ដូចជាស្រោចស្រពទឹកដែលផ្តល់ភាពងាយស្រួល និងចំណេញពេលវេលាយ៉ាងច្រើនដល់កសិករ។ ដ្រូនកសិកម្មនេះ អាចផ្ទុកទឹកក្នុងប្រមាណ ១៦លីត្រ ហើយចំពោះការប្រើប្រាស់វិញគឺចំណាយពេលត្រឹម ១០-១២នាទីប៉ុណ្ណោះ ក្នុង១ហិកតា និងចំពោះដំណាំស្រូវក្នុងផ្ទៃដី ១០ហិកតា ប្រើពេលត្រឹម ៣ម៉ោងប៉ុណ្ណោះ។ ក្រៅពីនេះ ដ្រូនកសិកម្មក៏អាចប្រើសម្រាប់ព្រោះគ្រាប់ពូជស្រូវបានផងដែរ ដោយវាមានសមត្ថភាពអាចផ្ទុកគ្រាប់ពូជបានទៅដល់ ២៥គីឡូក្រាមឯណោះក្នុងការបង្ហោះម្តង។ តាមទិន្នន័យបញ្ជាក់ថា ដ្រូនកសិកម្មចំណាយពេលតែ ២នាទីប៉ុណ្ណោះក្នុងការព្រោះគ្រាប់លើផ្ទៃដីស្រែ ១,២០០ម៉ែត្រការេ ខណៈពេលដែលការប្រើដៃត្រូវចំណាយពេលប្រមាណ ២៥នាទីឯណោះ។[40] នេះសមបញ្ជាក់ថាដ្រូនកសិកម្ម បានកាត់បន្ថយការចំណាយថវិកាយ៉ាងច្រើន ចំណេញពេលវេលា មានភាពងាយស្រួលក្នុងការប្រើប្រាស់ និងបានកាត់បន្ថយនូវផលប៉ះពាល់ចំពោះសុខភាពមនុស្ស។

**៣.២.៣.៥ ម៉ាស៊ីនច្រូតកាត់**

ម៉ាស៊ីនច្រូតកាត់បច្ចេកវិទ្យាថ្មី បានបង្កើតឡើងដើម្បីប្រើប្រាស់បានមុខងារជាច្រើនក្នុងម៉ាស៊ីនតែមួយ ហើយមុខងារចម្បងនោះគឺច្រូតកាត់ដំណាំស្រូវ និងដំណាំច្រើនប្រភេទទៀតយ៉ាងមានប្រសិទ្ធភាព។ ស្ថិតក្នុងស្ថានភាពដែលកម្លាំងពលកម្មនៅក្នុងវិស័យកសិកម្មបានថយចុះ ការច្រូតកាត់ដោយប្រើម៉ាស៊ីនប្រភេទកំបែនេះគឺពិតជាមានការចាំបាច់ និងពេញនិយមណាស់នាពេលបច្ចុប្បន្ន។ មានកត្តាចម្បងមួយដែលកសិករគួរងាកមកប្រើម៉ាស៊ីនកំបៃ ពីព្រោះម៉ាស៊ីនច្រូតកាត់នេះអាចបំពេញមុខងារបានច្រើនមុខដូចជាច្រូតកាត់ បោកបែន សម្អាត និងដឹកជញ្ជូន ដោយមិនចាំបាច់មានសកម្មភាពហាលដៃ បោកស្រូវក្រោយពេលច្រូតនោះទេ ដែលបញ្ជាក់ឲ្យឃើញថា កសិករមិនចាំបាច់ប្រើម៉ាស៊ីនច្រើនដំណាក់កាលដូចពីមុន។ ក្រៅពីនេះ មានមូលហេតុផ្សេងទៀតដែរគឺ ច្រូតបានលឿន ចំណាយថ្លៃដើមតិចជាងការច្រូតដោយដៃ មិនត្រូវការកម្លាំងពលកម្មច្រើន កាត់បន្ថយពេលវេលាកាត់បន្ថយការបាត់បង់ទាំងបរិមាណ និងគុណភាពក្រោយពេលប្រមូលផល។ ជាក់ស្តែង គិតជាមធ្យមត្រឹមឆ្នាំ ២០១៧កន្លងទៅនេះ ផ្ទៃដីដំណាំស្រូវស្ទើរទាំងអស់ក្នុងខេត្តទាំង ៦ដែលមានភាពលេចធ្លោក្នុងការប្រើគ្រឿងចក្របានងាកមកច្រូតកាត់ដោយប្រើប្រាស់ម៉ាស៊ីនកំបៃមានរហូតដល់ ៩៥.៧% នៃផ្ទៃដីដាំដុះស្រូវសរុប។[41]

---

[40] ភ្នំពេញ៖ https://www.business-cambodia.com/bootstrong/2-agriculture-drone-for-cambodia-farmer (ចូលទស្សនាថ្ងៃទី ០៧ កក្កដា ២០២០)

[41] វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា, *របាយការណ៍សង្ខេបសមិទ្ធិផលនៃការស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យាឆ្នាំ ២០១៨ និងទិសដៅសម្រាប់ឆ្នាំ ២០១៩*, ទំព័រ ៩។

### ៣.២.៤ កត្តាហេដ្ឋារចនាសម្ព័ន្ធ

ហេដ្ឋារចនាសម្ព័ន្ធនៅជនបទ មិនត្រឹមតែជាកត្តាដែលមិនអាចខ្វះបានក្នុងការអភិវឌ្ឍជនបទឲ្យមានល្អប្រសើរប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាភ្នាក់ងារដែលមានឥទ្ធិពលដោយផ្ទាល់ទៅលើការអភិវឌ្ឍវិស័យកសិកម្មផងដែរ ដោយសារតែហេដ្ឋារចនាសម្ព័ន្ធត្រូវបានគេប្រៀបប្រដូចទៅនឹងសរសៃឈាមរបស់កសិកម្មដែលកំពុងតែធ្វើចលនាឥតឈប់ឈរពីមួយថ្ងៃទៅមួយថ្ងៃក្នុងការដឹកជញ្ជូនកសិផលទៅកាន់ទីផ្សារ នាំយកព័ត៌មានតម្រូវការទីផ្សារមកកាន់កសិករវិញ ចែកចាយសេវាហិរញ្ញវត្ថុដែលជាទុនសំខាន់សម្រាប់ពង្រីកផលិតកម្មកសិកម្ម ព្រមទាំងផ្តល់នូវសេវាអប់រំ និងសេវាសុខាភិបាលដែលជាធាតុផ្សំសម្រាប់បង្កើនផលិតភាពពលកម្មទៀតផង។ ជាអាទិ៍ហេដ្ឋារចនាសម្ព័ន្ធទាំងអស់នោះ ត្រូវបានធ្វើការពង្រីកនិងកែលម្អឲ្យកាន់តែមានភាពទូលំទូលាយឡើង ដោយរាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងដែលពាក់ព័ន្ធនានា ក្នុងគោលបំណងចម្បងបង្កើននូវផលិតភាពកសិកម្ម។

#### ៣.២.៤.១ ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត

សម្រាប់កម្ពុជា ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តសាធារណៈដែលសំខាន់បំផុតក្នុងការចូលរួមអភិវឌ្ឍន៍ទៅលើវិស័យកសិកម្មគឺ ផ្លូវគមនាគមន៍ និងប្រព័ន្ធធារាសាស្ត្រ បានកំពុងតែដើរតួនាទីយ៉ាងសំខាន់នៅក្នុងការស្រោចស្រពផ្ទៃដីកសិកម្ម ដឹកជញ្ជូនកសិផល ភ្ជាប់ទំនាក់ទំនងរវាងអ្នកផលិតនិងឈ្មួញកណ្តាល ដែលជាកាតាលីករសំខាន់ដើម្បីជំរុញឲ្យកសិកម្មកាន់តែមានភាពទំនើប និងកំណើនសេដ្ឋកិច្ចជាតិ។ ភាពទ្រុឌទ្រោមបូករួមជាមួយកង្វះខាតនៃហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសផ្លូវថ្នល់ បង្កឲ្យមានឧបសគ្គយ៉ាងធ្ងន់ធ្ងរសម្រាប់វិស័យកសិកម្ម ដោយសារតែបញ្ហានៃការស្តុកទុក និងការដឹកជញ្ជូន។ ដូច្នេះ ត្រូវមានការស្តារឡើងវិញ ដើម្បីសម្រួលឲ្យការដឹកជញ្ជូនអស់ថ្លៃតិច ព្រមទាំងផ្សារភ្ជាប់ទំនាក់ទំនងពីជនបទទៅទីក្រុង ដែលវានឹងជំរុញឲ្យសកម្មភាពផលិតកម្មកាន់តែមានភាពល្អប្រសើរ។ គម្រោងពាក់ព័ន្ធនឹងការស្តារឡើងវិញនៃហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងអភិវឌ្ឍន៍ជនបទមានដូចជា៖

- បន្តការងារជួសជុល និងថែរក្សាផ្លូវដែលមានស្រាប់ឲ្យបានយូរ ដោយត្រួតពិនិត្យពីសកម្មភាពដឹកជញ្ជូនតាមលក្ខណៈបច្ចេកទេសនៃផ្លូវ
- កៀងគរជំនួយបរទេស និងការចូលរួមពីសំណាក់វិស័យឯកជនក្នុងការកសាងផ្លូវ
- ការកសាងផ្លូវថ្នល់ឲ្យត្រូវតាមបច្ចេកទេស ទើបអាចធានានូវការប្រើប្រាស់បានយូរ ព្រមទាំងធន់នឹងអាកាសធាតុ
- ស្ថាបនាបន្ថែមនូវផ្លូវថ្នល់ដែលតភ្ជាប់ពីតំបន់ដាច់ស្រយាលមកទីរួមស្រុក ខេត្ត និងពីខេត្តមកទីក្រុងដែលអាចជំរុញដល់សកម្មភាពពាណិជ្ជកម្ម

- បន្តសាងសង់ប្រព័ន្ធធារាសាស្ត្រខ្នាតតូចដូចជាប្រឡាយស្រោចស្រព ទំនប់ទឹក ស្ពាន សំណង់ស្ទាក់ទឹក
- ផ្តល់សមត្ថភាពនិងលទ្ធភាពដល់ថ្នាក់មូលដ្ឋានក្នុងការធ្វើគម្រោង ក៏ដូចជាតាមដាននូវលទ្ធផលការងារក្នុងមូលដ្ឋានរបស់ខ្លួន។

**៣.២.៤.២ ហេដ្ឋារចនាសម្ព័ន្ធសង្គម**

ហេដ្ឋារចនាសម្ព័ន្ធសង្គមសម្តៅទៅលើធាតុផ្សំនៃការអភិវឌ្ឍចម្រុះក្នុងតំបន់ជនបទរួមមានជាអាទិ៍ ការអប់រំ សេវាសុខភាព អនាម័យ ការផ្គត់ផ្គង់ទឹកស្អាត ថាមពលឬអគ្គីសនីជនបទ ដែលទាំងនេះគឺជាកត្តាជំរុញការអភិវឌ្ឍជនបទ រួមទាំងបង្កើនផលិតភាពកសិកម្មទៀតផង។ ក្នុងនោះដែរ ការអប់រំគឺជាចំណុចស្នូលនៅក្នុងការបង្កើនសមត្ថភាពធ្វើការរបស់ពលកម្មទាំងក្នុងវិស័យកសិកម្ម និងវិស័យមិនមែនកសិកម្ម។ ជាក់ស្តែង ការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់កសិករនៅតាមទីជនបទ មានទាន់មានគ្រប់គ្រាន់នៅឡើយទេ។ កសិករដែលមិនមានបច្ចេកទេសត្រឹមត្រូវ និងរៀនសូត្រតៗគ្នាពីមួយជំនាន់ទៅមួយជំនាន់ បានពឹងផ្អែកលើវិស័យកសិកម្មតាមបែបប្រពៃណី ជាហេតុធ្វើឲ្យទិន្នផលស្រូវរបស់ពួកគាត់មិនមានការកើនឡើង។ កង្វះការអប់រំទាំងកម្រិតមធ្យមសិក្សាបច្ចេកទេស និងបណ្តុះបណ្តាលជំនាញ គឺបង្អាក់ការបង្កើនផលិតភាពពលកម្ម។ ស្ថិតក្នុងលក្ខខណ្ឌនេះ ទាមទារឲ្យរដ្ឋនិងអង្គការពាក់ព័ន្ធ ដើរតួនាទីជាកាតាលីករចាត់ចែងក្នុងការផ្តល់ការអប់រំបច្ចេកទេស លើកកម្ពស់ប្រព័ន្ធអប់រំ លើកកម្ពស់ការបំប៉នបន្ថែមទៅដល់កសិករ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារដែលកំពុងតែមានសន្ទុះ។

ក្រៅពីការអប់រំនៅជនបទទៅ ការលើកកម្ពស់សុខភាព អនាម័យ ការផ្គត់ផ្គង់ទឹកស្អាតក៏ជាធាតុផ្សំដែលមិនអាចខ្វះបានដែរ។ កង្វះទឹកស្អាតប្រើប្រាស់ និងការទទួលបានសេវាថែទាំសុខភាព នៅតែជាកង្វល់ដ៏ចម្បងដោយសារភ្នាក់ងារចែកចាយទឹកស្អាតនៅមានកម្រិត រួមផ្សំជាមួយបុគ្គលិកសុខាភិបាលភាគច្រើន ជាពិសេសគ្រឹះស្ថានសាធារណៈមានតែនៅក្នុងតំបន់ទីក្រុង និងទីប្រជុំជន ដែលពិបាកដល់កសិករក្នុងការទទួលយកសេវាព្យាបាល ហើយងាកមកព្យាបាលតាមបែបបុរាណជំនួសវិញ។ ជាក់ស្តែង មានប្រជាជន ៣០%ប្រើប្រាស់សេវាសុខភាពឯកជន ២៤%ប្រើប្រាស់ថ្នាំបុរាណ និងនៅសេសសល់គឺប្រើប្រាស់សេវាសាធារណៈ។[42] ដោយមើលឃើញពីបញ្ហាទាំងនេះ សហគមន៍ជនបទ តម្រូវឲ្យមានគ្រប់គ្រាន់នូវការផ្គត់ផ្គង់ទឹកស្អាត និងបរិស្ថានអនាម័យ ដើម្បីឲ្យប្រជាជនមានសុខភាពល្អក្នុងការប្រកបការងារអភិវឌ្ឍន៍ខ្លួន។ តាមរយៈក្រសួងអភិវឌ្ឍន៍ជនបទ ក៏កំពុងតែខិតខំខ្លាំងឡើង ក្នុងការផ្តល់ជូនសេវាផ្គត់ផ្គង់ទឹកស្អាត អប់រំសុខភាព អនាម័យខ្លួនប្រាណ ក្នុងការលើកកម្ពស់លក្ខខណ្ឌនៃការរស់នៅរបស់ប្រជាជនឲ្យបានល្អប្រសើរ ដើម្បីឈានទៅសម្រេចឲ្យបាននូវទស្សនៈវិស័យរបស់រាជរដ្ឋាភិបាលដែលបានកំណត់ថា "ឆ្នាំ២០២៥ ប្រជាជននៅសហគមន៍ជនបទគ្រប់រូបត្រូវមានការផ្គត់ផ្គង់ទឹក

[42] បណ្ឌិត ហង់ ជួន ណារ៉ុន, *សេដ្ឋកិច្ចកម្ពុជា(២០១៥)*, ទំព័រ ២០៧។

ស្អាត អនាម័យគ្រប់គ្រាន់ និងរស់នៅក្នុងបរិស្ថានដែលមានអនាម័យប្រកបដោយនិរន្តរភាព”។[43] ដូច្នេះ តម្រូវឲ្យបំពេញបន្ថែមដោយការពង្រីកឲ្យបានគ្រប់គ្រាន់នូវសេវាផ្គត់ផ្គង់ទឹកស្អាតដូចជាការជីកស្រះ ធ្វើអាងស្តុកទឹក ពង្រីកការតបណ្តាញទឹកស្អាតទទួលទាននៅសហគមន៍ជនបទ ជំរុញការប្រើប្រាស់បង្គន់ ការលាងដៃនឹងសាប៊ូ និងការបរិភោគទឹកស្អាត។ ក៏មានដែរនូវការពង្រីកសេវាសុខាភិបាលឲ្យដល់តំបន់ឆ្ងាយៗពីផ្លូវជាតិ និងទីប្រជុំជនធំៗ ដើម្បីបង្កភាពងាយស្រួលឲ្យកសិករក្រីក្រទទួលបានសេវានេះដូចទីប្រជុំជននានាដែរ។

មួយវិញទៀត ការជំរុញបន្ថែមនូវការប្រើប្រាស់ប្រេងឥន្ធនៈ និងអគ្គីសនី គឺមានសារៈសំខាន់ណាស់សម្រាប់កសិករ។ ការកាត់បន្ថយថ្លៃថាមពលឥន្ធនៈបាន នឹងជួយឲ្យកសិករបង្កើននូវផលិតកម្មវិស័យកសិកម្ម ដោយសារថ្លៃថាមពលធ្លាក់ចុះ នឹងជំរុញឲ្យថ្លៃដើមដែលផលិតដំណាំធ្លាក់ចុះដែរ តាមរយៈការប្រើប្រាស់ថ្លៃប្រេងលើគ្រឿងយន្តអស់តិចជាងមុន។ ហេតុដូចនេះ រាជរដ្ឋាភិបាលគប្បីប្រើនូវកណ្តាប់ដៃដែករបស់ខ្លួន ដើម្បីកាត់បន្ថយពន្ធនាំចូលលើតម្លៃប្រេងឥន្ធនៈខ្លះ ក្នុងគោលបំណងឲ្យប្រជាកសិករអាចទិញថាមពលក្នុងតម្លៃតិចជាងមុន។

### ៣.២.៤.៣ សេវាឥណទានជនបទ

កង្វះខាតនូវសេវាហិរញ្ញវត្ថុមួយដែលមានប្រសិទ្ធភាពចំពោះកសិករនៅតំបន់ជនបទ គឺជាឧបសគ្គចម្បងមួយសម្រាប់ការរីកចម្រើនក្នុងផ្នែកកសិកម្ម។ ការពង្រឹងធនាគារជនបទ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពីសំណាក់រាជរដ្ឋាភិបាលមានសារៈសំខាន់ណាស់ ក្នុងការផ្តល់ឥណទានទៅគ្រប់ដំណាក់កាលនៃខ្សែសង្វាក់ផលិតកម្មកសិកម្មឲ្យកាន់តែទូលំទូលាយ។ ក្នុងនោះដែរ ធនាគារអភិវឌ្ឍន៍ជនបទដែលជាដៃម្ខាងរបស់រាជរដ្ឋាភិបាលបានបន្តការលើកកម្ពស់យ៉ាងខ្លាំងលើទៅផលិតផល និងជំរុញការនាំចេញស្រូវ-អង្ករ នៅក្រោមមូលនិធិទ្រទ្រង់ និងអភិវឌ្ឍន៍វិស័យកសិកម្ម។ បន្ថែមលើនេះ រាជរដ្ឋាភិបាលកំពុងលើកទឹកចិត្តដល់គ្រឹះស្ថានហិរញ្ញវត្ថុឯកជន ជាពិសេសគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឲ្យពង្រីកសកម្មភាពបន្ថែមទៅដល់កសិករក្នុងតំបន់ជនបទ។ ដូចនេះ ដើម្បីលើកកម្ពស់សេវាឥណទានជនបទឲ្យមានប្រសិទ្ធភាពសម្រាប់អភិវឌ្ឍន៍លើវិស័យកសិកម្ម ទាមទារឲ្យមានការរៀបចំនូវយុទ្ធសាស្ត្រ និងផែនការមួយចំនួន៖

- ជំរុញឲ្យអាជ្ញាធរមូលដ្ឋានដើរតួនាទីជាអ្នកសម្របសម្រួលជាមួយប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ។
- ជំរុញកៀងគរប្រាក់សន្សំក្នុងស្រុក បន្តទាក់ទាញប្រភពហិរញ្ញប្បទាននិងជំនួយពីក្នុងនិងក្រៅប្រទេស ដើម្បីផ្តល់ឥណទានដោយប្រើវិធីសាស្ត្រថ្មីៗទៅដល់សហគមន៍កសិករ និងក្រុមនានាក្នុងតំបន់ជនបទ។
- ជំរុញឲ្យមានការសន្សំក្នុងសហគមន៍ដែលនាំឲ្យមានហិរញ្ញប្បទានក្នុងសហគមន៍ និងមាននយោបាយគាំទ្រគ្នាទៅវិញទៅមក។

---

[43] ក្រសួងអភិវឌ្ឍន៍ជនបទ, *ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២*, ទំព័រ ៩។

- តាមរយៈធនាគារអភិវឌ្ឍន៍ជនបទ បានបង្កើនសេវាហិរញ្ញប្បទានសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្មដោយផ្តល់ជូនទុនរយៈពេលខ្លី និងទុនរយៈពេលវែង។ ចំពោះទុនរយៈពេលខ្លី គឺដើម្បីទិញស្រូវស្តុកទុកសម្រាប់តម្រូវការក្នុងស្រុក និងនាំចេញ។ ចំណែក ទុនរយៈពេលវែង គឺផ្តល់ជូនសម្រាប់វិនិយោគពង្រីក និងទំនើបកម្មម៉ាស៊ីនច្រូតកាត់ និងដំណើរការម៉ាស៊ីន។[44]
- លើកទឹកចិត្តឲ្យមានការប្រណាំងប្រជែងក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដើម្បីបន្ទាបអត្រាការប្រាក់ឲ្យទាបជាងអត្រាទីផ្សារក្រៅផ្លូវការ ក្នុងគោលបំណងឲ្យកសិករបង្កើនកម្ចីដើម្បីពង្រីកនូវផលិតកម្មកសិកម្ម។
- ស្ថាប័នហិរញ្ញវត្ថុជនបទគួរពិនិត្យឡើងវិញនូវលក្ខខណ្ឌរបស់ខ្លួន ដោយធ្វើយ៉ាងណាឲ្យស្ថិតក្នុងភាពសមស្របសម្រាប់កសិករ ដើម្បីពង្រីកផលិកម្ម ក៏ដូចជាកម្រិតជីវភាពរស់នៅ។

### ៣.២.៤.៤ ហេដ្ឋារចនាសម្ព័ន្ធអេឡិចត្រូនិច

ហេដ្ឋារចនាសម្ព័ន្ធអេឡិចត្រូនិច គឺសម្តៅទៅលើព័ត៌មាន និងបច្ចេកវិទ្យាគមនាគមន៍ឌីជីថលដែលផ្សារភ្ជាប់កសិករទៅកាន់ទីផ្សារកសិកម្មដូចជា ព័ត៌មានទីផ្សារ ព័ត៌មានបណ្តុះបណ្តាល តាមរយៈប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ ដូចជាប្រព័ន្ធអ៊ីនធឺណែត វិទ្យុ ទូរទស្សន៍ ទូរស័ព្ទជាដើម ដែលបានសម្រួលឲ្យកសិករបានដឹងពីតម្រូវការទីផ្សារពេលបច្ចុប្បន្ន។ ការអភិវឌ្ឍព័ត៌មាន និងបច្ចេកវិទ្យាគមនាគមន៍ឌីជីថលនេះ គឺប្រៀបប្រដូចទៅនឹងឆ្អឹងខ្នងដែលបានតភ្ជាប់ទំនាក់ទំនងពីទីក្រុង ឬទីប្រជុំជន ទៅកាន់តំបន់ជនបទ ក្នុងគោលបំណងជំរុញការអភិវឌ្ឍវិស័យកសិ-កម្ម។ គេសង្កេតឃើញថា គម្លាតឌីជីថល មានកម្រិតខ្ពស់រវាងប្រជាជននៅតាមទីជនបទ និងទីក្រុងដោយសារតែការប្រើប្រាស់សេវាទូរគមនាគមន៍ទាំងនោះ ភាគច្រើនមាននៅតាមទីប្រជុំជន ជាហេតុធ្វើឲ្យមានវិសមភាពនៃការទទួលបានឱកាស និងផលប្រយោជន៍នានាសម្រាប់កសិករ ដែលបានផ្តល់តាមបច្ចេកវិទ្យាឬប្រព័ន្ធអ៊ីនធឺណែតក្នុងសង្គមដូចជាព័ត៌មានពាក់ព័ន្ធនឹងតម្រូវទីផ្សារកសិកម្ម ឱកាសក្នុងការបណ្តុះបណ្តាលបច្ចេកទេសកសិកម្មពីសំណាក់អ្នកជំនាញ និងឱកាសស្តីពីការរៀនជំនាញបំប៉នផ្សេងៗសម្រាប់កសិករជាដើម។ យ៉ាងណាមិញ រាជរ-ដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានខិតខំអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធអេឡិចត្រូនិចនេះ ដោយបានជំរុញធ្វើឲ្យកំណើននៃការប្រើប្រាស់សេវាមានសន្ទុះគួរឲ្យកត់សម្គាល់ដែលក្នុងនោះ អត្រានៃការលក់ស៊ីមកាតទូរស័ព្ទចល័តមានចំនួនប្រមាណ ២០.៦លាន ស្មើនឹង ១៣៦%នៃប្រជាជនសរុបក្នុងឆ្នាំ ២០១៥ ហើយអត្រានៃការជាវសេវាប្រើប្រាស់អ៊ីនធឺណែតមានចំនួនប្រមាណ ៦.៨លាន ដែលស្មើនឹង ៤៥%នៃ

[44] ធនាគារអភិវឌ្ឍន៍ជនបទ, *មូលនិធិទ្រទ្រង់និងអភិវឌ្ឍន៍វិស័យកសិកម្ម*, ភ្នំពេញ៖ http://www.rdb.com.kh/km/our-project/rice-miller/ (ចូលទស្សនាថ្ងៃទី១៥ មិថុនា ២០២០)

ចំនួនប្រជាជនសរុបក្នុងឆ្នាំ ២០១៥ដដែល។[45] មួយវិញទៀត ក្នុងឆ្នាំ ២០១៦ ប្រជាជនប្រមាណ ៨៨%នៃប្រជាជនសរុបអាចទទួលបានព័ត៌មានអប់រំ ព័ត៌មានសេដ្ឋកិច្ចផ្សេងៗដែលផ្សាយតាមវិទ្យុ និងទូរទស្សន៍ ហើយមានប្រជាជនប្រមាណ ៥២%នៃប្រជាជនសរុបទទួលបានព័ត៌មានទាំងអស់នោះតាមទស្សនាវដ្ដី ព្រឹត្តិប័ត្រ និងកាសែត ក្នុងឆ្នាំ ២០១៦ដដែល។[46] តាមទិន្នន័យទាំងពីរនេះបញ្ជាក់ឲ្យឃើញថា សន្ទុះនៃការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធអេឡិចត្រូនិចមានការកើនឡើងយ៉ាងខ្លាំង ទាំងក្នុងទីប្រជុំជននិងតំបន់ជនបទ ជាហេតុនាំឲ្យការទទួលបានព័ត៌មានអប់រំ ក៏ដូចជាព័ត៌មានទីផ្សារពីសំណាក់ប្រជាជនក្នុងប្រទេស ជាពិសេសគឺប្រជាជនក្នុងតំបន់ជនបទកាន់តែមានភាពទូលំទូលាយជាងមុន ព្រមទាំងសុក្រឹតភាពជាមុនផងដែរ។ ដោយមើលឃើញពីកត្តាទាំងនេះហើយ រាជរដ្ឋាភិបាលកម្ពុជា ត្រូវតែខិតខំបន្ថែមទៀតក្នុងការពង្រីកហេដ្ឋារចនាសម្ព័ន្ធអេឡិចត្រូនិចឲ្យកាន់តែមានវិសាលភាពទូទាំងប្រទេស ជាពិសេសគឺតំបន់ជនបទ តាមរយៈការផ្សព្វផ្សាយព័ត៌មានបច្ចេកទេសកសិកម្ម ទីផ្សារកសិកម្មទៅកាន់កសិករ ធ្វើការបញ្ជ្រាបការប្រើប្រាស់ភាសាជាតិទៅក្នុងមាតិកាព័ត៌មានឲ្យបានច្រើនដើម្បីងាយស្រួលដល់កសិករ បង្ហាត់បង្រៀនដល់ប្រជាជនតំបន់ជនបទពីសំណាក់មន្ត្រីជំនាញមូលដ្ឋានឲ្យចេះប្រើ និងពង្រីកនូវសេវាអ៊ីនធឺណែតដើម្បីឲ្យពួកគាត់ទាញផលប្រយោជន៍ពីប្រព័ន្ធទាំងអស់នោះជាអតិបរមា។

## ៣.៣ ទីផ្សារកសិកម្ម

ទីផ្សារ មានន័យទូលំទូលាយណាស់ទៅតាមសម័យកាល និងទស្សនៈរបស់អ្នកប្រាជ្ញផ្សេងៗគ្នា ហើយវាមិនសម្ដៅតែលើសកម្មភាពទិញ និងលក់ប៉ុណ្ណោះទេ។ ជាក់ស្ដែង តាមទស្សនៈរបស់លោក Richard Kohls បាននិយាយថា ទីផ្សារគឺជាសកម្មភាពទាំងឡាយណាដែលពាក់ព័ន្ធចាប់តាំងពីដំណាក់កាលដំបូងនៃផលិតកម្មទំនិញ និងសេវាកម្មរហូតដល់ដំណាក់កាលដែលទំនិញនិងសេវាកម្មទាំងនោះបានស្ថិតក្នុងដៃអ្នកប្រើប្រាស់ចុងក្រោយ។[47] ដោយឡែក បើនិយាយតាមភាសាសាមញ្ញនៃសេដ្ឋកិច្ច ទីផ្សារគឺជាស្ថានភាពមួយដែលកើតឡើងក្នុងកំឡុងពេលជួបគ្នារវាងផលិតករ និងអ្នកប្រើប្រាស់។ ស្ថិតនៅក្រោមការបំភ្លឺពីនិយមន័យទីផ្សារខាងលើ យើងអាចទាញរកនិយមន័យទីផ្សារកសិកម្មបាន។ ទីផ្សារកសិកម្ម គឺជាការបញ្ចូលគ្នានូវគ្រប់ទិដ្ឋភាពទាំងអស់រាប់ចាប់តាំងពីមុនពេលដាំដុះ អំឡុងពេលដាំដុះ និងរហូតដល់ផលិតផលទៅដល់ដៃអ្នកប្រើប្រាស់ចុងក្រោយ។[48] ភាពចាំបាច់នៃទីផ្សារកសិកម្មនៅកម្ពុជាគឺ កំណើន ស្ថេរភាពសេដ្ឋកិច្ច បង្កើនប្រាក់ចំណូលជូនដល់កសិករ ផ្ដល់ឱ-

[45] ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, *គោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានឆ្នាំ ២០២០*, ទំព័រ ៧។

[46] រាជរដ្ឋាភិបាលកម្ពុជា, *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣*, ទំព័រ ៩១។

[47] Dr. Pranav K. Desai, *Agricultural Economics[សេដ្ឋកិច្ចកសិកម្ម], (បោះពុម្ពឆ្នាំ២០១០)*, ទំព័រ ៩៨។

[48] យាំង ចុងហ៊ី, ឡី គឹមហេង, មុច សាមីន, ធន់ វឌ្ឍនា និង អាត សុផាត, *សេចក្ដីផ្ដើមនៃទីផ្សារកសិកម្ម (២០១៩)*, ទំព័រ ៤។

កាសការងារ ពង្រីកនវានុវត្តន៍ពីឧបករណ៍ប្រើប្រាស់ដោយដៃទៅជាគ្រឿងម៉ាស៊ីន ពង្រីកចំណេះដឹង និងជំនាញ ដើម្បីគាំទ្រតួអង្គពាក់ព័ន្ធក្នុងវិស័យកសិកម្មទទួលបានអត្ថប្រយោជន៍ជាអតិបរមា ក៏ដូចជាបង្កើតទំនាក់ទំនងក្នុងខ្សែសង្វាក់ទីផ្សារកសិកម្មដោយបានចែករំលែកព័ត៌មាន តម្រូវការពីគ្នាដោយផ្ទាល់រហ័ស និងទាន់ពេលវេលា។

### ៣.៣.១ សារៈសំខាន់របស់ទីផ្សារកសិកម្ម[49]

ទីផ្សារកសិកម្ម បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងសេដ្ឋកិច្ចនៃប្រទេសមួយដែលពឹងផ្អែកជាចម្បងទៅលើវិ-ស័យកសិកម្ម។ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ដូចជាប្រទេសកម្ពុជា ទីផ្សារកសិកម្មគឺជាកត្តាកំណត់ជាក់លាក់ទៅដល់កំណើន និងស្ថេរភាពសេដ្ឋកិច្ចនៅក្នុងប្រទេស ដោយបានជួយកសិករក្នុងការបង្កើនប្រាក់ចំណូលរបស់ពួកគេ តាមរយៈការលក់ផលិតផលដែលផលិតលើស(គឺជាផលិតផលដែលផលិតបានច្រើនជាងការប្រើប្រាស់)ទៅកាន់ទីផ្សារ។ បន្ថែមពីនេះ ទីផ្សារកសិកម្មកាន់តែមានសារៈសំខាន់ខ្លាំងឡើង តាមរយៈការផ្គត់ផ្គង់ស្បៀងអាហារទៅដល់ប្រជាជនទាំងអស់ដែលកំពុងតែកើនឡើង។ ទីផ្សារកសិកម្ម ជាតំណភ្ជាប់កសិករទៅនឹងអ្នកប្រើប្រាស់ចុងក្រោយ។ ជាមួយគ្នានោះដែរ បានផ្តល់ការងារឱកាសការងារដល់មនុស្សជាច្រើនដូចជាកសិករ ឈ្មួញកណ្តាល អ្នកដឹកជញ្ជូន អ្នកកែច្នៃ និងពាណិជ្ជករដែលធ្វើការជាប់ពាក់ព័ន្ធនឹងវិស័យកសិកម្ម។ វាក៏បានជួយលុបបំបាត់នូវបញ្ហាកម្លាំងពលកម្មរបស់ប្រទេសផងដែរ តាមរយៈនវានុវត្តន៍ដែលបង្កើតឱកាសឲ្យមនុស្សបង្កើតនូវអ្វីដែលថ្មី(Innovation) ដើម្បីជំរុញការងាររបស់ពួកគេនៅក្នុងកសិដ្ឋាន។ មនុស្សបង្កើតឧបករណ៍ដែលប្រើប្រាស់ដោយដៃទៅជាគ្រឿងម៉ាស៊ីនសម្រាប់សម្រួលដល់ការងារពួកគេដូចជា ត្រាក់ទ័រ ម៉ាស៊ីនស្រោចស្រព ម៉ាស៊ីនភ្ជួររាស់ ម៉ាស៊ីនច្រូត ម៉ាស៊ីនស្ទូង ជ្រូនកសិកម្មជាដើម។ លើសពីនេះ អ្នកដែលធ្វើការពាក់ព័ន្ធនឹងវិស័យកសិកម្មមានជំនាញ និងចំណេះដឹងជាក់លាក់អំពីកសិកម្ម ហើយពួកគេអាចធ្វើឲ្យផលិតផលរបស់ខ្លួនកាន់តែប្រសើរឡើង ទាំងបរិមាណ និងគុណភាពសម្រាប់បំពេញតាមស្តង់ដារទីផ្សារ តាមរយៈការកែលម្អតម្លៃលក់ផលិតផល អភិវឌ្ឍន៍ជំនាញបច្ចេកទេសដល់កសិករ និងពាណិជ្ជករអំពីបច្ចេកទេសក្រោយពេលប្រមូលផលដូចជា ការសម្អាត ការវេចខ្ចប់ ការស្តុកទុក ការដឹកជញ្ជូន និងការផ្សព្វផ្សាយជាដើម។ ជាពិសេស ទីផ្សារកសិកម្មបានធ្វើឲ្យកសិករដឹងនូវដំណាំដែលត្រូវដាំ អ្នកលក់អាចស្វែងរកកសិករដើម្បីទិញកសិផលនិងលក់ទៅវិញឲ្យអ្នកប្រើប្រាស់ក្នុងគោលបំណងទទួលបានប្រាក់ចំណេញ ហើយអ្នកទិញអាចដឹងថាត្រូវទិញផលិតផលនៅកន្លែងណា ក្នុងតម្លៃណា។ ជាងនេះទៅទៀត ព័ត៌មានទីផ្សារអាចជួយកាត់បន្ថយហានិភ័យរបស់កសិករដែលកើតនៅលើទីផ្សារដោយឲ្យកសិករដឹងថាគួរលក់ផលិតផលចេញនៅពេលវេលាណាទើបបានផលចំណេញ។ បន្ថែមពីលើនេះ ទី-ផ្សារកសិកម្មក៏បានប្រាប់កសិករ ឬពាណិជ្ជករពីរបៀបនៃការវេចខ្ចប់ទៅតាមទំហំ ប្រភេទ រូបរាងមុននឹងលក់

[49] យាំង ចុងហ៊ី, ឡឺ គឹមហេង, មុច សាមីន, ធន់ វឌ្ឍនា និង អាត សុជាត, *សេចក្តីផ្តើមនៃទីផ្សារកសិកម្ម (២០១៩)*, ទំព័រ ៥-៧។

ទម្រង់ផលិតផល និងគុណភាព មុនពេលដឹកជញ្ជូនទៅកាន់ទីផ្សារ ព្រមទាំងអ្នកប្រើប្រាស់ ពីព្រោះថាការវេចខ្ចប់ដែលល្អ នឹងមានការបញ្ជាទិញកាន់តែច្រើន។

### ៣.៣.២ ការតភ្ជាប់កសិករទៅកាន់ទីផ្សារក្នុងស្រុក

កសិករទាំងឡាយ គឺជាក្រុមគ្រួសារជនបទដែលត្រូវបានគេផ្សារភ្ជាប់ទៅនឹងទីផ្សារកសិកម្ម។ នៅក្នុងបរិបទជាក់ស្តែង គេពិបាកនឹងកំណត់កសិដ្ឋានជាលក្ខណៈគ្រួសារកសិករណាស់ ដូច្នេះ ស្ថាប័នពាក់ព័ន្ធត្រូវបង្កើតនូវវិធីសាស្ត្រដែលផ្សារភ្ជាប់កសិករទាំងលក្ខណៈគ្រួសារ និងមិនមែនគ្រួសារទៅនឹងទីផ្សារកសិកម្ម និងកត្តាផលិតកម្មផ្សេងៗ។ យើងបានដឹងហើយថា ក្រោយពីច្រូតកាត់ និងប្រមូលផលកសិផលហើយភ្លាម កសិករដែលក្រីក្រភាគច្រើនបានជ្រើសរើសលក់ស្រូវទៅឲ្យឈ្មួញកណ្តាលដែលជាវិធីសាស្ត្រពេញនិយមមួយជាងគេ ពីព្រោះឈ្មួញកណ្តាលមានឃ្លាំងស្តុកទុកផលិតផល មានមធ្យោបាយដឹកជញ្ជូន ដែលងាយស្រួលសម្រាប់កសិករដោយមិនចាំបាច់មានមធ្យោបាយដឹកជញ្ជូន និងឃ្លាំងស្តុកកសិផល។ ការលក់ស្រូវទៅឲ្យឈ្មួញកណ្តាលមានគុណវិបត្តិចម្បងមួយគឺ ទទួលបានតម្លៃថោក។ ប្រការនេះហើយដែលធ្វើឲ្យកសិករភាគច្រើនកាន់តែមានជីវភាពលំបាកទៅៗ ដោយសារប្រាក់ចំណូលពីការលក់ផលិតផលស្រូវមិនបានច្រើន ពិបាកនឹងទូទាត់ចំនួនទឹកប្រាក់សរុបដែលចំណាយក្នុងការទិញធាតុផ្សំកសិកម្មដូចជា ជីកសិកម្ម គ្រាប់ពូជ ប្រព័ន្ធស្រោចស្រព ថ្លៃគ្រឿងចក្រកសិកម្ម និងសល់មួយចំណែកសម្រាប់ប្រាក់ចំណេញពីការលក់ នេះនៅមិនទាន់បូកបញ្ចូលប្រាក់ដែលត្រូវបង់ធនាគាររបស់កសិករដែលមានកម្ចីផង។ ហេតុដូចនេះ ការលុបបំបាត់ឈ្មួញកណ្តាលដែលនៅចន្លោះរវាងកសិករនិងអ្នកប្រើប្រាស់ នឹងជំរុញឲ្យថ្លៃកសិករទទួលបានកើនឡើងខ្ពស់ជាងមុន។ ការពង្រីកទីផ្សារក្នុងស្រុក និងបង្កើនការកែច្នៃកសិផលឬកសិ-ឧស្សាហកម្មសម្រាប់ការនាំចេញ ជាការងារដែលក្រសួងពាក់ព័ន្ធត្រូវយកចិត្តទុកដាក់ ដើម្បីធ្វើឲ្យផលិតផលកសិកម្មមានតម្រូវការកើនឡើង។ បច្ចុប្បន្ននេះ ក្រសួងពាណិជ្ជកម្មបានសហការណ៍ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈការបង្កើតនូវពិពណ៌កសិកម្ម ក្នុងគោលបំណងជំរុញផលិតផលកសិកម្មឲ្យមានប្រជាប្រិយភាព មានតម្រូវការក្នុងស្រុក និងកាត់បន្ថយការប្រើប្រាស់ទំនិញកសិកម្មនាំចូលដើម្បីលើកទឹកចិត្តកសិករក្នុងស្រុកឲ្យបន្ថែមការដាំដុះ។ មួយវិញទៀត ក្រៅពីការផ្សព្វផ្សាយព័ត៌មានទីផ្សារតាមរយៈទូរទស្សន៍ វិទ្យុ ព្រឹត្តិប័ត្រព័ត៌មាន ការសែត ក្នុងពេលថ្មីៗនេះទៀតសោត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចាត់វិធានការបន្ថែមដើម្បីផ្សារភ្ជាប់កសិករទៅកាន់ទីផ្សារឲ្យកាន់តែមានភាពស្អិតរមួតដោយបានបង្កើតគេហទំព័រ សេវាព័ត៌មានទីផ្សារកសិកម្ម ជាទីដែលកសិករ និងពាណិជ្ជករអាចទាក់ទងគ្នាដោយផ្ទាល់ក្នុងការទិញនូវកសិផល និងដឹងពីទិន្នន័យតម្លៃកសិផលរាប់សិបមុខបន្ថែមទៀត។ គេហទំព័រនេះ ជាប្រភពដែលអាចផ្តល់នូវព័ត៌មានដ៏មានសារៈប្រយោជន៍ ដើម្បីជួយកសិករឲ្យកាន់តែទទួលបានជោគជ័យលើទីផ្សារកសិកម្ម

ដោយបានកាត់បន្ថយវត្តមានរបស់ឈ្មួញកណ្តាល។ ទន្ទឹមនឹងនេះដែរ ការបង្កើតជាសហគមន៍អភិវឌ្ឍន៍កសិកម្មផ្សេងៗក៏ត្រូវដើរទន្ទឹមគ្នាផងដែរ ដើម្បីធានាដល់ការផ្គត់ផ្គង់ផលិតផលកសិកម្មទៅតាមតម្រូវការទីផ្សារប្រកបដោយចីរភាព។ [50] ក្រៅពីនេះ ការទាក់ទាញវិនិយោគតាមរយៈការបង្កើតតំបន់កែច្នៃផលិតផលកសិកម្មសម្រាប់ការនាំចេញ ជាកិច្ចការដែលត្រូវគិតគូរឲ្យខ្លាំងក្លា ពីព្រោះវាកន្លែងដែលធ្វើឲ្យមានតម្រូវការកសិផលយ៉ាងខ្លាំង មិនតែប៉ុណ្ណោះវាក៏នាំមកនូវមូលធន និងបច្ចេកវិទ្យាថ្មីមកកាន់ប្រទេស សម្រាប់ពន្លឿនដំណើរការកសិកម្ម។

### ៣.៣.៣ ផលិតផលកសិកម្មក្នុងទីផ្សារអន្តរជាតិ

កិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទតាមរយៈវិធានការពាក់ព័ន្ធនឹងផលិតកម្មដំណាំកសិកម្ម ពង្រឹងនិងពង្រីកសមត្ថភាពវិទ្យាស្ថានអភិវឌ្ឍន៍កសិកម្ម ជំរុញបន្ថែមនូវរចនាសម្ព័ន្ធផ្សព្វផ្សាយកសិកម្ម លើកកម្ពស់សមត្ថភាពកសិករនិងសហគមន៍កសិកម្មដែលផ្តោតសំខាន់លើការផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេស និងការផ្សារភ្ជាប់ទីផ្សារកសិកម្ម បានធ្វើឲ្យវិស័យកសិកម្មកម្ពុជាប្រែក្លាយមុខមាត់ថ្មីទាំងក្នុងស្រុក និងទីផ្សារអន្តរជាតិ។ ការវិនិយោគកន្លងមកនេះ បានធ្វើឲ្យមានការផ្លាស់ប្តូរជាវិជ្ជមានគួរឲ្យកត់សម្គាល់ ដោយបានប្រែក្លាយកម្ពុជាពីប្រទេសដែលជួបប្រទះបញ្ហាឱនភាពស្បៀង ទៅជាប្រទេសដែលសម្រេចបានសន្តិសុខស្បៀងនៅក្នុងឆ្នាំ១៩៩៥ ហើយបច្ចុប្បន្ននេះជាប្រទេសដែលមានអតិរេកផលិតផលកសិកម្មរាប់តោនក្នុងមួយឆ្នាំៗសម្រាប់បម្រើឲ្យឧស្សាហកម្មកែច្នៃក្នុងស្រុក និងសម្រាប់ការនាំចេញ។ ជាក់ស្តែងក្នុងឆ្នាំ២០១៩កន្លងមកនេះ កម្ពុជាសម្រេចបានការនាំចេញផលិតផលដំណាំកសិកម្មផ្លូវការដែលអនុវត្តន៍តាមប្រព័ន្ធភូតគាមអនាម័យជាតិ (ជាការធានាក្នុងការនាំចូលផលិតផលកសិកម្មនោះត្រូវមានសុវត្ថិភាព ដើម្បីបង្ការហានិភ័យដល់សុខភាពមនុស្ស សត្វជាដើម) សរុបប្រមាណ ៤,៨៧៦,៩៥៣តោន ដែលបានកើនឡើងប្រមាណ ១៣.២០% ធៀបនឹងការនាំចេញក្នុងឆ្នាំ២០១៨។ ក្នុងនោះដែរ ការនាំអង្ករចេញក្នុងឆ្នាំ២០១៩ សម្រេចបានចំនួន ៦២០,១០៦តោន ទៅកាន់ទីផ្សារអន្តរជាតិទាំង៥៩ប្រទេស ដែលទីផ្សារធំរបស់កម្ពុជាគឺនាំចេញទៅប្រទេសចិនចំនួន ២៤៨,១០៥តោន ស្មើនឹង៤០.៧៣% ទៅកាន់សហគមន៍អឺរ៉ុប(២៥ប្រទេស) ចំនួន ២០២,៩៩០តោន ស្មើនឹង៣២% ទៅកាន់ប្រទេសក្នុងតំបន់អាស៊ាន(៦ប្រទេស) ចំនួន៨៣,១៦៤តោន ស្មើនឹង១៣.៤១% និងទៅកាន់២៧ប្រទេសផ្សេងៗទៀតចំនួន ៨៥,៨៤៧តោន ស្មើនឹង១៣.៨៤%នៃការនាំចេញអង្ករផ្លូវការសរុប។ ទោះបីបរិមាណនាំចេញអង្ករផ្លូវការក្នុងឆ្នាំ២០១៩ មានការធ្លាក់ចុះបន្តិច(-0.៩%)ក៏ដោយ ក៏បរិមាណនាំចេញអង្ករក្រអូបគ្រប់ប្រភេទមានការកើនឡើងគួរឲ្យកត់សម្គាល់ ដែលទំហំនៃការនាំចេញមានចំនួន ៥៣១,៦៤៨តោន ស្មើ

[50] ច័ន្ទ សារុន, *"យុទ្ធសាស្ត្របង្កើនផលិតកម្មដំណាំស្រូវប្រកបដោយចីរភាព"*, (និក្ខេបបទបណ្ឌិត, សាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា, ២០០៦), ទំព័រ ១៣៥។

នឹង៨៥.៧៤% គឺកើនលើសឆ្នាំមុនចំនួន ៣៨,០៥១តោន ខណៈពេលដែលអង្ករចម្រុះមានចំនួនតែ ៨១,២៩១ តោន ស្មើនឹង១៣.១១% និងអង្ករចំហុយចំនួនតែ ៧,១៦៧តោន ស្មើនឹង១.១៦%នៃការនាំចេញអង្ករសរុប។[51] កំណើននៃបរិមាណនាំចេញអង្ករក្រអូបនេះ បានបង្ហាញពីការទទួលស្គាល់ពីគុណភាពល្អរបស់អង្ករកម្ពុជាដោយទីផ្សារអន្តរជាតិ និងម្យ៉ាងទៀតបានបញ្ជាក់អំពីការរីកចម្រើននៅក្នុងឧស្សាហកម្មស្រូវ អង្ករកម្ពុជាដែលបាននឹងកំពុងធ្វើពិពិធកម្ម ប្រពលវប្បកម្មផ្តោតលើមុខទំនិញដែលមានឧត្តមភាពប្រៀបធៀប ដែលជាបច្ច័យមួយជួយឲ្យកម្ពុជាអាចបង្កើនការប្រកួតប្រជែងប្រជែង ទាំងទីផ្សារក្នុងស្រុកនិងទីផ្សារអន្តរជាតិ។

ក្រាហ្វិកទី ១០៖បង្ហាញពីស្ថានភាពនៃការនាំចេញកសិផលសរុប និងអង្ករផ្លូវការឆ្នាំ ២០១៥-២០១៩




ប្រភព៖ របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ ២០១៩-២០២០

តាមក្រាហ្វិកខាងលើបង្ហាញថា ការនាំចេញផលិតផលកសិកម្មមាននិន្នាការកើនឡើងជាលំដាប់ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ។ ជាក់ស្តែង ការនាំចេញដំណាំកសិកម្មបានកើនឡើងពី ៤,១៥៧,២៤៦តោន ក្នុងឆ្នាំ ២០១៥ ទៅដល់៤,៨៧៦,៩៥៣តោន ក្នុងឆ្នាំ ២០១៩។ ហើយសម្រាប់ដំណាំស្រូវផ្លូវការក៏មានសន្ទុះគួរឲ្យកត់សម្គាល់ដែរ ដោយបានកើនឡើងពី ៣៣៨,៣៩៦តោន ក្នុងឆ្នាំ២០១៥ ទៅដល់ ៦២០,១០៦តោន ក្នុងឆ្នាំ២០១៩ ពោលគឺមានការកើនឡើងស្ទើរ ២ដង។ ដោយមើលឃើញពីតម្រូវការផលិតផលកសិកម្មមានការកើនឡើងជាលំដាប់ពីសំណាក់ទីផ្សារអន្តរជាតិ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការចរចារបើកទីផ្សារ និងពង្រីកទំហំនៃការនាំចេញផលិផលដំណាំសំខាន់ៗបន្ថែមទៀត ជាអាទិ៍រួមមាន៖

[51] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ ២០១៩-២០២០*, ទំព័រ ២១-២២។

(១)**ទីផ្សារប្រទេសចិន** បានចុះបញ្ជីបន្ថែមលើម៉ាស៊ីនកិនស្រូវចំនួន ១៨ទៀត ដើម្បីពង្រីកសមត្ថភាពនាំចេញអង្ករទៅកាន់ទីផ្សារប្រទេសចិន ព្រមទាំងបានចរចារបន្ថែមទៀតស្ដីពីលក្ខខណ្ឌតម្រូវភូតគាមអនាម័យផងដែរ។

(២)**ទីផ្សារអឺរ៉ុប** ជានិច្ចកាល កម្ពុជាបានខិតខំពង្រីកការនាំចេញផលិតផលកសិកម្មរបស់ខ្លួនទៅក្នុងសហភាពអឺរ៉ុប ដោយសារកម្ពុជាមានភាពអនុគ្រោះពន្ធគយសម្រាប់ទីផ្សារអឺរ៉ុបទាំងមូល(EBA) ដែលកត្តានេះហើយជំរុញឲ្យកម្ពុជាមានឧត្តមភាពប្រៀបធៀបខាងផលិតផលកសិកម្ម ផ្នែកតម្លៃជាងប្រទេសដែលនាំចេញកសិផលដូចគ្នា។ ក៏ប៉ុន្តែ ទីផ្សារនៅសហគមន៍អឺរ៉ុប បានរឹតបន្តឹងផ្នែកស្តង់ដារអង្ករ អនាម័យ និងភូតគាមអនាម័យ(SPS) ដែលតម្រូវឲ្យផលិតកម្មកសិកម្មរបស់កម្ពុជាត្រូវតែខិតខំពង្រឹងទាំងគុណភាព និងបរិមាណឲ្យត្រូវជាមួយបទដ្ឋានស្តង់ដារទាំងនោះបន្ថែមទៀត ទើបអាចចាប់យកផលចំណេញដែលសហភាពអឺរ៉ុបផ្តល់ឲ្យកម្ពុជាជាអតិបរមា។

(៣)**ទីផ្សារប្រទេសកូរ៉េ** បានសម្រេចនូវលក្ខខណ្ឌតម្រូវភូតគាមអនាម័យមួយចំនួនផងដែរ នៃការនាំចេញផលិតផលកសិកម្ម។

(៤)**ទីផ្សារប្រទេសថៃ** បានចាប់ផ្តើមនីតិវិធីចរចារបើកទីផ្សារបន្ថែមទៀតដែរក្នុងការនាំចេញកសិផល។

## ៣.៤ បទពិសោធន៍កសិកម្មរបស់ប្រទេសក្នុងតំបន់អាស៊ាន( ASEAN )

### ៣.៤.១ ប្រទេសថៃ

ប្រទេសថៃគឺជាប្រទេសឧស្សាហកម្មថ្មីមួយដែលមាន ផ.ស.ស ប្រមាណ ១៦.៣១៦ពាន់ពាន់លានបាត ឬ ៥០៥ពាន់លានដុល្លារ នៅក្នុងឆ្នាំ២០១៨ ដែលជាប្រទេសមានសេដ្ឋកិច្ចធំជាងគេទី៨ នៅអាស៊ីនេះបើយោងតាមធនាគារពិភពលោក។ ដោយឡែក នៅប្រទេសថៃ វិស័យកសិកម្មបានរួមចំណែកតែ ៨%ប៉ុណ្ណោះក្នុង ផ.ស.ស។ នៅក្នុងឆ្នាំ២០១៨ តម្លៃនៃការនាំចេញផលិតផលកសិកម្មមានចំនួន១,៣៨៨,៥៤១លានបាត (ប្រហែល ៤៤,៧៩២លានដុល្លារអាមេរិក) ដែលស្មើនឹងប្រមាណ ១៧%នៃការនាំចេញសរុប។ ប្រជាជនប្រហែល៣០% គឺស្ថិតក្នុងសកម្មភាពកសិកម្ម។ ដីដែលទុកសម្រាប់ផលិតផលកសិកម្មមានប្រមាណ ២៤លានហិកតា ឬ ៤៦% នៃផ្ទៃដីសរុបរបស់ប្រទេស និងជិតពាក់កណ្តាលនៃដីកសិកម្មគឺជាដីស្រែ ប៉ុន្តែមានតែប្រមាណ ២៥%ប៉ុណ្ណោះដែលត្រូវបានស្រោចស្រព (ក្រសួងកសិកម្ម និងសហប្រតិបត្តិការឆ្នាំ២០១៧)។ ផលិតផលកសិកម្មរបស់ប្រទេសថៃភាគច្រើនដែលត្រូវបាននាំចេញគឺជាប់ចំណាត់ថ្នាក់កំពូលទាំង១០ ហើយមានចំណែកទីផ្សារនៅលើពិភពលោកយ៉ាងច្រើនក្នុងផលិតផលស្រូវ-អង្ករ។ យ៉ាងណាមិញ វិស័យកសិកម្មរបស់ប្រទេសនៅតែប្រឈមនឹង

បញ្ហាមួយចំនួនដូចជា តម្លៃនៃផលិតផលកសិកម្មមានការឡើងចុះមិនទៀង ការប្រើធាតុផ្សំ(Inputs)កសិកម្មមិនសមស្រប កង្វះទឹកប្រើប្រាស់ ការថយចុះនៃធនធានធម្មជាតិ និងកសិករមានវ័យចំណាស់ច្រើន។[52]

### ៣.៤.២ សមិទ្ធិផលកសិកម្មដែលសម្រេចបាន

ស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ សេដ្ឋកិច្ចរបស់ប្រទេសថៃគឺពឹងផ្អែកលើការនាំចេញដែលមានចំនួនច្រើនជាង ២ភាគ៣ នៃ ផ.ស.ស របស់ប្រទេស។ ផលិតផលសរុបដែលនាំចេញពីប្រទេសថៃត្រូវបានទិញដោយអ្នកនាំចូលរួមមាន សហរដ្ឋអាមេរិក(១២.៨% នៃចំនួនសរុបទូទាំងពិភពលោក) ប្រទេសចិន(១១.៨%) ជប៉ុន(១០%) វៀតណាម(៤.៩%) ហុងកុង(៤.៨%) ម៉ាឡេស៊ី(៤.២%) អូស្ត្រាលី(៤.១%) ឥណ្ឌូណេស៊ី(៣.៧%) សឹង្ហបុរី(៣.៦%) ឥណ្ឌា(៣%) កម្ពុជា(២.៩%) ហ្វីលីពីន(២.៨%)។ ចំពោះការនាំចេញកសិផលវិញ ប្រទេសថៃបាននាំចេញទំនិញសំខាន់ជាងគេ គឺអង្ករ។

- **អង្ករ៖** ប្រទេសថៃគឺជាប្រទេសមួយដែលមានផលិតភាពកសិកម្មខ្លាំងទាំងនៅក្នុងតំបន់ និងនៅលើឆាកអន្តរជាតិ។ ដោយនៅក្នុងឆ្នាំ២០១៧ ប្រទេសថៃអាចផលិតស្រូវទទួលបានទិន្នផលសរុបរហូតទៅដល់ ៣២,៦៨៧,៧៥៧តោន ជាមួយនឹងផ្ទៃដីប្រមូលផលសរុបចំនួន ២៧,៧០២,១៩១ហិកតា។[53] ក្នុងនោះដែរប្រទេសថៃនាំចេញអង្ករទៅកាន់ទីផ្សារពិភពលោកបានរហូតចំនួន ៩,៩៦៧,០៣២តោន នៅក្នុងឆ្នាំ ២០១៧។[54]

តារាងទី ២៖ បង្ហាញពីទិន្នផលសរុប ផ្ទៃដីប្រមូលស្រូវ និងបរិមាណនាំចេញសរុប

| ឆ្នាំ | ស្រូវ/អង្ករ | | | |
|---|---|---|---|---|
| | ទិន្នផល(តោន) | ផ្ទៃដីប្រមូលផល (ហិកតា) | នាំចេញ(តោន) | ពលកម្មក្នុងកសិកម្មនៃពលកម្មសរុប(%) |
| ២០១៥ | ២៧,៧០២,១៩១ | ៩,៧១៧,៩៧៥ | ៨,៦១៧,៥៣៥ | ៣២.២៨ |
| ២០១៦ | ២៥,៣១២,៣៧៨ | ៨,៦៩៧,៣៣០ | ៨,៤៣០,២២៩ | ៣១.១៦ |
| ២០១៧ | ៣២,៦៨៧,៧៥៧ | ១០,៥០១,៩៥២ | ៩,៩៦៧,០៣២ | ៣១.៤៥ |

តាមតារាងខាងលើបង្ហាញថា ទិន្នផលសរុបរបស់ដំណាំស្រូវក្នុងប្រទេសថៃមាននិន្នាការកើនឡើងជារៀងរាល់ឆ្នាំ។ ជាក់ស្តែង បើតាមទិន្នន័យក្នុងឆ្នាំ ២០១៧ខាងលើ អាចឲ្យយើងធ្វើការប្រៀបធៀបបានថា ទាំងផ្ទៃដីប្រមូលផលនិងទិន្នផលសរុបក្នុងដំណាំស្រូវរបស់ប្រទេសថៃ មានចំនួនច្រើនជាងប្រទេសកម្ពុជាប្រហែលជិត

[52] Apichart Pongsrihadulchai, គោលនយោបាយកសិកម្ម និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រទេសថៃ, *[Thailand Agriculture Polices and Development Strategies]* (២០១៩), ទំព័រ ១។

[53] FAO, http://www.fao.org/faostat/en/#data/QC,(ចូលទស្សនាថ្ងៃទី២ កក្កដា ២០២០)

[54] FAO, http://www.fao.org/faostat/en/#data/TP,(ចូលទស្សនាថ្ងៃទី២ កក្កដា ២០២០)

៣ដង ក៏ប៉ុន្តែប្រទេសថៃអាចនាំចេញទៅកាន់ទីផ្សារអន្តរជាតិបានច្រើនជាងប្រទេសកម្ពុជារហូតទៅដល់ ១០ដង នៃបរិមាណស្រូវ-អង្ករដែលកម្ពុជាអាចនាំចេញទៅទីផ្សារអន្តរជាតិបាន។ ងាកមកកម្លាំងពលកម្មក្នុងឆ្នាំ ២០១៧ ដែលធ្វើការក្នុងវិស័យកសិកម្មរបស់ប្រទេសថៃវិញឃើញថា មានចំនួន ៣១.៤៥%នៃកម្លាំងពលកម្មសរុប ដែលតួលេខមួយនេះមានចំនួនតិចជាងចំនួនកម្លាំងពលកម្មក្នុងវិស័យកសិកម្មរបស់ប្រទេសកម្ពុជា ដែលអាចបញ្ជាក់បានថាវិស័យកសិកម្មក្នុងប្រទេសថៃមានការអភិវឌ្ឍច្រើន ទើបធ្វើឲ្យវិស័យមួយនេះមានអត្រាភាគរយក្នុងការស្រូបយកកម្លាំងពលកម្មបានតិច។[55] ទាំងនេះអាចបណ្តាលមកពីផលិតភាពកសិកម្មប្រទេសថៃខ្ពស់ បូករួមជាមួយផលិតភាពកសិករល្អ ការប្រើប្រាស់ជីនិងថ្នាំកសិកម្មបានត្រឹមត្រូវ គ្រាប់ពូជមានផលិតភាព ប្រព័ន្ធស្រោចស្រពសម្បូរបែប គ្រឿងយន្តកសិកម្មមានច្រើនជាដើម ដែលជាមូលហេតុបណ្តាលឲ្យកសិផលប្រទេសថៃមានគុណភាពខ្ពស់ជាង ហើយត្រូវស្តង់ដាររបស់ទីផ្សារពិភពលោកជាងកម្ពុជា។

### ៣.៤.៣ ផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្មក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមជាតិលើកទី១២ (២០១៧-២០២១)

ចក្ខុវិស័យនៃផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំនេះ គឺសង្កត់ធ្ងន់ទៅលើវិស័យកសិកម្មឲ្យឈានទៅមុខបានតាមរយៈបច្ចេកវិទ្យា និងភាពច្នៃប្រឌិត លើកកម្ពស់កម្រិតជីវភាពកសិករ ដើម្បីធានាបាននូវតុល្យភាព និងនិរន្តរភាពនៃធនធានធម្មជាតិ។ ចក្ខុវិស័យនៃផែនការអភិវឌ្ឍន៍នេះមានគោលបំណង (១) ដើម្បីលើកកម្ពស់ស្វ័យភាពវិជ្ជាជីវៈកសិកម្ម តាមរយៈការបន្តផ្ទេរនូវផ្នែកបច្ចេកវិទ្យា បង្កើតជាសហគមន៍កសិករ ការផ្សារភ្ជាប់ទំនាក់ទំនងនឹងបណ្តាញខាងក្រៅ និងការធ្វើឲ្យរួមតូចនៃគម្លាតប្រាក់ចំណូល។ (២) ដើម្បីលើកកម្ពស់រវាងកសិករ និងស្ថាប័នរបស់ពួកគេ ក្នុងការបង្កើនផលិតភាព ប្រសិទ្ធភាព និងស្តង់ដាររួម ព្រមទាំង Value added agricultural production ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ។ (៣) ដើម្បីបង្កើនការប្រកួតប្រជែងផលិតផលកសិកម្មក៏ដូចជាការបង្កើននវានុវត្តន៍ក្នុងការស្រាវជ្រាវ បច្ចេកទេស និងការច្នៃប្រឌិត។ (៤) ការអនុវត្តការគ្រប់គ្រងធនធានកសិកម្មឆ្ពោះទៅរកការកែតម្រូវ និងការបន្ស៊ាំខ្លួនទៅនឹងបម្រែបម្រួលអាកាសធាតុ។

ចំពោះផែនការពាក់កណ្តាលអាណត្តិ(៥ឆ្នាំ) របស់ប្រទេសថៃនេះបានដាក់ចេញនូវយុទ្ធសាស្ត្រចំនួន៥ ជាមួយនឹងគោលការណ៍ណែនាំមួយចំនួនដូចខាងក្រោម៖

- **យុទ្ធសាស្ត្រទី១៖** ជំរុញកសិករ និងសហគមន៍កសិករ ដោយដាក់ចេញជាគោលការណ៍ណែនាំចំនួន៤ រួមមាន បង្ការហានិភ័យដែលអាចកើតមានពីការជះឥទ្ធិពលនៃបរិបទសេដ្ឋកិច្ច។ បង្កើតទំនុកចិត្តកសិករ និងសេវា

[55] FAO, http://www.fao.org/faostat/en/#data/OE,(ចូលទស្សនាថ្ងៃទី៧ កក្កដា ២០២០)

ធានារ៉ាប់រងក្នុងផលិតកម្មកសិកម្ម។ លើកកម្ពស់ប្រសិទ្ធភាពនៃកសិកម្មប្រកបដោយចីរភាព។ អភិវឌ្ឍន៍ចំណេះដឹងរបស់កសិករឲ្យក្លាយជាកសិករឆ្លាតវៃ។

- **យុទ្ធសាស្ត្រទី២៖** លើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងទំនិញកសិកម្មតាមខ្សែសង្វាក់ផ្គត់ផ្គង់របស់ខ្លួនដោយមានការណែនាំដូចជា ជំរុញការផលិតនូវផលិតផលកសិកម្មដើម្បីឆ្លើយតបទៅនឹងស្តង់ដារទីផ្សារ។ ការកែលម្អការគ្រប់គ្រងចង្វាក់ផ្គត់ផ្គង់ផលិតផលកសិកម្ម។ ការបន្ថែមតម្លៃដល់ផលិតផលកសិកម្ម។ បង្កើតមជ្ឈមណ្ឌលទីផ្សារកសិកម្ម និងពង្រីកបណ្តាញទីផ្សារកសិកម្ម។ ការបង្កើតនូវសន្តិសុខស្បៀងដោយចីរភាពដោយការគ្រប់គ្រងភាពអាសន្ននៃស្បៀងអាហារ។ លើកកម្ពស់ភាពជាដៃគូជាមួយវិស័យឯកជនសាធារណៈ។ គាំទ្រការគ្រប់គ្រងហានិភ័យដែលប៉ះពាល់ដល់កសិកម្ម។ ជំរុញការធ្វើពាណិជ្ជកម្មតាមតំបន់សេដ្ឋកិច្ចពិសេស។
- **យុទ្ធសាស្ត្រទី៣៖** ការបង្កើនភាពប្រកួតប្រជែងនៃវិស័យកសិកម្មជាមួយនឹងបច្ចេកវិទ្យា និងការច្នៃប្រឌិតដោយមានគោលការណ៍ចំនួន៣ រួមមាន ជំរុញ និងគាំទ្រដល់ការស្រាវជ្រាវក្នុងវិស័យកសិកម្ម បច្ចេកវិទ្យា និងការច្នៃប្រឌិត។ អភិវឌ្ឍន៍បច្ចេកវិទ្យានៃព័ត៌មានកសិកម្ម។ លើកកម្ពស់ការប្រើប្រាស់ ការស្រាវជ្រាវកសិកម្ម បច្ចេកវិទ្យា និងការច្នៃប្រឌិត។
- **យុទ្ធសាស្ត្រទី៤៖** ការគ្រប់គ្រងប្រកបដោយតុល្យភាព និងនិរន្តរភាពនៃធនធានកសិកម្ម និងបរិស្ថានដោយដាក់គោលការណ៍មួយចំនួនរួមមាន ធ្វើការស្តារ និងអភិរក្សធនធានកសិកម្ម។ លើកកម្ពស់ការធ្វើកសិកម្មដែលមិនប៉ះពាល់ដល់បរិស្ថាន។ ការគ្រប់គ្រងធនធានទឹកប្រកបដោយនិរន្តរភាព។ គ្រប់គ្រងដីកសិកម្ម និងបន្សុំខ្លួនក្នុងវិស័យកសិកម្មចំពោះការប្រែប្រួលអាកាសធាតុ។
- **យុទ្ធសាស្ត្រទី៥៖** ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងវិស័យសាធារណៈដោយមានគោលការណ៍ណែនាំចំនួន ២រួមមាន អភិវឌ្ឍន៍សមត្ថភាព ចំណេះដឹងបុគ្គលិកជំនាញក្នុងវិស័យកសិម្ម រៀបចំរចនាសម្ព័ន្ធនៃស្ថាប័នកសិកម្ម និងដំណើការការងាររបស់ពួកគេ។ កែលម្អ និងកែសម្រួលច្បាប់ និងបទប្បញ្ញត្តិទាក់ទងនឹងកសិកម្មឲ្យមានភាពទំនើបកម្ម កែតម្រូវឲ្យស្របតាមស្ថានភាពសេដ្ឋកិច្ច និងសង្គមដែលមានភាពផ្លាស់ប្តូរ។

**៣.៤.៣.១ យុទ្ធសាស្ត្រអភិវឌ្ឍន៍ដំណាំស្រូវ** (២០១៧-២០២១)

ស្រូវជាដំណាំដ៏សំខាន់បំផុត និងជាដំណាំដែលជួយគាំទ្រសេដ្ឋកិច្ចរបស់ប្រទេសថៃ ក៏ដូចជាដំណាំដ៏សំខាន់ផងដែរនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ ខណៈតម្រូវការរបស់វានៅក្នុងទីផ្សារពិភពលោកកំពុងកើនឡើងដែលធ្វើឲ្យជីវភាពរស់នៅរបស់កសិករក៏កំពុងកើនឡើងជាលំដាប់ផងដែរ។ គួរបញ្ជាក់ផងដែរថា ប្រទេសថៃជាប្រភពនៃផលិតផលស្រូវ ដែលអាចបំពេញតម្រូវការទីផ្សារបាន។ ដើម្បីគាំទ្រទៅដល់ផលិតភាពនៃដំណាំស្រូវយុទ្ធសាស្ត្រចំនួន៨ ត្រូវបានអនុវត្តរួមមាន៖

(១) កសាងឲ្យកាន់តែខ្លាំងនូវសមត្ថភាព ចំណេះដឹងរបស់កសិករ និងសហគមន៍កសិករ។

(២) គ្រប់គ្រងឲ្យបានល្អនូវតំបន់ដែលដាំដំណាំ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ។

(៣) បង្កើនប្រសិទ្ធភាពនៃផលិតកម្មស្រូវ។

(៤) ការកែលម្អគុណភាព និងស្តង់ដារនៃដំណាំស្រូវ។

(៥) ការកែលម្អប្រសិទ្ធភាពនៃការគ្រប់គ្រងការដឹកជញ្ជូន។

(៦) ធ្វើឲ្យមានភាពស្មើគ្នាក្នុងការធ្វើពាណិជ្ជកម្មស្រូវ។

(៧) លើកកម្ពស់ការប្រើប្រាស់ស្រូវក្នុងស្រុក។

(៨) ការកែលម្អការស្រាវជ្រាវ និងការច្នៃប្រឌិតនៃដំណាំស្រូវ។

# ជំពូកទី ៤

# ការវាយតម្លៃលើការសិក្សាស្រាវជ្រាវស្តីពីផលិតភាពកសិកម្មកម្ពុជា

# ជំពូកទី៤

# ការវាយតម្លៃលើការសិក្សាស្រាវជ្រាវស្តីពីផលិតភាពកសិកម្មនៅកម្ពុជា

នៅក្នុងជំពូកនេះ ក្រុមយើងខ្ញុំមានគោលបំណងពិភាក្សាទៅលើទិដ្ឋភាពសំខាន់ៗជារួម ដែលពាក់ព័ន្ធនឹងដំណើរការអភិវឌ្ឍន៍កសិកម្មកម្ពុជា។ ជាពិសេស ក្រុមយើងខ្ញុំក៏បានសិក្សាវិភាគពីបញ្ហានានាដែលកំពុងតែកើតឡើងនៅក្នុងវិស័យនេះ ដែលបានរាំងស្ទះទៅដល់ដំណើរការវិវត្តន៍និងផលិតភាពកសិកម្ម ក្នុងគោលបំណងសំខាន់គឺឆ្ពោះទៅរកដំណោះស្រាយដ៏សមស្របនឹងបញ្ហាទាំងនោះដែលបានកើតមាននៅក្នុងវិស័យកសិកម្ម។

## ៤.១. បញ្ហាប្រឈមជារួមដែលរាំងស្ទះដល់កំណើនផលិតភាពកសិកម្ម

ជារួម ផលិតកម្មកសិកម្មកម្ពុជានៅមានសក្តានុពលច្រើន ដែលយើងមិនទាន់ប្រើប្រាស់ឲ្យអស់លទ្ធភាពនៅឡើយ។ ដោយសារតែបញ្ហាប្រឈមធំៗមួយចំនួន បានធ្វើឲ្យវិស័យកសិកម្មកម្ពុជាមិនទាន់ប្រែក្លាយជាទំនើបកម្មកសិកម្មពេញលេញ និងពិបាកបន្តិចក្នុងការប្រកួតប្រជែងជាមួយប្រទេសជិតខាងនៅលើទីផ្សារអន្តរជាតិ។

### ៤.១.១ បញ្ហាបរិស្ថាន

បញ្ហាបរិស្ថានផ្សេងៗដូចជា បញ្ហាដីជាតិដី បញ្ហាសត្វល្អិត បញ្ហាអាកាសធាតុ ត្រូវបានចាត់ទុកជាបញ្ហាប្រឈមចម្បងបង្អស់ដែលរារាំងក្នុងការបង្កើនទិន្នផលកសិកម្ម។ ការធ្វើកសិកម្មភាគច្រើន មិនថាលក្ខណៈគ្រួសារ ឬក្រុមហ៊ុនទេ តែងតែមានភាពអាស្រ័យទៅលើធម្មជាតិ។ ពេលខ្លះ របាយទឹកភ្លៀងមិនគ្រប់គ្រាន់នៅដើមរដូវវស្សា រួមផ្សំជាមួយភាពរាំងស្ងួត អាចនាំឲ្យមានការរៀបចំដីពុំបានល្អ ពន្យារពេលធ្វើសំណាប ពន្យារពេលស្ទូងដែលជាមូលហេតុធ្វើឲ្យការលូតលាស់របស់ដំណាំមិនបានល្អ និងទទួលបានទិន្នផលទាប។ ហើយពេលខ្លះវិញមានភ្លៀងធ្លាក់ខ្លាំងជ្រុល ដែលបង្កទៅជាទឹកជំនន់ ដែលបានបំផ្លាញដីស្រែ និងដំណាំផ្សេងៗអស់ជាច្រើនពាន់ហិកតារួមជាមួយនឹងទិន្នផលកសិកម្មអស់រាប់ពាន់តោនដូចដែលបានប្រកាសតាមព័ត៌មានក្នុងពេលកន្លងមក។

ក្រៅពីកត្តាធម្មជាតិទៅ ការធ្លាក់ចុះជីជាតិដីក៏បានក្លាយជាចំណោទបញ្ហាប្រឈមធំមួយដែរ។ ដីភាគច្រើននៅកម្ពុជា ជាប្រភេទដីខ្សោះជីជាតិ ដែលបណ្តាលមកពីការដាំដំណាំដដែលៗរាប់សតវត្ស និងពុំមានការថែទាំត្រឹមត្រូវ។ ហើយដីទាំងនោះ តែងខ្វះនូវសារធាតុ N P ហើយកន្លែងខ្លះទៀតខ្វះសារធាតុ K ដូច្នេះទើបធ្វើឲ្យការទទួលបានទិន្នផលកសិកម្មនៅមានកម្រិត ដោយសារតែសារធាតុចិញ្ចឹមរបស់ដីមិនអាចផ្គត់ផ្គង់ដំណាំបានគ្រប់គ្រាន់។ មួយវិញទៀត ដីនៅតំបន់ខ្លះសម្បូរទៅដោយជាតិប្រៃ និងជាតិអាស៊ីត គួបផ្សំជាមួយនឹងកង្វះបទដ្ឋានបច្ចេកទេសក្នុងការបែងចែកប្រភេទដីកសិកម្មដំណាំស្រូវដល់ប្រជាកសិករ ដែលជាសារធាតុបង្អាក់ដល់ការបង្កើនទិន្នផលកសិកម្ម។ យ៉ាងណាមិញ បញ្ហាមួយនេះគេអាចដោះស្រាយបានដោយការចេះគ្រប់គ្រងជីជាតិដីដោយមានជំនួយពីជីកំប៉ុស និងជីគីមីដើម្បីបំប៉នសារធាតុចិញ្ចឹមទាំងនោះវិញ។

បញ្ហារុក្ខជាតិ សត្វល្អិតចង្រៃ ដែលនៅតាមវាលស្រែនិងចម្ការ ជារឿយៗតែងតែបំផ្លិចបំផ្លាញទៅដល់ដំណាំកសិកម្ម ដែលបញ្ហានេះធ្វើឲ្យដំណាំលូតលាស់មិនបានល្អ ព្រមទាំងទទួលការខាតបង់យ៉ាងធ្ងន់ធ្ងរដល់បរិមាណ និងគុណភាពទៀតផង។ កសិករប្រមាណជា ៨៥%នៅតាមតំបន់ខ្ពង់រាបបានបញ្ជាក់ថា ស្មៅគឺជាកត្តាចម្បងបំផុត ព្រោះថាភាគច្រើនស្មៅតែងតែដុះលឿនជាងគ្រាប់ពូជស្រូវនិងដំណាំទៅទៀត។[56] បូករួមជាមួយសត្វល្អិតផ្សេងៗដូចជា ដង្កូវស៊ីរូងដើម មមាចខៀវ មមាចត្នោត កណ្តូប សត្វស្លាប ជាពិសេសគឺជំងឺដូចជា ជំងឺដុះផ្សិតគ្រាប់ ដែលកើតលើដំណាំស្រូវ បានធ្វើឲ្យផលិតកម្មស្រូវមាននិន្នាការថយចុះទាំងទិន្នផល និងគុណភាព។ ដើម្បីឆ្លើយតបទៅនឹងបញ្ហាខាងលើនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានជំរុញឲ្យបង្កើតនូវកម្មវិធីស្រាវជ្រាវវិទ្យាសាស្ត្រកសិកម្ម ដែលទាក់ទងនឹងការបង្កើតថ្នាំកសិកម្មសម្រាប់ការពារពីសត្វចង្រៃ ស្មៅ និងជំងឺផ្សេងៗដែលយាយីដល់ផលដំណាំរបស់ប្រជាកសិករ។

### ៤.១.២ ផ្នែកផលិតភាពកសិកម្ម និងទីផ្សារ

ផលិតភាពក្នុងការដាំដុះរបស់កម្ពុជា នៅមានកម្រិតទាបនៅឡើយ ដែលប្រឈមខ្លាំងក្នុងការប្រកួតប្រជែងលើទីផ្សារ ជាពិសេសថ្លៃដើមផលិតកម្មរបស់កសិករនៅមានកម្រិតខ្ពស់។ កម្ពុជាកំពុងប្រឈមបញ្ហានៃការធ្លាក់ចុះគុណភាពដីដែលធ្វើឲ្យទិន្នផលកសិកម្មមាននិន្នាការថយចុះ ជាមួយគ្នានេះដែរ ការរីកចម្រើននៃវិស័យផ្សេងទៀត បានធ្វើឲ្យរួមតូចនៃទំហំដីកសិកម្មដែលមានស្រាប់ ហើយការពង្រីកផ្ទៃដីកសិកម្មក៏កំពុងតែគម្រាមកំហែងដល់បរិស្ថានផងដែរ។ ម៉្យាងទៀត ធាតុផ្សំ(Inputs)របស់កសិកម្មជាពិសេសជីគីមី ថ្នាំកសិកម្ម ត្រូវបាននាំចូលពីបរទេស ដោយសារឧស្សាហកម្មក្នុងស្រុកនៅផ្នែកនេះនៅមិនទាន់រីកចម្រើនគ្រប់គ្រាន់ដើម្បីផ្គត់ផ្គង់តម្រូវការនៅឡើយ ជាហេតុនាំឲ្យថ្លៃដើមកសិករកើនឡើង។ ការបន្សាំរបស់កសិករទៅនឹងការប្រែប្រួលអាកាសធាតុ ការផ្សព្វផ្សាយបច្ចេកទេសកសិកម្មតាមផ្ទៃក និងការផ្តល់សេវាព័ត៌មានទីផ្សាររបស់កសិផលទៅដល់កសិករ គឺនៅមិនទាន់មានភាពទូលំទូលាយ។ មួយវិញទៀត កសិករតែងជួបប្រទះនូវការធ្លាក់ចុះនៃតម្លៃកសិផលក្រោយពេលប្រមូលផល ហើយការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យាក៏នៅពុំទាន់ល្អប្រសើរ។ ការហូរចូលនៃផលិតផលពីបរទេសមកទីផ្សារក្នុងស្រុក ជាមូលហេតុចម្បងដែលធ្វើឲ្យតម្លៃផលិតផលក្នុងស្រុកធ្លាក់ចុះ ហើយកសិករពិបាកនឹងប្រកួតប្រជែងតម្លៃជាមួយទំនិញនាំចូល ដោយសារទីផ្សារនៅឆ្ងាយ ពួកគាត់ពិបាកក្នុងការទាក់ទងផ្ទាល់ជាមួយអតិថិជន ដូចនេះហើយផលដំណាំរបស់ពួកគាត់ត្រូវបានប្រមូលទិញដោយឈ្មួញកណ្តាល។ ដោយសារតែកសិករពុំទទួលបានព័ត៌មានតម្លៃ និងតម្រូវការទីផ្សារច្បាស់ ធ្វើឲ្យឈ្មួញកណ្តាលអាចឆ្លៀតឱកាសទិញកសិផលក្នុងតម្លៃទាប ហើយលក់បន្តនៅតម្លៃខ្ពស់។ កត្តានេះហើយ បានធ្វើឲ្យកម្រិតជីវភាពប្រជាកសិករ

[56] ឡៃ ប៉ូរ៉ាពីន, *ការអភិវឌ្ឍកសិកម្មនៅប្រទេសកម្ពុជា(២០១៧)*, ទំព័រ ៧៥។

មិនអាចរីកចម្រើនបាន ព្រោះពួកគាត់ទទួលបានផលចំណេញតិចតួចបំផុត ហើយជាលទ្ធផលកសិករមួយចំនួនអស់ទឹកចិត្តក្នុងការធ្វើស្រែចម្ការបន្តទៀត។ ការគ្រប់គ្រង និងបច្ចេកទេសក្នុងការប្រើប្រាស់ដីកសិកម្មឲ្យចំគោលដៅនិងមានផលិតភាពខ្ពស់ទៅតាមភូមិសាស្ត្រនីមួយៗ នៅតែស្ថិតជាបញ្ហា ដែលក្រសួង និងស្ថាប័នដែលពាក់ព័ន្ធកំពុងកំណត់តំបន់ដាំដុះ ផ្សព្វផ្សាយបច្ចេកទេស ក៏ដូចជាដាក់ឲ្យប្រើប្រាស់គ្រាប់ពូជដែលធន់នឹងប្រភេទអាកាសធាតុ ក្នុងគោលបំណងទទួលបាននូវផលិតភាពខ្ពស់។ លើសពីនេះទៅទៀត នៅតំបន់ជនបទ អត្រាការប្រាក់ខ្ពស់ បូករួមជាមួយនឹងការទទួលបានហិរញ្ញប្បទាននៅមានកម្រិត ដែលធ្វើឲ្យប៉ះពាល់ដល់ថ្លៃដើមផលិតរបស់កសិករ និងលទ្ធភាពក្នុងការពង្រីកនូវកត្តាផលិតកម្ម ក៏ដូចជាផ្ទៃដីកសិកម្មផងដែរ។

### ៤.១.៣ ផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងស្តុកកសិកម្ម

ប្រព័ន្ធស្រោចស្រពកសិកម្មនៅមិនទាន់បានគ្របដណ្តប់លើផ្ទៃដីដាំដុះឲ្យបានទូលំទូលាយ ជាពិសេសការរៀបចំប្រព័ន្ធប្រឡាយបង្ហូរទឹកចូលស្រែដោយស្វ័យប្រវត្តិ ពុំទាន់បានពង្រីកដល់ដីស្រែរបស់កសិករនៅឡើយ គួបផ្សំនឹងប្រព័ន្ធបញ្ចេញបញ្ចូលទឹកក៏នៅមានភាពទន់ខ្សោយ ដែលធ្វើឲ្យមានបញ្ហាទឹកនៅរដូវប្រាំង និងរដូវវស្សា។ កសិករភាគច្រើនបានប្រើប្រាស់ចំណាយក្នុងការបូមទឹកជាកត្តាមួយបន្ថែមលើថ្លៃដើមផលិតកម្ម។ បញ្ហាតម្លៃដឹកជញ្ជូន គឺជាបញ្ហាមួយដែលរួមចំណែកធ្វើឲ្យថ្លៃដើមផលិតកម្មខ្ពស់ ដែលពិបាកនឹងធ្វើការប្រកួតប្រជែងជាមួយផលិតផលកសិកម្មពីបរទេស។ ជាមួយគ្នានេះដែរ កង្វះធនធានក្នុងការស្តារ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ការបង្កើនផលិតភាពលើដីស្រែចម្ការរបស់កសិករ ក៏ត្រូវតែមានវិធានការដោះស្រាយនាពេលខាងមុខ។ ម្យ៉ាងវិញទៀត វាលស្រែជាច្រើនមានទំហំតូចហើយគ្មានផ្លូវធ្វើដំណើរចូលទៅ ដែលបានរួមចំណែកភាពខុសគ្នារវាងថ្លៃទីផ្សារ និងថ្លៃកសិករ គឺមិនត្រឹមតែដោយសារឈ្មួញកណ្តាលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដោយសារថ្លៃដឹកជញ្ជូនខ្ពស់ ដែលបណ្តាលមកពីកង្វះខាតនូវបណ្តាញផ្លូវថ្នល់នៅតាមជនបទ ដូចនេះដើម្បីឲ្យកសិករអាចទទួលបានប្រាក់ចំណេញច្រើនពីទីផ្សារ នោះត្រូវតែកាត់បន្ថយចំណាយក្នុងការដឹកជញ្ជូនកសិផល តាមរយៈការកែលម្អនូវហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់។ កង្វះខាតនូវឃ្លាំងស្តុកកសិផល ក្នុងគោលបំណងត្រួតពិនិត្យសំណើមស្រូវ-អង្ករ ការសម្អាត គ្រប់គ្រងបញ្ហាសត្វល្អិត និងប្រមូលទុកក្រោយពេលហាលសម្ងួត មុនពេលយកទៅម៉ាស៊ីនកិនស្រូវទ្រង់ទ្រាយធំ ព្រោះថាប្រសិនបើមិនបានត្រួតពិនិត្យ និងហាលបានល្អទេ ការកិនអង្ករនឹងធ្វើឲ្យគ្រាប់ស្រូវបែកហើយខូច ជាមូលហេតុនាំឲ្យគុណភាពអង្ករទាប និងលក់មិនបានថ្លៃ។ មួយវិញទៀត ឃ្លាំងកសិផល គឺប្រើសម្រាប់រក្សាទុកនៅពេលថ្លៃទីផ្សារធ្លាក់ចុះ និងបញ្ចេញនៅពេលថ្លៃទីផ្សារកើនឡើង។ ការកែលម្អការគ្រប់គ្រងក្រោយពេលប្រមូលផលហាក់នៅមានកម្រិតនៅឡើយ ការជំរុញផ្នែកកសិ-ឧស្សាហកម្ម រួមទាំងការកែច្នៃក្រោយ

ពេលប្រមូលផល ការកែលម្អគុណភាពស្របតាមស្តង់ដារកសិផល គឺត្រូវបានវាយតម្លៃថានៅមិនទាន់មានភាពទូលំទូលាយ ជាហេតុដែលសមត្ថភាពបច្ចេកទេសផ្នែកអនាម័យ និងភូតគាមអនាម័យ គឺត្រូវពង្រឹងបន្ថែម។

### ៤.១.៤ ផ្នែកស្រាវជ្រាវបច្ចេកវិទ្យា និងបច្ចេកទេសកសិកម្ម

ការងារស្រាវជ្រាវ និងការផ្តល់សេវាបច្ចេកទេសកសិកម្មនៅមានកម្រិត ស្របពេលសមត្ថភាពទទួលយកចំណេះដឹងអំពីបច្ចេកទេសដាំដុះ ព្រមទាំងការប្រើប្រាស់ធាតុផ្សំកសិកម្មដែលសមស្របទៅតាមបទដ្ឋានបច្ចេកទេស ក៏មិនទាន់មានភាពទូលំទូលាយ។ ការកែច្នៃផលិតផលរបស់ប្រជាកសិករក៏នៅមានកម្រិត ដែលបានជះឥទ្ធិពលដល់ថ្លៃដើមផលិតខ្ពស់ និងពិបាកក្នុងការប្រកួតប្រជែង។ បន្ថែមពីលើនេះ កង្វះខាតទាំងថវិកា និងធនធានឧបករណ៍សម្ភារៈសម្រាប់មធ្យោបាយផលិតកម្មនៅតាមកសិដ្ឋាន ស្ថានីយ៍ពិសោធន៍ និងមណ្ឌលអភិវឌ្ឍន៍កសិកម្ម។ ភាពខ្វះខាតសម្រាប់ការងារស្រាវជ្រាវ និងផ្សព្វផ្សាយបច្ចេកទេសទាំងនៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ គឺជាបញ្ហាមួយទៀតដែលត្រូវតែពិនិត្យពិចារណា គួបផ្សំជាមួយភាពខ្វះខាតការស្រាវជ្រាវ អភិវឌ្ឍន៍ ការផលិត និងផ្សព្វផ្សាយពូជដំណាំដែលមានគុណភាពខ្ពស់ដែលជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ នៅមានកម្រិត និងមិនទាន់គ្រប់គ្រាន់សម្រាប់កសិករប្រើប្រាស់នៅឡើយ។ ម៉្យាងវិញទៀត ការវិនិយោគបន្ថែមក្នុងផ្នែកស្រាវជ្រាវ វិស័យអប់រំ និងផ្សព្វផ្សាយកសិកម្មនៅមានទំហំតូច ដែលត្រូវតែមានការយកចិត្តទុកដាក់ខ្ពស់នាពេលបច្ចុប្បន្ន។ ទំហំនៃការវិនិយោគពីផ្នែកឯកជនទៅក្នុងវិស័យកសិកម្មនៅមានទំហំតូច ជាពិសេសវិនិយោគក្នុងសហគ្រាសខ្នាតមធ្យម និងធំក្នុងការកែច្នៃផលិតផលកសិកម្ម ដើម្បីបង្កើនតម្លៃបន្ថែមទៅក្នុងកសិផល នៅមានកម្រិតតិចតួចណាស់ ដោយសារតែវិនិយោគិនភាគច្រើនពុំសូវមានទំនុកចិត្តក្នុងការវិនិយោគលើវិស័យនេះ ដោយហេតុតែពួកគេពិបាកស្វែងរកជួលកសិករជំនាញ និងអ្នកបច្ចេកទេសមកបម្រើក្នុងអាជីវកម្មរបស់ពួកគេ។

### ៤.១.៥ ធនធានមនុស្ស

ធនធានមនុស្សត្រូវបានចាត់ទុកជាអាទិភាពនៃការអភិវឌ្ឍផលិតភាពកសិកម្ម តាមរយៈការលើកកម្ពស់ចំណេះដឹង ជំនាញបច្ចេកទេស សមត្ថភាព សហគ្រិនភាព ការច្នៃប្រឌិត នវានុវត្តន៍ សម្រាប់បម្រើឲ្យគោលបំណងមួយនេះ។ ស្ថិតក្នុងបរិបទជាក់ស្តែង បញ្ហាចំណេះដឹងរបស់ប្រជាកសិករតាមទីជនបទ នៅតែជាបញ្ហាចោទដដែល។ កង្វះការយល់ដឹងរបស់កសិករក្នុងការប្រើប្រាស់សម្ភារៈកសិកម្មឲ្យបានត្រឹមត្រូវតាមបច្ចេកទេស និងការគ្រប់គ្រងដី ក៏នៅតែជាចំណុចគួរពិចារណា ដើម្បីអាចបង្កើនផលិតភាពកសិកម្មបាន។ ជាក់ស្តែង ប្រជាជនក្នុងទីជនបទប្រមាណ ៨០% ដែលមិនទទួលបានការអប់រំខ្ពស់ ពោលគឺកម្រិតនៃការយល់ដឹងនៅទាប ទាំងផ្នែកចំណេះដឹងទូទៅ និងចំណេះដឹងក្នុងផ្នែកកសិកម្ម ដែលភាគច្រើនពួកគាត់ដាំដុះតាមទម្លាប់ដូនតា និងពឹង

ផ្អែកលើធម្មជាតិ ឬទឹកភ្លៀងជ្រុល។[57] ពួកគាត់មិនទាន់មានបច្ចេកទេស និងលទ្ធភាពគ្រប់គ្រាន់ក្នុងការទិញឧបករណ៍បច្ចេកទេស ក៏ដូចជាការរៀបចំប្រព័ន្ធស្រោចស្រពបែបដំណក់ទឹកនៅឡើយទេ។ មួយវិញទៀត ធនធានមនុស្សដូចជា មន្ត្រីរាជការផ្នែកកសិកម្មមួយចំនួនខ្វះសមត្ថភាព និងចំណេះដឹង ក្នុងការផ្សព្វផ្សាយបច្ចេកទេសកសិកម្មទៅដល់កសិករ រួមផ្សំជាមួយរចនាសម្ព័ន្ធវិស្វកម្មកសិកម្មនៅតាមខេត្ត គឺមានភាពទន់ជ្រាយនៅឡើយ ដោយសារគ្មានមន្ត្រីទទួលបន្ទុកយន្តកម្មកសិកម្ម។ តាមការសង្កេត ការបង្កើតសហគមន៍កសិករ ជាចំណុចស្នូលដែលត្រូវតែដំណើរការក្នុងគោលបំណងចម្បងគឺពង្រីកផលិតភាពកសិករ ក៏ដូចជាមានសិទ្ធិអំណាចក្នុងការតថ្លៃនៅក្នុងទីផ្សារផងដែរ។ ក៏ប៉ុន្តែ ការបង្កើតសហគមន៍កសិករ ដែលជាតួអង្គសេដ្ឋកិច្ចជនបទសំខាន់ ហាក់បីដូចជាមិនទាន់មានភាពទូលំទូលាយនៅឡើយ ជាហេតុដែលការទទួលបាននូវបច្ចេកទេសដាំដុះរវាងកសិករនិងកសិករ ការទទួលបានឥណទានបន្ថែម និងអំណាចក្នុងទីផ្សារកសិកម្មរបស់កសិករនៅមិនទាន់មានប្រសិទ្ធភាព ដែលតម្រូវឲ្យមានការពង្រឹងល្អប្រសើរជាងនេះពីសំណាក់ស្ថាប័នពាក់ព័ន្ធ។ បន្ថែមពីលើនេះ តម្រូវការពង្រឹងសមត្ថភាព គុណភាពអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងយន្តកម្មកសិកម្មនៅមិនទាន់ឆ្លើយតបទៅនឹងតម្រូវការទីផ្សារកសិកម្មដែលបាននឹងកំពុងតែប្រែប្រួលរីកចម្រើន ដូចនេះវាសឹងតែមិនមាននូវការផ្តល់សេ-វាយន្តូបនីយកម្មទៅឲ្យប្រជាកសិករ ដើម្បីក្លាយទៅជាទំនើបកម្មកសិកម្ម ឲ្យស្របតាមបដិវត្តន៍ឧស្សាហកម្មទី៤។

## ៤.២. ដំណោះស្រាយជារួមក្នុងការបង្កើនផលិតភាពកសិកម្ម

វិធានការជាច្រើនត្រូវបានដាក់ចេញ និងកំពុងតែប្រើប្រាស់ជាបណ្តើរៗក្នុងការបង្កើនផលិតភាពកសិកម្ម ព្រមទាំងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជននៅជនបទឲ្យមានភាពប្រសើរឡើង។ វិធានការជារួមទាំងនោះមានដូចជា ការកែលម្អមធ្យោបាយផលិតកម្មកសិកម្ម ពង្រីកទីផ្សារកសិកម្មនិងរក្សាលំនឹងថ្លៃលក់ ការបង្កើតប្រព័ន្ធប្រពលវប្បកម្មនិងកែច្នៃកសិផល ការគាំទ្របន្ថែមដល់សេវាកសិកម្ម ជំរុញលើកទឹកចិត្តឲ្យប្រើប្រាស់បន្ថែមនូវយន្តកម្មកសិកម្ម និងបន្តការស្តារហេដ្ឋារចនាសម្ព័ន្ធ។

### ៤.២.១ ការកែលម្អមធ្យោបាយផលិតកម្មកសិកម្ម

ការជំរុញកសិកម្មឲ្យកាន់តែមានផលិតភាព និងចីរភាព ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារដែលកំពុងតែកើនឡើងជាលំដាប់ តម្រូវឲ្យការប្រើកត្តាផលិតកម្មកសិកម្មមានប្រសិទ្ធភាព ជាពិសេសគឺ ដី ទឹក ជីកសិកម្ម និងគ្រាប់ពូជ ដែលសមាសធាតុទាំង៤ នេះមានទំនាក់ទំនងគ្នាយ៉ាងស្អិតរមួតក្នុងការបង្កើនផលិតភាពកសិកម្ម។

**ក) កត្តាដី៖** ដីដាំដុះនៅកម្ពុជាតែងរងនូវភាពខ្សោះសារធាតុចិញ្ចឹមដូចជា N P និង Kជាដើម ដោយសារពុំមានការថែទាំត្រឹមត្រូវ និងដាំដំណាំដដែលអស់ពេលជាច្រើនទសវត្សរ៍មកហើយ។ មែនទែនទៅ មានតំបន់ដាំដុះ

[57] ឡៃ ប៉ូរ៉ាពីន, *ការអភិវឌ្ឍកសិកម្មនៅប្រទេសកម្ពុជា(២០១៧)*, ទំព័រ ៧៥។

តែ ៣០%ប៉ុណ្ណោះចាត់ទុកថាមានផលិតភាពខ្ពស់ក្នុងការធ្វើកសិកម្ម ហើយផ្ទៃដីដាំដុះប្រមាណជា ៥០%ផ្សេងទៀតគ្មានសក្តានុពលគ្រប់គ្រាន់ក្នុងការបង្កើនទិន្នផល ប៉ុន្តែគេអាចកែតម្រូវវាតាមរយៈការកែលម្អការគ្រប់គ្រងដី និងផ្តល់សារធាតុតាមតម្រូវការដី។ បច្ចុប្បន្ន ការអនុវត្តប្រពលវប្បកម្មដំណាំស្រូវកំពុងមាននិន្នាការកើនឡើងជាលំដាប់ ពីព្រោះតែរបៀបដាំមានភាពងាយស្រួល អស់តម្លៃតិច ប៉ុន្តែទទួលបានទិន្នផលខ្ពស់ ជាពិសេសគឺធ្វើឲ្យដីបង្កើនផលិតភាព និងកាត់បន្ថយសំណឹកដី។ ប៉ុន្តែ ការធ្វើប្រពលវប្បកម្មដំណាំស្រូវ ទាមទារឲ្យមានការយល់ដឹងច្បាស់ពីធនធានដី ការគ្រប់គ្រងជីជាតិដីឲ្យសមស្របតាមប្រភេទដំណាំ និងប្រភេទដី ដើម្បីធានាជីជាតិដីឲ្យមានស្ថិរភាពយូរអង្វែង តាមរយៈការប្រើប្រាស់កម្រិតជីដែលមានសារធាតុចិញ្ចឹមឲ្យដីសមស្របទៅតាមតម្រូវការរបស់ដំណាំ និងប្រភេទដីនៅតាមតំបន់ដាំដុះខុសៗគ្នា ព្រោះតែដីកសិកម្មនៅកម្ពុជាភាគច្រើនផ្ទុកនូវសារធាតុទាំងនោះក្នុងបរិមាណខុសគ្នា។ ដោយសារដីផលិតកម្មដំណាំស្រូវភាគច្រើននៅកម្ពុជា ពុំអាចផ្គត់ផ្គង់សារធាតុទាំងនេះឲ្យបានគ្រប់គ្រាន់តាមតម្រូវការរបស់ដំណាំ ដូចនេះដើម្បីធានានូវការលូតលាស់ប្រកបដោយផលិតភាពរបស់ដំណាំ និងរក្សាបាននូវលំនឹងជីជាតិរបស់ដី គេចាំបាច់ត្រូវធ្វើការបន្ថែមជីដែលមានសារធាតុ N P និងK ទៅដីឲ្យបានត្រឹមត្រូវតាមតម្រូវការរបស់ដំណាំប្រភេទដី រដូវកាលនិងវិធីសាស្ត្រដាំដុះ កត្តាបរិស្ថាន និងអនុវត្តឲ្យខ្ជាប់ខ្ជួនតាមបទដ្ឋានបច្ចេកទេស ដើម្បីចៀសវាងនូវការខាតបង់ថវិកា ពេលវេលា និងប៉ះពាល់បរិស្ថាន ដោយការបែងចែកប្រភេទដីសម្រាប់ដំណាំស្រូវ ត្រូវមានវត្តមានពីសំណាក់អាជ្ញាធរ និងស្ថាប័នជំនាញក្នុងការបែងចែកប្រភេទដីទាំងនោះជូនប្រជាកសិករ ទើបអាចឲ្យពួកគាត់ធ្វើស្រែទទួលបានផលិតភាពខ្ពស់។ បន្ថែមពីលើនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជារឿយៗ ក៏បានផ្តោតសំខាន់លើធនធានដីសម្រាប់បង្កើនផលិតភាពកសិកម្មផងដែរ តាមរយៈការបន្តជំរុញការគ្រប់គ្រង និងប្រើប្រាស់ដីកសិកម្មប្រកបដោយប្រសិទ្ធភាព ចាត់វិធានការទប់ស្កាត់បញ្ហាខិនភាពដី ការកំណត់តំបន់ដាំដុះសក្តានុពល ការកែលម្អជីជាតិដី ផ្សព្វផ្សាយវិធីសាស្ត្រគ្រប់គ្រង និងរៀបចំដីកសិកម្មទៅឲ្យប្រជាកសិករនៅតាមមូលដ្ឋានឲ្យត្រូវទៅតាមបទដ្ឋានរបស់ប្រភេទដីនីមួយៗ សម្រាប់ឲ្យពួកគាត់ប្រើប្រាស់ដីប្រកបដោយប្រសិទ្ធភាព ព្រមទាំងបន្សាំខ្លួនជាមួយនឹងការប្រែប្រួលអាកាសធាតុ ក្នុងគោលបំណងជំរុញផលិតកម្មកសិកម្ម ពិសេសដំណាំទៅតាមតំបន់សក្តានុពលនិងទាក់ទាញវិនិយោគទុនមកចូលរួមបង្កើតកសិ-ឧស្សាហកម្មដែលជាផ្នែកមួយធ្វើឲ្យតម្រូវការកសិផលកាន់តែមានកំណើនឡើង។

**ខ) កត្តាទឹក៖** ទឹកគឺជាធនធានចាំបាច់ក្នុងការបង្កើនផលិតភាពកសិកម្ម។ ប៉ុន្តែគេសង្កេតឃើញថា ចំពោះការប្រើប្រាស់ទឹកក្នុងវិស័យកសិកម្មនៅកម្ពុជាសព្វថ្ងៃ មិនទាន់ប្រើអស់ធនធាននិងមានប្រសិទ្ធភាពនៅឡើយទេ ដោយកសិកម្មកម្ពុជានៅតែពឹងផ្អែកលើលក្ខខណ្ឌអំណោយផលពីធម្មជាតិ(ការធ្វើស្រែប្រវាស់មេឃ) ដែលស្ថានការណ៍មួយនេះ គឺជាឧបសគ្គដ៏ចម្បងក្នុងការប្រែក្លាយជាទំនើបកម្មកសិកម្ម។ នៅតំបន់មានការដាំដុះសព្វថ្ងៃ

មានតែ ៧-៨%ប៉ុណ្ណោះដែលមានប្រព័ន្ធស្រោចស្រពល្អប្រសើរ ត្រង់ចំណុចនេះក៏មានភាពខុសគ្នាពីតំបន់មួយទៅតំបន់មួយដែរ ពោលគឺនៅតាមខេត្តតំបន់ឦសានមិនមានប្រព័ន្ធស្រោចស្រពសម្បូរបែបប៉ុន្មានទេ។[58] ប្រជាកសិករភាគច្រើនជួបប្រទះបញ្ហាខ្វះទឹកនៅរដូវប្រាំង ប៉ុន្តែមានទឹកច្រើនជ្រុលនៅរដូវវស្សាគឺទឹកជំនន់ ដោយសារគេនៅមិនទាន់មានហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រគ្រប់គ្រាន់ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធភាគច្រើនមិនទាន់មានទំនើបកម្ម ហើយខ្លះទៀតមានសភាពទ្រុឌទ្រោម និងមានការលេចធ្លាយទៀតផង ដែលទាំងអស់នេះជាបច្ច័យនាំឲ្យមានការខ្វះខាតទឹក លំបាកក្នុងការបែងចែក គ្រប់គ្រងទឹកសម្រាប់វិស័យកសិកម្ម។ ដូចនេះ ការបង្កើនផលិតភាពកសិកម្មចាំបាច់ត្រូវមានវត្តមានប្រព័ន្ធស្រោចស្រពគ្រប់គ្រាន់ ព្រោះថាផលិតភាពដីដែលមានប្រព័ន្ធស្រោចស្រពល្អ ផ្តល់ទិន្នផល ២ដងច្រើនជាងប្រសិទ្ធភាពដីដែលផ្គត់ផ្គង់ដោយទឹកភ្លៀង។[59] ដូចនេះ ការកសាងបន្ថែមនូវប្រព័ន្ធធារាសាស្ត្រ និងកែលម្អការគ្រប់គ្រងទឹក ជាកត្តាចាំបាច់ណាស់ក្នុងការទាញយកទឹកមកប្រើប្រាស់ឲ្យអស់ប្រសិទ្ធភាព ទាំងទឹកលើដីនិងទឹកក្រោមដី ក្នុងគោលបំណងសម្រាប់បំពេញនូវទឹកភ្លៀងដែលធ្លាក់ពុំទៀងទាត់នៅរដូវវស្សា និងខ្វះទឹកនៅរដូវប្រាំង។ កិច្ចខិតខំប្រឹងប្រែងទាំងនេះរួមមានការបន្តការអនុវត្តនយោបាយទឹកតាមរយៈការគ្រប់គ្រងធនធានទឹកឲ្យបានល្អ ដោយជំរុញឲ្យមាននូវការថែរក្សា ស្តាបនា និងស្តារប្រព័ន្ធធារាសា-ស្ត្រដែលទ្រុឌទ្រោមទាំងខ្នាតតូច មធ្យម និងធំ ក្នុងទិសដៅសំខាន់ធានាដល់ការផ្គត់ផ្គង់ទឹកពេញមួយឆ្នាំ ដើម្បីអនុញ្ញាតឲ្យកសិករអាចធ្វើការបង្កបង្កើនផលបាន ២-៣ដងក្នុងមួយឆ្នាំ។ បន្ថែមពីលើនេះ ក្រសួងអភិវឌ្ឍន៍ជនបទ ជារឿយៗបានបន្តពង្រីកតំបន់ស្រោចស្រព ដើម្បីកាត់បន្ថយការពឹងផ្អែកទៅលើទឹកភ្លៀងដោយការសាងសង់ទំនប់ ប្រឡាយមេ ប្រឡាយបង្ហូរទឹកដែលនាំទឹកពីប្រឡាយមេទៅកាន់តំបន់ដាំដុះ ពង្រីកការស្តុកទឹកនៅលើដីដូចជា អាងស្តុកទឹកសម្រាប់ផ្គត់ផ្គង់ពេលរដូវប្រាំង ពង្រីកប្រព័ន្ធធារាសាស្ត្រខ្នាតតូចដែលជាផ្នែកដ៏សំខាន់នៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទសមាហរណកម្ម ពង្រឹងបច្ចេកវិទ្យាទំនើបនៃការប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធ-ភាពតាមរយៈការស្រោចស្រពដោយបង្ហៀរទឹកបញ្ចូលស្រែ ទុយោបំពង់បង្កប់ដី ឧបករណ៍ស្រោចស្រពដំណក់ទឹក និងសាចទឹក ហើយជាពិសេសនោះគឺការពង្រឹងសមាគមន៍អ្នកប្រើប្រាស់ទឹក ដើម្បីធានាប្រសិទ្ធភាពនៃការបែងចែកនិងប្រើប្រាស់ទឹកនៅតាមតំបន់មូលដ្ឋានកសិកម្ម។

**គ) ជីកសិកម្ម៖** ដីគឺជាវត្ថុធម្មជាតិ ឬសមាសធាតុគីមីទាំងឡាយណាដែលរួមមានសមាសធាតុគីមី អាសូត ផូស្វ័រ និងប៉ូតាស្យូមជាដើម ដែលវាមានមុខងារសម្រាប់បង្កើនផលិតភាពរបស់ដី និងដើម្បីផ្គត់ផ្គង់ដល់ការលូតលាស់របស់ដំណាំ។[60] ការប្រើប្រាស់ថ្នាំ និងជីកសិកម្ម ជាវិធីសាស្ត្រមួយដែលកំពុងពេញនិយមក្នុងដំណើរការ

---

[58] បណ្ឌិត ឈុន ពហុ, *ការអភិវឌ្ឍជនបទ(២០១៧)*។

[59] របាយការណ៍អភិវឌ្ឍន៍ពិភពលោក, *កសិកម្មសម្រាប់ការអភិវឌ្ឍ*, ទំព័រ ១៧។

[60] AHPC, The American Heritage dictionary of the English language, [វចនានុក្រមបេតិកភណ្ឌអាមេរិកនៃភាសាអង់គ្លេស]។

ផលិតកម្មដូចជាការថែទាំ ការកម្ចាត់សមាសធាតុចង្រៃ និងបង្កើនទិន្នផលជាដើម។ ជាការពិតណាស់ ជីនិងថ្នាំកសិកម្មជាអាវុធមុខពីរ មានន័យថាបើសិនយើងប្រើប្រាស់ត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសនិងចំទិសដៅ នោះវានឹងជួយការពារផលដំណាំពីការបំផ្លាញរបស់សមាសធាតុចង្រៃ ព្រមទាំងបង្កើនផលិតភាពផងដែរ។ ប៉ុន្តែ បើយើងប្រើប្រាស់វាមិនបានត្រឹមត្រូវទេ នោះអាចបង្កឲ្យមានផលប៉ះពាល់អវិជ្ជមានជាច្រើនដូចជាបាត់បង់តុល្យភាពជីវសាស្ត្រ ប៉ះពាល់ដល់បរិស្ថាន ទឹក ដី បរិយាកាស សុខភាពសត្វ និងមនុស្សផងដែរ។ ជាក់ស្តែង ប្រជាកសិករភាគច្រើនមិនបានយល់ច្បាស់ពីរបៀបប្រើបាស់ជីនិងថ្នាំកសិកម្មនៅឡើយទេ ព្រមទាំងបានប្រើក្នុងបរិមាណច្រើនខុសការកំណត់ទៀតផង ដែលវាបានបំផ្លាញគុណភាពនិងសុខភាពរបស់ដីនៅរយៈពេលវែង បូករួមជាមួយចំណាយថ្លៃដើមផលិតកម្មខ្ពស់លើជីគីមី ជាហេតុនាំឲ្យចំណូលរបស់គាត់មានការថយចុះ។ ការប្រើប្រាស់មិនត្រូវតាមបច្ចេកទេសអាចបណ្តាលមកពីកង្វះការងារផ្សព្វផ្សាយការប្រើប្រាស់ជីនិងថ្នាំពីមន្ត្រីជំនាញ រួមជាមួយការណែនាំរបស់ជីគីមីដែលចរាចរណ៍លើទីផ្សារមិនបានសរសេរជាអក្សរជាតិ ជាហេតុដែលកសិករមានការភ័ន្តច្រឡំក្នុងការប្រើប្រាស់។ ដូច្នេះហើយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានលើកទឹកចិត្តឲ្យកសិករកម្ពុជាឈប់ប្រើជីគីមី ហើយងាកមកប្រើប្រាស់ជីធម្មជាតិជំនួសវិញ ដោយសារជីធម្មជាតិងាយស្រួលក្នុងការផលិត ចំណាយថ្លៃដើមតិច ទទួលបានទិន្នផលខ្ពស់ រក្សានូវតុល្យភាពបរិស្ថាន ហើយការប្រើប្រាស់ជីធម្មជាតិនេះទៀតសោត គឺជាការអភិវឌ្ឍកសិកម្មប្រកបដោយចីរភាព។ មួយវិញទៀត ក្រសួងក៏បានខិតខំផ្សព្វផ្សាយពីវិធីសាស្ត្រនៃការប្រើប្រាស់ជីគីមីឲ្យត្រូវតាមបច្ចេកទេសដើម្បីទទួលបានទិន្នផលគួរជាទីគាប់ចិត្ត ពីសំណាក់មន្ត្រីជំនាញនិងអ្នកបច្ចេកទេសផ្សព្វផ្សាយទៅកាន់កសិករនៅតាមមូលដ្ឋានកសិកម្ម។ បន្ថែមពីលើនេះ ក្រសួងកសិកម្មមានគោលការណ៍ថា អ្នកដែលនាំចូលជីនិងថ្នាំគីមីមកទីផ្សារក្នុងស្រុកត្រូវតែមានការបកប្រែជាភាសាខ្មែរ ដើម្បីឲ្យកសិករប្រើប្រាស់បានត្រឹមត្រូវ និងកុំឲ្យមានការភ័ន្តច្រឡំ។

**ឃ) គ្រាប់ពូជដំណាំ៖** កត្តាពូជដែលល្អហើយស៊ាំទៅនឹងអាកាសធាតុ គឺជាផ្នែកមួយដ៏សំខាន់ដែលជួយបង្កើនទិន្នផលកសិកម្មរបស់ប្រជាកសិករ។ រហូតមកដល់ពេលបច្ចុប្បន្ន វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជាបានធ្វើការស្រាវជ្រាវលើពូជស្រូវដែលមានទិន្នផលខ្ពស់ ដែលសមស្របទៅនឹងការដាំដុះនៅតំបន់ទំនាបអាស្រ័យរបបទឹកភ្លៀង ស្រោចស្រពរដូវប្រាំង និងតាមសណ្ឋានដី ហើយក៏បានផ្សព្វផ្សាយឲ្យកសិករប្រហែល ៣៥ពូជសម្រាប់ដាំដុះនៅប្រទេសកម្ពុជា។ ប៉ុន្តែ មានតែពូជស្រូវអ៊ីអ៊ែរ ៦៦ប៉ុណ្ណោះ ដែលប្រជាកសិករនិយមធ្វើការដាំដុះជាងគេ ពោលគឺមានប្រហែល ៩០%នៃផ្ទៃដីស្រូវប្រាំងទាំងមូល ព្រោះវាបានផ្តល់ទិន្នផលខ្ពស់ និងចំណាយពេលខ្លីក្នុងការដាំដុះ។ យ៉ាងណាមិញ តាមរបាយការណ៍បញ្ជាក់ថា ពួកគេមិនចង់បរិភោគពូជស្រូវនេះប៉ុន្មានទេ ដោយហេតុថាវារឹង និងគ្មានរសជាតិ ជាហេតុដែលពូជស្រូវប្រភេទនេះគឺគេដាំដើម្បីលក់ និងនាំ

ចេញ តែមិនមែនសម្រាប់បរិភោគក្នុងគ្រួសារនោះទេ។ ថ្វីបើមានបញ្ហានេះក៏ដោយ ក៏ពូជស្រូវទំនើបប្រភេទនេះនៅតែមានសារៈសំខាន់ក្នុងការបង្កើនផលិតភាព និងផលិតកម្មស្រូវនាពេលអនាគត។ បច្ចុប្បន្ននេះទៀតសោត ពូជស្រូវភាគច្រើនដែលបានធ្វើការផ្សព្វផ្សាយឲ្យកសិករដាំដុះកន្លងមក កំពុងរីកសាយភាយ និងទទួលនូវការនិយមចូលចិត្តពីសំណាក់កសិករក្នុងស្រុក ដោយពូជស្រូវទាំងនេះមានការដុះលូតលាស់ល្អសមស្របទៅនឹងបរិស្ថាននៃតំបន់ដាំដុះនីមួយៗព្រមទាំងផ្តល់ទិន្នផលខ្ពស់ គុណភាពអង្ករល្អ និងមានតម្លៃខ្ពស់លើទីផ្សារជាតិ និងទីផ្សារអន្តរជាតិ។ ដោយមើលឃើញពីកត្តានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានជំរុញឲ្យវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា បន្តការងារអភិវឌ្ឍន៍ដំណាំស្រូវ ដោយបន្ថែមការងារស្រាវជ្រាវបង្កើននូវគុណភាពពូជស្រូវដែលធន់នឹងការប្រែប្រួលអាកាសធាតុ ជ្រើសរើសរកពូជថ្មីៗដែលផ្តល់ទិន្នផលខ្ពស់សមស្របទៅតាមក្បេត្របរិស្ថាននៃតំបន់ដាំដុះ ប្រភេទដីនីមួយៗ និងតម្រូវការទីផ្សារ។ ម៉្យាងមួយវិញទៀត នៅកម្ពុជាមានស្ថានីយ៍ដែលផ្តោតសំខាន់ទៅលើការស្រាវជ្រាវ បញ្ហាផលិតភាពគ្រាប់ពូជស្រូវនោះគឺវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា(CARDI)។ ប៉ុន្តែវិទ្យាស្ថាននេះ មានការអភិវឌ្ឍនៅមានកម្រិតនៅឡើយ ដោយសារតែមិនមានថវិកាគ្រប់គ្រាន់នៅក្នុងដំណើរការស្រាវជ្រាវ ហើយបើសិនជាវិទ្យាស្ថានមួយនេះ នៅតែបន្តការស្រាវជ្រាវ និងមានការជួយឧបត្ថម្ភច្រើនជាងនេះ ទៅថ្ងៃអនាគតនឹងក្លាយជាទីចែកចាយពូជស្រូវសំខាន់នៅមួយប្រទេស។

### ៤.២.២ ទីផ្សារកសិកម្ម និងការរក្សាលំនឹងថ្លៃលក់

ការស្វែងរកទីផ្សារសម្រាប់ផលិតផលកសិកម្ម គឺជាកូនសោរចាក់ទំលុះភាពរាំងស្ទះនិងភាពយឺតយ៉ាវក្នុងការអភិវឌ្ឍវិស័យកសិកម្ម ជាពិសេសគឺកាត់បន្ថយភាពក្រីក្រនៅជនបទ ដោយហេតុថាតម្រូវការទីផ្សារកសិកម្មកាន់តែធំ នោះចំណូលរបស់អ្នកផលិតក៏កើនឡើងដែរ ហើយផលចំណេញទាំងនោះនឹងធ្លាក់ទៅលើប្រជាជនជាង ៧០%ដែលជាកសិករ ក៏ប៉ុន្តែអ្វីដែលជាបញ្ហាគឺទីផ្សារកសិកម្មសព្វថ្ងៃនៅមានភាពរាំងស្ទះនៅឡើយ ដោយសារកង្វះខាតព័ត៌មាន។ មួយវិញទៀត បញ្ហាតម្លៃទីផ្សារឡើងចុះដែលមិនអាចកំណត់បាន ជាពិសេសគឺពេលប្រមូលផលតម្លៃកសិផលបែរជាមានតម្លៃថោក ដែលជាឧបសគ្គដ៏ធំមួយក្នុងការបង្កើនផលិភាពកសិកម្ម។ ដូច្នេះដើម្បីឲ្យទីផ្សារផលិតផលកសិកម្មមានការរីកចម្រើន ជាបឋម ត្រូវតែពង្រីកបន្ថែមទាំងទីផ្សារក្នុងស្រុក និងទីផ្សារអន្តរជាតិ។ ក្នុងនោះផងដែរ ទីផ្សារអន្តរជាតិសម្រាប់កសិផលដែលកម្ពុជាបាននាំចេញទៅកាន់ប្រទេសជាដៃគូមានការរីកចម្រើនគួរសមដែរ តែភាគច្រើនផ្តោតទៅលើផលិតផលស្រូវនិងអង្ករ ដោយសារតែស្រូវ-អង្ករកម្ពុជាមានគុណភាពល្អ ហេតុនេះហើយបានជារាជរដ្ឋាភិបាលកម្ពុជាខិតខំស្វែងរកទីផ្សារកសិផលបន្ថែមទៅលើទីផ្សារអន្តរជាតិ ក្នុងការពង្រីកបរិមាណនាំចេញស្រូវ-អង្ករឲ្យស្របទៅតាមផែនការរបស់រាជរដ្ឋាភិបាលកម្ពុជា ពោលគឺឲ្យបាន ១ លានតោនក្នុងមួយឆ្នាំ។ ចំណែកឯទីផ្សារក្នុងស្រុកវិញក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាន

ដាក់ចេញនូវផែនការជាច្រើនសម្រាប់បង្កើនតម្រូវការតាមរយៈការជំរុញអភិវឌ្ឍន៍សហគមន៍កសិកម្ម ដើម្បីក្លាយជាកន្លែងផលិតទ្រង់ទ្រាយធំដោយអនុវត្តយន្តការផលិតផលកសិកម្មតាមកិច្ចសន្យា ជាពិសេសការភ្ជាប់ក្រុមផលិតករជាមួយក្រុមអ្នកប្រមូលទិញដែលជាគន្លឹះដោះស្រាយទីផ្សារកសិផល។ មួយវិញទៀត សហព័ន្ធស្រូវ-អង្ករកម្ពុជាក៏បានប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការលើកកម្ពស់ផលិតភាព ដើម្បីធ្វើឲ្យប្រសើរឡើងនូវបច្ចេកទេសកសិកម្ម និងការកិនកែច្នៃអង្ករកម្ពុជា កាត់បន្ថយចំណាយថ្លៃដើមក្នុងដំណើរការនាំចេញ ដើម្បីការពារគុណភាពអង្កររយៈពេលវែង និងនិរន្តរភាពនៃការផ្គត់ផ្គង់អង្ករកម្ពុជា។ ទន្ទឹមនឹងនេះដែរ ក្រសួងក៏បានដាក់ចេញនូវយន្តការនិងជម្រើសសំខាន់ៗ ទាំង៥ក្នុងការរក្សាលំនឹងថ្លៃកសិផល ព្រមទាំងផ្សព្វផ្សាយទៅឲ្យកសិករប្រើប្រាស់ផងដែរ។[61]

- **ជម្រើសទី ១៖ បង្កើតក្រុមជាឃ្លាំងស្តុកកសិផល**

កសិករម្នាក់ឯងមិនអាចមានអំណាចទៅលើតម្លៃលក់ផលិតផលរបស់ខ្លួនលើទីផ្សារបានទេ ប៉ុន្តែបើរួមកម្លាំងគ្នា គេអាចលក់ផលិតផលទាំងនោះបានតម្លៃខ្ពស់។ ក្នុងគម្រោងនេះ កសិករក្នុងសហគមន៍ត្រូវបង្កើតជាឃ្លាំងស្តុកផលិតផលកសិកម្មរួមគ្នាមួយ សម្រាប់យកកសិផលរបស់ពួកគាត់ទៅស្តុកក្នុងនោះ។ ការធ្វើបែបនេះគឺដើម្បីបញ្ចៀសការលក់ផលិតផលកសិកម្មទៅលើទីផ្សារក្នុងតម្លៃថោកទាំងបង្ខំចិត្ត ហើយទុកផលិតផលពួកគាត់ លក់ពេលណាដែលតម្លៃលើទីផ្សារមានការកើនឡើង។ ជម្រើសនេះអាចប្រើបានក្នុងរយៈពេលខ្លីប៉ុណ្ណោះ ព្រោះនៅរយៈពេលវែងអាចធ្វើឲ្យកសិផលខូចគុណភាពបើមិនមានការគ្រប់គ្រងកសិផលត្រឹមត្រូវ។

- **ជម្រើសទី ២៖ បង្កើតតំណាងក្រុមផលិតផលកសិកម្ម**

កសិករច្រើននាក់រួមគ្នាចុះកិច្ចសន្យាជាមួយក្រុមហ៊ុន រោងម៉ាស៊ីនកិនស្រូវ រោងចក្រកែច្នៃកសិផល ឬឈ្មួញកណ្តាលក្នុងតម្លៃមួយដែលបានចរចារ និងព្រមព្រៀងគ្នាជាមួយនឹងបរិមាណ ដោយកសិករសន្យាថា នៅពេលប្រមូលផលបាននឹងលក់កសិផលរបស់ពួកគាត់ទៅឲ្យភាគីទៅតាមកិច្ចសន្យា។ កិច្ចព្រមព្រៀងនេះត្រូវធ្វើឡើងវិញជារៀងរាល់ឆ្នាំ ទើបប្រជាកសិករទទួលបានផលប្រយោជន៍ច្រើនបំផុត។ ជម្រើសនេះខុសជម្រើសទី១ ត្រង់កសិករទាំងអស់មិនបាច់មានឃ្លាំងស្តុកកសិផលរួមគ្នាទេ។ ជម្រើសនេះសម្រេចបានដោយជោគជ័យ ត្រូវមានរោងចក្រ ឬក្រុមហ៊ុនកែច្នៃ និងឧបករណ៍កសិកម្មទំនើបៗនៅមូលដ្ឋានឲ្យបានច្រើនទើបជាការល្អ។

- **ជម្រើសទី ៣៖ កិច្ចព្រមព្រៀងផ្លូវការជាមួយក្រុមហ៊ុន**

នេះជាជម្រើសថ្មីដែលមានទ្រង់ទ្រាយធំ និងកាន់តែប្រិតប្រៀងជាងមុន ពោលគឺជាកិច្ចព្រមព្រៀងផ្លូវការមួយរវាងកសិករជាច្រើនជាមួយនឹងក្រុមហ៊ុនកែច្នៃកសិផល ឬក្រុមហ៊ុននាំចេញ។ នៅកម្ពុជាបច្ចុប្បន្ន កិច្ចព្រមព្រៀងបែបនេះទទួលបានជោគជ័យចំនួន ២ករណីហើយគឺករណីអង្គរក្រអូប និងថ្នាំជក់។ ជម្រើសនេះ ក្រុមហ៊ុនធំៗ

[61] បណ្ឌិត ឈុន ពហុ, *ការអភិវឌ្ឍជនបទ(២០១៧)*។

អាចចុះកិច្ចសន្យាទិញកសិផលជាមួយកសិករតូចៗជាច្រើននាក់ដោយផ្ទាល់ ឬក៏ជាមួយក្រុមសហករណ៍កសិករធំៗ នៅក្នុងតម្លៃនិងបរិមាណដែលបានកំណត់ជាមុន ដោយមានការត្រួតពិនិត្យយ៉ាងម៉ត់ចត់លើគុណភាព និងសម្ភារៈដែលប្រើប្រាស់ក្នុងដំណើរការផលិតកម្ម ដើម្បីធានាថាកសិផលនឹងអាចទទួលបានតាមពេលវេលាកំណត់ ជាមួយនឹងបរិមាណដែលបានព្រមព្រៀងគ្នា។ កិច្ចព្រមព្រៀងនេះ កសិករអាចទទួលបានផលចំណេញដោយមិនចាំបាច់ព្រួយបារម្ភពីតម្លៃលើទីផ្សារធ្លាក់ចុះពេលប្រមូលផលនោះទេ។ ប៉ុន្តែ កសិផលត្រូវតែមានបរិមាណក្នុងកម្រិតអប្បបរមាមួយជាដាច់ខាត បើពុំនោះទេក្រុមហ៊ុននឹងមិនទទួលបានផលចំណេញ ហើយដើម្បីអាចផលិតបានតាមបរិមាណកំណត់ កសិករត្រូវមានឧបករណ៍គ្រប់គ្រាន់ដូចជាប្រព័ន្ធស្រោចស្រពគ្រប់គ្រាន់ គ្រឿងយន្តកសិកម្ម ពូជស្រូវ ជីនិងថ្នាំកសិកម្មគ្រប់គ្រាន់សម្រាប់ដំណើរការកសិកម្ម។

- **ជម្រើសទី ៤៖ លក់ក្នុងតម្លៃណាមួយជាកំហិតទៅឲ្យឈ្មួញដោយធានាពីរដ្ឋ**

ប្រព័ន្ធថ្លៃគាំទ្រអប្បបរមា (MSP) ជាការកំណត់តម្លៃក្នុងកម្រិតមួយ ដើម្បីការពារកសិករទប់ទល់នឹងការធ្លាក់ចុះថ្លៃប្រចាំរដូវប្រមូលផល។ នេះជាការលូកដៃរបស់រដ្ឋាភិបាលទៅក្នុងទីផ្សារកសិកម្ម ដែលតម្រូវឲ្យឈ្មួញឯកជនក៏អនុវត្តតាមប្រព័ន្ធនេះដែរ មានន័យថានៅពេលដែលថ្លៃលើទីផ្សារទាបជាងថ្លៃរបស់ប្រព័ន្ធMSP ពួកឈ្មួញតម្រូវឲ្យទិញកសិផលពីកសិករក្នុងតម្លៃរបស់ប្រព័ន្ធMSPដោយមានការឧបត្ថម្ភធនពីរដ្ឋ។ ប៉ុន្តែ នៅពេលថ្លៃលើទីផ្សារខ្ពស់ជាងថ្លៃប្រព័ន្ធMSP រដ្ឋាភិបាលតម្រូវឲ្យពួកឈ្មួញបង់ពន្ធជូនរដ្ឋវិញ។ ប្រព័ន្ធមួយនេះ ក៏មានចំណុចខ្សោយរបស់វាដែរ ដោយហេតុថាវាមិនបានជំរុញឲ្យកសិករបង្កើនផលិតភាពកសិកម្ម និងប្រសិទ្ធភាពក្នុងការដាំដុះទេ។ ក្នុងបរិបទកម្ពុជាសព្វថ្ងៃ ប្រហែលជាមិនទាន់អាចប្រើប្រព័ន្ធនេះបានទេដោយសារតែអាចមានឱនភាពថវិការដ្ឋធ្ងន់ធ្ងរ។

- **ជម្រើសទី ៥៖ ការគាំពារកសិករក្នុងស្រុក**

នេះគឺជាតួនាទីរបស់រាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ការនាំចូលកសិផលពីប្រទេសជិតខាង ដោយហេតុថាប៉ះពាល់ដល់តម្លៃក្នុងស្រុក និងប៉ះពាល់ដល់ទឹកចិត្តរបស់កសិករក្នុងការផលិត។ ការទប់ស្កាត់ការនាំចូលអាចធ្វើឡើងក្នុងរូបភាពនៃការដាក់កូតា(Quota) ដែលជាការដាក់កំណត់នៃបរិមាណឬក៏លក្ខខណ្ឌគុណភាពនៃកសិ-ផលនាំចូល និងការដាក់ចេញនូវពន្ធនាំចូលលើផលិតផលកសិកម្ម ដែលនយោបាយទាំង ២នេះមានគោលដៅដូចគ្នា ពោលគឺកាត់បន្ថយការនាំចូលទំនិញ ក្នុងគោលបំណងជំរុញការផលិតក្នុងស្រុក និងរក្សាលំនឹងថ្លៃ។

### ៤.២.៣ ការលើកទឹកចិត្តឲ្យកសិករបន្ថែមការប្រើប្រាស់គ្រឿងយន្តកសិកម្ម

ពីមុន កសិកម្មកម្ពុជាជាកសិកម្មបែបចិញ្ចឹមជីវិត ព្រោះវាពឹងផ្អែកខ្លាំងទៅលើកម្លាំងពលកម្មមនុស្ស ជាហេតុដែលដំណើរការកសិកម្មត្រូវប្រើពេលយូរ និងទទួលបានទិន្នផលនៅមានកម្រិត។ ប៉ុន្តែចាប់តាំងពីឆ្នាំ ២០០៩មក

កសិករចាប់ផ្តើមប្រើនូវគ្រឿងយន្តកសិកម្មច្រើនឡើង ដោយសារតែកំណើននៃការចំណាកស្រុករបស់ប្រជាជនពីជនបទទៅកាន់ទីក្រុង កំណើននៃការចាកចេញកម្លាំងពលកម្មពីវិស័យកសិកម្មទៅកាន់វិស័យឧស្សាហកម្មនិងសេវាកម្ម និងការកើនឡើងនៃតម្រូវការកសិផលដោយសារការកំណើនប្រជាជនជាដើម។ និយាយជារួម គ្រឿងយន្តកសិកម្មបានបង្កើននូវផលិតភាពកសិកម្ម និងផលិតភាពរបស់កសិករគួរឲ្យភ្ញាក់ផ្អើល ថែមទាំងផ្តល់អត្ថប្រយោជន៍ទៅដល់កសិករដោយផ្ទាល់ដូចជាកាត់បន្ថយថ្លៃដើមផលិតកម្មតាមរយៈការកាត់បន្ថយកម្លាំងពលកម្មក្នុងដំណើរការកសិកម្ម ងាយស្រួលក្នុងការពង្រីកផ្ទៃដីកសិកម្ម លើកកម្ពស់សមត្ថភាពប្រមូលផល កាត់បន្ថយការបាត់បង់ក្រោយពេលប្រមូលផល ចំណេញពេលវេលា កសិករអាចធ្វើស្រែចម្ការ ២-៣ដងក្នុងមួយឆ្នាំ ដើម្បីបង្កើនប្រាក់ចំណូលដល់ប្រជាកសិករទៀតផង។ ដោយមើលឃើញពីគុណសម្បត្តិទាំងអស់នេះហើយ បានជារាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងកសិកម្មបានចាត់វិធានការផ្សព្វផ្សាយទៅដល់សហគមន៍កសិករបន្តលើកកម្ពស់យន្តូបនីយកម្មកសិកម្មបន្ថែមទៀតដូចជាការជំរុញការប្រើប្រាស់គ្រឿងយន្តកសិកម្ម ការបង្កើតមជ្ឈមណ្ឌលថែទាំជួសជុលគ្រឿងយន្តកសិកម្ម ការអភិវឌ្ឍវិស្វកម្មកសិកម្ម ការស្រាវជ្រាវផលិតឧបករណ៍ដើម្បីបង្កើនផលិតភាពកសិកម្ម ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាប្រកបដោយប្រសិទ្ធភាពខ្ពស់នៅគ្រប់ដំណាក់ខ្សែផលិតកម្មកសិកម្ម ដើម្បីធានានូវគុណភាព សុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់ កាត់បន្ថយជាអតិបរមាដល់ការហូរច្រោះខូចគុណភាពដី ការខ្ជះខ្ជាយថាមពល ទឹក និងការបាត់បង់ផលពេលផលិតបាន។ លើសពីនេះទៅទៀត រាជរដ្ឋាភិបាលកម្ពុជាគប្បីលើកទឹកចិត្តឲ្យមានការប្រើប្រាស់គ្រឿងយន្តកសិកម្មបន្ថែមទៀត តាមរយៈការកាត់បន្ថយពន្ធនាំចូលលើគ្រឿងចក្រទាំងនោះ ដើម្បីឲ្យកសិករអាចទិញវាបានក្នុងតម្លៃទាប ចូលរួមកាន់តែច្រើននៅក្នុងដំណើរការផលិតកម្ម និងបង្កើនផលិតភាពកសិកម្មប្រកបដោយប្រសិទ្ធភាព និងចីរភាព។

### ៤.២.៤ បន្ថែមការគាំទ្រដល់សេវាកម្មកសិកម្ម

កង្វះខាតនូវសម្ភារៈបច្ចេកទេសកសិកម្ម ធនធាន និងសមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការផ្សព្វផ្សាយបច្ចេកទេសកែលម្អផលិតកម្ម បច្ចេកវិទ្យាទំនើបដែលមានលក្ខណៈសមស្របសម្រាប់ប្រើប្រាស់ក្នុងប្រទេសទៅឲ្យកសិករនៅទីជនបទតាមរយៈបណ្តាញផ្សព្វផ្សាយជាអាទិ៍ ពីកសិករជិតខាងនៅក្នុងសហគមន៍ អ្នកចែកចាយផលិតផលកសិកម្ម អង្គការក្រៅរដ្ឋាភិបាល និងមន្ត្រីជំនាញ បានធ្វើឲ្យផលិតភាពកសិកម្មកម្ពុជានៅមានកម្រិតនៅឡើយ។ ដូចនេះតម្រូវឲ្យមានការស្រាវជ្រាវស្វែងរកបច្ចេកវិទ្យាថ្មីដែលមានតម្លៃថោក ប្រសិទ្ធភាពការងារ ងាយស្រួលថែរក្សា ហើយបច្ចេកទេសកសិកម្មដែលសមស្របក្នុងការអនុវត្តនៅតាមតំបន់ដាំដុះក្នុងប្រទេស តាមរយៈរាជរដ្ឋាភិបាល និងស្ថាប័នដែលពាក់ព័ន្ធត្រូវជំរុញការស្រាវជ្រាវ ស្តារឡើងវិញនូវមជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មដើម្បីបន្តកិច្ចការស្រាវជ្រាវនិងបណ្តុះបណ្តាលលើវិស័យកសិកម្ម ស្វែងរកបច្ចេកវិទ្យាថ្មីទំនើបនិងសមស្របអាច

ទទួលយកបានសម្រាប់កសិករកែលម្អវិធីសាស្ត្រផលិតកម្មកសិកម្ម ស្វែងរកពូជស្រូវដែលមានផលិតភាព និងគុណភាពខ្ពស់ធន់នឹងភាពរាំងស្ងួត ទឹកជំនន់ ការបំផ្លាញពីសត្វល្អិត ស្វែងរកវិធីសាស្ត្រការប្រើប្រាស់ជីដែលប៉ះពាល់ជាអប្បបរមាដល់បរិស្ថាន បង្កើនបច្ចេកទេសរៀបចំដី និងកែលម្អដីខូចឲ្យមានផលិតភាពឡើងវិញ។ បន្ថែមពីលើនេះ តាមរយៈភ្នាក់ងារស្រាវជ្រាវកសិកម្ម អង្គការកសិករ និងអង្គការបណ្តុះបណ្តាលនានា ជារឿយៗបានខិតខំផ្សព្វផ្សាយដំណើរការអប់រំរបស់កសិកម្ម ដើម្បីសម្របសម្រួលការរៀនសូត្រ ពង្រីកចំណេះដឹង បច្ចេកវិទ្យាថ្មីៗ ផ្សារភ្ជាប់កសិករជាមួយនឹងព័ត៌មានផ្នែកលើការស្រាវជ្រាវ ក្នុងគោលដៅកែលម្អផលិតភាពកសិកម្ម និងបង្កើនចំណូលកសិករ។ ជាពិសេស ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏បានចាត់វិធានការជំរុញនិងពង្រឹងស្ថាប័នសហគមន៍កសិករបន្ថែមទៀត ដើម្បីអាចជួយដល់កសិករខ្នាតតូចអាចធ្វើសេចក្តីសម្រេចចិត្តបានត្រឹមត្រូវផ្នែកផលិតកម្ម និងការលក់កសិផល ហើយអាចឲ្យអង្គការកសិករពឹងពាក់ខ្លួនឯង ព្រមទាំងមានចំណេះដឹងក្នុងការស្វែងរកផលប្រយោជន៍ដល់សមាជិករបស់ពួកគេ។ មិនត្រឹមតែប៉ុណ្ណោះ សហគមន៍កសិករថែមទាំងអាចមានអំណាចនៅក្នុងទីផ្សារគ្រប់ទិដ្ឋភាពផ្នែកផលិតកម្ម និងខ្សែសង្វាក់តម្លៃដូចជា ការទិញជីជាដុំ សម្ភារៈកសិកម្ម ការចែករំលែកព័ត៌មានកសិកម្ម និងការផ្សព្វផ្សាយបច្ចេកទេសកសិកម្មប្រកបដោយប្រសិទ្ធភាព។

### ៤.២.៥ ការបង្កើតកសិកម្មចម្រុះ ប្រពលវប្បកម្ម និងកសិ-ឧស្សាហកម្ម

ដំណាំស្រូវ គឺជាផ្នែកមួយដ៏សំខាន់ក្នុងការទ្រទ្រង់ការរស់រានមានជីវិត ប៉ុន្តែការពង្រីកដំណាំស្រូវតែមួយមុខគឺគ្រាន់តែជួយមួយផ្នែកនៃសន្តិសុខស្បៀងប៉ុណ្ណោះ។ ម្យ៉ាងទៀត ការធ្វើកសិកម្មតែមួយមុខនៅលើលើផ្ទៃដីទាំងអស់មិនមែនជាវិធីសាស្ត្រល្អនោះឡើយ ហើយវាអាចនឹងប្រឈមនឹងការខូចខាតទិន្នផលនៅពេលមានការប្រែប្រួលអាកាសធាតុ ការខូចគុណភាពដី ការយាយីពីសត្វល្អិតចង្រៃ ជាពិសេសប្រឈមនឹងតម្លៃទីផ្សារដែលឡើងចុះមិនទៀងទាត់។ ដើម្បីទប់ទល់នឹងបរិបទនេះ ការបង្កើតកសិកម្មចម្រុះ គឺជាការដាំដុះលើសពីមួយមុខ នៅលើផ្ទៃដីតែមួយ ឬផ្សេងគ្នាក្នុងពេលតែមួយឬខុសគ្នា ដែលនេះជាវិធីសាស្ត្រដ៏ប្រពៃនៅក្នុងទំនើបកម្មកសិកម្ម ដើម្បីកាត់បន្ថយហានិភ័យនៃលក្ខខណ្ឌធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី និងសេដ្ឋកិច្ចសង្គមដែលតែងតែកើតមានជាយថាហេតុ ធានានិរន្តរភាពដីកសិកម្មមិនឲ្យខូចរេចរិល ហើយការបញ្ចូលនូវកសិកម្មចម្រុះនេះទៀតសោតបានចូលរួមចំណែកក្នុងការបង្កើនសន្តិសុខស្បៀង និងចំណូលបន្ថែមសម្រាប់កសិករជនបទ ហើយវាជួយដល់ការរក្សាលំនឹងបរិស្ថាន។ យ៉ាងណាមិញ កសិកម្មចម្រុះលើដំណាំស្រូវ គឺសម្តៅលើការដាំស្រូវនៅលើផ្ទៃដីដដែលប៉ុន្តែធ្វើការឆ្លាស់គ្រាប់ពូជក្នុងការដាំខុសគ្នាៗ ដោយចៀសវាងការដាំដំណាំស្រូវដោយប្រើគ្រាប់ពូជតែមួយប្រភេទ។ ការធ្វើបែបនេះ គឺអាចជួយកាត់បន្ថយអត្រាសំណឹកនៃដី ក៏ដូចជាជីជាតិក្នុងដី។ ចំណែកឯ ប្រព័ន្ធប្រពលវប្បកម្មស្រូវគឺជារបៀបដាំស្រូវងាយស្រួល អស់ថ្លៃដើមផលិតកម្មតិច តែបានទិន្នផលខ្ពស់។ បច្ចុប្បន្ននេះ ប្រជាកសិករ

កំពុងតែកែលម្អរបៀបធ្វើស្រែរបស់ខ្លួនដោយយកតាមប្រព័ន្ធប្រពលវប្បកម្មស្រូវនេះ ដើម្បីបង្កើនផលិតផល មានប្រាក់ចំណូលច្រើន មានគុណភាពអាហារូបត្ថម្ភល្អជាងមុន។ ប្រព័ន្ធនេះប្រើជីគីមីតិច ហើយត្រូវការជីធម្មជាតិច្រើនជាង។ ធ្វើបែបនេះ អាចជួយកាត់បន្ថយចំណាយលើការទិញជីគីមី ដោយសារជីកំប៉ុសអាចធ្វើបាននៅតាមផ្ទះព្រមទាំងចំណាយតិចជាងមុនទៀតផង។ បន្ថែមពីលើនេះ ការអភិវឌ្ឍកសិ-ឧស្សាហកម្មនឹងជួយបង្កើនតម្លៃបន្ថែមលើកសិផល ដែលនឹងជំរុញកសិករឲ្យចាកចេញពីការធ្វើកសិកម្មបែបគ្រួសារទៅជាទំនើបកម្មកសិកម្មតាមរយៈកំណើននៃតម្រូវការដែលទាក់ទងទៅនឹងការកែច្នៃផលិតផលកសិកម្មទៅជាផលិតផលឧស្សាហកម្ម ឬពាក់កណ្ដាលឧស្សាហកម្ម ដែលសម្រាប់ផ្គត់ផ្គង់ធាតុផ្សំនៅក្នុងដំណើរការផលិតកម្មកសិកម្ម។

### ៤.២.៦ ការស្ដារ និងកសាងហេដ្ឋារចនាសម្ព័ន្ធ

ការស្ដារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តជនបទដែលអាចធន់ការដឹកជញ្ជូនធ្ងន់ៗ និងមានភាពធន់នឹងអាកាសធាតុ គឺមានសារៈសំខាន់ណាស់ដើម្បីជំរុញការអភិវឌ្ឍកសិកម្ម ដោយសារវាបានជួយកាត់បន្ថយការចំណាយផ្សេងៗដូចជា ពេលវេលា និងថវិការបស់ប្រជាពលរដ្ឋជាពិសេសកសិករនៅតំបន់ជនបទ។ ផ្លូវជនបទក៏សំខាន់ផងដែរក្នុងការដឹកជញ្ជូនសម្ភារៈកសិកម្ម វត្ថុធាតុដើមផ្សេងៗទៅកាន់កសិដ្ឋាន ឬទីកន្លែងបង្កបង្កើនផលរបស់កសិករ។ ជាមួយគ្នានេះ ដែរផ្លូវជនបទក៏បានជួយសំរួលដល់ប្រជាកសិករក្នុងការដឹកបញ្ជូនកសិផលទៅកាន់ទីផ្សារផងដែរ និងផ្សារភ្ជាប់រវាងតំបន់ជនបទ និងទីក្រុងផងដែរ។ ជាពិសេសវាជាផ្នែកមួយសំខាន់ផងដែរក្នុងការទាក់ទាញវិនិយោគិនទាំងក្នុង និងក្រៅប្រទេសដើម្បីអភិវឌ្ឍន៍វិស័យកសិកម្មនៅប្រទេសកម្ពុជា តាមរយៈការធ្វើដីសម្បទានសេដ្ឋកិច្ច ការបង្កើតសហគ្រាសកែច្នៃផ្សេងៗ ដើម្បីផ្ដល់តម្លៃបន្ថែមទៅឲ្យផលិតផលកសិកម្ម។

# សេចក្តីសន្និដ្ឋាន
# និង អនុសាសន៍

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ និងវិភាគជារួមទៅលើអនុវិស័យកសិកម្មដំណាំស្រូវបង្ហាញថា ស្ថានភាពនៃវិស័យកសិកម្មកម្ពុជាបច្ចុប្បន្ន កំពុងតែមានកំណើនយឺត។ យើងសង្កេតឃើញថា ដំណាំស្រូវនៅតែជាផលិតផលសំខាន់ជាងគេនៃកសិកម្មកម្ពុជា ហើយប៉ុន្មានឆ្នាំចុងក្រោយនេះ ទិន្នផលសរុបនៃដំណាំនេះមាននិន្នាការកើនឡើងជាលំដាប់ ក៏ព្រោះតែមានការបញ្ចូលពូជថ្មីៗដែលមានផលិតភាព ការពង្រីកប្រព័ន្ធធារាសាស្ត្រ ការប្រើប្រាស់ជី និងបច្ចេកទេសដាំដុះជាដើម។ ទោះបីជាផលិតកម្មដំណាំស្រូវទទួលបានទិន្នផលកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំក៏ពិតមែន ប៉ុន្តែវិស័យកសិកម្មកម្ពុជាហាក់បីដូចជានៅក្មេងខ្ចីនៅឡើយ បើប្រៀបធៀបជាមួយនឹងកសិកម្មនៅប្រទេសក្នុងតំបន់ដូចជាប្រទេសថៃ និងវៀតណាមជាដើម ជាពិសេសកសិកម្មកម្ពុជានឹងកាន់តែមិនមានភាពចាស់ទុំ បើស្ថិតនៅក្នុងក្របខណ្ឌសាកលលោក។ ស្ថិតនៅក្នុងសាកលភាវូបនីយកម្មសតវត្សទី២១ កម្ពុជាត្រូវតែបង្កើននូវផលិតភាពកសិកម្មរបស់ខ្លួន ក្នុងការប្រកួតប្រជែងជាមួយនឹងផលិតផលកសិកម្មរបស់ប្រទេសផ្សេងទៀត ដើម្បីចាប់យកចំណែកទីផ្សារពិភពលោកជាអតិបរមា។ ប៉ុន្តែបច្ចុប្បន្ននេះ កសិកម្មកម្ពុជាកំពុងតែជួបប្រទះនូវបញ្ហាធំៗជាច្រើនដែលធ្វើឲ្យការបង្កើនផលិតភាពកសិកម្មមានភាពយឺតយ៉ាវនៅឡើយ ជាអាទិ៍រួមមាន កង្វះចំណេះដឹងក្នុងការបង្កើនផលិតភាពនិងគ្រប់គ្រងដីជាតិដី ភាពខ្វះខាតនៃប្រព័ន្ធស្រោចស្រព ហេដ្ឋារចនាសម្ព័ន្ធនៅជនបទមានកម្រិត កង្វះឥណទានសម្រាប់កសិករក្នុងការបង្កើនផលិតកម្មកសិកម្ម ប្រជាកសិករមិនមានផលិតភាពខ្ពស់នឹងការធ្វើការងារកសិកម្ម កង្វះនូវព័ត៌មានទីផ្សារកសិកម្ម ការចែកចាយនិងផ្សព្វផ្សាយកសិកម្មមានកម្រិតទាប រួមជាមួយការអនុវត្តរបស់មន្ត្រីតាមមូលដ្ឋានមិនសមប្រកបទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ដើម្បីដោះស្រាយបញ្ហារាំងស្ទះទាំងនេះប្រកបដោយប្រសិទ្ធភាព រដ្ឋាភិបាលជាអ្នកដើរតួនាទីសំខាន់ជាងគេក្នុងការសម្របសម្រួល និងអនុវត្តមធ្យោបាយទាំងនោះ។ ជាលទ្ធភាពរាជរដ្ឋាភិបាលមិនអាចដោះស្រាយគ្រប់បញ្ហាក្នុងពេលតែមួយបានទេ ដូចនេះរាជរដ្ឋាភិបាលត្រូវថ្លឹងថ្លែងមើលបញ្ហាជាអាទិភាព ហើយស្ថិតក្នុងដែនកំណត់របស់ខ្លួន យកមកធ្វើការដោះស្រាយ។ ជាក់ស្តែង បញ្ហាដែលមានឥទ្ធិពលខ្លាំងមកលើការអភិវឌ្ឍផលិតភាពកសិកម្មកម្ពុជាមានដូចជា មធ្យោបាយផលិតកម្មកសិកម្ម(ដី ជីកសិកម្ម គ្រាប់ពូជ) ប្រព័ន្ធធារាសាស្ត្រ ផលិតភាពរបស់កសិករ គ្រឿងយន្តកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធជនបទ។ បញ្ហាទាំងនេះ រាជរដ្ឋាភិបាលអាចដោះស្រាយបាន តែត្រូវមើលលើលទ្ធភាព និងវិភាគថាគួរដោះស្រាយនៅតំបន់ណាដែលទទួលបានលទ្ធផលខ្ពស់ជាងគេ។ មែនទែនទៅ រាជរដ្ឋាភិបាលក្រៅពីដាក់ចេញគម្រោងវិនិយោគសាធារណៈ និងអនុម័តថវិកាជាតិ គប្បី

គួរតែកៀងគរផ្នែកឯកជនឲ្យចូលរួមក្នុងការអភិវឌ្ឍលើគម្រោងណាដែលមានទំនាក់ទំនងដោយផ្ទាល់ និងដោយប្រយោលក្នុងការបង្កើនផលិតភាពកសិកម្ម ពីព្រោះថាអ្នកដែលទទួលបានផលប្រយោជន៍ពីគម្រោងសាធារណៈមិនត្រឹមតែកសិករប៉ុណ្ណោះទេ តែថែមទាំងផ្នែកឯកជនខ្លួនឯងផងដែរ។ លើសពីនេះទៅទៀត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបង្កើនការលើកកម្ពស់ការស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្មបន្ថែមទៀត ក្នុងទិសដៅបង្កើនបរិមាណ និងគុណភាពផលិតផលកសិកម្ម តាមរយៈការប្រើប្រាស់បន្ថែមនូវគ្រឿងយន្តកសិកម្ម បច្ចេកវិទ្យាទំនើបៗ បច្ចេកទេសថ្មីៗ ដែលស្ថិតក្នុងបរិបទបម្រែបម្រួលអាកាសធាតុ ព្រមទាំងប្រែក្លាយទៅជាកសិកម្មបែបទំនើប ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារទាំងក្នុងប្រទេស ក្នុងតំបន់ និងពិភពលោក។

## ២. អនុសាសន៍

យោងទៅតាមការបកស្រាយវាយតម្លៃ និងសន្និដ្ឋាននៅទំព័រខាងលើ បានជំរុញឲ្យក្រុមយើងខ្ញុំចូលរួមបញ្ចេញមតិយោបល់ខ្លះ ដើម្បីធ្វើឲ្យសកម្មភាពការងារនៅក្នុងការបង្កើនផលិតភាពកសិកម្មកម្ពុជាកាន់តែទទួលបានជោគជ័យជាងនេះប្រកបដោយប្រសិទ្ធភាព និងចីរភាព។ ជាអាទិ៍ ចំណុចដែលគួរកែលម្អ និងពង្រឹងបន្ថែមរួមមានៈ

### ០ ប្រជាកសិករ

- កសិករគប្បីចូលរួមរាល់វគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសកសិកម្មផ្សេងៗដោយយកចិត្តទុកដាក់ ដើម្បីបង្កើនផលិតភាពរបស់ខ្លួន។
- ប្រជាកសិករគួរតែកែលម្អរចនាសម្ព័ន្ធដីស្រែរបស់ខ្លួនឲ្យមានសភាពល្អប្រសើរ ដើម្បីរក្សាទឹកក្នុងស្រែបានរយៈពេលយូរ។
- គប្បីថែរក្សាហេដ្ឋារចនាសម្ព័ន្ធជនបទដែលមានស្រាប់ ដើម្បីនិរន្តរភាពនៃការប្រើប្រាស់។
- ជំរុញការប្រើប្រាស់ដីឲ្យមានប្រសិទ្ធភាព ដោយចៀសវាងការទុកផ្ទៃដីចោលឲ្យនៅទំនេរ តាមរយៈអ្នកមានដីកសិកម្មច្រើន គប្បីជួលឬលក់មួយចំណែកទៅឲ្យកសិករដើម្បីបង្កបង្កើនទិន្នផលថែមទៀត។

### ០ សហគមន៍កសិករ

- ជំរុញឲ្យក្រុមកសិករកសាងឃ្លាំងស្តុកផលិតផលកសិកម្មរួមគ្នាសម្រាប់រក្សាទុក នៅពេលដែលកសិផលជោរជន់លើទីផ្សារ ក្នុងគោលបំណងទប់ស្កាត់ការធ្លាក់ចុះនៃតម្លៃកសិផល។
- បង្កើនបន្ថែមនូវកម្មវិធីចែករំលែកបទពិសោធន៍ដែលទទួលបានប្រសិទ្ធភាព រវាងកសិករនិងកសិករនៅក្នុងសហគមន៍កសិកម្មតែមួយ។

- ➢ បង្កើនឲ្យបានកាន់តែច្រើននូវការផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីៗដល់សហគមន៍កសិករ និងបង្កើតបន្ថែមកម្មវិធីសាលារៀនកសិករតាមមូលដ្ឋានដើម្បីឲ្យប្រជាកសិកររៀនសូត្រពីគ្នា ព្រមទាំងអភិវឌ្ឍន៍បច្ចេកទេសដាំដុះប្រកបដោយប្រសិទ្ធភាពខ្ពស់។
- ➢ លើកទឹកចិត្តឲ្យសហគមន៍កសិករគប្បីសហការណ៍ជាមួយនឹងបណ្តាសហគមន៍កសិករផ្សេងទៀតដើម្បីចែករំលែកពីបទពិសោធន៍កសិកម្ម បច្ចេកទេស និងព័ត៌មានទីផ្សារផ្សេងៗទៀត។
- ➢ ជំរុញឲ្យមានទីផ្សារតាមមូលដ្ឋានសម្រាប់លក់ផលិតផលកសិករ និងលើកទឹកចិត្តឲ្យកសិករក្នុងសហ-គមន៍ដាំដំណាំស្រូវខុសប្រភេទគ្នា ដើម្បីបញ្ចៀសការធ្លាក់ចុះនៃតម្លៃពេលប្រមូលផល។

**o ស្ថាប័នពាក់ព័ន្ធ**

- ➢ បង្កើនវគ្គសិក្សាស្តីពីកសិកម្មឲ្យបានច្រើនបន្ថែមទៀត ដើម្បីពង្រឹងសមត្ថភាពកសិករតាមរយៈការអប់រំបណ្តុះបណ្តាលអំពីប្រព័ន្ធប្រពលវប្បកម្ម បែងចែកប្រភេទនៃដី ការគ្រប់គ្រងជីនិងថ្នាំកសិកម្មទៅតាមតម្រូវការប្រភេទដី ដើម្បីបង្កើនផលិតភាពដីកសិកម្ម កាត់បន្ថយសំណឹកដី ផលប៉ះពាល់ដល់សុខភាពនិងប្រព័ន្ធអេកូឡូស៊ី។
- ➢ ពង្រីកប្រព័ន្ធស្រោចស្រពខ្នាតតូចដែលអនុញ្ញាតឲ្យនាំទឹកពីប្រឡាយមេ មកកាន់តំបន់ដាំដុះដើម្បីកាត់បន្ថយចំណាយក្នុងការបូមទឹក និងពង្រឹងបច្ចេកទេសប្រើប្រាស់ទឹកឲ្យមានប្រសិទ្ធភាពតាមបែបតំណក់ទឹកនិងបាចសាចទឹក។
- ➢ ស្ថាបនាបន្ថែមទៀតនូវហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនៅជនបទដែលមានគុណភាព ធន់នឹងអាកាសធាតុដើម្បីសម្រួលដល់ការដឹកជញ្ជូនកសិផលទៅកាន់ទីផ្សារ។
- ➢ គម្រោងឥណទានបង់រំលោះគួរត្រូវបានផ្តល់ឲ្យគ្រប់ទំហំ និងទ្រង់ទ្រាយម៉ាស៊ីនកសិកម្ម ដែលលើកទឹកចិត្តឲ្យកសិករដែលមិនមានធនធានគ្រប់គ្រាន់អាចមានឱកាសប្រើប្រាស់។
- ➢ ធនាគារអភិវឌ្ឍន៍ជនបទ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឯកជន គប្បីបន្ថយអត្រាការប្រាក់ឲ្យទាបដើម្បីផ្តល់ឥណទានឲ្យកសិករក្នុងការពង្រីកផលិតកម្មកសិកម្ម។
- ➢ បន្ថែមការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងព័ត៌មានទីផ្សារតាមរយៈទូរទស្សន៍ វិទ្យុ ហើយនិងបណ្តាញផ្សព្វផ្សាយផ្សេងៗដោយធ្វើការសហការណ៍ជាមួយរាជរដ្ឋាភិបាល ពោលគឺភាពជាដៃគូររវាងរដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាល។

- វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា គួរតែអភិវឌ្ឍន៍និងគាំទ្រការងារស្រាវជ្រាវស្តីពីគ្រាប់ពូជដែលមានផលិតភាព គុណភាព ធន់នឹងអាកាសធាតុ រួចផ្សព្វផ្សាយទៅឲ្យកសិករប្រើប្រាស់បន្ថែមទៀត ដើម្បីបង្កើនទិន្នផលកសិកម្ម ក៏ដូចជាបង្កើនប្រាក់ចំណូល។

**o រាជរដ្ឋាភិបាល**

- លើកទឹកចិត្តឲ្យកសិករប្រើប្រាស់បន្ថែមនូវគ្រឿងយន្តកសិកម្ម តាមរយៈការកាត់បន្ថយឬមិនយកពន្ធលើគ្រឿងយន្តទាំងនោះ ដើម្បីឲ្យពួកគាត់អាចមានលទ្ធភាពទិញមកប្រើប្រាស់ក្នុងដំណើរការកសិកម្ម។
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវតែបណ្តុះបណ្តាលមន្ត្រីកសិកម្មនៅតាមមូលដ្ឋានឲ្យមានជំនាញកាន់តែច្បាស់ក្នុងការពង្រឹងសមត្ថភាព និងចែកចាយទៅកាន់ប្រជាកសិករ តាមរយៈការណែនាំ និងពិសោធន៍ពីប្រភេទដីស្រែឲ្យបានច្បាស់ដើម្បីឲ្យពួកគាត់អាចទាញផលិតភាពពីដីបានខ្ពស់ និងផ្គត់ផ្គង់តម្រូវការនៃសារធាតុចិញ្ចឹមទៅឲ្យដីវិញប្រកបដោយប្រសិទ្ធភាព។
- បន្តការងារស្តារ និងកសាងបន្ថែមប្រព័ន្ធធារាសាស្ត្រដូចជាប្រឡាយទឹកធំ-តូច ទំនប់ទឹក សំណង់ស្ទាក់ទឹកផ្សេងៗដែលមានគុណភាពខ្ពស់ និងមានតុល្យភាពគ្នាតាមតំបន់នីមួយៗ ក្នុងគោលបំណងអភិវឌ្ឍន៍វិស័យកសិកម្មទាំងតំបន់អាទិភាព និងមិនអាទិភាពទាំងអស់ ដើម្បីធានាដល់ការផ្គត់ផ្គង់ទឹកពេញមួយឆ្នាំ ដើម្បីឲ្យកសិករអាចធ្វើស្រែពី ២-៣ដងក្នុងមួយឆ្នាំ។
- ជំរុញ និងលើកទឹកចិត្តអភិវឌ្ឍន៍វិស័យកសិ-ឧស្សាហកម្មទៅលើការវិនិយោគខ្នាតតូច មធ្យម និងធំ លើដំណាំកសិកម្មគ្រប់ប្រភេទ ដើម្បីបង្កើតនូវធាតុផ្សំកសិកម្ម(ជី និងថ្នាំកសិកម្ម) ដែលជាផ្នែកមួយនៃការបង្កើនតម្រូវការផលិតផលកសិកម្មក្នុងស្រុក បង្កើនតម្លៃបន្ថែមនៃកសិផល ដើម្បីចូលរួមកាត់បន្ថយថ្លៃដើមផលិតកម្មកសិកម្ម។
- រាជរដ្ឋាភិបាល តាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយនឹងក្រសួងដែលពាក់ព័ន្ធ គួរសហការណ៍គ្នាដើម្បីស្វែងរកទីផ្សារកសិកម្មបន្ថែមទៀត(ទាំងក្នុងនិងក្រៅស្រុក)។
- រាជរដ្ឋាភិបាលគួរតែមានផែនការឧបត្ថម្ភធន់ដល់កសិករពេលជួបប្រទះបញ្ហាទីផ្សារ ក៏ដូចជាការផ្តល់នូវសម្ភារៈ ឧបករណ៍ និងធនធានផ្សេងៗសម្រាប់ប្រើប្រាស់ក្នុងកសិកម្មគ្រួសារ។

# ឯកសារយោង

# ឯកសារយោង

**សៀវភៅ ព្រឹត្តិប័ត្រផ្សព្វផ្សាយ សារណា និងរបាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា**


- សៀវភៅ សេដ្ឋកិច្ចកម្ពុជា (បណ្ឌិត ហង់ ជួន ណារ៉ុន, ២០១៥)
- សៀវភៅ ការអភិវឌ្ឍជនបទ (បណ្ឌិត ឈុន ពហុ, ២០១៧)
- សៀវភៅ ការយល់ដឹងពីកសិកម្ម (ជា លេងស្រ៊ុន, ទិត ប៊ុនឈឿន,ឈុន តូរី, យិន វឌ្ឍនា និងរ៉ូ សោភ័ណរិទ្ធ, ២០១៩)
- សៀវភៅ សេចក្តីផ្តើមនៃទីផ្សារកសិកម្ម (យាំង ចុងហ៊ី, ធន់ វឌ្ឍនា, ឡឹ គឹមហេង, អាត សុជាត និងមុច សាមីន, ២០១៩)
- សៀវភៅ បច្ចេកទេសមូលដ្ឋាននៃផលិតកម្មដំណាំ និងសត្វ (សួន សេរី, ឈុន តូរី និងលន់ សុផល, ២០១៩)
- សៀវភៅ ណែនាំស្តីពីផលិតកម្មគ្រាប់ពូជស្រូវ (២០១៨)
- សៀវភៅ បង្កុំបច្ចេកទេសប្រពលវប្បកម្មដំណាំស្រូវ (២០១១)
- សៀវភៅ ការកាត់បន្ថយការបាត់បង់ក្រោយពេលប្រមូលផល (២០១១)
- សៀវភៅ ការគ្រប់គ្រងជីជាតិដីលើដំណាំស្រូវនៅកម្ពុជា (២០១០)
- សៀវភៅ ការជ្រើសរើសពូជស្រូវសម្រាប់ការដាំដុះតំបន់ទំនាបរំពឹងទឹកភ្លៀង (២០០៦)
- សៀវភៅ គោលការណ៍ណែនាំស្តីពីការរៀនសូត្រពីកសិករទៅកសិករ និងការផ្សារភ្ជាប់ផលិតផលកសិកម្មទៅទីផ្សារ (២០១៨)
- សៀវភៅ បច្ចេកទេសក្រោយពេលប្រមូលផល (២០១៤)
- សៀវភៅ ដំណាំស្រូវនៅកម្ពុជា (ម៉ែន សារុម, ឆយ លីណា, និងជេដ្ឋ គីមង៉ុយ, ២០១៩)
- សៀវភៅ ការអភិវឌ្ឍកសិកម្ម និងការប្រែប្រួលអាកាសធាតុៈ ករណីប្រទេសកម្ពុជា (រស់ បានសុខ, ណាំង ភិរុណ និងឈឹម ឈុន, ២០១៩)
- សៀវភៅ សេដ្ឋកិច្ចកសិកម្ម(Agricultural Economics), (Dr. Pranav K. Desai, ២០១០)
- សៀវភៅ ការអភិវឌ្ឍកសិកម្ម និងការផ្លាស់ប្តូរសេដ្ឋកិច្ច(Agricultural Development and Economic Transformation), (John W. Mellor, ២០១៧)
- ព្រឹត្តិប័ត្រផ្សព្វផ្សាយ គោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា (២០១៥)
- ព្រឹត្តិប័ត្រផ្សព្វផ្សាយ ពូជស្រូវសំខាន់ៗសម្រាប់ផលិតកម្មស្រូវ និងនាំអង្ករចេញ

- ព្រឹត្តិប័ត្រផ្សព្វផ្សាយ បង្កើនជីជាតិដីឲ្យកាន់តែល្អប្រសើរឡើង
- ព្រឹត្តិប័ត្រព័ត៌មានកសិករ ក្រុមដីសំខាន់ៗនៃដំណាំស្រូវក្នុងប្រទេសកម្ពុជា
- សារណាបញ្ចប់ការសិក្សា ការអភិវឌ្ឍវិស័យកសិកម្មនៅប្រទេសកម្ពុជា (ឡៃ បូរ៉ាពីន, ២០១៧)
- សារណាបញ្ចប់ការសិក្សា ការអភិវឌ្ឍជនបទកម្ពុជាផ្អែកលើវិស័យកសិកម្ម (នាង អ៊ីសាយ និងឡុងមុំ សុជីវី, ២០១៣)
- សារណាបញ្ចប់ការសិក្សា វិស័យកសិកម្ម និងការអភិវឌ្ឍ (កង តារ៉ាវុធ និងពូក សុភាព, ២០១២)
- របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា ការបង្កើនផលិតភាពកសិកម្មស្រុកសំឡូត (វណ្ណា ដារិទ្ធ, ២០០៦)
- របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា តួនាទីប្រព័ន្ធធារាសាស្ត្រក្នុងការអភិវឌ្ឍវិស័យកសិកម្ម (ទ្រុយ សុថាវ និងច័ន្ទធី ឧត្តម, ២០១៦)
- របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា សន្តិសុខស្បៀងតាមរយៈការលើកកម្ពស់ផលិតភាពកសិកម្ម (ឡី ច័ន្ទមាលា និងស៊ិញ រិទ្ធីយ៉ា, ២០០៩)
- របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា ការអភិវឌ្ឍដំណាំស្រូវដើម្បីលើកកម្ពស់ជីវភាពកសិករនៅឃុំលំចង់ ស្រុកសំរោង ខេត្តតាកែវ ចាប់ពីឆ្នាំ ២០០៦ ដល់ ២០១០ (ឃី ពុជ្ជី និងឆន ចាន់ធី, ២០១១)
- សារណាបញ្ចប់ការសិក្សា ទំនើបកម្មវិស័យកសិកម្មក្នុងទិសដៅលើកកម្ពស់ជីវភាពប្រជាជន (សុខ ម៉ុងអាន និងហេង ស្រីស្រស់, ២០១៤)
- សារណាបញ្ចប់ការសិក្សា ការគ្រប់គ្រងដំណាំកសិកម្មចំរុះដើម្បីបង្កើនប្រាក់ចំណូលកសិករ (ហ៊ាង រះ, ២០១២)
- និក្ខេបបទបណ្ឌិត យុទ្ធសាស្ត្របង្កើនផលិតកម្មដំណាំស្រូវប្រកបដោយចីរភាព (ច័ន្ទ សារុន, ២០០៦)

**របាយការណ៍ និងផែនការយុទ្ធសាស្ត្រ**

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *របាយការណ៍បូកសរុបលទ្ធផលការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំឆ្នាំ ២០១៩-២០២០ និងទិសដៅអនុវត្តឆ្នាំ២០២០-២០២១*
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *របាយការណ៍បូកសរុបលទ្ធផលការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំឆ្នាំ ២០១៨-២០១៩ និងទិសដៅអនុវត្តឆ្នាំ២០១៩-២០២០*
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *របាយការណ៍បូកសរុបលទ្ធផលការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំឆ្នាំ ២០១៧-២០១៨ និងទិសដៅអនុវត្តឆ្នាំ២០១៨-២០២១៩*

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣*
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *ផែនការសកម្មភាពជាយុទ្ធសាស្ត្រសម្រាប់ការផ្សព្វផ្សាយកសិកម្ម និងគោលការណ៍ណែនាំសម្រាប់ការអនុវត្តគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា ឆ្នាំ ២០១៨*
- វិទ្យាស្ថានស្ថិតិជាតិ, *របាយការណ៍អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ ២០១៥-២០១៧*
- វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា, *របាយការណ៍សង្ខេបសមិទ្ធិផលនៃការស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាឆ្នាំ ២០១៨ និងទិសដៅសម្រាប់ឆ្នាំ ២០១៩*
- ក្រសួងអភិវឌ្ឍន៍ជនបទ, *ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២០-២០២២*
- ក្រសួងអភិវឌ្ឍន៍ជនបទ, *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទឆ្នាំ ២០១៩-២០១៣*
- រាជរដ្ឋាភិបាលកម្ពុជា, *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣*
- ក្រសួងធនធានទឹក និងឧតុនិយម, *ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុសម្រាប់វិស័យធនធានទឹកឆ្នាំ ២០១៣-២០១៧*
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, *គោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានឆ្នាំ ២០២០*
- ធនាគារជាតិនៃកម្ពុជា, *របាយការណ៍ប្រចាំឆ្នាំ២០១៩*
- ធនាគារពិភពលោក, *របាយការណ៍អភិវឌ្ឍន៍ពិភពលោក (កសិកម្មសម្រាប់ការអភិវឌ្ឍឆ្នាំ ២០០៨)*
- Asian Development Bank (ធនាគារអភិវឌ្ឍន៍អាស៊ី), *របាយការណ៍ការអភិវឌ្ឍនៅអាស៊ីឆ្នាំ ២០១៩*
- កម្រងឯកសារការងាររបស់ ADBI(Asian Development Bank Institute), *ការលើកកម្ពស់ផលិតភាពកសិកម្មរបស់ប្រទេស CLMV(Cambodia Lao Myanmar Viet Nam)៖ បញ្ហាប្រឈម និងកំណែទម្រង់, ២០១៥*
- ក្រសួងកសិកម្ម និងសហករណ៍នៃប្រទេសថៃ, *ផែនការយុទ្ធសាស្ត្រកសិកម្មសម្រាប់ពេល ២០ឆ្នាំ (២០១៧-២០៣៦)*
- គោលនយោបាយកសិកម្ម និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រទេសថៃ (Thailand Agriculture Polices and Development Strategies, ២០១៩)
- វិស័យកសិកម្មកម្ពុជា៖ ឱកាស និងហានិភ័យ, ២០១៥

ប្រព័ន្ធអ៊ីនធឺណែត និងគេហទំព័រ(Websites)


- https://www.mef.gov.kh/
- https://www.business-cambodia.com/bootstrong/2-agriculture-drone-for-cambodia-farmer
- http://www.rdb.com.kh/km/our-project/rice-miller/
- http://ap.fftc.agnet.org/
- http://www.fao.org/faostat/en/#data/QC
- http://www.fao.org/faostat/en/#data/TP
- http://www.fao.org/faostat/en/#data/OE

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី ១៖ បរិមាណផលិតកម្មដំណាំស្រូវប្រចាំឆ្នាំ ២០១៩-២០២០

( ក )

| ល.រ | រាជធានី-ខេត្ត | រដូវវស្សាឆ្នាំ២០១៩ | | | | រដូវប្រាំងឆ្នាំ២០១៩-២០២០ | | | | សរុបប្រចាំឆ្នាំ២០១៩-២០២០ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផ្ទៃដីអនុវត្ត (ហ.ត) | ផ្ទៃដីប្រមូលផល (ហ.ត) | ទិន្នផល (ត/ហ.ត) | បរិមាណផល (តោន) | ផ្ទៃដីអនុវត្ត (ហ.ត) | ផ្ទៃដីប្រមូលផល (ហ.ត) | ទិន្នផល (ត/ហ.ត) | បរិមាណផល (តោន) | ផ្ទៃដីអនុវត្ត (ហ.ត) | ផ្ទៃដីប្រមូលផល (ហ.ត) | ទិន្នផល (ត/ហ.ត) | បរិមាណផល (តោន) |
| 01 | បន្ទាយមានជ័យ | 249,449 | 224,834 | 3.052 | 686,185 | 55,067 | 55,067 | 4.405 | 242,570 | 304,516 | 279,901 | 3.318 | 928,755 |
| 02 | បាត់ដំបង | 366,357 | 358,633 | 3.250 | 1,165,563 | 17,244 | 17,244 | 4.130 | 71,218 | 383,601 | 375,877 | 3.290 | 1,236,781 |
| 03 | កំពង់ចាម | 93,792 | 93,792 | 3.419 | 320,653 | 42,706 | 42,325 | 4.150 | 175,654 | 136,498 | 136,117 | 3.646 | 496,307 |
| 04 | កំពង់ឆ្នាំង | 127,655 | 127,655 | 3.499 | 446,660 | 41,712 | 41,652 | 4.650 | 193,682 | 169,367 | 169,307 | 3.782 | 640,342 |
| 05 | កំពង់ស្ពឺ | 114,996 | 111,829 | 3.035 | 339,435 | 450 | 450 | 3.351 | 1,508 | 115,446 | 112,279 | 3.037 | 340,943 |
| 06 | កំពង់ធំ | 224,890 | 221,727 | 2.658 | 589,329 | 65,455 | 65,235 | 4.296 | 280,255 | 290,345 | 286,962 | 3.030 | 869,584 |
| 07 | កំពត | 140,199 | 140,199 | 3.216 | 450,901 | 8,515 | 8,515 | 4.100 | 34,912 | 148,714 | 148,714 | 3.267 | 485,813 |
| 08 | កណ្តាល | 32,619 | 31,851 | 3.263 | 103,922 | 57,600 | 57,600 | 4.421 | 254,650 | 90,219 | 89,451 | 4.009 | 358,572 |
| 09 | កោះកុង | 9,835 | 9,835 | 2.701 | 26,560 | - | | - | - | 9,835 | 9,835 | 2.701 | 26,560 |
| 10 | ក្រចេះ | 33,571 | 32,134 | 2.770 | 89,010 | 14,143 | 14,143 | 4.393 | 62,130 | 47,714 | 46,277 | 3.266 | 151,140 |
| 11 | មណ្ឌលគិរី | 22,858 | 22,858 | 2.931 | 66,999 | 130 | 130 | 4.246 | 552 | 22,988 | 22,988 | 2.939 | 67,551 |
| 12 | ភ្នំពេញ | 7,884 | 7,884 | 2.699 | 21,282 | 450 | 450 | 3.400 | 1,530 | 8,334 | 8,334 | 2.737 | 22,812 |
| 13 | ព្រះវិហារ | 93,313 | 91,086 | 2.919 | 265,884 | 12 | 12 | 3.000 | 36 | 93,325 | 91,098 | 2.919 | 265,920 |
| 14 | ព្រៃវែង | 270,544 | 270,544 | 3.250 | 879,344 | 111,040 | 111,040 | 4.400 | 488,576 | 381,584 | 381,584 | 3.585 | 1,367,920 |
| 15 | ពោធិ៍សាត់ | 126,813 | 118,598 | 3.609 | 428,027 | 26,912 | 22,376 | 4.446 | 99,484 | 153,725 | 140,974 | 3.742 | 527,511 |
| 16 | រតនគិរី | 26,727 | 26,177 | 2.319 | 60,702 | - | | - | - | 26,727 | 26,177 | 2.319 | 60,702 |
| 17 | សៀមរាប | 186,525 | 182,621 | 2.610 | 476,626 | 22,585 | 22,585 | 3.530 | 79,725 | 209,110 | 205,206 | 2.711 | 556,351 |
| 18 | ព្រះសីហនុ | 10,638 | 10,598 | 3.232 | 34,254 | - | | - | - | 10,638 | 10,598 | 3.232 | 34,254 |
| 19 | ស្ទឹងត្រែង | 27,424 | 24,807 | 2.499 | 62,005 | - | | - | - | 27,424 | 24,807 | 2.499 | 62,005 |
| 20 | ស្វាយរៀង | 169,820 | 169,577 | 2.831 | 480,091 | 20,102 | 20,102 | 4.300 | 86,439 | 189,922 | 189,679 | 2.987 | 566,530 |
| 21 | តាកែវ | 209,373 | 209,373 | 3.398 | 711,473 | 101,511 | 101,511 | 4.898 | 497,201 | 310,884 | 310,884 | 3.888 | 1,208,674 |
| 22 | ឧត្តរមានជ័យ | 95,784 | 95,784 | 2.737 | 262,121 | 139 | 139 | 3.504 | 487 | 95,923 | 95,923 | 2.738 | 262,608 |
| 23 | កែប | 3,632 | 3,632 | 3.385 | 12,294 | 20 | 20 | 3.650 | 73 | 3,652 | 3,652 | 3.386 | 12,367 |
| 24 | ប៉ៃលិន | 8,100 | 8,100 | 3.197 | 25,899 | 795 | 795 | 3.301 | 2,624 | 8,895 | 8,895 | 3.207 | 28,523 |
| 25 | ត្បូងឃ្មុំ | 78,540 | 77,518 | 3.409 | 264,261 | 10,920 | 10,737 | 4.000 | 42,948 | 89,460 | 88,255 | 3.481 | 307,209 |
| | សរុប | 2,731,338 | 2,671,646 | 3.095 | 8,269,480 | 597,508 | 592,128 | 4.418 | 2,616,253 | 3,328,846 | 3,263,774 | 3.335 | 10,885,733 |
| | តួលេខឆ្នាំមុន | 2,739,446 | 2,654,314 | 3.094 | 8,212,893 | 596,483 | 593,747 | 4.512 | 2,678,842 | 3,335,929 | 3,248,061 | 3.353 | 10,891,735 |
| | ប្រៀបធៀប | -8,108 | 17,332 | 0.001 | 56,587 | 1,025 | -1,619 | -0.093 | -62,589 | -7,083 | 15,713 | -0.018 | -6,002 |

# ផលិតកម្មដំណាំស្រូវរយៈពេល ១០ឆ្នាំ ២០១០-២០១៩

(ខ)

| ឆ្នាំ-កំរិតកំណត់ | ឯកតា | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | មធ្យមភាគ ១០ឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| **ផ្ទៃដីដាំដុះប្រចាំឆ្នាំ** | ហត | **2,795,892** | **2,968,529** | **3,007,545** | **3,052,420** | **3,055,507** | **3,051,412** | **3,118,160** | **3,206,523** | **3,335,929** | **3,328,846** | **3,092,076** |
| - វស្សា | ហត | *2,391,016* | *2,496,569* | *2,512,038* | *2,567,723* | *2,564,572* | *2,561,957* | *2,599,586* | *2,657,768* | *2,739,446* | *2,731,338* | *2,582,201* |
| - ប្រាំង | ហត | *404,876* | *471,960* | *495,507* | *484,697* | *490,935* | *489,455* | *518,574* | *548,755* | *596,483* | *597,508* | *509,875* |
| **ផ្ទៃដីប្រមូលផលប្រចាំឆ្នាំ** | ហត | **2,777,323** | **2,766,617** | **2,980,297** | **2,968,967** | **3,028,836** | **3,025,630** | **3,099,769** | **3,189,485** | **3,248,061** | **3,263,774** | **3,034,876** |
| - វស្សា | ហត | *2,372,519* | *2,294,784* | *2,484,832* | *2,485,521* | *2,537,976* | *2,536,175* | *2,581,255* | *2,641,637* | *2,654,314* | *2,671,646* | *2,526,066* |
| - ប្រាំង | ហត | *404,804* | *471,833* | *495,465* | *483,446* | *490,860* | *489,455* | *518,514* | *547,848* | *593,747* | *592,128* | *508,810* |
| **ទិន្នផលប្រចាំឆ្នាំ** | ត/ហត | **2.970** | **3.173** | **3.117** | **3.163** | **3.079** | **3.085** | **3.211** | **3.298** | **3.353** | **3.335** | **3.18** |
| - វស្សា | ត/ហត | *2.760* | *2.920* | *2.872* | *2.925* | *2.815* | *2.827* | *2.959* | *3.047* | *3.094* | *3.095* | *2.93* |
| - ប្រាំង | ត/ហត | *4.201* | *4.406* | *4.349* | *4.383* | *4.443* | *4.422* | *4.465* | *4.508* | *4.512* | *4.418* | *4.41* |
| **បរិមាណផលប្រចាំឆ្នាំ** | តោន | **8,249,452** | **8,779,365** | **9,290,940** | **9,389,961** | **9,324,416** | **9,335,284** | **9,952,270** | **10,518,339** | **10,891,735** | **10,885,733** | **9,661,750** |
| - វស្សា | តោន | *6,548,709* | *6,700,439* | *7,136,139* | *7,271,251* | *7,143,521* | *7,170,684* | *7,636,906* | *8,048,797* | *8,212,893* | *8,269,480* | *7,413,882* |
| - ប្រាំង | តោន | *1,700,743* | *2,078,926* | *2,154,801* | *2,118,710* | *2,180,896* | *2,164,600* | *2,315,364* | *2,469,542* | *2,678,842* | *2,616,253* | *2,247,868* |
| **ត្រូវការស្បៀងក្នុង១ឆ្នាំ** | តោន | **2,076,542** | **2,108,022** | **2,142,178** | **2,137,878** | **2,178,050** | **2,222,078** | **2,266,335** | **2,298,001** | **2,329,364** | **2,375,097** | **2,213,355** |
| **ស្បៀងសល់ ឬខ្វះ (អង្ករ)** | តោន | **2,516,752** | **2,780,328** | **3,031,017** | **3,090,452** | **3,013,783** | **2,975,809** | **3,275,089** | **3,558,612** | **3,735,153** | **3,686,077** | **3,166,307** |
| **ស្បៀងសល់ ឬខ្វះ (ស្រូវ)** | តោន | *3,932,425* | *4,344,263* | *4,735,964* | *4,828,832* | *4,709,036* | *4,649,702* | *5,117,327* | *5,560,331* | *5,836,177* | *5,759,495* | **4,947,355** |

# ផលិតផលស្រូវឆ្នាំ ២០១៩-២០២០ និងតុល្យភាពស្បៀងឆ្នាំ ២០២០

(គ)

| កំរិតកំណត់ | ឯកត្តា | រដូវវស្សា | រដូវប្រាំង | សរុប |
|---|---|---|---|---|
| ផែនការដាំដុះ | ហ.ត | 2,586,152 | 459,599 | **3,045,751** |
| ផ្ទៃដីអនុវត្ត | ហ.ត | 2,731,338 | 597,508 | **3,328,846** |
| ផ្ទៃដីខូចខាត | ហ.ត | 59,692 | - | **59,692** |
| ផ្ទៃដីប្រមូលផល | ហ.ត | 2,671,646 | 592,128 | **3,263,774** |
| ទិន្នផលមធ្យម | ត/ហ.ត | 3.095 | 4.418 | **3.335** |
| បរិមាណផល | តោន | 8,269,480 | 2,616,253 | **10,885,733** |

<u>កំណត់សម្គាល់</u>

- កាត់ចេញ ១៣ភាគរយ លើបរិមាណសរុបសំរាប់ទុកពូជ ចំណីសត្វ និងបាត់បង់ពេលប្រមូលផល 1,415,148 តោន
- ស្រូវចំណីនៅសល់ ក្រោយពីកាត់ចេញ (១៣%) 9,470,586 តោន
- សរុបស្បៀងដែលមាន គិតជាអង្ករ 6,061,174 តោន
- តម្រូវការស្បៀងមួយឆ្នាំ 2,375,097 តោន
- បរិមាណអង្ករលើស **3,686,077** តោន
- គិតជាស្រូវលើស **5,759,495** តោន

## ឧបសម្ព័ន្ធទី ២៖ កម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ចឆ្នាំ ២០១៥-២០១៧

| កម្លាំងពលកម្ម | ២០១៥ | | |
|---|---|---|---|
| | ស្ត្រី | បុរស | សរុប |
| ពលកម្មសរុប(ពាន់នាក់) | ៤,០២៩ | ៤,៣២២ | ៨,៣៥២ |
| កសិកម្ម(%) | ៤៣.៩ | ៣៩.៤ | ៤១.៥ |
| ឧស្សាហកម្ម(%) | ២៤.៨ | ២៦.១ | ២៥.៥ |
| សេវាកម្ម(%) | ៣១.២ | ៣៤.៤ | ៣២.៩ |
| ផ្សេងៗ | 0.១ | 0.១ | 0.១ |
| សរុប | ១០០ | ១០០ | ១០០ |
| កម្លាំងពលកម្ម | ២០១៦ | | |
| | ស្ត្រី | បុរស | សរុប |
| ពលកម្មសរុប(ពាន់នាក់) | ៤,១៦៧ | ៤,៤៤១ | ៨,៦០៨ |
| កសិកម្ម(%) | ៣៩.៣ | ៣៣.៧ | ៣៦.៤ |
| ឧស្សាហកម្ម(%) | ២៥.២ | ២៧.៩ | ២៦.៦ |
| សេវាកម្ម(%) | ៣៥.៥ | ៣៨.៤ | ៣៧.០ |
| សរុប | ១០០ | ១០០ | ១០០ |
| កម្លាំងពលកម្ម | ២០១៧ | | |
| | ស្ត្រី | បុរស | សរុប |
| ពលកម្មសរុប(ពាន់នាក់) | ៥,៣៦០ | ៥,០៥៦ | ១០,៤១៦ |
| កសិកម្ម(%) | ៣៩.០ | ៣៥.១ | ៣៧.០ |
| ឧស្សាហកម្ម(%) | ២៥.១ | ២៧.៣ | ២៦.២ |
| សេវាកម្ម(%) | ៣៥.៩ | ៣៧.៦ | ៣៦.៨ |
| ផ្សេងៗ | | 0.១ | |
| សរុប | ១០០ | ១០០ | ១០០ |

ប្រភព៖ របាយការណ៍អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ ២០១៥-២០១៧

# ឧបសម្ព័ន្ធទី ៣៖ លក្ខណៈសម្បត្តិរបស់ប្រភេទក្រុមដីទាំង ១១

Cambodian Agricultural Research and Development Institute (CARDI)

លក្ខណៈសម្បត្តិសំខាន់ៗរបស់ក្រុមដីទាំង ១១ សម្រាប់ជំនួយក្នុងការធ្វើចំណាត់ថ្នាក់ដីដាំស្រូវនៅកម្ពុជា

| លេខ | ក្រុមដី | សណ្ឋានដី | វាយនភាព | | ក្រហែង | ពណ៌ | លក្ខណៈពិសេស |
|---|---|---|---|---|---|---|---|
| | | | ស្រទាប់លើ | ស្រទាប់ក្រោម | | | |
| ០ | ព្រៃខ្មែរ | តំបន់វាលរាប, តំបន់ខ្ពស់ទាបមិនរាបស្មើ | ខ្សាច់ | ខ្សាច់ | គ្មាន | ប្រផេះទៅត្នោតខ្ចី | ស្រទាប់ខ្សាច់ជ្រៅ |
| ១ | ប្រទះឡាង | តំបន់វាលរាប | ខ្សាច់ | ល្បាយ, ឥដ្ឋ | គ្មាន | ប្រផេះទៅត្នោតខ្ចី | ដីហាប់ក្រោយពេលភ្ជួររាស់ |
| ២ | ឡាបានសៀក | តំបន់ភ្នំ | ឥដ្ឋ | ឥដ្ឋ | មាន | ក្រហមទៅក្រហមក្រមៅ | ដីក្រហមចម្ការកៅស៊ូ |
| ៣ | អូរាំង | តំបន់វាលរាប | ល្បាយ, ឥដ្ឋ | ខ្សាច់ | រាក់ | ប្រផេះទៅប្រផេះខ្ចី | ស្រទាប់លើល្បាយ ឬឥដ្ឋ ស្រទាប់ក្រោមខ្សាច់ |
| ៤ | ក្រគរ | តំបន់ទំនាបជំនន់ | ល្បាយ, ឥដ្ឋ | ឥដ្ឋ | ពីរាក់ទៅជ្រៅ | ប្រផេះ, ត្នោត | ភាគច្រើនមាននៅជុំវិញបឹងទន្លេសាប |
| ៥ | បាកាន | តំបន់វាលរាប | ល្បាយ, ឥដ្ឋ | ល្បាយ, ឥដ្ឋ | គ្មាន ឬ រាក់ | ប្រផេះខ្ចីទៅត្នោត | |
| ៦ | ក្បាលពោធិ៍ | តំបន់ទំនាបជំនន់ | ឥដ្ឋ | ឥដ្ឋ | ជ្រៅ | ប្រផេះក្រមៅទៅខ្មៅ | |
| ៧ | កៀនស្វាយ | តំបន់ច្រាំង ឬ ជម្រាលច្រាំង | ល្បាយ, ឥដ្ឋ | ល្បាយ, ឥដ្ឋ | មាន | ប្រផេះ, ត្នោត | ស្រទាប់ដីលើ និងក្រោមមិនសូវខុសគ្នា |
| ៨ | ទួលសំរោង | តំបន់វាលរាប, តំបន់ខ្ពស់ទាបមិនរាបស្មើ | ល្បាយ, ឥដ្ឋ | ល្បាយ, ឥដ្ឋ | ជ្រៅ | ប្រផេះ, ត្នោត | ដីបាក់ដិបង |
| ៩ | គោកត្រប់ | តំបន់វាលរាប, តំបន់វាលរាប | ល្បាយ, ឥដ្ឋ | ល្បាយ, ឥដ្ឋ | មាន | ប្រផេះក្រមៅទៅខ្មៅ | |
| ១០ | កំពង់សៀម | តំបន់ខ្ពស់ទាបមិនរាបស្មើ | ឥដ្ឋ | ឥដ្ឋ | ជ្រៅ | ខ្មៅ | ច្រើនមានគ្រួស ឬ ថ្មបាសាល់ |

## ឧបសម្ព័ន្ធទី ៤៖ ប្រភេទក្រុមដីទាំង ១១ប្រភេទ

១. ក្រុមដីព្រៃខ្មែរ




២. ក្រុមដីប្រទះឡាង




៣. ក្រុមដីឡាបានសៀក




៤. ក្រុមដីអូរូង




៥. ក្រុមដីក្រគរ




៦. ក្រុមដីបាកាន




៧. ក្រុមដីក្បាលពោធិ




៨. ក្រុមដីកៀនស្វាយ



៩. ក្រុមដីទួលសំរោង




១០. ក្រុមដីគោកត្រប់



១១. ក្រុមដីកំពង់សៀម




## ឧបសម្ព័ន្ធទី ៥៖ ពូជស្រូវគុណភាពខ្ពស់ទាំង ១០ប្រភេទ

១. ពូជស្រូវសែនពិដោរ



២. ពូជស្រូវអ៊ីអ៊ែរ៦៦




៣. ពូជស្រូវជលសារ




៤. ពូជស្រូវក្រអូបផ្ការំដួល



៥. ពូជស្រូវក្រអូបផ្ការំដេង




៦. ពូជស្រូវក្រអូបផ្ការមៀត




៧. ពូជស្រូវកណ្ដាលផ្កាច័ន្ទសែន



៨. ពូជស្រូវរាំងជ័យ



៩. ពូជស្រូវខា៤



១០. ពូជស្រូវខា៦



# ឧបសម្ព័ន្ធទី ៦៖ ប្រភេទគ្រឿងយន្តកសិកម្ម

ត្រាក់ទ័រភ្ជួររាស់



ម៉ាស៊ីនស្រោចស្រព



ម៉ាស៊ីនដាំគ្រាប់ ឬម៉ាស៊ីនស្ទូង



ដ្រូនកសិកម្ម



ម៉ាស៊ីនច្រូតកាត់

